ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# យុទ្ធសាស្ត្រអភិវឌ្ឍន៍ វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០៦-២០១៥




រាជរដ្ឋាភិបាលកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# យុទ្ធសាស្ត្រអភិវឌ្ឍន៍ វិស័យហិរញ្ញវត្ថុ* ឆ្នាំ២០០៦-២០១៥

## រាជរដ្ឋាភិបាលកម្ពុជា

* ឯកសារនេះធ្វើបច្ចុប្បន្នកម្ម និងកែលំអ ចក្ខុវិស័យនិងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០១-២០១០ ដើម្បីកំណត់អាទិភាព និងលំដាប់លំដោយនៃកំណែទម្រង់សម្រាប់ រយៈកាល ២០០៦-២០១៥។

# មាតិកា

អារម្ភកថា

សេចក្តីថ្លែងអំណរគុណ

សេចក្តីផ្តើម

ជំពូកទី ១ អត្ថន័យទូទៅ

ជំពូកទី ២ មូលដ្ឋានគ្រឹះនៃវិស័យហិរញ្ញវត្ថុ

ជំពូកទី ៣ វិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ

ជំពូកទី ៤ វិស័យហិរញ្ញវត្ថុមិនមែនធនាគារ

ជំពូកទី ៥ ការពិចារណាឆ្លងវិស័យទូទៅ

ជំពូកទី ៦ ម៉ាទ្រីសអាទិភាពសម្រាប់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ឆ្នាំ២០០៦-២០១៥

ឧបសម្ព័ន្ធ ១ គណៈកម្មាធិការសម្រាប់គោលនយោបាយហិរញ្ញវត្ថុនិងសេដ្ឋកិច្ច និងគណៈកម្មាធិការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា និងក្រុមការងារបច្ចេកទេសសម្រាប់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ

ឧបសម្ព័ន្ធ ២ ក្រុមការងារនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០៦-២០១៥

ឧបសម្ព័ន្ធ ៣ ក្រុមការងាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី ទទួលបន្ទុករៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០៦-២០១៥

# អារម្ភកថា

វិស័យហិរញ្ញវត្ថុដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍវិស័យឯកជន និងធានាចីរភាពនៃកំណើនសេដ្ឋកិច្ច។ នៅឆ្នាំ២០០១ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័ត *"ចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០១-២០១០"* ដែលជាយុទ្ធសាស្ត្ររយៈពេលវែងសំរាប់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជា។ចាប់ពីពេលនោះមកយុទ្ធសាស្ត្រនេះបានបំរើជាមគ្គុទ្ទេសក៏ដល់ការខិតខំរបស់រាជរដ្ឋាភិបាល ស្ថាប័នពាក់ព័ន្ធនានា និងដៃគូអភិវឌ្ឍន៍ទាំងឡាយ ក្នុងការកំណត់គោលនយោបាយ និងកម្មវិធីនានាសំរាប់ទ្រទ្រង់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជាក្នុងបំណងសំរេចឱ្យបាននូវប្រព័ន្ធហិរញ្ញវត្ថុរឹងមាំផ្អែកលើយន្តការទីផ្សារ។

ដោយអនុវត្តតាម *"ចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០១-២០១០"* រាជរដ្ឋាភិបាលកម្ពុជាសំរេចបានសមិទ្ធិផលធំៗគួរកត់សំគាល់ រួមមាន ការពង្រឹងវិស័យធនាគារ និងការអភិវឌ្ឍវិស័យមិនមែនធនាគារ ដូចជា ធានារ៉ាប់រងជាដើម។ ទោះយ៉ាងណាក៏ដោយ ដោយសារតែល្បឿននៃការអភិវឌ្ឍសេដ្ឋកិច្ចប្រទេសកម្ពុជា និងបញ្ហាប្រឈមដែលកើតមានឡើងក្នុងការអនុវត្តន៏ *"ចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០១-២០១០"* កន្លងមក រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាកែលំអ និងធ្វើបច្ចុប្បន្នកម្ម *"ចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០១-២០១០"* នេះឱ្យស្របតាមកាលៈទេសៈ និងតម្រូវការជាក់ស្តែងរបស់ប្រទេស។

រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តគំនិតផ្តួចផ្តើមខាងលើជាពីរដំណាក់កាលៈ ដំណាក់កាលទី១ គឺការពិនិត្យឡើងវិញលើវិស័យហិរញ្ញវត្ថុនៅកម្ពុជាតាមរយៈការបូកសរុបនិងការវិភាគស្ថានភាពជាក់ស្តែងដែលត្រូវបានធ្វើឡើងនៅខែមករាឆ្នាំ២០០៥។ លទ្ធផលនៃការពិនិត្យឡើងវិញនេះ ត្រូវបានផ្សព្វផ្សាយរួមជាមួយឯកសារនេះ។ ដំណាក់កាលទី២ គឺដំណើរការកែលំអ និងការធ្វើបច្ចុប្បន្នកម្ម *"ចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០១-២០១០"* ដោយផ្តោតលើអាទិភាព និងលំដាប់លំដោយនៃកំណែទម្រង់សម្រាប់ឆ្នាំ២០០៦-២០១៥។ កិច្ចដំណើរការកែលំអ និងការធ្វើបច្ចុប្បន្នកម្មនេះ បានផ្អែកលើមេរៀនដែលទទួលបានក្នុងរយៈពេល៥ឆ្នាំដំបូងនៃការអនុវត្តន៏ *"ចក្ខុវិស័យនិងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០១-២០១០"* និងផ្អែកលើគោលដៅរបស់រាជរដ្ឋាភិបាល ដូចមានឆ្លុះបញ្ចាំងនៅក្នុង**យុទ្ធសាស្ត្រចតុកោណរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន** និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០០៦-២០១០ **និងគោលដៅអភិវឌ្ឍន៍សហសវត្សកម្ពុជា។**

ក្នុងរយៈពេល៦ខែដើមឆ្នាំ២០០៦ ក្រុមការងាររបស់រាជរដ្ឋាភិបាលកម្ពុជាដែលមានសមាសភាពមកពីធនាគារជាតិនៃកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងមជ្ឈដ្ឋានពាក់ព័ន្ធក្នុងវិស័យហិរញ្ញវត្ថុនៅកម្ពុជា បានធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រុមការងារបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងដៃគូអភិវឌ្ឍន៍ដទៃទៀត តាមរយៈដំណើរការពិភាក្សាពិគ្រោះយោបល់ ដើម្បីបានជាធាតុចូលសំរាប់បង្កើតជា *"ឯកសារយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០៦-២០១៥"* នេះឡើង។ និយាយរួម *"យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០៦-២០១៥"* នេះ ត្រូវបានបង្កើតឡើងតាមអភិក្រមមួយដែលមានការចូលរួមដ៏ទូលំទូលាយពីសំណាក់អ្នកពាក់ព័ន្ធនានាក្នុងវិស័យហិរញ្ញវត្ថុនៅកម្ពុជា។

គោលដៅរួមមានលក្ខណៈស៊ីសង្វាក់ និងប្រកបដោយចីរភាព សម្រាប់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជា។ ទន្ទឹមនោះ បន្ថែមលើតួនាទីជាមគ្គុទ្ទេសក៍ *"យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០៦-២០១៥"* មានបំណងផ្តល់នូវក្របខ័ណ្ឌមួយ សម្រាប់ទ្រទ្រង់ការសម្របសម្រួល និងសហប្រតិបត្តិការរវាងស្ថាប័នរាជរដ្ឋាភិបាល រវាងរាជរដ្ឋាភិបាលនិងមជ្ឈដ្ឋានពាក់ពន្ធ័ និងអ្នកចូលរួមនានាក្នុងវិស័យឯកជន និងរវាងដៃគូអភិវឌ្ឍន៍នានាដែលប្រាថ្នាគាំទ្រការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជា ។

បន្ទាប់ពីដំណើរការអភិវឌ្ឍន៍នៅដំណាក់កាលដំបូង សេចក្តីព្រាងនៃ *"យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០៦-២០១៥"* ត្រូវបានចេញផ្សាយនៅខែសីហា ឆ្នាំ២០០៦ ដើម្បីធ្វើការពិគ្រោះយោបល់ជាសាធារណៈ ពិសេសក្រុមការងារផ្នែកសេវា រាប់បញ្ចូលទាំងសេវាធនាគារ និងហិរញ្ញវត្ថុ (ក្រុមការងារ "ង") និងក្រុមការងារផ្នែកនីតិកម្ម ពន្ធដារ និងអភិបាលកិច្ច (ក្រុមការងារ "ឃ") នៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន និងមជ្ឈដ្ឋានសិក្សាធិការ (Academic)។ ជាលទ្ធផល យើងបានទទួលនូវមតិជាច្រើនពីមជ្ឈដ្ឋានពាក់ព័ន្ធក្នុងវិស័យហិរញ្ញវត្ថុកម្ពុជា ហើយមតិទាំងនោះត្រូវបានពិភាក្សា ដោះស្រាយ និងបញ្ចូលបន្ថែមតាមករណីនិមួយៗយ៉ាងសមស្រប ។

*"យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០៦-២០១៥"* ក៏បានឆ្លុះបញ្ចាំងផងដែរនូវការខិតខំរបស់គណៈកម្មាធិការសំរាប់គោលនយោបាយហិរញ្ញវត្ថុ និងសេដ្ឋកិច្ច គណៈកម្មាធិការដឹកនាំការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងក្រុមការងារបច្ចេកទេសរបស់គណៈកម្មាធិការនេះ។ យើងខ្ញុំសូមវាយតំលៃខ្ពស់ចំពោះការខិតខំប្រឹងប្រែង និងការទទួលខុសត្រូវទាំងឡាយក្នុងការបំពេញការងារដ៏ធំធេងនេះ។

*"យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០៦-២០១៥"* នេះ ត្រូវបានគណៈរដ្ឋមន្ត្រីពិនិត្យ និងអនុម័តនៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៧។

បាន *"យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០៦-២០១៥"* ហើយ រាជរដ្ឋាភិបាលចាប់អនុវត្តយុទ្ធសាស្ត្រនេះ ដើម្បីអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុនៅកម្ពុជាឱ្យមានដំណើរការល្អ សំដៅនាំមកនូវផលចំណេញសំរាប់បំរើដល់សេដ្ឋកិច្ច។ មួយវិញទៀត រាជរដ្ឋាភិបាលនឹងធ្វើអ្វីៗទាំងអស់ ដើម្បីបង្កើតឡើងនូវរាល់កត្តាដែលធានាឱ្យបាននូវការប្រកួតប្រជែងជាមួយទីផ្សារហិរញ្ញវត្ថុនានា។

ភ្នំពេញ ថ្ងៃទី ២៦ ខែ មិនា ឆ្នាំ ២០០៧

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**គាត ឈន់**

**ទេសាភិបាល**
**ធនាគារជាតិនៃកម្ពុជា**
**ជា-ចាន់តូ**

# សេចក្តីថ្លែងអំណរគុណ

រាជរដ្ឋាភិបាលកម្ពុជា សូមសំដែងនូវសេចក្តីដឹងគុណជាពិសេសចំពោះធនាគារអភិវឌ្ឍន៍អាស៊ី ដែលបានរួមចំណែកផ្តល់ធាតុចូលមានលក្ខណៈជាយុទ្ធសាស្ត្រដល់ការងាររៀបចំឯកសារ *“យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០៦-២០១៥”* នេះ។

រាជរដ្ឋាភិបាលកម្ពុជា ក៏សូមថ្លែងអំណរគុណផងដែរ ចំពោះក្រុមជំនាញការរៀបចំ *“យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០៦-២០១៥”* និងក្រុមការងារបច្ចេកទេសរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ដែលបានចូលរួម និងប្រឹងប្រែងរៀបចំយុទ្ធសាស្ត្រនេះ។

# សេចក្តីផ្តើម

១.០១ ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុមិនមែនជាគោលដៅចុងក្រោយដោយផ្ទាល់ទេ ប៉ុន្តែគឺជាទិដ្ឋភាពមួយដែលទ្រទ្រង់ការអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។ មានកាតព្វកិច្ចជាច្រើនដែលត្រូវធ្វើដើម្បីសម្រេចគោលដៅដ៏លំបាកនេះ ប៉ុន្តែមានការឯកភាពជាទូទៅថា ការបង្កើនល្បឿន និងបំបែកមុខព្រួញកំណើនសេដ្ឋកិច្ច គឺជាកត្តាគន្លឹះ និងថាការអភិវឌ្ឍវិស័យហិរញ្ញវត្ថុទ្រទ្រង់នូវគោលដៅនេះ។ ដើម្បីឱ្យមានកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌ វិស័យហិរញ្ញវត្ថុត្រូវតែបានពង្រីក និងអាចប្រើប្រាស់បានចំពោះសហគ្រាសធុនតូចនិងមធ្យម និងមីក្រូសហគ្រាស ក៏ដូចជាចំពោះសហគ្រាសធំៗ និងសហគ្រាសបរទេសដែរ។ កំណែទម្រង់ និងការកែប្រែមានសារៈសំខាន់ណាស់សម្រាប់កំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌។ ទន្ទឹមនោះដែរ ការពង្រីកវិស័យហិរញ្ញវត្ថុនាំមកនូវហានិភ័យ ដូច្នេះ ត្រូវមានការពិចារណាយ៉ាងល្អិតល្អន់ទៅលើបរិដ្ឋាននៃការអភិវឌ្ឍវិស័យហិរញ្ញវត្ថុដោយត្រូវផ្តោតទៅលើការប្រុងប្រយ័ត្នកាត់បន្ថយហានិភ័យ តម្លាភាព និងការអនុវត្តន៍ជាឯកសមោធាន នូវច្បាប់និងបទបញ្ញត្តិ។

១.០២ បច្ចុប្បន្នមានការទទួលស្គាល់យ៉ាងច្បាស់ថា ប្រព័ន្ធហិរញ្ញវត្ថុមួយដ៏សំបូរបែបប្រកបដោយភាពប្រកួតប្រជែង តែជាប្រព័ន្ធហិរញ្ញវត្ថុដែលមានភាពរឹងមាំប្រុងប្រយ័ត្ន នឹងដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការអភិវឌ្ឍន៍ តាមរយៈការធានានូវការកេណ្ឌប្រមូល និងការបែងចែងធនធានហិរញ្ញវត្ថុ ប្រកបដោយប្រសិទ្ធភាព។ តាមរយៈការអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុនៅកម្ពុជា ប្រព័ន្ធនេះនឹងជម្រុញដំណើរការប្រមូលផ្តុំរវាងអ្នកសន្សំនិងអ្នកវិនិយោគ រួមជាមួយនឹងអ្នកដែលមានតម្រូវការហិរញ្ញវត្ថុ ឱ្យកាន់តែមានប្រសិទ្ធភាព ហើយដូចនោះនឹងពង្រឹងការបង្កើនកំណើនសេដ្ឋកិច្ច និងភាពមានការងារធ្វើ។

១.០៣ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលកម្ពុជា ជារួម និងជាពិសេស គណៈកម្មាធិការរបស់រាជរដ្ឋាភិបាល ទទួលបន្ទុកគោលនយោបាយហិរញ្ញវត្ថុនិងសេដ្ឋកិច្ច និងគណៈកម្មាធិការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា និងក្រុមការងារបច្ចេកទេសសម្រាប់ការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ (ឧបសម្ព័ន្ធ ១) ប្តេជ្ញានឹងអនុវត្តភារកិច្ចដ៏ប្រឈម សំដៅបង្កើតមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ។ ភារកិច្ចនោះរួមមាន ការបង្កើតក្របខ័ណ្ឌច្បាប់ និងបទបញ្ញត្តិ សម្រាប់ការពង្រីកវិស័យហិរញ្ញវត្ថុប្រកបដោយសុចរិតភាព និងការបង្កើនភាពរឹងមាំនៃវិស័យនេះ។ បច្ចុប្បន្ន ការងារជាមូលដ្ឋានមួយភាគធំត្រូវបានអនុវត្តហើយ ឬនឹងត្រូវបញ្ចប់ក្នុងពេលដ៏ខ្លីខាងមុខ។ ជាមួយនឹងការបង្កើតនូវក្របខ័ណ្ឌច្បាប់និងបទបញ្ញត្តិជាមូលដ្ឋាន សម្រាប់ការអភិវឌ្ឍ និងស្ថិរភាពវិស័យហិរញ្ញវត្ថុ ភារកិច្ចគន្លឹះត្រូវប្រែក្លាយជាពិសេសទៅជាការប្រតិបត្តិជាក់ស្តែងនិងការពង្រឹងតម្លាភាព សំដៅកាត់បន្ថយចំណាយ និងការលំបាកក្នុងការរៀបចំកិច្ចសម្របសម្រួលពាណិជ្ជកម្មរយៈកាលវែង ព្រមទាំងក្នុងការរកហិរញ្ញប្បទានចាំបាច់សម្រាប់ទ្រទ្រង់ការអភិវឌ្ឍកិច្ចសម្របសម្រួលនេះ។ ទន្ទឹមនោះដែរ ការខិតខំជាបន្តដើម្បីកសាងសមត្ថភាពធនធានមនុស្សក្នុងវិស័យហិរញ្ញវត្ថុទាំងមូល គឺជាកត្តាសំខាន់ចំពោះកាលៈទេសៈពិសេសនៃសេដ្ឋកិច្ច និងប្រព័ន្ធហិរញ្ញវត្ថុកម្ពុជា។ ការគួបផ្សំគ្នារវាងមូលដ្ឋានគ្រឹះដ៏សមស្រប ការប្រតិបត្តិប្រកបដោយតម្លាភាព និងការអភិវឌ្ឍធនធានមនុស្ស ចំពោះគ្រប់ទិដ្ឋភាព

ទាំងអស់នៃវិស័យហិរញ្ញវត្ថុ នឹងទ្រទ្រង់ដល់ការបង្កើតគំនិតកែច្នៃថ្មីនិងការធ្វើវិនិយោគនៅក្នុងសហគ្រាស ដែលជាមាគ៌ាតែមួយគត់សម្រាប់ការកាត់បន្ថយភាពក្រីក្រ និងវឌ្ឍនភាពដ៏រុងរឿងជាងមុននៅក្នុងប្រទេសកម្ពុជា។

១.០៤ ដូច្នេះចាំបាច់ត្រូវពិចារណាយ៉ាងប្រុងប្រយ័ត្នថា គប្បីសម្រេចបាននូវឧត្តមភាពនៃការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ដោយវិធីណាដែលប្រសើរ ព្រមពេលជាមួយការកាត់បន្ថយហានិភ័យឱ្យនៅតិចជាអប្បបរមា។

# អត្ថន័យទូទៅ

## ជំពូកទី ១

## ក. ផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០១-២០១០

១.០៥ ក្នុងឆ្នាំ១៩៩៩-២០០០ រាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី បានសហការរៀបចំយុទ្ធសាស្ត្ររយៈកាលវែងមួយ ដើម្បីអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុនៅកម្ពុជា។ លទ្ធផលនៃការខិតខំនេះ គឺជាឯកសារចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០១-២០១០[១] ដែលត្រូវបានអនុម័តដោយរាជរដ្ឋាភិបាល ហើយចាប់ពីពេលនោះមកបានបំរើតួនាទីជាមគ្គុទេសក៍សម្រាប់ការខិតខំរបស់រាជរដ្ឋាភិបាល ស្ថាប័នពាក់ព័ន្ធនានា និងដៃគូអភិវឌ្ឍន៍ទាំងឡាយ ក្នុងការទ្រទ្រង់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តឯកសារចក្ខុវិស័យនិង ផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០១-២០១០ នៅក្នុងកិច្ចប្រជុំពេញអង្គនៃគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពរបស់សម្តេចនាយករដ្ឋមន្ត្រីនៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០១។ នេះជាគំនិតផ្តួចផ្តើមស្ថាបនារបស់រាជរដ្ឋាភិបាល សម្រាប់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ។

១.០៦ ចក្ខុវិស័យនិងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០១-២០១០៖

- កំណត់ចក្ខុវិស័យរយៈកាលវែង និងយុទ្ធសាស្ត្រអភិវឌ្ឍន៍សម្រាប់វិស័យហិរញ្ញវត្ថុ និង
- មានបំណងអភិវឌ្ឍន៍ប្រព័ន្ធហិរញ្ញវត្ថុមួយដ៏រឹងមាំផ្អែកលើយន្តការទីផ្សារ ដើម្បីទ្រទ្រង់ការកេណ្ឌប្រមូលធនធាន និងកំណើនសេដ្ឋកិច្ចទូលំទូលាយប្រកបដោយចីរភាព។

ដើម្បីសម្រេចបាននូវចក្ខុវិស័យទាំងនោះ ចក្ខុវិស័យនិងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០១-២០១០ បានកំណត់ឡើងនូវគោលការណ៍ណែនាំ និងធាតុផ្សំចំនួនដប់ ជាយុទ្ធសាស្ត្ររយៈកាលវែងរបស់រាជរដ្ឋាភិបាល សម្រាប់អភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ។ នៅក្រោមមគ្គុទេសន៍នៃយុទ្ធសាស្ត្ររយៈកាលវែង ចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០១-២០១០ បានបង្ហាញយ៉ាងលំអិតនូវយុទ្ធសាស្ត្រ និងគោលនយោបាយកំណែទម្រង់សម្រាប់អភិវឌ្ឍន៍វិស័យនេះ។ យុទ្ធសាស្ត្រអភិវឌ្ឍន៍នៃចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០១-២០១០ នោះ គឺជាផែនការរំកិលបន្ត ដែលត្រូវការធ្វើបច្ចុប្បន្នកម្មជាលំដាប់ ដើម្បីឆ្លុះបញ្ចាំងសមិទ្ធផលរបស់រាជរដ្ឋាភិបាល ក៏ដូចជាបំរែបំរួលបរិដ្ឋានសេដ្ឋកិច្ច និងសង្គមកិច្ច។

១.០៧ ឯកសារយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០៦-២០១៥ នេះ មានលក្ខណៈកែលំអ និងធ្វើបច្ចុប្បន្នកម្មចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០១-២០១០ តាមបែបមួយដែលប្រកបដោយ៖

- ប្រសិទ្ធភាពក្នុងការកំណត់សកម្មភាពយុទ្ធសាស្ត្រ និងអាទិភាព សំដៅលុបចេញនូវភាពរឹតត្បិត ដែលជាចំណងនៃការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ
- ភាពប្រាកដនិយមដោយអាចសម្រេចបានយ៉ាងសមស្របនៅក្នុងបរិបទនៃលក្ខណៈពិសេសរបស់កម្ពុជា និង
- ចីរភាពដោយមានលំដាប់លំដោយត្រឹមត្រូវនៃកំណែទម្រង់វិស័យហិរញ្ញវត្ថុ។

[១] *អាចទទួលបានតាមប្រភព* http://www/adb.org/Documents/Reports/CAM_Blueprint/default.asp

# ២. គោលបំណង ចក្ខុវិស័យ និងគោលការណ៍ណែនាំ

១.០៨ គោលដៅរួមនៃចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ គឺសំដៅទ្រទ្រង់ដល់ការអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុរឹងមាំផ្អែកលើយន្តការទីផ្សារដើម្បីគាំទ្រការកេណ្ឌប្រមូលធនធាន ការបែងចែកធនធានហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព និងកំណើនសេដ្ឋកិច្ចដ៏ទូលំទូលាយប្រកបដោយសមធម៌ និងចីរភាព។

១.០៩ ចក្ខុវិស័យនេះ គ្របសោបនូវចំណុចដូចតទៅ ៖

- មូលដ្ឋានច្បាប់ ស្ថាប័ន និងនយោបាយសមស្រប ដើម្បីជម្រុញប្រព័ន្ធហិរញ្ញវត្ថុរឹងមាំផ្អែកលើយន្តការទីផ្សារ និងការទ្រទ្រង់អភិបាលកិច្ចល្អ និងនីតិរដ្ឋ ។
- ប្រព័ន្ធធនាគារដែលមានលក្ខណៈប្រកួតប្រជែង សមាហរណកម្ម និងប្រសិទ្ធភាព ប្រកបដោយការគ្រប់គ្រង និងត្រួតពិនិត្យសមស្រប និងដែលគៀងគរប្រាក់សន្សំដោយប្រសិទ្ធភាព ដើម្បីផ្តល់ហិរញ្ញប្បទានដល់ការទ្រទ្រង់ចំពោះកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌ ប្រព័ន្ធទូទាត់សងប្រាក់ដែលអាចទុកចិត្តបាន និងបណ្តាញសុវត្ថិភាពហិរញ្ញវត្ថុ ។
- ប្រព័ន្ធមីក្រូហិរញ្ញវត្ថុដ៏ស្ថិតស្ថេរ យកចិត្តទុកដាក់ចំពោះពលរដ្ឋក្រីក្រ និងមានប្រសិទ្ធភាព ដែលផ្តល់សេវាហិរញ្ញវត្ថុក្នុងតម្លៃសមស្រប ដែលអនុញ្ញាតដល់ពលរដ្ឋក្រីក្រឱ្យមានលទ្ធភាពបង្កើនចំណូលជនបទ និងកាត់បន្ថយភាពក្រីក្រ ។

## ចក្ខុវិស័យនៃវិស័យហិរញ្ញវត្ថុ



- វិស័យធានារ៉ាប់រងដែលការពារអាជីវកម្ម និងឯកត្តជនចំពោះហេតុការណ៍មហន្តរាយ និងប្រព័ន្ធសោធននិវត្តន៍ដែលទ្រទ្រង់ផែនការចូលនិវត្តន៍ ហើយដែលប្រភពទាំងពីរនេះអាចផ្តល់ទុនសម្រាប់ការវិនិយោគរយៈពេលវែង។
- ទីផ្សារហិរញ្ញវត្ថុដែលដោះស្រាយបញ្ហាហានិភ័យយ៉ាងសមស្រប បំបាត់ចោលនូវឧបសគ្គចំពោះការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងទ្រទ្រង់ការគ្រប់គ្រងហានិភ័យ ព្រមទាំងការកេណ្ឌប្រមូល និងបែងចែកធនធានហិរញ្ញវត្ថុ ។
- ការបើកចំហចំពោះផលិតផលហិរញ្ញវត្ថុ និងការកែច្នៃថ្មីចំពោះស្ថាប័ន ដែលបង្កើតនូវរចនាសម្ព័ន្ធវិស័យហិរញ្ញវត្ថុដ៏កាន់តែមានតុល្យភាព បង្កើនជំរៅនៃវិស័យហិរញ្ញវត្ថុ និងជម្រុញការប្រកួតប្រជែង នៅក្នុងបរិបទនៃស្ថិរភាពហិរញ្ញវត្ថុ។

១.១០ យុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈកាលវែង ដែលបានរៀបចំឡើងសម្រាប់អនុវត្តចក្ខុវិស័យនៃវិស័យហិរញ្ញវត្ថុ ត្រូវបានទាញចេញពីកត្តាដូចតទៅ: (១) មេរៀនសំខាន់ៗបានមកពីបទពិសោធន៍របស់បណ្តាសេដ្ឋកិច្ចនានាក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ (២) ស្ថានភាពបច្ចុប្បន្ននៃវិស័យហិរញ្ញវត្ថុរបស់កម្ពុជា និង(៣) វឌ្ឍនភាពនៃកំណែទម្រង់ដែលពាក់ព័ន្ធទាំងឡាយ។

១.១១ បទពិសោធន៍ក្នុងការធ្វើកំណែទម្រង់វិស័យហិរញ្ញវត្ថុនៅក្នុងសេដ្ឋកិច្ចនៃតំបន់អាស៊ី និងបណ្តាសេដ្ឋកិច្ចដទៃទៀតត្រូវបានសរសេរឡើងយ៉ាងក្បោះក្បាយនៅក្នុងអត្ថបទសិក្សាជាច្រើន។ ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុដ៏រឹងមាំ ទាមទារនូវការយកចិត្តទុកដាក់ទៅលើ : (១) មូលដ្ឋានគ្រឹះនៃវិស័យហិរញ្ញវត្ថុ (២)វិស័យធនាគារនិងមីក្រូហិរញ្ញវត្ថុ (៣)វិស័យហិរញ្ញវត្ថុមិនមែនធនាគារ និង(៤) ការពិចារណាឆ្លងវិស័យទូទៅ។

១.១២ បទពិសោធន៍ក្នុងការធ្វើកំណែទម្រង់ និងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅក្នុងសេដ្ឋកិច្ចនៃតំបន់អាស៊ី និងបណ្តាសេដ្ឋកិច្ចអន្តរកាលដទៃទៀត បានផ្តល់នូវមេរៀនជាច្រើនសម្រាប់ពិចារណាក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជា។ ក្នុងការកំណត់យុទ្ធសាស្ត្ររយៈកាលវែង គោលការណ៍ណែនាំគន្លឹះចំនួន១០ ត្រូវបានកត់សម្គាល់ ៖

- នយោបាយសារពើពន្ធដ៏រឹងមាំ និងស្ថិរភាពថ្លៃ គឺជាបុរេលក្ខខណ្ឌសម្រាប់ឱ្យប្រព័ន្ធហិរញ្ញវត្ថុមានដំណើរការល្អ ។
- វិស័យហិរញ្ញវត្ថុនឹងមិនមានការអភិវឌ្ឍឡើយ បើពុំមានជំនឿទុកចិត្តរបស់សាធារណជនទៅលើការការពារ និងសុវត្ថិភាពនៃសិទ្ធិលើកម្មសិទ្ធិ និងការអនុវត្តន៍កិច្ចសន្យា ។
- វិស័យហិរញ្ញវត្ថុដ៏រឹងមាំនឹងមិនអាចបង្កើតបានឡើយ បើពុំមានការបង្កើតនូវនីតិរដ្ឋដែលទ្រទ្រង់ ដោយប្រព័ន្ធច្បាប់ និងតុលាការសមស្រប និងការអនុវត្តន៍ច្បាប់ ។
- ដើម្បីឱ្យមាននូវអន្តរការិយកម្មហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព ចាំបាច់ត្រូវអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុជាពិសេសប្រព័ន្ធគណនេយ្យនិងសវនកម្ម ប្រព័ន្ធព័ត៌មានឥណទាន និងក្របខ័ណ្ឌបទបញ្ញត្តិ។
- ការប្រកួតប្រជែងដ៏ត្រឹមត្រូវនៅក្នុងទីផ្សារហិរញ្ញវត្ថុ ជាកំលាំងជម្រុញគន្លឹះដែលនាំឱ្យមាននូវភាពស៊ីជម្រៅនៃវិស័យហិរញ្ញវត្ថុតាមរយៈការលើកទឹកចិត្តចំពោះគ្រឹះស្ថានហិរញ្ញវត្ថុឱ្យសម្រេចបាននូវសេដ្ឋកិច្ចមាត្រដ្ឋាន និងវិសាលភាព។
- វិស័យហិរញ្ញវត្ថុដ៏រឹងមាំត្រូវកសាងឡើងនៅលើគោលការណ៍អភិបាលកិច្ចត្រឹមត្រូវ និងវិន័យទីផ្សាររឹងមាំដែលទ្រទ្រង់ចំពោះវប្បធម៌ឥណទានដ៏រឹងមាំ។

- កម្មសិទ្ធិរដ្ឋនៅលើគ្រឹះស្ថានហិរញ្ញវត្ថុ និងអន្តរាគមន៍របស់រដ្ឋនៅក្នុងការបែងចែកធនធានហិរញ្ញវត្ថុ នឹងរារាំងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុផ្អែកលើយន្តការទីផ្សារ ។
- បញ្ញត្តិកម្មលើការបើកច្រកចូលដ៏តឹងរ៉ឹងហួសហេតុចំពោះវិស័យហិរញ្ញវត្ថុ ជាកត្តាមួយដែលមានផលប៉ះពាល់ជាអវិជ្ជមានទៅលើការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ព្រមទាំងប្រសិទ្ធភាពក្នុងការបែងចែកមូលនិធិវិនិយោគ ។
- លក្ខខណ្ឌបើកច្រកចូលដ៏ធូររលុងនៅក្រោមប្រព័ន្ធត្រួតពិនិត្យដ៏ទន់ខ្សោយ នាំឱ្យមាននូវគ្រឹះស្ថានហិរញ្ញវត្ថុដ៏ច្រើនហួសហេតុដែលពុំមានការគ្រប់គ្រងល្អ ។
- ដើម្បីអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុប្រកបដោយចីរភាព ចាំបាច់ត្រូវកសាងការគ្រប់គ្រងមួយផ្អែកលើទីផ្សារ ប្រព័ន្ធប្រតិបត្តិការដ៏រឹងមាំ និងត្រូវលើកកម្ពស់សមត្ថភាពបច្ចេកទេស សមស្របតាមបំរែបំរួលដែលប្រាថ្នានៅក្នុងហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ ។

១.១៣ ផ្អែកលើគោលបំណងចក្ខុវិស័យនិងគោលការណ៍ណែនាំខាងលើ សមាសធាតុគន្លឹះនៃយុទ្ធសាស្ត្ររយៈកាលវែង សម្រាប់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ដែលអនុម័តដោយរាជរដ្ឋាភិបាលមានដូចតទៅ ៖

(១) រក្សានយោបាយសារពើពន្ធនិងរូបិយវត្ថុដ៏សមស្រប ដើម្បីធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ។

(២) បង្កើតក្របខ័ណ្ឌច្បាប់រឹងមាំសម្រាប់ការពារសិទ្ធិលើកម្មសិទ្ធិ និងការអនុវត្តន៍កិច្ចសន្យា ។

(៣) បង្កើតនីតិរដ្ឋតាមរយៈកំណែទម្រង់ប្រព័ន្ធច្បាប់និងតុលាការ ដើម្បីទ្រទ្រង់សកម្មភាពហិរញ្ញវត្ថុ និងពាណិជ្ជកម្ម ។

(៤) ការខិតខំជាលំដាប់លំដោយដើម្បីអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធវិស័យហិរញ្ញវត្ថុ ជាពិសេសប្រព័ន្ធផាត់ទាត់ និងទូទាត់សងប្រាក់ ប្រព័ន្ធគណនេយ្យនិងសវនកម្ម ប្រព័ន្ធព័ត៌មានឥណទាន និងក្របខ័ណ្ឌបទបញ្ញត្តិ ។

(៥) កំណែទម្រង់ក្របខ័ណ្ឌបទបញ្ញត្តិនិងគោលនយោបាយ សំដៅលើកកម្ពស់ការប្រកួតប្រជែងនៅក្នុងទីផ្សារហិរញ្ញវត្ថុ និងលើកទឹកចិត្តចំពោះគ្រឹះស្ថានហិរញ្ញវត្ថុឱ្យសម្រេចបាននូវសេដ្ឋកិច្ចមាត្រដ្ឋាន និងវិសាលភាព ។

(៦) បង្កើតក្របខ័ណ្ឌស្ថាប័ននិងបទបញ្ញត្តិដើម្បីលើកកម្ពស់គោលការណ៍អភិបាលកិច្ចត្រឹមត្រូវ និងដើម្បីអនុញ្ញាតឱ្យវិន័យទីផ្សារមានដំណើរការបានល្អនៅក្នុងការគ្រប់គ្រង និងប្រតិបត្តិការរបស់គ្រឹះស្ថានហិរញ្ញវត្ថុ ។

(៧) បង្កើតក្របខ័ណ្ឌសមស្របសម្រាប់ការអភិវឌ្ឍនៃវិស័យឯកជននៅក្នុងប្រព័ន្ធហិរញ្ញវត្ថុ តាមរយៈការលុបបំបាត់ចោលនូវកម្មសិទ្ធិរដ្ឋ និងអន្តរាគមន៍របស់រដ្ឋនៅក្នុងប្រព័ន្ធនោះ ។

(៨) បង្កើតក្របខ័ណ្ឌបើកច្រកចូលប្រកបដោយតម្លាភាព ដើម្បីលើកទឹកចិត្តចំពោះប្រសិទ្ធភាព និងភាពស៊ីជម្រៅនៃវិស័យហិរញ្ញវត្ថុ ។

(៩) បង្កើតយន្តការចាកចេញប្រកបដោយប្រសិទ្ធភាពសម្រាប់គ្រឹះស្ថានដែលមានបញ្ហា សំដៅជម្រុញការរៀបចំឡើងវិញជាបន្តនៃប្រព័ន្ធហិរញ្ញវត្ថុ ដោយពុំបង្កនូវការខាតបង់ដល់សង្គម និង

(១០) អភិវឌ្ឍន៍សមត្ថភាពធនធានមនុស្ស និងស្ថាប័នទាំងនៅក្នុងវិស័យឯកជន និងសាធារណៈ តាមរយៈ ភាពជាដៃគូរវាងវិស័យឯកជន និងសាធារណៈ ។

## គ. អាទិភាពសម្រាប់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ឆ្នាំ២០០៦-២០១៥

១.១៤ ចាប់តាំងពីឆ្នាំ២០០១មក សមិទ្ធផលជាច្រើនត្រូវបានសម្រេច ប៉ុន្តែនៅមានការងារជាច្រើនទៀតដែលត្រូវធ្វើ។ នៅក្នុងការធ្វើបច្ចុប្បន្នកម្មនិងកំណែលំអចក្ខុវិស័យនិងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០១-២០១០ ជំពូកនិមួយៗជាបន្តទៅនេះផ្តល់នូវ ៖

- ទស្សនាទានរួមអំពីការអភិវឌ្ឍ និងស្ថានភាពបច្ចុប្បន្ននៃវិស័យហិរញ្ញវត្ថុនៅកម្ពុជា
- ការពិភាក្សាអំពីវឌ្ឍនភាពនៅក្នុងបរិបទនៃចក្ខុវិស័យនិងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ ២០០១-២០១០ និង
- ទស្សនាទានរួមអំពីគោលដៅ ដែលត្រូវសម្រេចនៅក្នុងបរិបទនៃដំណាក់កាលនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ ២០០៦-២០១៥។

១.១៥ គោលដៅរួម គឺជាវិធីសាស្ត្រមានលក្ខណៈស៊ីសង្វាក់ ប្រាកដនិយម និងប្រកបដោយចីរភាព ដែលឆ្ពោះទៅរកគោលបំណង ចក្ខុវិស័យ គោលការណ៍ណែនាំ និងសមាសធាតុនៃយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលសម្រាប់ទ្រទ្រង់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា។ ទន្ទឹមនោះ ឯកសារនេះមានបំណងផ្តល់ជាបន្ថែមលើមគ្គុទេសន៍នូវក្របខ័ណ្ឌមួយសម្រាប់ទ្រទ្រង់ការសម្របសម្រួល និងសហប្រតិបត្តិការរវាងស្ថាប័នរដ្ឋាភិបាលនៅកម្ពុជា រវាងរដ្ឋាភិបាលនិងមជ្ឈដ្ឋានពាក់ព័ន្ធនិងរវាងអ្នកចូលរួមនានាក្នុងវិស័យឯកជន និងរវាងដៃគូអភិវឌ្ឍន៍នានា ដែលប្រាថ្នាគាំទ្រការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជា។

១.១៦ ឯកសារយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០៦-២០១៥ ផ្តោតលើទិដ្ឋភាពដូចតទៅ ៖

- មូលដ្ឋានគ្រឹះនៃវិស័យហិរញ្ញវត្ថុ (ជំពូកទី ២)
- វិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ (ជំពូកទី ៣)
- វិស័យហិរញ្ញវត្ថុមិនមែនធនាគារ (ជំពូកទី ៤) និង
- ការពិចារណាឆ្លងវិស័យទូទៅ (ជំពូកទី ៥)។

ជំពូកចុងក្រោយផ្តល់នូវម៉ាទ្រីសសង្ខេបនៃចក្ខុវិស័យនិងអាទិភាព សម្រាប់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជា នៅក្នុងអំឡុងពេល ១០ឆ្នាំ ខាងមុខ។

### ១. អាទិភាពគន្លឹះ ឆ្នាំ២០០៦-២០១៥ ៖

១.១៧ ដោយសំលឹងឆ្ពោះទៅមុខ ក្រោមការណែនាំសម្រាប់គោលបំណងរយៈកាលវែង ចក្ខុវិស័យ គោលការណ៍ណែនាំ និងយុទ្ធសាស្ត្រ អាទិភាពចំបងក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ រួមមាន ៖

- លើកកម្ពស់ការអនុវត្តន៍កិច្ចសន្យា និងយន្តការដោះស្រាយជម្លោះពាណិជ្ជកម្ម
- លើកកម្ពស់ការអនុវត្តន៍នយោបាយសារពើពន្ធ ម៉ាក្រូសេដ្ឋកិច្ច និងរូបិយវត្ថុ

- អភិវឌ្ឍន៍ប្រព័ន្ធទូទាត់សងប្រាក់ និងផាត់ទាត់មួយប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាព
- លើកកម្ពស់ការត្រួតពិនិត្យវិស័យហិរញ្ញវត្ថុ សំដៅដោះស្រាយឱ្យបានសមស្របនូវបញ្ហាហានិភ័យ ទន្ទឹមនោះ ផ្តល់ការលើកទឹកចិត្តចំពោះការអភិវឌ្ឍ និងការកែច្នៃថ្មីក្នុងវិស័យហិរញ្ញវត្ថុ និង
- ទ្រទ្រង់ការអភិវឌ្ឍធនធានមនុស្ស និងការអប់រំផ្នែកហិរញ្ញវត្ថុចំពោះគ្រប់មជ្ឈដ្ឋាននៃប្រជាជនកម្ពុជា។

ជារួម គោលដៅគឺ កសាងទំនុកចិត្តទៅលើប្រព័ន្ធហិរញ្ញវត្ថុកម្ពុជា ហើយតាមរយៈនោះ លើកទឹកចិត្តនូវភាពជាផ្លូវការនៃប្រតិបត្តិការហិរញ្ញវត្ថុ និងទ្រទ្រង់ការបែងចែកធនធានហិរញ្ញវត្ថុឱ្យកាន់តែមានប្រសិទ្ធភាព ដែលនឹងទ្រទ្រង់កំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌ និងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។

## ២. មូលដ្ឋានគ្រឹះនៃវិស័យហិរញ្ញវត្ថុ

១.១៨ អាទិភាពចំពោះមុខពាក់ព័ន្ធនឹងមូលដ្ឋានគ្រឹះនៃវិស័យហិរញ្ញវត្ថុមាន៖

- បន្តទ្រទ្រង់វិធីសាស្ត្រផ្អែកលើនីតិរដ្ឋចំពោះច្បាប់និងបទបញ្ញត្តិពាក់ព័ន្ធនឹងវិស័យហិរញ្ញវត្ថុ តាមរយៈ (១) ការពិគ្រោះយោបល់ជាសាធារណៈពាក់ព័ន្ធនឹងសេចក្តីព្រាងច្បាប់និងបទបញ្ញត្តិទាំងអស់ដែលទាក់ទិននឹងវិស័យហិរញ្ញវត្ថុ និង(២) ការបើកចំហសម្រាប់ប្រើប្រាស់នូវច្បាប់និងបទបញ្ញត្តិទាំងអស់ ដែលទាក់ទិននឹងវិស័យហិរញ្ញវត្ថុ តាមរយៈអ៊ិនធឺណេត។
- បញ្ចប់ក្របខ័ណ្ឌច្បាប់ពាណិជ្ជកម្មកម្ពុជា តាមរយៈការអនុមតិច្បាប់និងក្រមដែលកំពុងរង់ចាំការអនុមតិ រួមមានច្បាប់ស្តីពីប្រតិបត្តិការមានកិច្ចធានា ច្បាប់ស្តីពីភតិសន្យា ច្បាប់ស្តីពីក្ស័យធន ច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម ច្បាប់ស្តីពីតុលាការពាណិជ្ជកម្ម និងក្រមរដ្ឋប្បវេណី។
- អនុវត្ត និងប្រតិបត្តិក្របខ័ណ្ឌច្បាប់ពាណិជ្ជកម្មរបស់កម្ពុជា ដែលនេះគឺជាអាទិភាពគន្លឹះប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាព។ ការអនុវត្តន៍នេះនឹងកើតមានតាមរយៈប្រព័ន្ធបទបញ្ញត្តិនិងរដ្ឋបាលសមស្រប ការផ្សព្វផ្សាយ ការអភិវឌ្ឍកម្មវិធីសិក្សា និងការបណ្តុះបណ្តាល។ ការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាពនឹងទាមទារនូវការប្តេជ្ញាយូរអង្វែង ព្រមទាំងកំណែទម្រង់ច្បាប់និងតុលាការ។ ក្នុងរយៈកាលខ្លីទៅមធ្យម ជម្រើសមួយទៀតអាចត្រូវបានផ្តល់ឱ្យ តាមរយៈការអភិវឌ្ឍប្រព័ន្ធមជ្ឈត្តការពាណិជ្ជកម្ម រួមមានការអភិវឌ្ឍមជ្ឈមណ្ឌលមជ្ឈត្តការពាណិជ្ជកម្ម។ ជាបន្ថែម ការទ្រទ្រង់សម្រាប់ការអភិវឌ្ឍនៃបច្ចេកទេសដោះស្រាយជម្លោះនៅថ្នាក់ខេត្ត ឬថ្នាក់ផ្សេងៗ នឹងត្រូវបានពិនិត្យ។
- អភិវឌ្ឍន៍ និងអនុវត្តក្របខ័ណ្ឌបំប្លែងទម្រង់ក្រុមហ៊ុន : ជាមួយនឹងការមាននូវលក្ខខណ្ឌតាមលំដាប់ថ្នាក់សម្រាប់ក្រុមហ៊ុនតូចៗ ក្រុមហ៊ុនឯកជនដទៃទៀត ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត កំណត់ តទៅនេះហៅថា "ក្រុមហ៊ុនមហាជន" និងក្រុមហ៊ុនចុះបញ្ជីនៅក្នុងទីផ្សារមូលប័ត្រ តទៅនេះ ហៅថា "ក្រុមហ៊ុនចុះបញ្ជី"។
- ការអភិវឌ្ឍធនធានមនុស្ស : នេះជាតម្រូវការចំពោះមុខ និងជាបន្តទៅទៀត ជាពិសេសពាក់ព័ន្ធនឹងព័ត៌មានហិរញ្ញវត្ថុ។ ពាក់ព័ន្ធនឹងតម្រូវការធនធានមនុស្សសម្រាប់វិស័យហិរញ្ញវត្ថុ កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលនិងស្ថាប័នរដ្ឋផ្សេងៗ ក៏ដូចជាក្រុមប្រឹក្សាជាតិគណនេយ្យ និងវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា សមាគមធនាគារិកកម្ពុជា សមាគម

មីក្រូហិរញ្ញវត្ថុកម្ពុជា និងសមាគមធានារ៉ាប់រងទូទៅនៃកម្ពុជានឹងត្រូវបានលើកទឹកចិត្ត និងគាំទ្រ។ លើសពីនេះ កិច្ចខិតខំប្រឹងប្រែងនេះ ចាំបាច់ត្រូវគាំទ្រដល់ការអភិវឌ្ឍការអប់រំជាសាធារណៈនិងការអប់រំកម្រិតឧត្តមសិក្សា និងការយល់ដឹង។

- ការចុះបញ្ជីដីធ្លី និងអចលនវត្ថុ : ការបញ្ចប់ការចុះបញ្ជីដីធ្លី និងអចលនវត្ថុ គឺជាគោលដៅរយៈកាលវែង ដែលទាមទារពេលច្រើនឆ្នាំ។ ទន្ទឹមនោះ ចំពោះមុខ ត្រូវយកចិត្តទុកដាក់ទៅលើផ្នែកណាដែលប្រតិបត្តិការ ទំនងជាមានការកើនឡើង ហើយដូចនោះលទ្ធភាពនៃការកើតមានជម្លោះក៏កើនឡើងដែរ។ ឧទាហរណ៍ តំបន់ប្រជុំជនសំខាន់ៗដែលការចុះបញ្ជីចាំបាច់ត្រូវតែបានបញ្ចប់ ជាអាទិភាពចំពោះមុខ ក៏ដូចជាការអភិវឌ្ឍប្រព័ន្ធបទបញ្ញត្តិសមស្របដើម្បីទ្រទ្រង់ដល់ការវាយតម្លៃលើទ្រព្យសម្បត្តិ និងសេវាប្រតិបត្តិការអចលនវត្ថុ។
- បន្តកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ពង្រឹងឧបករណ៍នយោបាយរូបិយវត្ថុ និងអភិវឌ្ឍន៍ក្របខ័ណ្ឌនយោបាយរូបិយវត្ថុផ្អែកលើទីផ្សារ។ ការនេះទាមទារនូវការទ្រទ្រង់ចំពោះការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ និងទីផ្សាររូបិយវត្ថុនិងអន្តរធនាគារ រួមទាំងមូលប័ត្ររដ្ឋរយៈកាលខ្លី។

## ១.១៩ អាទិភាពអន្តរកាល និងរយៈកាលមធ្យម និងគោលដៅរយៈកាលវែង៖

- បញ្ចប់ដំណើរការចុះបញ្ជីដីធ្លី និងអចលនវត្ថុ។ ការនេះអាចនឹងមិនបញ្ចប់មុនឆ្នាំ២០១៥ ទេ ប៉ុន្តែជា កត្តាអាទិភាពនាបច្ចុប្បន្នដ៏សំខាន់ សម្រាប់ទ្រទ្រង់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ។
- ទ្រទ្រង់ការអភិវឌ្ឍទីផ្សារអចលនវត្ថុ។
- ការអនុវត្តន៏កិច្ចសន្យា និងនីតិរដ្ឋ។ ការលើកកម្ពស់សមត្ថភាពប្រព័ន្ធតុលាការក្នុងការអនុវត្តន៍ដោយសង្កតភាពនូវកិច្ចសន្យា និងការដោះស្រាយជម្លោះពាណិជ្ជកម្មដោយសមស្រប ទាមទារនូវការខិតខំជាបន្ត និងយូរអង្វែង។ ក្នុងរយៈកាលមធ្យម ការបង្កើតប្រព័ន្ធតុលាការពាណិជ្ជកម្ម ជាបន្ថែមលើប្រព័ន្ធមជ្ឈត្តការពាណិជ្ជកម្ម នឹងផ្តល់នូវយន្តការមួយ ដែលតាមរយៈនោះការអនុវត្តន៏កិច្ចសន្យាពាណិជ្ជកម្ម និងការដោះស្រាយជម្លោះពាណិជ្ជកម្ម អាចនឹងមានភាពប្រសើរឡើង។ ប្រព័ន្ធតុលាការពាណិជ្ជកម្ម នឹងត្រូវបានរៀបចំឡើងឱ្យមានដំណើរការស្របតាមគោលការណ៍នីតិរដ្ឋ។
- បន្តកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ការអភិវឌ្ឍរូបិយវត្ថុ : បង្កើនទំនុកចិត្ត និងការប្រើប្រាស់រូបិយវត្ថុក្នុងស្រុក។ នៅលើមូលដ្ឋាននេះ ក្របខ័ណ្ឌលើកទឹកចិត្តសារពើពន្ធនឹងត្រូវបានអនុវត្ត រួមទាំងការទូទាត់ប្រាក់បៀវត្សរបស់មន្ត្រីរាជការ និងចំណាយផ្សេងៗទៀតជាប្រាក់រៀលតាមរយៈគណនីធនាគារនិងប្រព័ន្ធទូទាត់សងប្រាក់ និងការតម្រូវឱ្យការទូទាត់ពន្ធ និងការទូទាត់ផ្សេងៗចំពោះរដ្ឋាភិបាល ធ្វើឡើងជាប្រាក់រៀលតាមរយៈប្រព័ន្ធទូទាត់សងប្រាក់ដែរ។ នៅពេលដែលតម្រូវការកើនឡើង ក្រដាសប្រាក់មានតម្លៃចារឹកធំៗអាចនឹងត្រូវបានបោះផ្សាយ។

## ៣. វិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ

១.២០ អាទិភាពគន្លឹះសម្រាប់គាំទ្រការអភិវឌ្ឍវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុនៅកម្ពុជា មានដូចតទៅ ៖

- កំណត់អត្តសញ្ញាណ និងដោះស្រាយបញ្ហាហានិភ័យឱ្យបានសមស្រប ។
- លើកកម្ពស់ប្រតិបត្តិការរបស់គ្រឹះស្ថានហិរញ្ញវត្ថុ និងបង្កើនអន្តរការិយកម្ម តាមរយៈការអភិវឌ្ឍធនធានមនុស្ស ការអប់រំ ការត្រួតពិនិត្យ និងបទបញ្ញត្តិសមស្រប ។
- បង្កើនជំនឿទុកចិត្ត តាមរយៈការលើកកម្ពស់គ្រឹះស្ថានហិរញ្ញវត្ថុ មុខងារត្រួតពិនិត្យ និងការអប់រំ ។
- លើកកម្ពស់ភាពជាផ្លូវការនៃប្រតិបត្តិការហិរញ្ញវត្ថុ តាមរយៈការបង្កើនជំនឿទុកចិត្ត ។
- ផ្សារភ្ជាប់វិស័យធនាគារជាមួយនឹងមីក្រូហិរញ្ញវត្ថុ តាមរយៈការបង្កើនជំនឿទុកចិត្តលើផ្នែកបទបញ្ញត្តិ ការត្រួតពិនិត្យ ការអនុវត្តន៍ច្បាប់ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុសមស្រប ជាពិសេស ប្រព័ន្ធទូទាត់សងប្រាក់ទីផ្សាររូបិយវត្ថុ និងទីផ្សារអន្តរធនាគារ រាប់បញ្ចូលទាំងមូលប័ត្ររដ្ឋរយៈកាលខ្លី និងលើកកម្ពស់គុណភាព និងតម្លាភាពនៃព័ត៌មានហិរញ្ញវត្ថុឱ្យប្រសើរឡើង ។
- ចាត់ទុកអ្នកផ្តល់សេវាហិរញ្ញវត្ថុស្មើភាពគ្នា ដើម្បីផ្តល់ទីលានប្រកួតប្រជែងស្មើភាពមួយ និងជៀសវាង ការអនុវត្តន៍បទបញ្ញត្តិតាមទំនើងចិត្ត និងផ្តល់នូវប្រព័ន្ធមួយដែលមានការអភិវឌ្ឍ និងជឿនលឿន សម្រាប់គ្រឹះស្ថានមិនមែនធនាគារដែលធ្វើសកម្មភាពធនាគារ ។

### *៣.១ វិស័យធនាគារ*

១.២១ ចំពោះអនាគត គោលដៅគន្លឹះគឺ ៖

- ដោះស្រាយបញ្ហាពាក់ព័ន្ធនឹងបុរេលក្ខខណ្ឌសម្រាប់ប្រតិបត្តិការធនាគារ និងការត្រួតពិនិត្យ ដែលទាក់ទងជាពិសេសនឹងការអភិវឌ្ឍប្រព័ន្ធសម្រាប់ដោះស្រាយធនាគារមានបញ្ហានិងអសាធនភាព និងអភិវឌ្ឍន៍ប្រព័ន្ធទូទាត់សងប្រាក់ និងផាត់ទាត់ជាតិមួយប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាព ។
- បន្តលើកកម្ពស់ក្របខ័ណ្ឌច្បាប់និងបទបញ្ញត្តិសម្រាប់ការត្រួតពិនិត្យធនាគារ និងការត្រួតពិនិត្យ ធនាគារផ្ទៃក្នុងដោយខ្លួនឯង ដោយទាំងពីរនេះ មានគោលបំណងរួមសំដៅទ្រទ្រង់ស្ថិរភាពហិរញ្ញវត្ថុ និងការអភិវឌ្ឍវិស័យធនាគារ ដើម្បីលើកកម្ពស់កំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌ និងកាត់បន្ថយភាពក្រីក្រ ។

១.២២ អាទិភាពចំពោះមុខ រួមមាន ៖

- បន្តធ្វើឱ្យប្រសើរឡើងនូវការត្រួតពិនិត្យ ការកសាងសមត្ថភាពនៅធនាគារជាតិនៃកម្ពុជា និងធនាគារ ព្រមទាំងសកម្មភាពអប់រំនិងផ្តល់ការយល់ដឹងដល់អតិថិជន ។

- ការផាត់ទាត់ និងការទូទាត់មូលប្បទានប័ត្រដោយស្វ័យប្រវត្តិ ។
- ការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ជាតិដុលតាមអេឡិចត្រូនិច រួមមាន ការគាំទ្រសម្រាប់ទីផ្សារអន្តរធនាគារ ដោយជាដំបូងមានធនាគារពាណិជ្ជ និងធនាគារឯកទេស ជាអ្នកចូលរួម ។
- បញ្ចូលអ្នកឱ្យខ្ចីចងការ និងអ្នកប្តូរប្រាក់ទៅក្នុងក្របខ័ណ្ឌបទបញ្ញត្តិផ្លូវការ តាមរយៈការចុះបញ្ជី និងបំពេញបែបបទផ្សេងៗឱ្យបានសមស្រប ។
- ការអភិវឌ្ឍដ៏ទូលំទូលាយនូវព័ត៌មានវិទ្យា និងការគ្រប់គ្រងប្រព័ន្ធព័ត៌មានរបស់ធនាគារជាតិនៃកម្ពុជា ដើម្បីទ្រទ្រង់ដំណើរការរបស់ខ្លួន ។
- ពង្រឹងការដាក់ឱ្យអនុវត្តច្បាប់របស់ធនាគារជាតិនៃកម្ពុជា និងប្រព័ន្ធតុលាការ ។

១.២៣ អាទិភាពអន្តរកាល និងរយៈកាលមធ្យម ៖

- ពង្រីកការប្រើប្រាស់ប្រព័ន្ធទូទាត់សងប្រាក់ចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណ ។
- បង្កើតប្រាតិភោគចំពោះហានិភ័យប្រព័ន្ធទូទាត់សងប្រាក់តាមរយៈមូលប័ត្ររដ្ឋរយៈកាលខ្លី ។
- បន្តកសាងសមត្ថភាពនៅធនាគារជាតិនៃកម្ពុជា និងធនាគារ ។
- អប់រំអតិថិជន និងសកម្មភាពផ្សព្វផ្សាយការយល់ដឹងផ្សេងៗ ។
- បន្តលើកកម្ពស់ការត្រួតពិនិត្យ ។
- ផ្ទេរប្រព័ន្ធព័ត៌មានឥណទានអន្តរធនាគារទៅឱ្យផ្នែកឯកជន រួមទាំងការបង្កើតក្របខ័ណ្ឌច្បាប់ និងបទបញ្ញត្តិចាំបាច់ដើម្បីទ្រទ្រង់ដំណើរការរបស់ប្រព័ន្ធនោះ ។
- គាំទ្រការបង្កើតផលិតផល និងសកម្មភាពហិរញ្ញវត្ថុថ្មីៗ នៅក្នុងបរិបទនៃសមធម៌រវាងអ្នកផ្តល់សេវា និងស្ថិរភាពហិរញ្ញវត្ថុ ។ ទាំងនេះរួមបញ្ចូលនូវការគ្រប់គ្រងចំពោះអ្នកឱ្យខ្ចីចងការ និងអ្នកប្តូរប្រាក់ផងដែរ នៅពេលណាពួកគេប្រកបអាជីវកម្មធនាគារ ។

១.២៤ គោលដៅរយៈកាលវែង រួមមាន ៖

- ពិនិត្យឡើងវិញឱ្យបានគ្រប់ជ្រុងជ្រោយនូវច្បាប់និងបទបញ្ញត្តិ ក្នុងផ្នែកធនាគារ ដើម្បីធ្វើបច្ចុប្បន្នកម្ម និងធ្វើឱ្យកាន់តែប្រសើរឡើង តាមការចាំបាច់ ។
- អនុវត្តការពិនិត្យឡើងវិញលើបញ្ហាប្រព័ន្ធការពារអ្នកផ្ញើប្រាក់ និងដោះស្រាយនូវការខ្វះខាតនានា ។

## ៣.២ *វិស័យមីក្រូហិរញ្ញវត្ថុ*

១.២៥ អាទិភាពកម្រិតម៉ាក្រូ ពាក់ព័ន្ធនឹងអាជ្ញាធរបញ្ញត្តិកម្ម និងរដ្ឋាភិបាល រួមមាន ៖

- បន្តអភិវឌ្ឍន៍សមត្ថភាពនៅធនាគារជាតិនៃកម្ពុជា សម្រាប់ការធ្វើបញ្ញត្តិកម្ម និងការត្រួតពិនិត្យវិស័យមីក្រូហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព ។ លក្ខខណ្ឌតម្រូវសម្រាប់វិស័យនេះ គឺមានលក្ខណៈផ្សេងគ្នាជាច្រើនពីផ្នែកធនាគារពាណិជ្ជ ដោយ

ហេតុថា តម្រូវការការទ្រទ្រង់ឧបត្ថម្ភមានសភាពទូលំទូលាយជាង ។

- ការព្រមព្រៀងអំពីស្តង់ដាររាយការណ៍រួម ដើម្បីលើកកម្ពស់ការវិភាគយ៉ាងសមស្របលើលទ្ធផលប្រតិបត្តិការហិរញ្ញវត្ថុ និង គាំទ្រដល់កំណើននៃវិស័យនេះ ព្រមទាំងដើម្បីផ្តល់ព័ត៌មានដល់សាធារណជន ។
- ដោះស្រាយបញ្ហាហានិភ័យជារចនាសម្ព័ន្ធដែលកើតមានចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុពាក់ព័ន្ធនឹងអភិបាលកិច្ចកម្មសិទ្ធិភាព និងទំហំតូចនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួន ។
- កែលំអការវិភាគស្ថិតិ និងនិយមន័យទីផ្សារ ។
- បង្កើតសមត្ថភាពដើម្បីជួយរចនាសម្ព័ន្ធផ្សេងៗទៀតនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដូចជា គ្រឹះស្ថានតាមសហគមន៍ និងដែលមិនបានចុះបញ្ជី ។ល ។ ដើម្បីពង្រីកប្រភេទនៃតម្រូវការដែលបំពេញបាន ហើយនិងបង្ហាញភាពច្រើនបែប និងភាពទន់ភ្លន់នៅក្នុងប្រព័ន្ធឱ្យកាន់តែទូលាយ ។

១.២៦ អាទិភាពកម្រិតមេសូ ថ្នាក់ជំនួយបច្ចេកទេស រួមមាន ៖

- បង្កើតមធ្យោបាយបណ្តុះបណ្តាលសម្រាប់វិស័យមីក្រូហិរញ្ញវត្ថុ ។
- លើកកម្ពស់ការផ្តល់ប្រព័ន្ធព័ត៌មានគ្រប់គ្រងដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ រួមទាំងស្តង់ដារអប្បបរមា ។
- អភិវឌ្ឍន៍ទីផ្សាររូបិយវត្ថុនិងអន្តរធនាគារ សំដៅរួមបញ្ចូលទាំងការចូលរួមរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលមានអាជ្ញាប័ណ្ណ
- ទ្រទ្រង់ការអភិវឌ្ឍសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ។
- កសាងសមត្ថភាពក្នុងប្រទេសលើការធ្វើចំណាត់ថ្នាក់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដោយផ្អែកលើការទ្រទ្រង់អំពីការធ្វើចំណាត់ថ្នាក់ពាណិជ្ជកម្ម និងផ្សារភ្ជាប់ផងដែរទៅនឹងការផ្តោះប្តូរព័ត៌មានឥណទាន ។
- គាំទ្រជាបន្តទៀតនូវការចូលរួមមូលធន និងការវិនិយោគទុនពីអ្នកវិនិយោគក្នុងស្រុក និងបរទេសសម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

១.២៧ អាទិភាពកម្រិតមីក្រូ ( សេវារាយ) ៖

- ទ្រទ្រង់ដល់ការពង្រឹងស្ថាប័នផ្តល់សេវារាយ ជាពិសេស ស្ថាប័នដែលស្ថិតក្រោមកម្រិតគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណ ។
- ផ្អែកលើការស្រាវជ្រាវ និងការវិភាគស្ថិតិដែលរៀបចំឡើងនៅកម្រិតម៉ាក្រូ នោះតម្រូវការមួយអាចកើតមានឡើងដើម្បីជួយបង្កើតឱ្យមានទម្រង់ផ្សេងៗរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ( គ្រឹះស្ថានតាមសហគមន៍ និងដែលមិនបានចុះបញ្ជី ។ល ។) និងដើម្បីធានាថា កន្លែងដែលត្រូវការនោះត្រូវឆ្លើយតបទៅនឹងការ រៀបចំបណ្តោះអាសន្ន ភាពសំបូរបែប និងភាពទន់ភ្លន់នៅក្នុងប្រព័ន្ធឱ្យកាន់តែទូលាយ ហើយវាកាន់តែមានកម្លាំងខ្លាំងឡើងៗថែមទៀត ។
- ទ្រទ្រង់ដល់ការអភិវឌ្ឍទំនាក់ទំនងបន្ថែមទៀតរវាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនិងអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការបំរើទុរគតជន ។ ប្រការនេះអាចនឹងជួយឱ្យទុរគតជនរួចចាកពីទុរគតភាព តាមរយៈការគាំទ្ររបស់អង្គការក្រៅរដ្ឋាភិបាល ឱ្យមានភាពងាយស្រួលចូលទៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ។

## ៤. វិស័យហិរញ្ញវត្ថុមិនមែនធនាគារ

១.២៨ ក្នុងការពិនិត្យលើវិស័យហិរញ្ញវត្ថុមិនមែនធនាគារ វិស័យជាអាទិភាពគឺវិស័យធានារ៉ាប់រង និងទីផ្សារហិរញ្ញវត្ថុ។

### *៤.១ វិស័យធានារ៉ាប់រង*

១.២៩ អាទិភាពចំពោះមុខ រួមមាន ៖

- ការពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នកម្មប្រព័ន្ធបទបញ្ញត្តិ ឱ្យស្របតាមស្តង់ដារតំបន់និងអន្តរជាតិ ។
- អនុម័តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុសមស្រប សម្រាប់ក្រុមហ៊ុនធានារ៉ាប់រង ។
- ទ្រទ្រង់ការកសាងសមត្ថភាពត្រួតពិនិត្យ ។
- ការធ្វើឯកជនភាវូបនីយកម្មក្រុមហ៊ុនកាមិនកូ ។
- លើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរក្រសួង ។
- អភិវឌ្ឍន៍ក្របខ័ណ្ឌសម្រាប់វិស័យមីក្រូធានារ៉ាប់រង ។
- ទ្រទ្រង់ការអភិវឌ្ឍវិស័យធានារ៉ាប់រងអាយុជីវិតតាមរយៈការសិក្សាលើលទ្ធភាពដែលអាចធ្វើបាន និង
- អភិវឌ្ឍយុទ្ធសាស្ត្រសមស្របសម្រាប់ការអភិវឌ្ឍវិស័យធានារ៉ាប់រងអាយុជីវិត រួមទាំងសមាសធាតុសំខាន់ៗនៃក្របខ័ណ្ឌបទបញ្ញត្តិ ។

១.៣០ អាទិភាពអន្តរកាល និងរយៈកាលមធ្យម រួមមាន ៖

- បន្តទ្រទ្រង់ការអភិវឌ្ឍវិស័យធានារ៉ាប់រងអាយុជីវិត តាមរយៈការអភិវឌ្ឍក្របខ័ណ្ឌច្បាប់ និងបទបញ្ញត្តិសមស្រប ។
- លើកកម្ពស់សមត្ថភាពអ្នកគណនាតម្លៃហានិភ័យ និងតម្រូវការពាក់ព័ន្ធផ្សេងៗ ។
- អភិវឌ្ឍន៍វិទ្យាស្ថានបណ្តុះបណ្តាលវិស័យធានារ៉ាប់រង ។
- លើកកម្ពស់ការការពារអតិថិជន និងការយល់ដឹងរបស់អតិថិជន ។
- ទ្រទ្រង់ឱ្យមានជាស្តង់ដារនូវ “Policy Wording” និងតម្រូវការពាក់ព័ន្ធមួយចំនួនទៀត និង
- សិក្សាលើលទ្ធភាពដែលអាចធ្វើបានចំពោះការអភិវឌ្ឍប្រព័ន្ធសោធននិវត្តន៍ឯកជន និងស្ម័គ្រចិត្តមួយនៅកម្ពុជា ។

១.៣១ គោលដៅរយៈពេលវែង រួមមាន ៖

- អនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គម និងដាក់ឱ្យប្រើប្រាស់នូវឧបករណ៍ទ្រទ្រង់សមស្រប ។
- អភិវឌ្ឍន៍ប្រព័ន្ធបទបញ្ញត្តិដើម្បីដោះស្រាយបញ្ហាសោធននិវត្តន៍ឯកជន ។ ចាំបាច់ត្រូវរួមបញ្ចូលនូវវិធានផ្តល់សិទ្ធិសោធននិវត្តន៍ដល់និយោជិតសម្រាប់ការចូលរួមវិភាគទានរបស់និយោជក កាតព្វកិច្ចផ្តល់មូលនិធិសម្រាប់ធានានូវផលធានារ៉ាប់រង លិខិតបញ្ជាក់ពីអ្នកគណនាតម្លៃហានិភ័យចំពោះគំរោងអំពីផលធានារ៉ាប់រងដែលបានកំណត់ វិធានវិនិយោគដែលផ្តោតលើទិន្នផល និងត្រូវការសុវត្ថិភាព និងសាច់ប្រាក់ងាយស្រួលជាចាំបាច់ ។

- ពិនិត្យលើឧត្តមភាពនៃការបញ្ចូលគំរោងសន្សំជាកាតព្វកិច្ចសម្រាប់និយោជិតនៅក្នុងវិស័យផ្លូវការ ដែលអាចជាផ្នែកមួយនៃប្រព័ន្ធសន្តិសុខសង្គម ។

## ៤.២ ទីផ្សារហិរញ្ញវត្ថុ

១.៣២ ពាក់ព័ន្ធនឹងទីផ្សាររូបិយវត្ថុនិងអន្តរធនាគារ អាទិភាពចំពោះមុខ រួមមាន ៖

- ការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ជាតិដុល ។
- កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបានធ្វើជាបន្តក្រោមការដឹកនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- ប្រព័ន្ធមូលប័ត្ររដ្ឋជាអេឡិចត្រូនិច ភ្ជាប់ទៅនឹងការចុះបញ្ជីប្រតិបត្តិការមានកិច្ចធានា កាតព្វកិច្ចដើមទុនចំពោះគ្រឹះស្ថានហិរញ្ញវត្ថុ និងប្រព័ន្ធទូទាត់សងប្រាក់ជាតិដុល ដែលស្ថិតក្រោមការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា ។ ការអភិវឌ្ឍអាចចាប់ផ្តើមជាមួយការបោះផ្សាយសញ្ញាប័ណ្ណ ឬប័ណ្ណរយៈពេលខ្លី (មានរយៈពេលតិចជាង១ឆ្នាំ ដោយគួរចាប់ផ្តើមជាមួយសញ្ញាប័ណ្ណដែលមានរយៈពេល ៣០ថ្ងៃ) ។

១.៣៣ ពាក់ព័ន្ធនឹងទីផ្សាររូបិយវត្ថុនិងអន្តរធនាគារ អាទិភាពអន្តរកាល រួមមាន ៖

- បន្តពង្រឹងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។
- ពង្រីកឥណប្រតិទានរបស់មូលប័ត្ររដ្ឋ ដោយផ្អែកលើការណែនាំនិងការត្រៀមលក្ខណៈសមស្រប ។
- ពិចារណាលើការអនុញ្ញាតចំពោះគ្រឹះស្ថានហិរញ្ញវត្ថុដែលស្ថិតក្រោមការគ្រប់គ្រង ជាដំបូង ធនាគារ បន្ទាប់មក ពង្រីកទៅដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណ ឱ្យផ្តល់ផលប័ត្រពាណិជ្ជកម្ម រយៈពេលខ្លី (១ឆ្នាំ ឬតិចជាង) តាមរយៈប្រព័ន្ធមូលប័ត្ររដ្ឋ ដែលតាមរយៈនេះនឹងបង្កើតបានជាមូលដ្ឋាននៃទីផ្សាររូបិយវត្ថុនិងអន្តរធនាគារ ពិតប្រាកដមួយ ។

១.៣៤ ពាក់ព័ន្ធនឹងទីផ្សារទុន អាទិភាពចំពោះមុខ រួមមាន ៖

- អភិវឌ្ឍន៍ក្របខ័ណ្ឌគ្រប់គ្រងសមស្រប រួមទាំងការអនុមតិច្បាប់ស្តីពីក្ស័យធន ការអភិវឌ្ឍក្របខ័ណ្ឌវឌ្ឍនភាពតាមលំដាប់សម្រាប់បណ្តាក្រុមហ៊ុន ចំពោះទាំងក្រុមហ៊ុនតូច ក្រុមហ៊ុនឯកជនផ្សេងៗ ក្រុមហ៊ុនមហាជន និងក្រុមហ៊ុនចុះបញ្ជី ។
- អនុម័តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលប័ត្រមហាជន ដែលផ្តល់នូវក្របខ័ណ្ឌបង្ខំអនុវត្តច្បាប់ និងអាជ្ញាធរអនុវត្តច្បាប់សមស្រប សម្រាប់ចាត់វិធានការចំពោះការក្លែងបន្លំហិរញ្ញវត្ថុ គំរោងអូសទាញបោកបញ្ឆោតបន្ត ។ល ។ ស្របតាមស្តង់ដារអន្តរជាតិ និងប្រតិបត្តិកររក្សាទុកមូលប័ត្រអេឡិចត្រូនិចរួមសម្រាប់ក្រុមហ៊ុនមហាជនទាំងអស់ ដែលភ្ជាប់ទៅនឹងប្រព័ន្ធចុះបញ្ជីនៃប្រតិបត្តិការមានកិច្ចធានា ។
- បន្តលើកកម្ពស់សមត្ថភាពផ្នែកគណនេយ្យនិងសវនកម្ម ។
- បង្កើនការយល់ដឹងរបស់សាធារណជន ការអប់រំអ្នកវិនិយោគ និងការអភិវឌ្ឍន៍ធនធានមនុស្ស ដើម្បីគាំទ្រដល់ការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុ ហើយកាត់បន្ថយទំហំ និងភាពងាយស្រួលនៃការប្រព្រឹត្តកំហុសក្នុងទីផ្សារ ។

- បង្កើតភាពជាដៃគូជាមួយទីផ្សារមូលប័ត្របរទេស សំដៅទ្រទ្រង់ដល់ការអភិវឌ្ឍទីផ្សារទុនក្នុងស្រុក។

១.៣៥ ពាក់ព័ន្ធនឹងទីផ្សារទុន អាទិភាពអន្តរកាល រួមមាន ៖

- ដាក់ឱ្យអនុវត្តក្របខ័ណ្ឌបំប្លែងទម្រង់តាមលំដាប់សម្រាប់បណ្ដាក្រុមហ៊ុន។
- បង្កើតកន្លែងរក្សាទុកមូលប័ត្រសម្រាប់ក្រុមហ៊ុនមហាជនទាំងអស់ដែលកំពុងធ្វើប្រតិបត្តិការ និងការចុះបញ្ជីក្រុមហ៊ុនមហាជនជាចំហ។ ប្រការនេះនឹងបង្កើតនូវមូលដ្ឋានគ្រឹះសម្រាប់ទីផ្សារមូលប័ត្រមហាជនជាយថាភាពមួយ ដែលនឹងរួមមានការចុះបញ្ជីឈ្មោះពិតប្រាកដ ទិន្នន័យអំពីថ្លៃ ព្រមទាំងមូលប័ត្របំណុល និងមូលប័ត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនមហាជន ហើយជាពិសេស ដាក់ឱ្យដំណើរការជាទីផ្សារមូលប័ត្ររំលងបញ្ជរសម្រាប់ក្រុមហ៊ុនមហាជន។

១.៣៦ ពាក់ព័ន្ធនឹងទីផ្សារទុន អាទិភាពរយៈកាលមធ្យម រួមមាន ៖

- អនុវត្តប្រព័ន្ធបង្ខំអនុវត្តន៍ និងប្រព័ន្ធគ្រប់គ្រង តាមរយៈស្ថាប័នសមស្រប។
- បន្តទ្រទ្រង់ដល់ការអភិវឌ្ឍព័ត៌មានហិរញ្ញវត្ថុ និងក្រុមហ៊ុន។
- ពិចារណាបង្កើតទីផ្សារមូលប័ត្រផ្លូវការដោយផ្អែកលើមូលដ្ឋាននៃប្រតិបត្តិកររក្សាទុកមូលប័ត្ររបស់ក្រុមហ៊ុនមហាជន ដោយមានការសិក្សាអំពីលទ្ធភាពអាចអនុវត្តន៍បាននាដំណាក់កាលដំបូង។
- ការដាក់លក់មូលប័ត្រជាសាធារណៈអាចត្រូវបានអនុញ្ញាតតែតាមរយៈទីផ្សារមូលប័ត្រផ្លូវការ និងពីសំណាក់ក្រុមហ៊ុនមហាជន រួមទាំង សម្រាប់មូលនិធិវិនិយោគប៉ុណ្ណោះ។ ការដាក់លក់ជាឯកជននឹងត្រូវបានអនុញ្ញាតឱ្យចំពោះក្រុមហ៊ុនមហាជន និងក្រុមហ៊ុនចុះបញ្ជី។
- រៀបចំគំរោងសំណងដល់អ្នកវិនិយោគ ដើម្បីដោះស្រាយហានិភ័យនៃការបរាជ័យរបស់អន្តរការិយកម្មមូលប័ត្រដែលកាន់កាប់ទ្រព្យសកម្មអតិថិជន។

១.៣៧ ពាក់ព័ន្ធនឹងទីផ្សារទុន ការពិចារណាសម្រាប់រយៈកាលវែង រួមមាន ៖

- មូលនិធិវិនិយោគ។
- សោធននិវត្តន៍ : ស្របតាមសំណើនៅក្នុងវិស័យធានារ៉ាប់រង កម្ពុជានឹងពិចារណាអភិវឌ្ឍន៍ប្រព័ន្ធសោធននិវត្តន៍មួយដែលមានសមាសធាតុបី រួមទាំងគំរោងមូលនិធិសញ្ច័យសម្រាប់វិស័យឯកជនដែលមានភាពស្រដៀងគ្នានឹងគំរោងរបស់ប្រទេសផ្សេងៗ ពិសេសនៅអាស៊ី។
- មូលប័ត្រនីយកម្ម : ក្នុងការស្វែងរកហិរញ្ញប្បទានរយៈពេលវែងសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ និងប្រភេទផ្សេងៗនៃការអភិវឌ្ឍ កម្ពុជាអាចពិចារណាអភិវឌ្ឍន៍នូវក្របខ័ណ្ឌមួយសមស្របដើម្បីទ្រទ្រង់ដល់ការធ្វើមូលប័ត្រនីយកម្ម។ ក្របខ័ណ្ឌនេះអាចរួមមានគ្រឹះស្ថានធ្វើមូលប័ត្រនីយកម្ម ដូចជាសាជីវកម្មផ្ដល់កម្ចី ដែលមានអចលនវត្ថុជាទ្រព្យបញ្ចាំ ឬហៅថាសាជីវកម្មនិក្ខេបផងដែរ។

- ឧបករណ៍និស្សន្ទ (ឧបករណ៍ដេរីវេទីវ) : នៅពេលក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច រូបិយវត្ថុ និងសារពើពន្ធ មានភាពប្រសើរឡើង ហើយការប្រើប្រាក់រៀលក៏មានការកើនឡើង កម្ពុជាអាចពិចារណាអនុញ្ញាតឱ្យមានការអភិវឌ្ឍប្រភេទឧបករណ៍និស្សន្ទមួយចំនួន ដើម្បីជួយដល់ការគ្រប់គ្រងហានិភ័យ ។

## ៥. ការពិចារណាឆ្លងវិស័យទូទៅ

### *៥.១ សេរីភាវូបនីយកម្ម និងការប្រកួតប្រជែង*

១.៣៨ អាទិភាពចំពោះមុខ រួមមាន ៖

- បន្តអនុវត្តការប្តេជ្ញាលើវិស័យហិរញ្ញវត្ថុជាមួយអង្គការពាណិជ្ជកម្មពិភពលោក និងអាស៊ាន និងការប្តេជ្ញាពាក់ព័ន្ធផ្សេងៗទៀត
- អភិវឌ្ឍន៍ច្បាប់ និងគោលនយោបាយស្តីពីការប្រកួតប្រជែង : ដោយគិតគូរដល់តម្រូវការពិសេសនៃវិស័យហិរញ្ញវត្ថុ តាមរយៈការខិតខំឱ្យមានការពិគ្រោះយោបល់ជាមួយស្ថាប័នបញ្ញត្តិកម្មសមស្រប សំដៅដោះស្រាយបញ្ហាប្រកួតប្រជែងនៅក្នុងវិស័យហិរញ្ញវត្ថុ ។

១.៣៩ អាទិភាពអន្តរកាល និងរយៈកាលមធ្យម រួមមាន ៖

- ការអនុវត្តន៍ច្បាប់ និងគោលនយោបាយស្តីពីការប្រកួតប្រជែង តាមរយៈក្របខ័ណ្ឌស្ថាប័ន និងប្រតិបត្តិសមស្រប រួមទាំងកិច្ចសហប្រតិបត្តិការ និងការពិគ្រោះយោបល់ជាមួយស្ថាប័នបញ្ញត្តិកម្មហិរញ្ញវត្ថុ ក្នុងស្ថានភាពដែលពាក់ព័ន្ធនឹងសេវាកម្ម និងគ្រឹះស្ថានហិរញ្ញវត្ថុ ។
- ការចូលរួម និងការទ្រទ្រង់ជាបន្ត ដើម្បីសកម្មភាពអភិវឌ្ឍន៍ទីផ្សារហិរញ្ញវត្ថុនៃតំបន់អាស៊ាន ។

១.៤០ គោលដៅរយៈកាលវែង រួមមានការជម្រុញឱ្យសមាជិកអាស៊ាន និងអង្គការពាណិជ្ជកម្មពិភពលោកផ្សេងៗទៀតធ្វើសេរីភាវូបនីយកម្មដែលសមស្របគ្នានឹងការប្តេជ្ញាលើវិស័យហិរញ្ញវត្ថុរបស់កម្ពុជា ហើយតាមរយៈនោះ នឹងនាំមកនូវអត្ថប្រយោជន៍មិនចំពោះតែវិស័យហិរញ្ញវត្ថុកម្ពុជាប៉ុណ្ណោះទេ ក៏ប៉ុន្តែចំពោះការអភិវឌ្ឍវិស័យហិរញ្ញវត្ថុអាស៊ីផងដែរ ។

### *៥.២ ការកែច្នៃថ្មីក្នុងវិស័យហិរញ្ញវត្ថុ*

១.៤១ អាទិភាពចំពោះមុខ រួមមាន ៖

- អនុញ្ញាតឱ្យបង្កើតគ្រឹះស្ថានហិរញ្ញវត្ថុថ្មីៗ ដែលបំពេញបានតាមកាតព្វកិច្ចអាជ្ញាប័ណ្ណ និងប្រតិបត្តិការដែលពាក់ព័ន្ធ ។
- ទ្រទ្រង់ដល់វិធីសាស្ត្រអនុញ្ញាតសមស្របចំពោះផលិតផល និងសេវាកម្មហិរញ្ញវត្ថុ នៅក្នុងបរិបទនៃការដោះស្រាយបញ្ហាហានិភ័យនានា ។
- បញ្ចប់នូវក្របខ័ណ្ឌច្បាប់ និងបទបញ្ញត្តិសម្រាប់ភតិសន្យា

- កំណត់ឱ្យច្បាស់នូវវិធីសាស្ត្រចំពោះសកម្មភាពគ្រឹះស្ថានហិរញ្ញវត្ថុ ជាពិសេស នៅក្នុងបរិបទធនាគារ និងក្រុមហ៊ុនធានារ៉ាប់រង និងកំណត់ការយល់ដឹងនេះជាផ្លូវការតាមរយៈអនុស្សារណៈស្តីពីការយោគយល់គ្នារវាងស្ថាប័នបញ្ញត្តិកម្មពាក់ព័ន្ធ ។

១.៤២ អាទិភាពអន្តរកាល និងរយៈកាលមធ្យម រួមមាន អភិវឌ្ឍន៍វិធីសាស្ត្រអនុញ្ញាតសមស្រប ចំពោះការបង្កើតផលិតផលហិរញ្ញវត្ថុ ដោយផ្អែកលើបទពិសោធន៍ដែលទទួលបាននៅក្នុងបរិបទនៃភតិសន្យា ។

១.៤៣ គោលដៅរយៈពេលវែង រួមមាន ៖

- អភិវឌ្ឍន៍ក្របខ័ណ្ឌច្បាប់និងបទបញ្ញត្តិតាមការចាំបាច់ ដើម្បីទ្រទ្រង់ដល់ការកែច្នៃថ្មីចំពោះផលិតផល និងសេវាកម្មហិរញ្ញវត្ថុ
- អភិវឌ្ឍន៍វិធីសាស្ត្រច្បាស់លាស់មួយសម្រាប់សកម្មភាពនៃគ្រឹះស្ថានហិរញ្ញវត្ថុ និងក្រុមហ៊ុនចំរុះអាជីវកម្មហិរញ្ញវត្ថុដែលទ្រទ្រង់ដោយក្របខ័ណ្ឌច្បាប់ និងបទបញ្ញត្តិសមស្រប ឬអនុស្សារណៈស្តីពីការយោគយល់គ្នាតាមការចាំបាច់ ។

## *៥.៣ រចនាសម្ព័ន្ធបទបញ្ញត្តិហិរញ្ញវត្ថុ*

១.៤៤ អាទិភាពចំពោះមុខ រួមមាន ៖

- កំណត់ឱ្យច្បាស់នូវសកម្មភាពនានា និងវិធីសាស្ត្ររបស់គ្រឹះស្ថានហិរញ្ញវត្ថុ ដែលត្រូវបានអនុញ្ញាត ដោយគិតគូរជាពិសេសទៅលើហានិភ័យជាប្រព័ន្ធបង្កឡើងដោយធនាគារ និងសកម្មភាពធនាគារ ។
- ការពិចារណាលើកិច្ចសម្របសម្រួលសមស្រប សម្រាប់ការទទួលខុសត្រូវលើការអភិវឌ្ឍគោលនយោបាយវិស័យហិរញ្ញវត្ថុ ។
- ទ្រទ្រង់តាមការចាំបាច់ តាមរយៈការកែប្រែក្របខ័ណ្ឌច្បាប់ និងបទបញ្ញត្តិ ឬអនុស្សារណៈស្តីពីការយោគយល់គ្នា ។

១.៤៥ អាទិភាពអន្តរកាល និងរយៈកាលមធ្យម រួមមាន ៖

- ធ្វើការវាយតម្លៃគ្រប់ជ្រុងជ្រោយទៅលើរចនាសម្ព័ន្ធបទបញ្ញត្តិហិរញ្ញវត្ថុ នៅក្នុងបរិបទនៃសកម្មភាពគ្រឹះស្ថានហិរញ្ញវត្ថុ និងក្រុមហ៊ុនចំរុះអាជីវកម្មហិរញ្ញវត្ថុ ព្រមទាំងសមត្ថភាពត្រួតពិនិត្យ និងបញ្ញត្តិកម្មក្នុង ស្រុក ។
- អនុវត្តនូវកំណែប្រែចាំបាច់នានា ចំពោះរចនាសម្ព័ន្ធបទបញ្ញត្តិ ដែលជាលទ្ធផលបានពីការវាយតម្លៃគ្រប់ជ្រុងជ្រោយនោះ ។

១.៤៦ គោលដៅរយៈកាលវែង រួមមាន ការពិនិត្យឡើងវិញ និងវាយតម្លៃវិស័យហិរញ្ញវត្ថុដ៏គ្រប់ជ្រុងជ្រោយ ។

# មូលដ្ឋានគ្រឹះនៃហិរញ្ញវត្ថុ

## ជំពូកទី ២

# មូលដ្ឋានគ្រឹះនៃហិរញ្ញវត្ថុ



២.០១ ចាប់តាំងពីឆ្នាំ២០០១មក ប្រទេសកម្ពុជាបានសម្រេចនូវវឌ្ឍនភាពជាច្រើនក្នុងការបង្កើតគោលនយោបាយ មូលដ្ឋានក្របខ័ណ្ឌស្ថាប័ន និងបទបញ្ញត្តិ សម្រាប់វិស័យហិរញ្ញវត្ថុ និងកំណើនសេដ្ឋកិច្ចជាទូទៅ។ ចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០១-២០១០ បានកំណត់នូវមូលដ្ឋានគ្រឹះសំខាន់បីសម្រាប់វិស័យហិរញ្ញវត្ថុ ៖

១- ក្របខ័ណ្ឌច្បាប់សម្រាប់ប្រតិបត្តិការពាណិជ្ជកម្ម និងហិរញ្ញវត្ថុ

២- ស្តង់ដារគណនេយ្យ និងសវនកម្ម និង

៣- ហេដ្ឋារចនាសម្ព័ន្ធព័ត៌មានទីផ្សារហិរញ្ញវត្ថុ។

២.០២ នៅក្រោមក្របខ័ណ្ឌនេះ ក្របខ័ណ្ឌច្បាប់សម្រាប់ប្រតិបត្តិការពាណិជ្ជកម្ម និងហិរញ្ញវត្ថុ រួមមាន ៖ ច្បាប់ស្តីពីក្រុមហ៊ុន ច្បាប់ស្តីពីក្ស័យធន ច្បាប់ស្តីពីប្រតិបត្តិការមានកិច្ចធានា ក្រមនិងនីតិវិធីរដ្ឋប្បវេណីព្រមទាំងតុលាការ និងតុលាការពាណិជ្ជកម្ម។ កម្ពុជាបានដាក់ឱ្យប្រើប្រាស់ច្បាប់ក្រុមហ៊ុនមានលក្ខណៈគ្រប់ជ្រុងជ្រោយជាលើកដំបូង(ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម) នៅឆ្នាំ២០០៥ និងក្រមនីតិវិធីរដ្ឋប្បវេណីថ្មីនៅកម្ពុជា ឆ្នាំ២០០៦។ លើសពីនេះទៀត ច្បាប់ស្តីពីប្រតិបត្តិការមានកិច្ចធានាកំពុងស្ថិតនៅក្រោមការពិនិត្យរបស់សភាជាតិ ដែលរំពឹងថានឹងត្រូវបានអនុម័តនាពេលឆាប់ៗខាងមុខ។ ទន្ទឹមនេះ ច្បាប់ស្តីពីក្ស័យធន និងក្រមរដ្ឋប្បវេណីថ្មី បានរៀបចំជិតរួចរាល់ហើយ។ ក្រសួងពាណិជ្ជកម្មបានបង្កើតការចុះបញ្ជីក្រុមហ៊ុន ហើយនឹងបង្កើតការចុះបញ្ជីប្រតិបត្តិការមានកិច្ចធានាតាមរយៈអេឡិចត្រូនិចនៅពេលខាងមុខ បន្ទាប់ពីច្បាប់ស្តីពីប្រតិបត្តិការមានកិច្ចធានាត្រូវបានដាក់ឱ្យប្រើប្រាស់។ ទន្ទឹមនឹងនោះដែរ ខណៈដែលក្របខ័ណ្ឌច្បាប់ជាមូលដ្ឋានមាន ឬនឹងមាន សម្រាប់ប្រើប្រាស់ឆាប់ៗក្តី ក៏ប្រព័ន្ធតុលាការមានលក្ខណៈពុំទាន់រឹងមាំនៅឡើយក្នុងបរិបទនៃការអនុវត្តនីកិច្ចសន្យា និងការដោះស្រាយជម្លោះពាណិជ្ជកម្ម ហើយដូចនោះធ្វើឱ្យប្រសិទ្ធភាពនៃក្របខ័ណ្ឌច្បាប់ពាណិជ្ជកម្មដែលទើបនឹងលេចរូបរាងឡើង មានភាពថមថយ។

២.០៣ ពាក់ព័ន្ធនឹងស្តង់ដារគណនេយ្យនិងសវនកម្ម ចក្ខុវិស័យនិងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០១-២០១០ បានកំណត់ជាដំបូងនូវច្បាប់ និងជាបន្ទាប់ នូវស្តង់ដារដែលផ្អែកលើស្តង់ដារគណនេយ្យអន្តរជាតិ បច្ចុប្បន្ន ហៅថា ស្តង់ដារអន្តរជាតិនៃរបាយការណ៍ហិរញ្ញវត្ថុ ឬ IFRS និងស្តង់ដារសវនកម្មអន្តរជាតិ។ ច្បាប់ស្តីពីគណនេយ្យសហគ្រាស វិជ្ជាជីវៈគណនេយ្យនិងសវនកម្មត្រូវបានដាក់ឱ្យប្រើប្រាស់នៅក្រោមការទទួលខុសត្រូវរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយក្រុមប្រឹក្សាជាតិគណនេយ្យត្រូវបានបង្កើតឡើងដើម្បីកំណត់ស្តង់ដារគណនេយ្យ និងសវនកម្ម។ ស្តង់ដារផ្អែកលើស្តង់ដារគណនេយ្យអន្តរជាតិ និងស្តង់ដារសវនកម្មអន្តរជាតិ កំពុងត្រូវបានអនុវត្ត ដោយសម្រេចបាននូវវឌ្ឍនភាពជាច្រើននៅក្នុងការបង្កើតគណនេយ្យករ និងសវនករគុណវុឌ្ឍិ ដែលជាមួយនេះ វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា មានតួនាទីយ៉ាងសំខាន់។

២.០៤ ពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធព័ត៌មាននៃទីផ្សារហិរញ្ញវត្ថុ ចក្ខុវិស័យនិងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០១-២០១០ បានកំណត់ជាបឋមនូវតម្រូវការបង្កើតប្រព័ន្ធព័ត៌មានឥណទាន។ នៅក្នុងបរិបទនេះ ធនាគារជាតិ នៃកម្ពុជា និងសមាគមធនាគារិកនៅកម្ពុជាបានដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធព័ត៌មានឥណទានអន្តរធនាគារថ្មីមួយនៅខែសីហាឆ្នាំ២០០៦ដែលនឹងអនុញ្ញាតឱ្យមាននូវការផ្ដោះប្ដូរអន្តរធនាគារនូវព័ត៌មានឥណទានរបស់អតិថិជន។

២.០៥ ចាប់តាំងពីបានរៀបចំនូវចក្ខុវិស័យនិងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០១-២០១០ការយល់ដឹងអំពីមូលដ្ឋានគ្រឹះគន្លឹះនៃការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងកំណើនសេដ្ឋកិច្ចមានការរីកចំរើនជាច្រើន។ បច្ចុប្បន្ន ទិដ្ឋភាពចំនួនបីនៃមូលដ្ឋានគ្រឹះវិស័យហិរញ្ញវត្ថុត្រូវបានកំណត់ឡើង ដែលចាំបាច់ត្រូវដោះស្រាយ សំដៅទ្រទ្រង់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ៖

- បុរេលក្ខខណ្ឌសម្រាប់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងកំណើនសេដ្ឋកិច្ច
- មូលដ្ឋានស្ថាប័ននៃវិស័យហិរញ្ញវត្ថុ
- ហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ។

ផ្នែកទាំងបីនេះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយបញ្ញត្តិកម្ម និងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ជាពិសេស នៅក្នុងទំនាក់ទំនងជាមួយវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ (ជំពូកទី ៣) វិស័យហិរញ្ញវត្ថុមិនមែនធនាគារ រួមទាំង វិស័យធានារ៉ាប់រង និងទីផ្សារហិរញ្ញវត្ថុ (ជំពូកទី ៤) ក៏ដូចជាជាមួយសេរីភាវូបនីយកម្ម និងការប្រកួតប្រជែង (ជំពូកទី ៥ អំពីការពិចារណាឆ្លងវិស័យទូទៅ)។

២.០៦ មូលដ្ឋានគ្រឹះទាំងនេះ រួមទាំងមាគ៌ាដោយឡែកសម្រាប់វិស័យហិរញ្ញវត្ថុ ដែលត្រូវបានបកស្រាយនៅក្នុងផ្នែកជាបន្តទៅនេះ នឹងត្រូវបានពង្រឹងថែមទៀតតាមរយៈគោលនយោបាយប្រកបដោយលំដាប់លំដោយសមស្របអំពីសេរីភាវូបនីយកម្ម និងការប្រកួតប្រជែង[២] ។

## ក. បុរេលក្ខខណ្ឌសម្រាប់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងកំណើនសេដ្ឋកិច្ច

២.០៧ បុរេលក្ខខណ្ឌសម្រាប់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងកំណើនសេដ្ឋកិច្ច រួមមាន សមាសធាតុបួនដែលបំរើជាមូលដ្ឋានគ្រឹះដ៏សំខាន់នៃសេដ្ឋកិច្ចផ្អែកលើទីផ្សារ ៖

- អភិបាលកិច្ចប្រកបដោយប្រសិទ្ធភាព
- សិទ្ធិលើកម្មសិទ្ធិ និងការការពារសិទ្ធិទាំងនោះ
- ការអនុវត្តន៍កិច្ចសន្យា និងការដោះស្រាយជម្លោះពាណិជ្ជកម្ម និង
- ការអភិវឌ្ឍធនធានមនុស្ស។

[២] *មើលជំពូកទី ៥*

## ១. អភិបាលកិច្ច

២.០៨ ដើម្បីឱ្យសេដ្ឋកិច្ចណាមួយអាចអភិវឌ្ឍន៍ហួសពីកម្រិតដ៏សាមញ្ញបំផុតបាន សេដ្ឋកិច្ចនោះត្រូវមានប្រព័ន្ធអភិបាលកិច្ចដំណើរការល្អ ដែលផ្ដល់យ៉ាងហោចក្នុងកម្រិតអប្បបរមានូវស្ថិរភាពនយោបាយ និងសុវត្ថិភាព ។ ចាប់តាំងពី ឆ្នាំ១៩៩៣ មក កម្ពុជាសម្រេចបានការរីកចំរើនជាច្រើននៅលើមូលដ្ឋានគ្រឹះដ៏ចាំបាច់បំផុតនេះនៃការអភិវឌ្ឍសេដ្ឋកិច្ច ។ ជារួម អភិបាលកិច្ចមានភាពប្រសើរឡើងនៅកម្ពុជា ប៉ុន្តែនៅទាមទារការយកចិត្តទុកដាក់ជាបន្តទៀត ជាពិសេសពាក់ព័ន្ធនឹងបញ្ហាក្នុងកម្រិតទីពីរ ដូចជាចីរភាពសារពើពន្ធជាដើម ។

## ២. សិទ្ធិលើកម្មសិទ្ធិ និងការការពារសិទ្ធិនោះ

២.០៩ ដើម្បីឱ្យសេដ្ឋកិច្ចទីផ្សារមួយដំណើរការបាន ចាំបាច់ត្រូវមានសិទ្ធិលើកម្មសិទ្ធិ ហើយសិទ្ធិលើកម្មសិទ្ធិនោះត្រូវតែបានទទួលការការពារ និងអនុវត្ត ។ សិទ្ធិលើកម្មសិទ្ធិគប្បីត្រូវគ្របដណ្ដប់លើអចលនវត្ថុ រួមទាំង ដីធ្លី និងអាគារ ចលនវត្ថុ ដូចជារថយន្ត និងសម្បត្តិផ្ទាល់ខ្លួន និងសម្បត្តិអរូបីយ ដូចជា សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសម្បត្តិ និង កម្មសិទ្ធិបញ្ញា ។ ក៏ដូចគ្នាដែរ កម្ពុជាសម្រេចបានការរីកចំរើនជាច្រើននៅលើមូលដ្ឋានគ្រឹះដ៏ចាំបាច់បំផុតសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាពិសេសពាក់ព័ន្ធនឹងការចុះបញ្ជីដីធ្លីទ្រព្យសម្បត្តិ ។ ជារួម ការចុះបញ្ជីដីធ្លីកំពុងដំណើរការ ប៉ុន្តែនឹងទាមទារពេលវេលាច្រើនឆ្នាំទៀតដើម្បីបញ្ចប់ ។ លើសពីនេះទៀត ច្បាប់ស្ដីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ដែលត្រូវបានដាក់ឱ្យប្រើនៅឆ្នាំ២០០៣បានផ្ដល់នូវមូលដ្ឋានសម្រាប់ការពារកម្មសិទ្ធិខាងបញ្ញា ។ ពិនិត្យទៅអនាគត មានការចាំបាច់ជាអាទិភាពនឹងផ្ដោតទៅលើការបញ្ចប់ការអង្កេតលើដីធ្លី និងទ្រព្យសម្បត្តិ និងការអនុវត្តន៍ប្រព័ន្ធនានា ដើម្បីការពារកម្មសិទ្ធិលើដីធ្លី ក៏ដូចជាកម្មសិទ្ធិខាងបញ្ញាដែរ ។

## ៣. ការអនុវត្តន៍កិច្ចសន្យា និងការដោះស្រាយជម្លោះពាណិជ្ជកម្ម

២.១០ ដើម្បីឱ្យការជួញដូរពាណិជ្ជកម្មឈានទៅមុខហួសពីប្រតិបត្តិការចំពោះមុខ ចាំបាច់ត្រូវមានប្រព័ន្ធមួយសម្រាប់អនុវត្តកិច្ចសន្យា និងការដោះស្រាយជម្លោះពាណិជ្ជកម្ម ។ បច្ចុប្បន្ននេះ ប្រព័ន្ធតុលាការកម្ពុជាពុំបានបំពេញមុខងារនេះដោយសង្គតភាពឡើយ ។ ទន្ទឹមនោះដែរ ច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មថ្មី ត្រូវបានដាក់ឱ្យប្រើប្រាស់នៅឆ្នាំ២០០៦ ហើយទង្វើនេះអាចផ្ដល់នូវក្របខ័ណ្ឌជាជំរើសមួយទៀតសម្រាប់ដោះស្រាយតម្រូវការជាមូលដ្ឋាននេះនៅក្នុងប្រព័ន្ធសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា ព្រមពេលជាមួយគ្នាដែលប្រព័ន្ធតុលាការត្រូវបានពង្រឹងដល់កម្រិតចាំបាច់ដែលបង្កើតនូវទំនុកចិត្តទៅលើសមត្ថភាពរបស់តុលាការក្នុងការអនុវត្តន៍កិច្ចសន្យាដោយសង្គតភាព និងការដោះស្រាយជម្លោះពាណិជ្ជកម្មដោយសមស្រប ។ នៅក្នុងការពង្រឹងប្រសិទ្ធភាពប្រព័ន្ធតុលាការក្នុងការដោះស្រាយជម្លោះពាណិជ្ជកម្ម ច្បាប់ស្ដីពីកិច្ចសន្យាពាណិជ្ជកម្មនឹងត្រូវបានអនុម័ត ហើយប្រព័ន្ធតុលាការពាណិជ្ជកម្មនឹងត្រូវបានបង្កើតឡើង ដែលដំណើរការនៅក្រោមវិធាននៃក្របខ័ណ្ឌច្បាប់ ។ ជាបន្ថែម ការទ្រទ្រង់សម្រាប់ការអភិវឌ្ឍបច្ចេកទេសដោះស្រាយជម្លោះនៅថ្នាក់ខេត្ត និងថ្នាក់ដទៃទៀត នឹងត្រូវបានពិនិត្យ ។

### ៤. ការអភិវឌ្ឍធនធានមនុស្ស

២.១១ ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុកម្ពុជាត្រូវបាន និងបន្តរងផលប៉ះពាល់ជាច្រើនទៀតពីភាពរីតត្បិតលើធនធានមនុស្ស ដែលបណ្តាលមកពីការអភិវឌ្ឍជាប្រវត្តិសាស្ត្រនាប្រមាណពាក់កណ្តាលសតវត្សកន្លងមក។ ប៉ុន្តែកន្លងមក មានការសម្រេចបាននូវវឌ្ឍនភាពមួយចំនួន ដោយមានការពង្រឹងការសិក្សាអប់រំថ្នាក់បឋមភូមិ ទុតិយភូមិ និងឧត្តមសិក្សា ក៏ដូចជាការបង្កើតកម្មវិធីវិជ្ជាជីវៈកម្មវិធីពាក់ព័ន្ធនឹងគណនេយ្យ និងសវនកម្មជាដើម។ ប៉ុន្តែជាក់ស្តែង មូលដ្ឋានគ្រឹះនេះទាមទារនូវការខិតខំជាបន្ត និងយូរអង្វែងទៀត។ ចំពោះគ្រប់ទិដ្ឋភាពទាំងអស់ ចាំបាច់ត្រូវការនូវសកម្មភាពបែងចែក ផ្សព្វផ្សាយ ការអភិវឌ្ឍកម្មវិធីសិក្សា និងការបណ្តុះបណ្តាល។ ចំណុចពិសេសដែលត្រូវចាប់អារម្មណ៍រួមមាន ការលើកកម្ពស់ការផ្តល់ការបណ្តុះបណ្តាលលើការអនុវត្តន៍ជាក់ស្តែងទាក់ទិននឹងស្តង់ដារគណនេយ្យកម្ពុជា និងច្បាប់ស្តីពីពន្ធដារ។ ការងារនេះក៏ត្រូវពង្រីកឱ្យបានទូលាយផងដែរដល់ការខិតខំដើម្បីអប់រំអ្នកប្រើប្រាស់ពាក់ព័ន្ធនឹងអត្ថប្រយោជន៍នៃវិស័យហិរញ្ញវត្ថុផ្លូវការ ហើយទន្ទឹមនោះត្រូវលើកកម្ពស់ការយល់ដឹងអំពីហានិភ័យជាយថាហេតុដែរ។

## ខ. មូលដ្ឋានស្ថាប័ននៃវិស័យហិរញ្ញវត្ថុ

២.១២ មូលដ្ឋានស្ថាប័ននៃវិស័យហិរញ្ញវត្ថុ ត្រូវបានកសាងឡើងនៅលើបុរេលក្ខខណ្ឌសម្រាប់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ដូចមានបកស្រាយខាងលើ និងរួមមាន៖

- ប្រាតិភោគ ប្រតិបត្តិការមានកិច្ចធានា និងភតិសន្យា
- ច្បាប់ក្រុមហ៊ុន
- ប្រព័ន្ធសារពើពន្ធ និងពន្ធដារប្រកបដោយចីរភាព
- គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងរូបិយវត្ថុ និងក្របខ័ណ្ឌស្ថាប័នដែលពាក់ព័ន្ធ និង
- នីតិរដ្ឋ។

មូលដ្ឋានស្ថាប័ន គឺជាដំណាក់កាលទីពីរនៃការអភិវឌ្ឍ នៅពេលណាបុរេលក្ខខណ្ឌដំបូងភាគច្រើនត្រូវបានបង្កើតឡើងហើយ។ ទន្ទឹមនោះ មូលដ្ឋានស្ថាប័ននេះមានសារៈសំខាន់ណាស់ដើម្បីឱ្យអន្តរការិយកម្មហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាពអាចអភិវឌ្ឍន៍ទៅបាន។

### ១. ប្រាតិភោគ ប្រតិបត្តិការមានកិច្ចធានា និងភតិសន្យា

២.១៣ នៅពេលណាប្រព័ន្ធនៃសិទ្ធិលើកម្មសិទ្ធិ និងយន្តការសម្រាប់ការពារសិទ្ធិនោះត្រូវបានបង្កើតឡើងរួច ចាំបាច់ត្រូវផ្តល់នូវយន្តការមួយទៀត ដែលតាមរយៈនោះ សិទ្ធិលើកម្មសិទ្ធិនេះអាចនឹងត្រូវបានប្រើប្រាស់សម្រាប់មូលហេតុហិរញ្ញវត្ថុ។ យន្តការនោះមានទម្រង់ពីរជាមូលដ្ឋានគឺៈ រចនាសម្ព័ន្ធប្រាតិភោគ ដូចជាហ៊ីប៉ូតែកនិងប្រតិបត្តិការមានកិច្ចធានា និងភតិសន្យា។

២.១៤ ក្របខ័ណ្ឌសម្រាប់ប្រតិបត្តិការមានកិច្ចធានាអនុញ្ញាតឱ្យមានសិទ្ធិលើកម្មសិទ្ធិ រួមទាំងលើអចលនវត្ថុ ដូចជា ដីធ្លី ឬ ចលនវត្ថុ ដូចជា រថយន្តជាដើម សម្រាប់ប្រើប្រាស់ជាវត្ថុបញ្ចាំដើម្បីទ្រទ្រង់ការខ្ចីប្រាក់។ នៅកម្ពុជា ច្បាប់ភូមិបាល មានចែងនូវបទបញ្ញត្តិអំពីវត្ថុបញ្ចាំ ដែលទ្រទ្រង់ការប្រើប្រាស់អចលនវត្ថុ និងសិទ្ធិលើអចលនវត្ថុជាវត្ថុបញ្ចាំ។ ទន្ទឹមនឹងនោះ វាគឺជាការចាំបាច់ណាស់ក្នុងការអភិវឌ្ឍនូវក្របខ័ណ្ឌច្បាប់និងបទបញ្ញត្តិសមស្រប ដើម្បីទ្រទ្រង់ដល់ការវាយតម្លៃលើទ្រព្យសម្បត្តិ និងសេវាប្រតិបត្តិការអចលនវត្ថុ ក៏ដូចជាទីផ្សារអចលនវត្ថុផងដែរ។ លើសពីនេះទៀត ច្បាប់ថ្មីស្តីពីប្រតិបត្តិការមានកិច្ចធានា នឹងត្រូវបានដាក់ឱ្យប្រើនៅពេលឆាប់ៗខាងមុខ ហើយដែលនឹងត្រូវបានទ្រទ្រង់ ដោយប្រព័ន្ធចុះបញ្ជីមួយដ៏ទំនើប មានសុវត្ថិភាពនិងប្រសិទ្ធភាព សម្រាប់ទ្រព្យសម្បត្តិផ្សេងៗក្រៅពីអចលនវត្ថុ។ ប្រព័ន្ធនេះទាមទារនូវការខិតខំជាច្រើន ដើម្បីទ្រទ្រង់ការអភិវឌ្ឍដែលកំពុងដំណើរការ រួមទាំងបទបញ្ញត្តិ ការបណ្តុះបណ្តាល និងការគាំទ្រផ្នែករដ្ឋបាល ផងដែរ។

២.១៥ ភតិសន្យាគឺជាយន្តការមួយទៀតដែលអនុញ្ញាតឱ្យប្រើប្រាស់សិទ្ធិលើកម្មសិទ្ធិដើម្បីទ្រទ្រង់សកម្មភាពសេដ្ឋកិច្ចតាមរយៈវិស័យហិរញ្ញវត្ថុ។ ប្រតិបត្តិការភតិសន្យាអនុញ្ញាតឱ្យប្រើទ្រព្យសកម្មសម្រាប់ជម្រុញនូវសកម្មភាពអ្នកប្រើប្រាស់ទ្រព្យនោះក្នុងការបង្កើតចំណូល ខណៈទន្ទឹមនោះ ការពារសិទ្ធិលើកម្មសិទ្ធិរបស់ម្ចាស់ទ្រព្យ។ កម្ពុជានឹងដាក់ឱ្យប្រើប្រាស់នាពេលឆាប់ៗខាងមុខនូវច្បាប់ស្តីពីភតិសន្យាសំដៅទ្រទ្រង់ប្រតិបត្តិការនោះ ព្រមទាំងការពារសិទ្ធិលើកម្មសិទ្ធិ និងផលប្រយោជន៍របស់អ្នកពាក់ព័ន្ធទាំងឡាយ ក៏ដូចជាដើម្បីដោះស្រាយឱ្យបានសមស្របនូវបញ្ហាហានិភ័យចំពោះស្ថិរភាពវិស័យហិរញ្ញវត្ថុ។ ទន្ទឹមនោះ ក៏ទាមទារនូវធាតុផ្សំផ្សេងទៀតផងដែរ ដើម្បីទ្រទ្រង់ការអនុវត្តន៍ប្រព័ន្ធថ្មីនេះ រួមទាំង បទបញ្ញត្តិ ការបណ្តុះបណ្តាល និងការទ្រទ្រង់ផ្នែករដ្ឋបាល។

## ២. ច្បាប់ក្រុមហ៊ុន

២.១៦ ដើម្បីប្រមូលផ្តុំធនធានហិរញ្ញវត្ថុ ចាំបាច់ត្រូវមានក្របខ័ណ្ឌច្បាប់សម្រាប់ក្រុមហ៊ុន។ ដូចបានកត់សម្គាល់ពីខាងលើ កម្ពុជាបានដាក់ឱ្យប្រើជាលើកដំបូងនៅឆ្នាំ២០០៥ នូវច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ដែលចែងពីអង្គភាពអាជីវកម្មរួមទាំងក្រុមហ៊ុនផងដែរ។ ប្រព័ន្ធចុះបញ្ជីត្រូវបានបង្កើតឡើងនៅក្រសួងពាណិជ្ជកម្ម និងត្រូវបានលើកកម្ពស់ឱ្យប្រសើរថែមឡើងដែលធ្វើឱ្យការចុះបញ្ជីនាបច្ចុប្បន្នអស់ចំណាយតិចនិងងាយស្រួល ហើយចំនួនក្រុមហ៊ុនចុះបញ្ជីបានកើនឡើង ព្រមទាំងមានការចាកចេញពីសេដ្ឋកិច្ចក្រៅផ្លូវការចូលមកក្នុងសេដ្ឋកិច្ចផ្លូវការ។

២.១៧ ជាមួយនឹងការដាក់ឱ្យប្រើនូវច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម និងការលើកកម្ពស់ប្រព័ន្ធចុះបញ្ជីក្រុមហ៊ុន ការយកចិត្តទុកដាក់មួយជាបន្ទាន់ទៀត គឺត្រូវផ្តោតទៅលើការលើកកម្ពស់បរិដ្ឋានសម្រាប់ក្រុមហ៊ុន ដើម្បីទ្រទ្រង់ការកេណ្ឌប្រមូលធនធានជាពិសេសបញ្ហាក្ស័យធន ព័ត៌មានហិរញ្ញវត្ថុ និងអភិបាលកិច្ចសហគ្រាស។ លើសពីនេះទៀត ប្រព័ន្ធនោះចាំបាច់ត្រូវផ្តល់នូវក្របខ័ណ្ឌសមាហរណមានវឌ្ឍនកម្ម មានលក្ខណៈតាមលំដាប់លំដោយ មានការអភិវឌ្ឍ និងផ្អែកលើការលើកទឹកចិត្តសំដៅទ្រទ្រង់ភាពលូតលាស់ និងការពង្រីកក្រុមហ៊ុន។ ជាសំខាន់ ក្របខ័ណ្ឌនោះត្រូវ ដោះស្រាយតម្រូវការនានាសម្រាប់៖

- **ក្រុមហ៊ុនតូចៗ** : ក្រុមហ៊ុនតូចៗ ដែលបច្ចុប្បន្នបានចុះបញ្ជីកាន់តែច្រើនឡើង និងត្រូវមានកាតព្វកិច្ចដ៏សាមញ្ញក្នុងការចុះបញ្ជី និងផ្តល់ព័ត៌មានហិរញ្ញវត្ថុ ក៏ដូចជាការមាននូវប្រព័ន្ធដ៏សាមញ្ញមួយនៃពន្ធដារ អភិបាលកិច្ចសហគ្រាស និងបញ្ហាក្ស័យធន។ ចំណុចនេះត្រូវបានផ្តួចផ្តើមឡើងដោយបទបញ្ញត្តិថ្មីៗរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- **ក្រុមហ៊ុនឯកជនផ្សេងៗ** : ខណៈដែលក្រុមហ៊ុនបានរីកចំរើនធំឡើង ប៉ុន្តែនៅមានភាគទុនិកត្រឹម ៣០ ឬតិចជាងនេះ ក្រុមហ៊ុនទាំងនោះត្រូវមានកាតព្វកិច្ចចុះបញ្ជី និងផ្តល់ព័ត៌មានហិរញ្ញវត្ថុក្នុងកម្រិតមួយខ្ពស់ជាង ក៏ដូចជាត្រូវមាននិតិវិធីមាំទាំពាក់ព័ន្ធនឹងពន្ធដារ អភិបាលកិច្ចសហគ្រាស និងបញ្ហាក្ស័យធន។
- **ក្រុមហ៊ុនមហាជន** : ការចុះបញ្ជីជាទូទៅនៃក្រុមហ៊ុនមហាជន ដែលមានភាគទុនិកលើសពី ៣០ និង/ឬដែលមូលប័ត្ររបស់គេអាចនឹងត្រូវលក់ជាសាធារណៈ នឹងមិនត្រូវបានអនុញ្ញាតឱ្យបង្កើតឡើយ រហូតដល់ក្របខ័ណ្ឌបទបញ្ញត្តិប្រកបដោយប្រសិទ្ធភាពមួយត្រូវបានបង្កើតឡើង រួមទាំងហេដ្ឋារចនាសម្ព័ន្ធព័ត៌មានហិរញ្ញវត្ថុ ប្រព័ន្ធអភិបាលកិច្ចសហគ្រាស និងបញ្ហាក្ស័យធន។ ក៏ដូចគ្នាដែរ ការចុះបញ្ជីរួមនូវមូលប័ត្រសម្រាប់ក្រុមហ៊ុនមហាជនទាំងអស់រួមទាំងការចុះបញ្ជីឈ្មោះពិតនៃម្ចាស់មូលប័ត្រ នឹងត្រូវបានបង្កើតឡើងមុនពេលអនុញ្ញាតឱ្យបង្កើតក្រុមហ៊ុនមហាជនថ្មី។
- **ក្រុមហ៊ុនចុះបញ្ជី** : អាស្រ័យលើតម្រូវការទីផ្សារ កម្ពុជាអាចមានក្រុមហ៊ុនដែលចុះបញ្ជីមូលប័ត្រខ្លួននៅលើទីផ្សារមូលប័ត្រ និងដាក់លក់ដល់សាធារណជននាអនាគត។ ជាទូទៅ ក្រុមហ៊ុនប្រភេទនេះនឹងត្រូវមានស្តង់ដារដ៏ខ្ពស់ក្នុងការចុះបញ្ជីនិងផ្តល់ព័ត៌មានហិរញ្ញវត្ថុ ក៏ដូចជា ពន្ធដារ ប្រព័ន្ធអភិបាលកិច្ច សហគ្រាស និងការដោះស្រាយបញ្ហាក្ស័យធនសមស្រប។

## ៣. ប្រព័ន្ធសារពើពន្ធ និងពន្ធដារប្រកបដោយចីរភាព

២.១៨ ប្រព័ន្ធសារពើពន្ធ រួមទាំងប្រព័ន្ធពន្ធដារ ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងចីរភាព គឺជាកត្តាដ៏ចាំបាច់សម្រាប់អនុញ្ញាតឱ្យរដ្ឋាភិបាលមានលទ្ធភាពផ្តល់សេវាជាប្រយោជន៍សាធារណៈសំខាន់ៗ រួមទាំងការអនុវត្តនីតិរដ្ឋ ការដោះស្រាយជម្លោះពាណិជ្ជកម្ម និងការការពារសិទ្ធិលើកម្មសិទ្ធិ ក៏ដូចជាការរក្សាសណ្តាប់ធ្នាប់ និងស្ថិរភាពសាធារណៈ។ ប្រព័ន្ធនេះក៏មានសារៈសំខាន់ក្នុងការដោះស្រាយបញ្ហាពុករលួយ។

២.១៩ កម្ពុជា នៅក្រោមការទទួលខុសត្រូវរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រេចបាននូវវឌ្ឍនភាពក្នុងការសំរួលរបបពន្ធដារឱ្យមានភាពសាមញ្ញ ការរៀបចំបែបបទត្រូវបានសំរួល តាមរយៈការចេញឱ្យប្រើប្រាស់នូវប័ណ្ណប្រកាសពន្ធដារប្រចាំឆ្នាំ ហើយបច្ចុប្បន្នកំពុងខិតខំកសាងនូវស្ថានភាពសារពើពន្ធរបស់រដ្ឋាភិបាលមួយប្រកបដោយចីរភាព ប៉ុន្តែពុំទាន់ឈានដល់កម្រិតចីរភាពសារពើពន្ធនៅឡើយទេ។ ទន្ទឹមនោះ ចាំបាច់ត្រូវធ្វើឱ្យប្រព័ន្ធពន្ធដារកាន់តែមានភាពសាមញ្ញថែមទៀត និងត្រូវពង្រឹងបន្ថែមនូវការប្រតិបត្តិប្រព័ន្ធពន្ធដារនោះ ដើម្បីពង្រីកវិសាលភាពនៃអ្នកជាប់ពន្ធ លើកកម្ពស់ការប្រមូលពន្ធដារ និងបង្កើនចំណូលរដ្ឋាភិបាលដល់កម្រិតចីរភាពមួយសំដៅទ្រទ្រង់ចំណាយ។

២.២០ ចំពោះអនាគត ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងបន្តខិតខំលើកកំណែទម្រង់ការគ្រប់គ្រងវិស័យហិរញ្ញវត្ថុសាធារណៈអនុលោមទៅតាមស្តង់ដារ និងបទពិសោធន៍អន្តរជាតិសំខាន់ៗ ។

## ៤. គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងរូបិយវត្ថុ និងក្របខ័ណ្ឌស្ថាប័នដែលពាក់ព័ន្ធ

២.២១ គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងរូបិយវត្ថុត្រូវតែមានស្ថិរភាពសមស្រប និងត្រូវទ្រទ្រង់ដោយក្របខ័ណ្ឌមួយប្រកបដោយប្រសិទ្ធភាព ។ ពាក់ព័ន្ធនឹងគោលនយោបាយ ចំណុចផ្តោតគន្លឹះត្រូវស្ថិតនៅលើបញ្ហាស្ថិរភាពថ្លៃ ស្ថិរភាពរូបិយវត្ថុនិងហិរញ្ញវត្ថុ ។ បញ្ហាស្ថិរភាពហិរញ្ញវត្ថុនឹងត្រូវបកស្រាយដោយលំអិតនៅផ្នែកខាងក្រោមនៅក្នុងបរិបទអំពីវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ (ជំពូកទី ៣) និងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ (ជំពូកទី ៤) ។ ពាក់ព័ន្ធនឹង នយោបាយម៉ាក្រូសេដ្ឋកិច្ច កម្ពុជារងនូវភាពរឹតត្បិតដោយសារដុល្លារូបនីយកម្មនៃសេដ្ឋកិច្ច ជាពិសេសពាក់ព័ន្ធនឹងគោលនយោបាយរូបិយវត្ថុ ។ ទន្ទឹមនោះ ការប្រើប្រាស់ប្រាក់ដុល្លារអាមេរិកមានប្រសិទ្ធភាពក្នុងការទ្រទ្រង់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ។

២.២២ ក្នុងការពិនិត្យលើការអភិវឌ្ឍវិស័យហិរញ្ញវត្ថុកម្ពុជា គេឃើញមាននូវក្របខ័ណ្ឌស្ថាប័នមូលដ្ឋានជាស្រេច សម្រាប់រក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ។ ក្របខ័ណ្ឌស្ថាប័នមូលដ្ឋានផ្តល់នូវមូលដ្ឋានគ្រឹះដែលអាចធ្វើឱ្យគោលនយោបាយរូបិយវត្ថុអនុវត្តទៅបានដោយប្រសិទ្ធភាពខ្ពស់ សម្រាប់ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ។ តែដើម្បីសម្រេចការនេះបាន ចាំបាច់ត្រូវមានការអភិវឌ្ឍឧបករណ៍និងមធ្យោបាយសមស្របសិន ។

២.២៣ ចំពោះអនាគត កម្ពុជានឹងបន្តអនុវត្តតាមស្តង់ដារ និងបទពិសោធន៍អន្តរជាតិសំខាន់ៗ នៅក្នុងផ្នែកម៉ាក្រូសេដ្ឋកិច្ច និងអនុលោមតាមក្របខ័ណ្ឌស្ថាប័នដែលពាក់ព័ន្ធ ។

២.២៤ លើសពីនេះទៀត អាទិភាពជាបន្ទាន់ក្នុងការបង្កើតនូវប្រព័ន្ធមួយសម្រាប់គោលនយោបាយរូបិយវត្ថុប្រកបដោយប្រសិទ្ធភាព គឺ ទីមួយ ត្រូវពង្រឹងឧបករណ៍នយោបាយរូបិយវត្ថុ និងទីពីរ ត្រូវអភិវឌ្ឍន៍ក្របខ័ណ្ឌនយោបាយរូបិយវត្ថុផ្អែកលើទីផ្សារ ។ ដូចមានចែងនៅក្នុងចក្ខុវិស័យនិងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០១-២០១០ ការពង្រឹងឧបករណ៍នយោបាយរូបិយវត្ថុនឹងនាំឱ្យមានការកើនឡើងនូវការប្រកួតប្រជែងរវាងបណ្តាធនាគារ ហើយដូចនេះ នឹងពង្រឹងមុខងារអន្តរការិយកម្មរបស់គេ ។ នាបច្ចុប្បន្ន តម្រូវការគន្លឹះគឺ ៖

- **ប្រព័ន្ធទូទាត់សងប្រាក់ :** លុះត្រាតែប្រព័ន្ធទូទាត់សងប្រាក់មានការអភិវឌ្ឍល្អ នោះទើបគេអាចសម្រេចបាននូវប្រសិទ្ធភាពនៃនយោបាយរូបិយវត្ថុ ។ ដូច្នេះគោលដៅគន្លឹះគឺការសម្រេចបាននូវការបង្កើតប្រព័ន្ធទូទាត់សងប្រាក់មួយដែលធានា និងប្រកបដោយសុវត្ថិភាព និងមានវិសាលភាពជាតិ ។ លើសពីនេះទៀត គេរំពឹងថា នឹងមាននូវប្រព័ន្ធទូទាត់សងប្រាក់តាមអេឡិចត្រូនិច ទាំងសម្រាប់ប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក ។

- **ទីផ្សាររូបិយវត្ថុ/អន្តរធនាគារ/មូលប័ត្ររដ្ឋ :** ទីផ្សារហិរញ្ញវត្ថុដើរតួជាសមាសធាតុសំខាន់មួយទៀតនៃក្របខ័ណ្ឌនយោបាយម៉ាក្រូសេដ្ឋកិច្ច ដោយកំណត់នូវរូបរាងនៃនយោបាយរូបិយវត្ថុផ្អែកលើទីផ្សារ។ ជាពិសេស ការបង្កើតទីផ្សាររូបិយវត្ថុ និង អន្តរធនាគារ រួមទាំងមូលប័ត្ររដ្ឋរយៈកាលខ្លី[៣] និងទ្រទ្រង់ដល់លំហូរធនធានហិរញ្ញវត្ថុ និងផ្តល់ដល់រដ្ឋាភិបាលនិងធនាគារជាតិនៃកម្ពុជានូវព័ត៌មានសំខាន់ៗ ព្រមទាំងមធ្យោបាយសម្រាប់ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច។

២.២៥ ការបង្កើតនូវប្រព័ន្ធទូទាត់សងប្រាក់មួយប្រកបដោយប្រសិទ្ធភាព និងទីផ្សាររូបិយវត្ថុ និងអន្តរធនាគារ រួមទាំងមូលប័ត្ររដ្ឋរយៈកាលខ្លី នឹងបើកផ្លូវមិនត្រឹមតែចំពោះនយោបាយរូបិយវត្ថុផ្អែកលើទីផ្សារប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនឹងជម្រុញការអភិវឌ្ឍរូបិយវត្ថុផងដែរ ដែលជាអាទិភាពរយៈកាលមធ្យម និងរយៈកាលវែង សម្រាប់កម្ពុជា។

២.២៦ ការអភិវឌ្ឍរូបិយវត្ថុ និងការបង្កើនការប្រើប្រាស់ប្រាក់រៀល ក៏ត្រូវបានទ្រទ្រង់ផងដែរតាមរយៈកំណើនជំនឿទុកចិត្តរបស់សាធារណជន។ នៅពេលដែលទំនុកចិត្តទៅលើរដ្ឋាភិបាល ប្រព័ន្ធហិរញ្ញវត្ថុ និងស្ថាប័នហិរញ្ញវត្ថុមានភាពប្រសើរឡើង ហើយនៅពេលដែលមានការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ផងនោះ ជំនឿទុកចិត្តទៅលើរូបិយវត្ថុជាតិក៏នឹងកើនឡើង។ ខណៈដែលហេដ្ឋារចនាសម្ព័ន្ធត្រូវបានអភិវឌ្ឍន៍ ប្រាក់បៀវត្ស និងចំណាយផ្សេងៗទៀតរបស់រដ្ឋាភិបាល អាចនឹងត្រូវបានទូទាត់សងប្រាក់តាមរយៈប្រព័ន្ធទូទាត់សងប្រាក់ទៅក្នុងគណនីធនាគារ ហើយប្រាក់ពន្ធ និងចំណូលដទៃទៀតរបស់រដ្ឋាភិបាលក៏អាចទូទាត់ជាប្រាក់រៀលតាមរយៈប្រព័ន្ធធនាគារ និងប្រព័ន្ធទូទាត់សងប្រាក់បានដែរ។ ទង្វើនេះក៏អាចនឹងពង្រីកផងដែរចំពោះប្រាក់បៀវត្សទាំងអស់ នៅពេលណាដែលវិស័យហិរញ្ញវត្ថុមានការអភិវឌ្ឍគ្រប់គ្រាន់។ នៅពេលដែលទំនុកចិត្តបែបនេះកើនឡើង ក្រដាសប្រាក់ចារឹកតម្លៃកាន់តែធំជាងមុនអាចនឹងត្រូវបានបោះផ្សាយ ដើម្បីពង្រឹងប្រសិទ្ធភាពប្រាក់រៀលជាមធ្យោបាយទូទាត់។ ក្នុងបរិបទបែបនេះ ថ្លៃទំនិញក៏អាចនឹងដាក់ចេញជាប្រាក់រៀលបានដែរ។ លើសពីនេះទៅទៀត ខណៈដែលទំនុកចិត្តលើរូបិយវត្ថុកើនឡើង ហើយការប្រើប្រាស់ប្រាក់រៀលក៏កើនឡើងដែរនោះ ឧបករណ៍ដែលមានសម្រាប់អនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង រូបិយវត្ថុ ក៏នឹងមានភាពប្រសើរឡើងដែរ។

## ៥. នីតិរដ្ឋ

២.២៧ ដើម្បីធ្វើឱ្យវិស័យហិរញ្ញវត្ថុមានការអភិវឌ្ឍលើសពីភាពសាមញ្ញ ដោយប្រតិបត្តិការរយៈកាលខ្លី និងច្រើនផ្អែកលើសាច់ប្រាក់ ចាំបាច់ត្រូវមានប្រព័ន្ធនីតិរដ្ឋសម្រាប់សកម្មភាពហិរញ្ញវត្ថុនិងពាណិជ្ជកម្ម។ នៅក្នុងបរិបទនៃវិស័យហិរញ្ញវត្ថុ នីតិរដ្ឋមានខ្លឹមសារច្រើនជាងការអនុវត្តន៍ដោយសង្គតភាពនូវកិច្ចសន្យា និងការដោះស្រាយជម្លោះដ៏សមស្រប ពោលគឺត្រូវមានការពាក់ព័ន្ធទៅនឹងធាតុនៃប្រព័ន្ធច្បាប់ដែលមាននៅក្នុងប្រទេសមួយផងដែរ។ ដើម្បីទ្រទ្រង់នូវការអភិវឌ្ឍវិស័យហិរញ្ញវត្ថុកម្រិតកណ្តាលមួយ ច្បាប់ត្រូវតែ៖

- បានបង្កើតឡើងដោយអាជ្ញាធរមានសមត្ថកិច្ច មានភាពច្បាស់លាស់ប្រាកដប្រជា ងាយស្រួល សម្រាប់ប្រជាជនប្រើប្រាស់បានមានសង្គតភាពរវាងគ្នា មានទស្សនាទានទៅអនាគត អាចគោរព និងអនុវត្តបាន

[៣] *មើលជំពូកទី ៤ អំពីវិស័យហិរញ្ញវត្ថុមិនមែនធនាគារ : ទីផ្សារហិរញ្ញវត្ថុ*

- ប្រតិបត្តិបានតាមរយៈដំណើរការប្រកបដោយតម្លាភាព មានហេតុផលសមស្រប និងជាកម្មវត្ថុនៃការតវ៉ាតាមច្បាប់
- បកស្រាយ និងតាមដានដោយតុលាការឯករាជ្យ មិនស្ថិតនៅក្រោមការគ្រប់គ្រងនយោបាយ និង
- សមស្របនឹងចរិយានៃមន្ត្រីគ្រប់គ្រង។

២.២៨ នាពេលបច្ចុប្បន្ន ដូចបានលើកឡើងខាងលើ គឺនៅមានភាពមិនច្បាស់លាស់ និងកង្វះទំនុកចិត្តនៅលើតួនាទីប្រព័ន្ធតុលាការក្នុងការអនុវត្តនីកិច្ចសន្យា និងដោះស្រាយជម្លោះ។ បញ្ហានេះត្រូវតែបានដោះស្រាយតាមរយៈការអភិវឌ្ឍប្រព័ន្ធមជ្ឈត្តការពាណិជ្ជកម្ម ការទ្រទ្រង់ឱ្យមានជំរើសផ្សេងៗទៀតសម្រាប់ដោះស្រាយជម្លោះ និងប្រព័ន្ធតុលាការពាណិជ្ជកម្ម។ ទន្ទឹមនោះ ដើម្បីឱ្យប្រព័ន្ធហិរញ្ញវត្ថុនាំមកនូវផលប្រយោជន៍ជាអតិបរមា កំណែទម្រង់ត្រូវតែផ្តោតទៅលើសមាសភាពលើកឡើងពីខាងលើទាំងបួនពាក់ព័ន្ធនឹងការអភិវឌ្ឍនីតិរដ្ឋនៅក្នុងបរិបទនៃវិស័យហិរញ្ញវត្ថុ។ ក្នុងកំឡុងពេលពីរយៈកាលមធ្យមទៅវែង កម្ពុជាប្តេជ្ញានឹងអនុវត្តនីតិរដ្ឋ។ ប៉ុន្តែការនេះនឹងទាមទារនូវកំណែទម្រង់រដ្ឋបាលនិងតុលាការយ៉ាងទូលំទូលាយ ការប្តេជ្ញា និងធនធានសម្រាប់អនុវត្ត ប៉ុន្តែក្នុងរយៈកាលវែង ទង្វើនេះនឹងផ្តល់នូវការទ្រទ្រង់ដ៏ធំធេងសម្រាប់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ កំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌ និងការកាត់បន្ថយភាពក្រីក្រ។

២.២៩ កម្ពុជានឹងបន្តលើកកម្ពស់តម្លាភាព និងសមត្ថកិច្ចស្របច្បាប់នៅក្នុងវិស័យហិរញ្ញវត្ថុតាមរយៈការពិគ្រោះយោបល់ជាសាធារណៈនៅលើសេចក្តីព្រាងច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធនឹងវិស័យហិរញ្ញវត្ថុ។ លើសពីនេះទៀត ច្បាប់និងបទបញ្ញត្តិទាំងអស់ពាក់ព័ន្ធនឹងវិស័យហិរញ្ញវត្ថុ នឹងត្រូវបើកចំហសម្រាប់សាធារណជនប្រើប្រាស់បានតាមរយៈអ៊ីនធឺណេត។ ទង្វើនេះ មិនត្រឹមតែទ្រទ្រង់ការអភិវឌ្ឍនីតិរដ្ឋនៅក្នុងវិស័យហិរញ្ញវត្ថុប៉ុណ្ណោះទេប៉ុន្តែក៏មានសារៈសំខាន់ផងដែរនៅក្នុងបរិបទនៃការសន្យាប្តេជ្ញារបស់កម្ពុជាជាមួយអង្គការពាណិជ្ជកម្មពិភពលោក និងកាតព្វកិច្ចពាក់ព័ន្ធនឹងតម្លាភាព។ ក្នុងដំណាក់កាលទីពីរ កម្ពុជានឹងបន្តដំណើរការបង្កើតតុលាការពាណិជ្ជកម្មជំនាញដែលប្រតិបត្តិនៅក្រោមវិធាននៃគោលការណ៍ច្បាប់។ ក្នុងរយៈកាលវែងខាងមុខ កម្ពុជានឹងខិតខំអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងរដ្ឋបាល ទាំងស្រុងរបស់ខ្លួនឱ្យមានប្រតិបត្តិការនៅក្រោមវិធាននៃគោលការណ៍ច្បាប់។

## គ. ហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ

២.៣០ ផ្អែកលើបុរេលក្ខខណ្ឌ និងមូលដ្ឋានស្ថាប័ន ប្រតិបត្តិការហិរញ្ញវត្ថុ និងការអភិវឌ្ឍជាមូលដ្ឋាន អាចនឹងកើតឡើងបានហើយជាក់ស្តែង នេះគឺជាស្ថានភាពនៅកម្ពុជានាពេលបច្ចុប្បន្ន។ ទន្ទឹមនោះ ដើម្បីឈានទៅសម្រេចបាននូវទម្រង់កាន់តែសុក្រិតនៃអន្តរការិយកម្ម និងការកេណ្ឌប្រមូល និងបែងចែកធនធាន ចាំបាច់ត្រូវអភិវឌ្ឍន៍នូវហេដ្ឋារចនាសម្ព័ន្ធច្បាប់ និងស្ថាប័នឱ្យកាន់តែសុក្រិត្យសម្រាប់វិស័យហិរញ្ញវត្ថុ។ ចំណុចនេះពិពណ៌នាយ៉ាងច្បាស់នូវកាលៈទេសៈបច្ចុប្បន្ននៅកម្ពុជា។ ហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុនោះចាំបាច់ត្រូវដោះស្រាយបញ្ហាដូចតទៅ ៖

- បញ្ហាក្ស័យធន
- ព័ត៌មានហិរញ្ញវត្ថុ

- អភិបាលកិច្ចសហគ្រាស
- ប្រព័ន្ធទូទាត់សងប្រាក់និងផាតទាត់
- អំពើពុករលួយ និងសុចរិតភាពទីផ្សារ និង
- ទីផ្សារមូលប័ត្រ ។

## ១. បញ្ហាក្ស័យធន

២.៣១ នៅពេលដែលប្រទេសមានច្បាប់ក្រុមហ៊ុនហើយ គេចាំបាច់ត្រូវដោះស្រាយបញ្ហាដួលរលំរបស់ក្រុមហ៊ុនទៀត ដែលជាហេតុការណ៍ដែលតែងកើតឡើងនៅក្នុងសេដ្ឋកិច្ចទីផ្សារ តាមរយៈការអភិវឌ្ឍប្រព័ន្ធមួយដែលដោះស្រាយបញ្ហាក្ស័យធន ។ បច្ចុប្បន្ននេះ កម្ពុជាស្ថិតក្នុងដំណើរការអនុម័តច្បាប់ស្តីពីក្ស័យធនជាលើកដំបូង ស្របតាមស្តង់ដារនិងបទពិសោធន៍អន្តរជាតិ ។ ដំណាក់កាលបន្ទាប់ គឺប្រព័ន្ធរដ្ឋបាលពាក់ព័ន្ធដែលចាំបាច់សម្រាប់ឱ្យច្បាប់អាចអនុវត្តបាន ។ ការនេះទាមទារនូវបទបញ្ញត្តិសមស្របការអភិវឌ្ឍផ្នែកវិជ្ជាជីវៈនិងរដ្ឋបាល សកម្មភាពបែងចែកផ្សព្វផ្សាយ ការអភិវឌ្ឍកម្មវិធីសិក្សា និងការបណ្តុះបណ្តាល ។

## ២. ព័ត៌មានហិរញ្ញវត្ថុ

២.៣២ ដើម្បីឱ្យប្រតិបត្តិការហិរញ្ញវត្ថុអាចឈានហួសពីការឱ្យខ្ចីយ៉ាងសាមញ្ញផ្អែកលើវត្ថុបញ្ចាំ ឬផ្អែកលើទំនាក់ទំនង ចាំបាច់ត្រូវអភិវឌ្ឍន៍នូវប្រព័ន្ធសមស្របសម្រាប់ព័ត៌មានហិរញ្ញវត្ថុ ជាពិសេសប្រព័ន្ធពាក់ព័ន្ធនឹងគណនេយ្យ និងសវនកម្ម ។ លើសពីនេះទៀត ប្រព័ន្ធព័ត៌មានឥណទានសម្រាប់ការឱ្យខ្ចី និងភ្នាក់ងារចំណាត់ថ្នាក់ឥណទាន ក៏មានសារៈសំខាន់ដែរ ។ កម្ពុជាបានដាក់ឱ្យប្រើនូវច្បាប់ស្តីពីគណនេយ្យសហគ្រាស វិជ្ជាជីវៈគណនេយ្យ និងសវនកម្មជាលើកដំបូង បានបង្កើតក្រុមប្រឹក្សាជាតិគណនេយ្យជាអ្នកកំណត់ស្តង់ដារ និងបង្កើតវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា ជាអង្គភាពវិជ្ជាជីវៈ និងបង្កើតស្តង់ដារគណនេយ្យនិងសវនកម្មផ្អែកលើស្តង់ដារគណនេយ្យអន្តរជាតិ ។ ទន្ទឹមនឹងនេះ ក៏មានការរីកចំរើនដែរនៅក្នុងការអភិវឌ្ឍធនធានមនុស្សដើម្បីទ្រទ្រង់ប្រព័ន្ធទាំងនោះ ។ ប្រព័ន្ធព័ត៌មានឥណទានអន្តរធនាគារត្រូវបានដាក់ឱ្យប្រើនៅខែសីហា ឆ្នាំ២០០៦ ។ ប្រព័ន្ធនេះត្រូវបានសម្របសម្រួល និងទ្រទ្រង់ពីសំណាក់ធនាគារជាតិនៃកម្ពុជា ហើយនឹងក្លាយជារបស់វិស័យឯកជន នៅពេលណាដែលប្រព័ន្ធនេះមានចីរភាពហិរញ្ញវត្ថុ ជាមួយនឹងការពង្រីកលទ្ធភាពឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណអាចចូលរួមផងដែរ ។ លើសពីនេះទៀត ភ្នាក់ងារចំណាត់ថ្នាក់ឥណទានអាចនឹងមានផលប្រយោជន៍ចំពោះការលើកកម្ពស់វប្បធម៌ឥណទាន នៅពេលដែលទីផ្សារហិរញ្ញវត្ថុមានការអភិវឌ្ឍ ។

២.៣៣ នៅក្នុងបរិបទនេះ ចាំបាច់ត្រូវមានការទ្រទ្រង់ជាបន្តទៀតសម្រាប់ការអភិវឌ្ឍស្តង់ដារគណនេយ្យ និងសវនកម្ម ព្រមទាំងបទបញ្ញត្តិដែលពាក់ព័ន្ធ ក៏ដូចជាការបែងចែកផ្សព្វផ្សាយ ការអភិវឌ្ឍកម្មវិធីសិក្សា និងការបណ្តុះបណ្តាល ។ ការអភិវឌ្ឍនិងការផ្ទេរប្រព័ន្ធព័ត៌មានឥណទានអន្តរធនាគារទៅឱ្យវិស័យឯកជន នឹងទាមទារនូវការអភិវឌ្ឍច្បាប់និងបទបញ្ញត្តិ ក៏ដូចជាការបែងចែកផ្សព្វផ្សាយ និងការបណ្តុះបណ្តាលផងដែរ ។

## ៣. អភិបាលកិច្ចសហគ្រាស

២.៣៤ ដើម្បីឱ្យក្រុមហ៊ុនអាចដើរតួជាយន្តការប្រមូលផ្តុំដើមទុនពីអ្នកវិនិយោគក្នុងចំនួនដ៏ច្រើនបាន ពោលគឺឈានពីក្រុមហ៊ុនឯកជនមានភាគទុនិកតិចជាង ឬស្មើនឹង៣០នាក់ ទៅក្រុមហ៊ុនមហាជនមានភាគទុនិកចំនួនច្រើន និង ជាយថាភាព ទៅជាក្រុមហ៊ុនចុះបញ្ជីដែលលក់មូលប័ត្រចំពោះសាធារណជន យន្តការសមស្របផ្សេងៗទៀតក៏ត្រូវអភិវឌ្ឍន៍ផងដែរសម្រាប់អភិបាលកិច្ចសហគ្រាសស្របតាមស្តង់ដារអន្តរជាតិ ដូចជាគោលការណ៍អភិបាលកិច្ចសហគ្រាសរបស់ស្ថាប័នអភិវឌ្ឍន៍និងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច (OECD) ជាដើម។ ការចុះបញ្ជីទូទៅនៃក្រុមហ៊ុនមហាជនថ្មីៗនឹងត្រូវចាប់ផ្តើម នៅពេលណាក្របខ័ណ្ឌបទបញ្ញត្តិសមស្របត្រូវបានបង្កើតឡើងហើយ។ ការអភិវឌ្ឍប្រព័ន្ធបទបញ្ញត្តិ នឹងទាមទារនូវការខិតខំជាច្រើន។

## ៤. ប្រព័ន្ធទូទាត់សងប្រាក់ និងផាត់ទាត់

២.៣៥ ប្រព័ន្ធទូទាត់សងប្រាក់និងផាត់ទាត់ ជាកត្តាចាំបាច់សម្រាប់ការអភិវឌ្ឍទីផ្សាររូបិយវត្ថុនិងអន្តរធនាគារ និងការកេណ្ឌប្រមូលធនធានតាមរយៈប្រព័ន្ធហិរញ្ញវត្ថុ ក៏ដូចជាការទ្រទ្រង់ការអនុវត្តន៍នយោបាយម៉ាក្រូសេដ្ឋកិច្ច។ នា បច្ចុប្បន្ន សេដ្ឋកិច្ចកម្ពុជាគឺជាសេដ្ឋកិច្ចផ្អែកលើសាច់ប្រាក់ ដោយពុំមានប្រព័ន្ធទូទាត់សងប្រាក់និងផាត់ទាត់ដុលជាផ្លូវការទេ លើកលែងតែចំពោះការផាត់ទាត់មូលប្បទានប័ត្រ ជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក មួយចំនួនតូច ថ្វីត្បិតតែមានការកើនឡើងក្តី។ នេះគឺជាឧបសគ្គដ៏ចំបងចំពោះការអភិវឌ្ឍវិស័យហិរញ្ញវត្ថុកម្ពុជា និងជាអាទិភាពគន្លឹះនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០៦-២០១៥។ ទន្ទឹមនោះ ច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ត្រូវបានដាក់ឱ្យប្រើនៅឆ្នាំ២០០៥ ដែលផ្តល់ជាលើកទីមួយនូវក្របខ័ណ្ឌច្បាប់ដ៏ទូលំទូលាយ សម្រាប់ការអភិវឌ្ឍឧបករណ៍អាចជួញដូរបាន ដូចជាមូលប្បទានប័ត្រ រូបិយាណត្តិ និងប័ណ្ណសងតាមបញ្ជា ព្រមទាំងនូវក្របខ័ណ្ឌបទបញ្ញត្តិសម្រាប់ប្រព័ន្ធទូទាត់សងប្រាក់ដុលជាផ្លូវការ។ បញ្ហានេះត្រូវបានបកស្រាយលំអិតនៅក្នុងបរិបទអំពីវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ (ជំពូកទី ៣)។

## ៥. អំពើពុករលួយ និងសុចរិតភាពទីផ្សារ

២.៣៦ យន្តការសម្រាប់ដោះស្រាយបញ្ហាពុករលួយ និងសុចរិតភាពទីផ្សារ ត្រូវបានចាត់ទុកថាជាគន្លឹះចំពោះការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ។ សុចរិតភាពទីផ្សារផ្តោតជាបឋមទៅលើការសំអាតប្រាក់ និងលំហូររូបិយវត្ថុពាក់ព័ន្ធនានា ដែលកើតឡើងពីសកម្មភាពមិនស្របច្បាប់។ នាបច្ចុប្បន្ន កម្ពុជាកំពុងដំណើរការអនុវត្តប្រព័ន្ធដ៏ទូលំទូលាយមួយសំដៅដោះស្រាយបញ្ហាសំអាតប្រាក់។ ជាបន្ថែមលើការសំអាតប្រាក់ សុចរិតភាពទីផ្សារក៏រួមបញ្ចូលផងដែរនូវការការពារចំពោះអំពើបន្លំ និងបទឧក្រិដ្ឋផ្នែកហិរញ្ញវត្ថុ។ បញ្ហានេះទាមទារនូវការខិតខំជាច្រើន ខណៈដែលវិស័យហិរញ្ញវត្ថុកម្ពុជាដំណើរការអភិវឌ្ឍ ហើយនឹងត្រូវបានបកស្រាយនៅក្នុងបរិបទនៃជំពូកទី ៤។

២.៣៧ ពាក់ព័ន្ធនឹងការសំអាតប្រាក់ និងសុចរិតភាពទីផ្សារ សេចក្តីណែនាំបឋមជាអន្តរជាតិគឺជាអនុសាសន៍របស់ក្រុមការងារហិរញ្ញវត្ថុអំពីការសំអាតប្រាក់ (FATF) ។ កម្ពុជាកំពុងអនុវត្តគោលការណ៍ណែនាំរបស់ក្រុមការងារហិរញ្ញវត្ថុអំពីការសំអាតប្រាក់ និងបន្តការខិតខំយ៉ាងខ្ពស់ថែមទៀតសំដៅប្រឆាំងនឹងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដោយផ្អែកលើគោលការណ៍ "ស្គាល់អតិថិជនខ្លួន" និងកាតព្វកិច្ចរាយការណ៍ អំពីប្រតិបត្តិការសង្ស័យក្នុងវិស័យហិរញ្ញវត្ថុទាំងមូល ។

២.៣៨ ចំពោះការដោះស្រាយបញ្ហាអំពើពុករលួយ ផ្អែកលើបទពិសោធន៍ជុំវិញពិភពលោក និងជាពិសេសនៅតំបន់អាស៊ី គេអាចកំណត់នូវវិធានការមួយចំនួនដូចតទៅ ៖

- **កំណែលំអ និងចីរភាពសារពើពន្ធ :** អំពើពុករលួយអាចជាលទ្ធផលនៃកម្រិតបៀវត្សដ៏ទាបក្នុងវិស័យសាធារណៈ ។ មុននឹងរដ្ឋាភិបាលអាចបង្កើនកម្រិតបៀវត្សក្នុងវិស័យសាធារណៈបាន រដ្ឋាភិបាលត្រូវមានលទ្ធភាពបង្កើតចំណូលគ្រប់គ្រាន់ និងដោយចីរភាព តាមរយៈប្រព័ន្ធពន្ធដារដ៏សាមញ្ញ និងរបបសារពើពន្ធប្រកបដោយចីរភាព ។ ចំណុចនេះកំពុងត្រូវបានដោះស្រាយតាមរយៈកំណែទម្រង់ការគ្រប់គ្រងវិស័យហិរញ្ញវត្ថុសាធារណៈ នៅក្រោមការដឹកនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ នៅក្នុងបរិបទនេះ របបពន្ធដារដែលអាចគោរពបាន និងដែលទាមទារនូវកម្រិតសមស្របមួយនៃការបង់ពន្ធ ក៏នឹងលើកទឹកចិត្តឱ្យមាននូវការគោរពចំពោះរដ្ឋាភិបាល និងច្បាប់ផងដែរ ។
- **បង្កើនប្រាក់បៀវត្សរបស់មន្ត្រីរាជការ :** ជាពិសេសចំពោះតុលាការ ឱ្យដល់កម្រិតមួយដ៏សមស្រប នៅពេលសម្រេចបាននូវចីរភាពសារពើពន្ធ សំដៅកាត់បន្ថយការលើកទឹកចិត្តចំពោះអំពើពុករលួយនៅក្នុងវិស័យសាធារណៈ ។ ប្រាក់បៀវត្សរបស់តុលាការត្រូវបានបង្កើន ហើយការខិតខំត្រូវបានធ្វើឡើងនៅក្នុងបរិបទនៃកំណែទម្រង់ការគ្រប់គ្រងវិស័យហិរញ្ញវត្ថុសាធារណៈ សំដៅដោះស្រាយបញ្ហាហិរញ្ញវត្ថុរបស់រដ្ឋាភិបាល និងចីរភាព ។
- **ច្បាប់ស្តីពីអំពើពុករលួយ គួបផ្សំនិងការលើកលែងទោសចំពោះការរំលោភច្បាប់ដែលមានពីមុនមក :** ទន្ទឹមនឹងបង្កើនប្រាក់បៀវត្សសម្រាប់វិស័យសាធារណៈ ចាំបាច់ក៏ត្រូវដាក់ឱ្យប្រើនូវច្បាប់ស្តីពីអំពើពុករលួយដ៏តឹងតែងមួយស្របតាមស្តង់ដារអន្តរជាតិ ដូចជាសេចក្តីណែនាំគន្លឹះមានចែងនៅក្នុងកតិកាសញ្ញា នៃអង្គការសម្រាប់សហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍ (OECD) ស្តីពីការសូកប៉ាន់មន្ត្រីសាធារណៈ និងក្នុងក្រមស្តីពីលទ្ធកម្មសាធារណៈរបស់អង្គការពាណិជ្ជកម្មពិភពលោក ។ ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ នឹងត្រូវបានដាក់ឱ្យប្រើប្រាស់នាពេលអនាគតខាងមុខ ។
- **អាជ្ញាធរឯករាជ្យប្រឆាំងនឹងអំពើពុករលួយ :** ទន្ទឹមនឹងនោះ ខណៈដែលច្បាប់ស្តីពីអំពើពុករលួយបានអនុម័តរួចហើយ រយៈពេលលើកលែងទោសត្រូវផុតកំណត់ ចាំបាច់ត្រូវបង្កើតអាជ្ញាធរគ្រប់គ្រង និងអង្កេតដោយឯករាជ្យមួយសម្រាប់អនុវត្តប្រព័ន្ធថ្មីនោះ ។ឧត្តមក្រុមប្រឹក្សាទទួលបន្ទុកលើការប្រឆាំង អំពើពុករលួយនឹងត្រូវបានបង្កើតឡើងនិងកំពុងរៀបចំក្របខ័ណ្ឌច្បាប់សមស្រប ព្រមទាំងប្រព័ន្ធពាក់ព័ន្ធនានា ។

២.៣៩ កម្ពុជាមានការប្តេជ្ញាដោះស្រាយបញ្ហាអំពើពុករលួយនៅក្នុងបរិបទនៃស្តង់ដារ និងបទពិសោធន៍អន្តរជាតិ ។

### ៦. ទីផ្សារមូលប័ត្រ

២.៤០ នៅពេលណារាជរដ្ឋាភិបាលបានអភិវឌ្ឍន៍ប្រព័ន្ធពន្ធដារ និងសារពើពន្ធប្រកបដោយចីរភាពហើយ រាជរដ្ឋាភិបាលធ្វើការអភិវឌ្ឍទីផ្សារមូលប័ត្រ។ ច្បាប់ស្តីពីមូលប័ត្ររដ្ឋត្រូវបានរដ្ឋសភាអនុម័តនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៦។ ក្រៅពីការទ្រទ្រង់ការគ្រប់គ្រងសាច់ប្រាក់ងាយស្រួលរបស់រាជរដ្ឋាភិបាល តាមរយៈការបោះផ្សាយជាប្រចាំនូវមូលប័ត្ររដ្ឋរយៈពេលខ្លី ទីផ្សារមូលប័ត្ររដ្ឋក៏ទ្រទ្រង់ផងដែរចំពោះដំណើរការនៃប្រព័ន្ធទូទាត់សងប្រាក់ និងផាត់ទាត់ តាមរយៈការផ្តល់នូវមធ្យោបាយសម្រាប់ការធានាការទូទាត់មុនពេលធ្វើការទូទាត់ជំរះជាបញ្ចប់ នយោបាយម៉ាក្រូសេដ្ឋកិច្ចនិងរូបិយវត្ថុ និងផ្តល់នូវព័ត៌មានគន្លឹះចំពោះអ្នកចូលរួមក្នុងវិស័យហិរញ្ញវត្ថុតាមរយៈការវិវត្តន៍នៃខ្សែកោងរបាយអត្រាការប្រាក់។ លើសពីនេះទៀត ពេលណាទីផ្សារមូលប័ត្ររដ្ឋរយៈកាលខ្លីមានដំណើរការ និងផ្តល់នូវខ្សែកោងរបាយអត្រាការប្រាក់ប្រកបដោយប្រសិទ្ធភាព រាជរដ្ឋាភិបាលនឹងបង្កើនរយៈកាលនៃការខ្ចីរបស់ខ្លួន ហើយតាមរយៈនេះនឹងផ្តល់នូវមធ្យោបាយហិរញ្ញប្បទានរយៈពេលវែង ក៏ដូចជានឹងទ្រទ្រង់ចំពោះកាលានុវត្តភាពវិនិយោគ។ បញ្ហានេះត្រូវបានពិភាក្សាលំអិតនៅក្នុងបរិបទអំពីវិស័យហិរញ្ញវត្ថុមិនមែនធនាគារ : ទីផ្សារហិរញ្ញវត្ថុ (ជំពូកទី ៤)។

## ឃ. យុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ : មូលដ្ឋានគ្រឹះសម្រាប់វិស័យហិរញ្ញវត្ថុ

២.៤១ ចំពោះអនាគត ផ្នែកនេះនឹងបកស្រាយនូវបញ្ហាប្រឈមសំខាន់ៗពាក់ព័ន្ធនឹងមូលដ្ឋានគ្រឹះនៃវិស័យហិរញ្ញវត្ថុ នៅក្នុងបរិបទនៃស្តង់ដារ និងបទពិសោធន៍អន្តរជាតិ។

### ១. អាទិភាពចំពោះមុខ

២.៤២ អាទិភាពចំពោះមុខពាក់ព័ន្ធនឹងមូលដ្ឋានគ្រឹះនៃវិស័យហិរញ្ញវត្ថុមាន៖

- **បន្តទ្រទ្រង់វិធីសាស្ត្រផ្អែកលើនីតិរដ្ឋ :** ចំពោះការអភិវឌ្ឍ និងការបើកចំហសម្រាប់ប្រើប្រាស់នូវច្បាប់និងបទបញ្ញត្តិពាក់ព័ន្ធនឹងវិស័យហិរញ្ញវត្ថុតាមរយៈ (១) ការពិគ្រោះយោបល់ជាសាធារណៈពាក់ព័ន្ធនឹងសេចក្តីព្រាងច្បាប់និងបទបញ្ញត្តិទាំងអស់ដែលទាក់ទិននឹងវិស័យហិរញ្ញវត្ថុ និង(២) ការបើកចំហសម្រាប់ប្រើប្រាស់នូវច្បាប់និងបទបញ្ញត្តិទាំងអស់ដែលពាក់ព័ន្ធនឹងវិស័យហិរញ្ញវត្ថុតាមរយៈអ៊ិនធឺណេត។
- **អនុម័តច្បាប់ និងក្រមពាណិជ្ជកម្ម :** រួមទាំងច្បាប់ស្តីពីប្រតិបត្តិការមានកិច្ចធានា ច្បាប់ស្តីពីភតិសន្យា ច្បាប់ស្តីពីក្ស័យធន ច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម ច្បាប់ស្តីពីការប្រកួតប្រជែង ច្បាប់ស្តីពីតុលាការពាណិជ្ជកម្ម និងក្រមរដ្ឋប្បវេណី។ ច្បាប់ដទៃទៀតដែលត្រូវពិចារណារួមមាន ច្បាប់ស្តីពីភ្នាក់ងារ និងសិទ្ធិលក់ផលិតផលអ្នកដទៃជាដើម។
- **អនុវត្តច្បាប់ពាណិជ្ជកម្មថ្មីៗ :** តាមរយៈបទបញ្ញត្តិ និងសេវារដ្ឋបាលសមស្របសម្រាប់ទ្រទ្រង់ ដូចជា ការិយាល័យតំកល់ និងការចុះបញ្ជីនិងប្រព័ន្ធផ្តល់អាជ្ញាប័ណ្ណ ក៏ដូចជាការបែងចែកផ្សព្វផ្សាយ ការអភិវឌ្ឍកម្មវិធីសិក្សា និងសកម្មភាពបណ្តុះបណ្តាលផងដែរ។ ទាំងនេះនឹងត្រូវបានទ្រទ្រង់ដោយការបង្កើតមជ្ឈមណ្ឌលច្បាប់ និងឯកសារពាណិជ្ជកម្ម។ សកម្មភាពអនុវត្តនឹងត្រូវធ្វើឡើងជាចាំបាច់ចំពោះច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ច្បាប់ស្តីពីប្រតិបត្តិការមានកិច្ចធានា ច្បាប់ស្តីពីភតិសន្យា

ច្បាប់ស្តីពីក្ស័យធន ច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម និងក្រមរដ្ឋប្បវេណី ក្នុងចំណោមច្បាប់ដទៃផ្សេងៗទៀត ដូចជាច្បាប់ស្តីពីភ្នាក់ងារនិងសិទ្ធលក់ផលិតផលអ្នកដទៃ។ សកម្មភាពពាក់ព័ន្ធផ្សេងៗទៀតរួមមានសេវាវាយតម្លៃលើទ្រព្យសម្បត្តិ និងសេវាប្រតិបត្តិការអចលនវត្ថុ។

- **ប្រតិបត្តិក្របខ័ណ្ឌច្បាប់ពាណិជ្ជកម្មរបស់កម្ពុជា :** នេះគឺជាអាទិភាពគន្លឹះ ប៉ុន្តែជាបញ្ហាដែលមិនអាចសម្រេចដោយស្រួលឡើយ ហើយនឹងទាមទារនូវការប្តេជ្ញាយូរអង្វែង ព្រមទាំងកំណែទម្រង់ច្បាប់និងតុលាការ។ក្នុងរយៈកាលខ្លីទៅមធ្យម ជម្រើសមួយទៀតអាចត្រូវបានផ្តល់ឱ្យតាមរយៈការអភិវឌ្ឍប្រព័ន្ធមជ្ឈត្តការពាណិជ្ជកម្ម។ ដូច្នេះការអភិវឌ្ឍមជ្ឈត្តការពាណិជ្ជកម្ម ផ្អែកលើមូលដ្ឋានផ្តល់ដោយច្បាប់ស្តីពីមជ្ឈត្តការពាណិជ្ជកម្ម គឺជាអាទិភាពចំពោះមុខ។ ការអភិវឌ្ឍនោះនឹងរួមបញ្ចូលនូវការអភិវឌ្ឍបទបញ្ញត្តិ និងសេវារដ្ឋបាលសំខាន់ៗ មជ្ឈមណ្ឌលច្បាប់និងឯកសារពាណិជ្ជកម្ម ក៏ដូចជា ការបែងចែកផ្សព្វផ្សាយ ការអភិវឌ្ឍកម្មវិធីសិក្សា និងសកម្មភាពបណ្តុះបណ្តាលផងដែរ។ ជាបន្ថែម ការទ្រទ្រង់សម្រាប់ការអភិវឌ្ឍបច្ចេកទេសដោះស្រាយជម្លោះនៅថ្នាក់ខេត្ត និងថ្នាក់ដទៃទៀត នឹងត្រូវបានពិនិត្យ។
- **អភិវឌ្ឍ និងអនុវត្តក្របខ័ណ្ឌបំប្លែងទម្រង់ក្រុមហ៊ុន :** ជាមួយនឹងការមាននូវស្តង់ដារតាមលំដាប់ថ្នាក់សម្រាប់ក្រុមហ៊ុនតូចៗ ក្រុមហ៊ុនឯកជនដទៃទៀត ក្រុមហ៊ុនមហាជន និងក្រុមហ៊ុនចុះបញ្ជី។ បញ្ហានេះ ត្រូវបានពិភាក្សាលំអិតក្នុងបរិបទអំពីវិស័យហិរញ្ញវត្ថុមិនមែនធនាគារ : ទីផ្សារហិរញ្ញវត្ថុ (ជំពូកទី ៤)។
- **អភិវឌ្ឍន៍ធនធានមនុស្ស :** នេះជាតម្រូវការចំពោះមុខ និងជាបន្តទៅទៀត ជាពិសេសពាក់ព័ន្ធនឹងព័ត៌មានហិរញ្ញវត្ថុ។ ការអភិវឌ្ឍក្របខ័ណ្ឌបំប្លែងទម្រង់ក្រុមហ៊ុន ក៏ត្រូវការផ្តល់លើកទឹកចិត្តចំពោះបុគ្គលឯកជននានា ឱ្យមានតម្រូវការលើកកម្ពស់ជំនាញរបស់ខ្លួនខាងផ្នែកព័ត៌មានហិរញ្ញវត្ថុ និងជំនាញជាគុណវុឌ្ឍិពាក់ព័ន្ធផ្សេងៗទៀតផងដែរ ខណៈដែលចាំបាច់ត្រូវមានកម្រិតផ្សេងៗគ្នាសម្រាប់ក្រុមហ៊ុន ដែលស្ថិតនៅក្នុងដំណាក់កាលផ្សេងៗគ្នានៃការអភិវឌ្ឍ។ ការអភិវឌ្ឍធនធានមនុស្សនឹងត្រូវបានទ្រទ្រង់ដោយការបែងចែកផ្សព្វផ្សាយ ការអភិវឌ្ឍកម្មវិធីសិក្សា និងសកម្មភាពបណ្តុះបណ្តាលសមស្រប ចំពោះគ្រប់ទិដ្ឋភាពទាំងអស់នៃវិស័យហិរញ្ញវត្ថុ។
- **ការចុះបញ្ជីដីធ្លី និងអចលនវត្ថុ :** ការបញ្ចប់ការចុះបញ្ជីដីធ្លី និងអចលនវត្ថុ គឺជាគោលដៅរយៈកាលវែង ដែលទាមទារពេលច្រើនឆ្នាំទំរាំបញ្ចប់។ ទន្ទឹមនោះ ចំពោះមុខ ត្រូវយកចិត្តទុកដាក់ទៅលើផ្នែកណាដែលប្រតិបត្តិការទំនងមានការកើនឡើង ហើយដូចនោះ លទ្ធភាពនៃការកើតមាននូវជម្លោះក៏កើនឡើងដែរ។ ឧទាហរណ៍ តំបន់ប្រជុំជនសំខាន់ៗដែលការចុះបញ្ជីចាំបាច់ត្រូវតែបានបញ្ចប់ជាអាទិភាពចំពោះមុខ។ សកម្មភាពពាក់ព័ន្ធផ្សេងៗទៀតរួមមានការអភិវឌ្ឍបទបញ្ញត្តិសមស្របសម្រាប់ទ្រទ្រង់ដល់អាជីវកម្មអចលនវត្ថុ។
- បន្តកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ពង្រឹងឧបករណ៍នយោបាយរូបិយវត្ថុ និងអភិវឌ្ឍន៍ក្របខ័ណ្ឌនយោបាយរូបិយវត្ថុ ផ្អែកលើទីផ្សារ។ ការនេះទាមទារនូវការទ្រទ្រង់ចំពោះការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់[៤] និងទីផ្សាររូបិយវត្ថុអន្តរធនាគារ រួមទាំងមូលប័ត្ររដ្ឋរយៈកាលខ្លី [៥]។

---

[៤] មើលជំពូកទី ៣

[៥] មើលជំពូកទី ៤

## ២. អាទិភាពរយៈកាលមធ្យម និងវែង

២.៤៣ អាទិភាពរយៈកាលមធ្យម និងវែង ពាក់ព័ន្ធនឹងមូលដ្ឋានគ្រឹះនៃវិស័យហិរញ្ញវត្ថុរួមមាន៖

- **បញ្ចប់ដំណើរការចុះបញ្ជីដីធ្លី និងអចលនវត្ថុ** ៖ ការនេះអាចនឹងមិនបញ្ចប់មុនឆ្នាំ២០១៥ ទេ ប៉ុន្តែជាកត្តាអាទិភាពនាបច្ចុប្បន្នដ៏សំខាន់ សម្រាប់ទ្រទ្រង់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ។ ជាបន្ថែម ការអភិវឌ្ឍក្របខ័ណ្ឌច្បាប់សមស្របដើម្បីដោះស្រាយការវាយតម្លៃនិងការលក់អចលនវត្ថុ នឹងទ្រទ្រង់ដល់ការអភិវឌ្ឍទីផ្សារ។
- **ការអនុវត្តន៍កិច្ចសន្យា និងនីតិរដ្ឋ** ៖ ការលើកកម្ពស់សមត្ថភាពប្រព័ន្ធតុលាការក្នុងការអនុវត្តន៍ដោយសង្កតភាពនូវកិច្ចសន្យា និងការដោះស្រាយជម្លោះពាណិជ្ជកម្មដោយសមស្រប ទាមទារនូវការខិតខំជាបន្ត និងយូរអង្វែង។ ក្នុងរយៈកាលខ្លី ការនេះនឹងត្រូវបានពង្រឹងតាមរយៈការអភិវឌ្ឍមជ្ឈត្តការពាណិជ្ជកម្ម ការទ្រទ្រង់ដល់ការអភិវឌ្ឍយន្តការដោះស្រាយជម្លោះថ្នាក់ខេត្ត និងការអនុវត្តន៍ច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម។ ក្នុងរយៈកាលមធ្យម ការបង្កើតប្រព័ន្ធតុលាការពាណិជ្ជកម្ម ជាបន្ថែមលើប្រព័ន្ធមជ្ឈត្តការពាណិជ្ជកម្ម នឹងផ្តល់នូវយន្តការជាបន្ថែមមួយទៀត ដែលតាមរយៈនោះ ការអនុវត្តន៍កិច្ចសន្យាពាណិជ្ជកម្ម និងការដោះស្រាយជម្លោះពាណិជ្ជកម្ម អាចនឹងមានភាពប្រសើរឡើង។ ប្រព័ន្ធតុលាការពាណិជ្ជកម្មនឹងត្រូវបានរៀបចំឡើងឱ្យមានដំណើរការស្របតាមគោលការណ៍នីតិរដ្ឋ។ការអភិវឌ្ឍប្រព័ន្ធតុលាការពាណិជ្ជកម្មនឹងទាមទារនូវការអភិវឌ្ឍប្រព័ន្ធទ្រទ្រង់យ៉ាងទូលំទូលាយផ្នែកបទបញ្ញត្តិ និងសេវារដ្ឋបាល រួមទាំងតុលាការពាណិជ្ជកម្មចល័ត ក៏ដូចជាក្របខ័ណ្ឌច្បាប់ ការបែងចែកផ្សព្វផ្សាយ ការអភិវឌ្ឍកម្មវិធី សិក្សា និងសកម្មភាពបណ្តុះបណ្តាល។ ទន្ទឹមនោះកម្ពុជានឹងអនុវត្តនូវកម្មវិធីដ៏ទូលំទូលាយមួយនៃកំណែទម្រង់ច្បាប់ និងតុលាការ ដើម្បីទ្រទ្រង់នីតិរដ្ឋនៅក្នុងវិស័យហិរញ្ញវត្ថុ។
- បន្តកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- **ការអភិវឌ្ឍរូបិយវត្ថុ** ៖ បង្កើនទំនុកចិត្ត និងការប្រើប្រាស់រូបិយវត្ថុក្នុងស្រុក។ ទំនុកចិត្ត និងហេដ្ឋារចនាសម្ព័ន្ធនឹងត្រូវបានអភិវឌ្ឍន៍តាមរយៈវឌ្ឍនភាពក្នុងការដោះស្រាយបញ្ហាមូលដ្ឋានគ្រឹះនៃវិស័យហិរញ្ញវត្ថុ (ជំពូកទី ២) វិស័យធនាគារនិងមីក្រូហិរញ្ញវត្ថុ (ជំពូកទី ៣) និងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ (ជំពូកទី ៤)។ ឈរលើមូលដ្ឋាននេះ ក្របខ័ណ្ឌលើកទឹកចិត្តសារពើពន្ធនឹងត្រូវបានអនុវត្ត រួមទាំងការទូទាត់ប្រាក់បៀវត្សរបស់មន្ត្រីរាជការ និងចំណាយផ្សេងៗទៀតជាប្រាក់រៀលតាមរយៈគណនីធនាគារ និងប្រព័ន្ធទូទាត់សងប្រាក់ និងការតម្រូវឱ្យការទូទាត់ពន្ធ និងការទូទាត់ផ្សេងៗចំពោះរដ្ឋាភិបាលធ្វើឡើងជាប្រាក់រៀលតាមរយៈប្រព័ន្ធទូទាត់សងប្រាក់ដែរ។ នៅពេលដែលតម្រូវការកើនឡើង ក្រដាសប្រាក់មានតម្លៃចារឹកធំៗអាចនឹងត្រូវបានបោះផ្សាយ។

# ធនាគារ
# និងមីក្រូហិរញ្ញវត្ថុ

ជំពូកទី ៣

៣.០១ វិស័យធនាគារដែលមានសុវត្ថិភាព សមត្ថភាព និងប្រសិទ្ធភាព មានសារៈសំខាន់យ៉ាងខ្លាំងក្នុងការគាំទ្រដល់ការអភិវឌ្ឍន៍ហិរញ្ញវត្ថុ និងកំណើនសេដ្ឋកិច្ចនៅកម្ពុជា។ ធនាគារដែលគ្មានសុវត្ថិភាពអាចនាំឱ្យមានវិបត្តិហិរញ្ញវត្ថុជាប្រព័ន្ធ ការដួលរលំសេដ្ឋកិច្ច និងការខាតបង់សេដ្ឋកិច្ចជាអចិន្ត្រៃយ៍ដ៏ធំធេង ដូចជាវិបត្តិហិរញ្ញវត្ថុនៅអាស៊ីកាលពីឆ្នាំ ១៩៩៧-១៩៩៨។ ហេតុដូច្នេះហើយ ការពិចារណាជាគន្លឹះដំបូងគឺដោះស្រាយហានិភ័យដើម្បីគោលដៅរក្សាស្ថិរភាពហិរញ្ញវត្ថុតាមរយៈការបង្កើតបណ្តាញសុវត្ថិភាពហិរញ្ញវត្ថុមួយដ៏មានប្រសិទ្ធភាព ដោយផ្តោតទៅលើ (១) ស្ថិរភាពហិរញ្ញវត្ថុ (២) ការត្រួតពិនិត្យនិងបទបញ្ញត្តិធនាគារ (៣) ការការពារអ្នកផ្ញើប្រាក់។ ដូចគ្នានេះដែរ ចំពោះគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត ដូចជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អ្នកប្តូរប្រាក់ និងអ្នកឱ្យខ្ចីចងការ ហើយមានហានិភ័យប្រហាក់ប្រហែលនឹងធនាគារដែរ ដែលកំពុងធ្វើប្រតិបត្តិការធនាគារ គួរតែត្រូវបានដោះស្រាយដូចគ្នា។ ហេតុនេះហើយ ផ្នែកនេះដោះស្រាយមិនត្រឹមតែធនាគារ និងសកម្មភាពធនាគារប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដោះស្រាយបញ្ហាមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ព្រមទាំងអ្នកឱ្យខ្ចីចងការ និងអាជីវករប្តូរប្រាក់ដែលធ្វើសកម្មភាពធនាគារផងដែរ។

៣.០២ ទន្ទឹមនឹងនេះ ការបង្កើតធនាគារ និងសកម្មភាពធនាគារ ព្រមទាំងគ្រឹះស្ថានដែលពាក់ព័ន្ធមានសារៈសំខាន់ដល់ការគាំទ្រការសន្សំ និងការបែងចែកធនធានហិរញ្ញវត្ថុ។ ការផ្តោតជាសំខាន់នៅទីនេះ សំដៅលើការដាក់បទបញ្ញត្តិ និងការលើកទឹកចិត្តដើម្បីគាំទ្រធនាគារ និងគ្រឹះស្ថានដែលពាក់ព័ន្ធប្រកបអាជីវកម្មធនាគារតាមលក្ខណៈមួយមានប្រសិទ្ធភាព និងសុវត្ថិភាពតាមរយៈ (១) មូលដ្ឋានគ្រឹះនៃប្រព័ន្ធហិរញ្ញវត្ថុ ជាពិសេសសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិ និងការអនុវត្តន៍កិច្ចសន្យា និងយន្តការដោះស្រាយជម្លោះ[៦] (២) លក្ខខណ្ឌដំបូងចំពោះប្រតិបត្តិការ និងការត្រួតពិនិត្យធនាគារប្រកបដោយប្រសិទ្ធភាព ជាពិសេសប្រព័ន្ធទូទាត់សងប្រាក់ដែលមានសមត្ថភាព និងសុវត្ថិភាព (៣) បទបញ្ញត្តិ និងការត្រួតពិនិត្យធនាគារ និងគ្រឹះស្ថានស្រដៀងគ្នាដូចជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អ្នកប្តូរប្រាក់ និងអ្នកឱ្យខ្ចីចងការ ដែលកំពុងប្រកបអាជីវកម្មធនាគារ ប្រកបដោយប្រសិទ្ធភាព។

៣.០៣ នៅក្នុងសេដ្ឋកិច្ចដែលកំពុងអភិវឌ្ឍន៍ជាច្រើនរាប់ទាំងនៅអាស៊ីផង ធនាគារបានដើរតួនាទីយ៉ាងសំខាន់បំផុត ក្នុងការសន្សំ និងបែងចែកធនធានហិរញ្ញវត្ថុទៅក្នុងសេដ្ឋកិច្ច។ នេះក៏ជាករណីរបស់កម្ពុជាផងដែរ ដែលនឹងគូសបញ្ជាក់អំពីតួនាទីជាគន្លឹះនៃវិស័យធនាគារនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា។ ទន្ទឹមនឹងនេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អ្នកប្តូរប្រាក់ និងអ្នកឱ្យខ្ចីចងការ ក៏សកម្មផងដែរក្នុងប្រព័ន្ធហិរញ្ញវត្ថុកម្ពុជា ព្រមទាំងមានតួនាទីយ៉ាងសំខាន់ក្នុងការបង្គរ និងបែងចែកធនធានហិរញ្ញវត្ថុ។ ហេតុនេះវាមានសារៈសំខាន់សម្រាប់កម្ពុជា ដើម្បីបង្កើតប្រព័ន្ធទូលំទូលាយមួយ ដើម្បីដោះស្រាយហានិភ័យនៃសកម្មភាពធនាគារធ្វើឡើងដោយប្រភេទគ្រឹះស្ថានខុសៗគ្នា ព្រមទាំងដើម្បីគាំទ្រដល់ការអភិវឌ្ឍតួនាទីរបស់គ្រឹះស្ថានទាំងនោះ ក្នុងការគាំទ្រដល់កំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ។

[៦] មើលជំពូកទី ២

៣.០៤ ដោយពិនិត្យមើលលើវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុកម្ពុជា កំណត់សម្គាល់សំខាន់ៗមួយចំនួនបានលេចឡើង។ នៅក្នុងចំណោមធនាគារនិងប្រព័ន្ធធនាគារ មានសាច់ប្រាក់ងាយស្រួលយ៉ាងច្រើន ប៉ុន្តែការផ្តល់ឥណទានមានកម្រិតកំណត់។ ក្រៅពីប្រព័ន្ធធនាគារផ្លូវការ សកម្មភាពហិរញ្ញវត្ថុមានការពាក់ព័ន្ធជាមួយគ្រឹះស្ថានដែលមានសកម្មភាពទាំងផ្លូវការ និងក្រៅផ្លូវការ។ នៅក្នុងប្រព័ន្ធហិរញ្ញវត្ថុផ្លូវការ មីក្រូហិរញ្ញវត្ថុគឺជាអ្នកឱ្យខ្ចីយ៉ាងសកម្ម ប៉ុន្តែប្រឈមមុខនឹងកង្វះសាច់ប្រាក់ងាយស្រួល។ ទន្ទឹមនឹងនោះ ការប៉ាន់ស្មានជាច្រើនលើកឡើងថា វិស័យហិរញ្ញវត្ថុក្រៅផ្លូវការប្រហែលជាធំធេងជាងវិស័យហិរញ្ញវត្ថុផ្លូវការ ហើយមានសកម្មភាពពាក់ព័ន្ធនឹងសកម្មភាពធនាគារជាច្រើន។នៅក្នុងវិស័យហិរញ្ញវត្ថុក្រៅផ្លូវការ មានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមិនបានចុះបញ្ជី ដែលបាន ឬមិនបានចាត់ទុកខ្លួនឯងថាជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៉ុន្តែជារឿយៗច្រើនចាត់ទុកថាខ្លួនជាអង្គការអភិវឌ្ឍន៍ អ្នកប្តូរប្រាក់ និងអ្នកឱ្យខ្ចីចងការ ព្រមទាំងសកម្មភាពហិរញ្ញវត្ថុក្រៅផ្លូវការជាច្រើនទៀតដូចជាតុងទីនជាដើម។

៣.០៥ ក្នុងន័យនេះ ការប្រឈមនិងអាទិភាពគន្លឹះសម្រាប់គាំទ្រការអភិវឌ្ឍធនាគារ និងមីក្រូហិរញ្ញវត្ថុនៅកម្ពុជា មានដូចខាងក្រោម៖

- កំណត់អត្តសញ្ញាណ និងដោះស្រាយហានិភ័យ។
- ធ្វើឱ្យប្រសើរឡើងនូវប្រតិបត្តិការរបស់គ្រឹះស្ថានហិរញ្ញវត្ថុ និងបង្កើនអន្តរការិយកម្មតាមរយៈការអភិវឌ្ឍធនធានមនុស្ស ការអប់រំ និងការត្រួតពិនិត្យនិងបទប្បញ្ញត្តិសមស្រប។
- បង្កើនជំនឿទុកចិត្ត តាមរយៈការធ្វើឱ្យប្រសើរឡើងនូវគ្រឹះស្ថានហិរញ្ញវត្ថុ មុខងារត្រួតពិនិត្យ និងការអប់រំ
- ធ្វើទម្រង់ហិរញ្ញប្បទានឱ្យទៅជាផ្លូវការតាមរយៈការបង្កើនជំនឿទុកចិត្ត។
- ភ្ជាប់ទំនាក់ទំនងធនាគារ និងមីក្រូហិរញ្ញវត្ថុ តាមរយៈការបង្កើនជំនឿទុកចិត្តលើផ្នែកបទបញ្ញត្តិ ការត្រួតពិនិត្យ ការអនុវត្តន៍ច្បាប់ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុសមស្រប ជាពិសេសប្រព័ន្ធទូទាត់សងប្រាក់ជាតិដុល ទីផ្សាររូបិយវត្ថុ និងអន្តរធនាគារ រាប់បញ្ចូលទាំងមូលប័ត្ររដ្ឋរយៈកាលខ្លី និងធ្វើឱ្យប្រសើរឡើងនូវគុណភាព និងតម្លាភាពនៃព័ត៌មានហិរញ្ញវត្ថុ។
- ចាត់ទុកអ្នកផ្តល់សេវាហិរញ្ញវត្ថុស្មើភាពគ្នា ដើម្បីផ្តល់ទីលានប្រកួតប្រជែងស្មើភាពមួយ និងជៀសវាងការរំលោភអំណាចបទបញ្ញត្តិ និងផ្តល់នូវប្រព័ន្ធមួយដែលមានការអភិវឌ្ឍជាលំដាប់សម្រាប់គ្រឹះស្ថានមិនមែនធនាគារដែលធ្វើសកម្មភាពធនាគារ។

## ក. ធនាគារ

៣.០៦ បច្ចុប្បន្ន មានធនាគារដែលមានអាជ្ញាប័ណ្ណចំនួន ១៥ រាប់ទាំងធនាគារសាខាបរទេសចំនួន ៣ ធនាគារឯកទេសចំនួន ៤ និងការិយាល័យតំណាងធនាគារបរទេសចំនួន២។បន្ថែមលើនេះ មានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជា ច្រើនដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការប្រមែប្រមូលការសន្សំ និងអន្តរការិយកម្មហិរញ្ញវត្ថុសម្រាប់ឯកត្តជន និងសហគ្រាសធុនតូច ជាពិសេសនៅក្រៅតំបន់ទីក្រុងសំខាន់ៗ។ ជាងនេះទៅទៀត មានអ្នកឱ្យខ្ចីចងការ និងអ្នកប្តូរប្រាក់ ជាច្រើនបានដើរតួយ៉ាងសំខាន់ក្នុងការផ្ទេររូបិយប័ណ្ណបរទេស និងការឱ្យខ្ចីតូចៗ។

៣.០៧ ទាក់ទងនឹងស្ថិរភាពហិរញ្ញវត្ថុ និងធនាគារ ធនាគារជាតិនៃកម្ពុជាបានដើរតួយ៉ាងសកម្មក្នុងការបង្កើត និងអនុវត្តក្របខ័ណ្ឌច្បាប់ ដើម្បីគាំទ្រសកម្មភាពធនាគារ និងធ្វើបញ្ញត្តិកម្មគ្រប់គ្រងលើធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុឯកទេស រាប់បញ្ចូលទាំងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផង ។សកម្មភាពទាំងនេះជួយជម្រុញឱ្យមានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងកាត់បន្ថយភាពក្រីក្រ ។

## ១. ភាពជឿនលឿន និងសមិទ្ធផលតាំងពីឆ្នាំ២០០១

៣.០៨ ដើម្បីសំលឹងមើលទៅអនាគត វាជាការសំខាន់ដែលជាបឋមត្រូវដឹងពីអ្វីដែលសម្រេចបានមកដល់ពេលនេះ ។

៣.០៩ ដើម្បីអភិវឌ្ឍន៍វិស័យធនាគារមួយដែលរឹងមាំ ចក្ខុវិស័យនិងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០១-២០១០ បានសង្កត់ធ្ងន់លើផ្នែក ៦គឺ ៖

- បង្កើតក្របខ័ណ្ឌមូលដ្ឋានសម្រាប់គោលនយោបាយរូបិយវត្ថុ
- បង្កើតក្របខ័ណ្ឌត្រួតពិនិត្យធនាគារ
- កែទម្រង់រចនាសម្ព័ន្ធប្រព័ន្ធធនាគារ
- បង្កើតក្របខ័ណ្ឌសម្រាប់ប្រព័ន្ធទូទាត់សងប្រាក់
- ឆ្ពោះទៅកាន់តំបន់ជនបទ និង
- ការកសាងសមត្ថភាព ។

៣.១០ ចំពោះការបង្កើតក្របខ័ណ្ឌមូលដ្ឋានសម្រាប់គោលនយោបាយរូបិយវត្ថុ ចំណុចនេះត្រូវបានពិភាក្សារួចមកហើយនៅក្នុងបរិបទនៃមូលដ្ឋានហិរញ្ញវត្ថុ ( ជំពូកទី ២) ។ ចំពោះការបង្កើតក្របខ័ណ្ឌសម្រាប់ការត្រួតពិនិត្យធនាគារ កិច្ចការជាច្រើនត្រូវបានសម្រេច ដូចជាក្របខ័ណ្ឌច្បាប់ និងបរិធានបទបញ្ញត្តិសម្រាប់ធនាគារកណ្តាល ការត្រួតពិនិត្យធនាគារនិងមីក្រូហិរញ្ញវត្ថុ និងអាជីវកម្មធនាគារ ទាំងអស់នេះត្រូវបានបង្កើតឡើង ។ ក្នុងផ្នែកនេះ បញ្ហាប្រឈមសំខាន់ៗស្ថិតនៅលើការបន្តជម្រុញការត្រួតពិនិត្យធនាគារនិងមីក្រូហិរញ្ញវត្ថុ ព្រមទាំងបង្កើតបន្ថែមទៀតនូវមូលដ្ឋានហិរញ្ញវត្ថុ និងសមត្ថភាពសម្រាប់មុខងារវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុសមស្រប ។ ទាក់ទងទៅនឹងមូលដ្ឋានហិរញ្ញវត្ថុចំពោះធនាគារ ចាំបាច់ត្រូវមានការងារបន្ថែមទៀតដើម្បីគាំទ្រការឱ្យខ្ចីដោយមានកិច្ចធានា សិទ្ធិកាន់កាប់ទ្រព្យសម្បត្តិ សិទ្ធិរបស់ឥណទាយកនិងភាគទុនិក ព័ត៌មានហិរញ្ញវត្ថុ និងប្រព័ន្ធដែលពាក់ព័ន្ធ ។ លើសពីនេះទៅទៀត កិច្ចខិតខំបន្ថែមគឺចាំបាច់ដើម្បីពង្រីកតំបន់អាជីវកម្មធនាគារ និងអាជីវកម្មដែលពាក់ព័ន្ធដូចជាភតិសន្យា ។ ការកសាងសមត្ថភាពនៅតែជាកត្តាគន្លឹះសម្រាប់គ្រប់ផ្នែកទាំងអស់ ។

៣.១១ ចំពោះការកែទម្រង់រចនាសម្ព័ន្ធវិស័យធនាគារឡើងវិញ ក៏ដូចគ្នាដែរ កិច្ចការជាច្រើនត្រូវបានសម្រេច ដូចជាការកែទម្រង់រចនាសម្ព័ន្ធធនាគារដ៏សំខាន់បានធ្វើឡើងក្នុងឆ្នាំ២០០១ ដោយមានការបង្កើនដើមទុនអប្បបរមា ដែលជាលទ្ធផលធនាគារមួយចំនួនបានបិទទ្វារ ហើយធនាគារដែលនៅសល់បានប្តេជ្ញាបន្ថែមដើមទុន ដែលធ្វើឱ្យវិស័យធនាគារកាន់តែរឹងមាំ

ថែមទៀត។ ការកែទម្រង់រចនាសម្ព័ន្ធធនាគារបន្ត ដើម្បីបង្កើតវិស័យធនាគារមួយដែលខ្លាំង និងមានប្រសិទ្ធភាព ទាមទារឱ្យមានការខិតខំប្រឹងប្រែងបន្ថែម ដូចបានកត់សម្គាល់ខាងលើ ជាពិសេសទាក់ទងទៅនឹងមូលដ្ឋានហិរញ្ញវត្ថុ (ជំពូកទី ២) គាំទ្រអាជីវកម្មធនាគារ និងការកសាងសមត្ថភាពបន្ត ព្រមទាំងការត្រួតពិនិត្យ និងការអនុវត្តនីច្បាប់ដែលមានប្រសិទ្ធភាព និងមានតម្លាភាព។ លើសពីនេះទៅទៀត ការចូលទៅក្នុងអង្គការពាណិជ្ជកម្មពិភពលោករបស់កម្ពុជា និងសេរីភាវូបនីយកម្មវិស័យហិរញ្ញវត្ថុដែលពាក់ព័ន្ធបានផ្តល់នូវឱកាសសម្រាប់ធនាគារបរទេសចូលទៅក្នុងវិស័យហិរញ្ញវត្ថុកម្ពុជា និងជម្រុញឱ្យមានការប្រកួតប្រជែង[៧] ។

៣.១២ ចំពោះប្រព័ន្ធទូទាត់សងប្រាក់ ជំហានដ៏សំខាន់ត្រូវបានសំរេចតាមរយៈការអនុមតិច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ នាដំណាច់ឆ្នាំ២០០៥។ កត្តាទាំងនេះនឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រដល់តួនាទីគន្លឹះរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងវិស័យហិរញ្ញវត្ថុក្នុងការជម្រុញការទូទាត់សងប្រាក់។ ក្នុងផ្នែកនេះ គោលដៅចំបងរួមបញ្ចូលទាំងការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ដ៏រឹងមាំ ប្រុងប្រយ័ត្ន និងមានប្រសិទ្ធភាព ដើម្បីបន្ថយចំណាយប្រតិបត្តិការ បង្កើនជំនឿទុកចិត្តក្នុងប្រព័ន្ធហិរញ្ញវត្ថុ និងក្នុងចំណោមគ្រឹះស្ថានហិរញ្ញវត្ថុ និងកែលំអគោលនយោបាយរូបិយវត្ថុ និងប្រតិបត្តិការធនាគារ។

## ២. គោលដៅ និងវិធីសាស្ត្រ

៣.១៣ ចំពោះធនាគារ គោលដៅគឺការអភិវឌ្ឍប្រព័ន្ធធនាគារមួយមានប្រសិទ្ធភាព សមាហរណកម្ម និងមានលក្ខណៈប្រកួតប្រជែង ដែលត្រូវបានបញ្ញត្តិកម្មនិងត្រួតពិនិត្យត្រឹមត្រូវ និងប្រមែប្រមូលការសន្សំដោយមានប្រសិទ្ធភាព ដើម្បីផ្តល់ហិរញ្ញប្បទានដើម្បីគាំទ្រកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ។ វិស័យធនាគារដែលខ្លាំងបែបនេះ និងគាំទ្រកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ ហើយជាមួយគ្នានោះ បន្ថយជាអប្បបរមានូវហានិភ័យនៃវិបត្តិហិរញ្ញវត្ថុ។

៣.១៤ គោលដៅរួមទាំងនេះមានធាតុសំខាន់ពីរគឺ (១)ស្ថិរភាពហិរញ្ញវត្ថុ និង(២)ការអភិវឌ្ឍហិរញ្ញវត្ថុ ដើម្បីគាំទ្រកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ។

៣.១៥ សារៈសំខាន់នៃស្ថិរភាពហិរញ្ញវត្ថុ ជាធម្មតា ត្រូវបានមើលឃើញថា ជួយដល់ការអភិវឌ្ឍ និងកាត់បន្ថយនូវហេតុការណ៍នៃវិបត្តិហិរញ្ញវត្ថុ ត្រូវបានឯកភាពជាទូទៅ ដោយសង្កត់ធ្ងន់ទៅលើ (១)បទបញ្ញត្តិហិរញ្ញវត្ថុ និងការត្រួតពិនិត្យ និង(២)កែលំអប្រតិបត្តិការរបស់គ្រឹះស្ថានហិរញ្ញវត្ថុ និងការអនុវត្តនីឱ្យស្របតាមច្បាប់។

៣.១៦ ខណៈដែលមានមូលហេតុនៃអស្ថិរភាពហិរញ្ញវត្ថុដែលហួសពីអានុភាពរបស់គ្រឹះស្ថាននីមួយៗ និងត្រូវបានដោះស្រាយបានល្អបំផុតតាមរយៈគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចសមស្រប និងក្របខ័ណ្ឌស្ថាប័នពាក់ព័ន្ធ[៨] ប្រសិនបើគ្រឹះស្ថានហិរញ្ញវត្ថុណាមួយគ្រប់គ្រងអាជីវកម្មរបស់ខ្លួនដោយប្រុងប្រយ័ត្ន សុវត្ថិភាព និងរឹងមាំនោះ វិបត្តិដែលបណ្តាលមកពីបញ្ហាក្នុងគ្រឹះស្ថានហិរញ្ញវត្ថុដាច់ដោយឡែកនោះនឹងត្រូវកាត់បន្ថយនៅកម្រិតអប្បបរមា ដូច្នេះវាបង្កើនស្ថិរភាពហិរញ្ញវត្ថុជាទូទៅ។ ក្នុងស្ថានភាពបែបនេះ

[៧] *សេរីភាវូបនីយកម្ម និងការប្រកួតប្រជែងត្រូវបានពិភាក្សាបន្ថែមក្នុងបរិបទនៃជំពូកទី ៥ : ការពិចារណាទូទៅ ។*

[៨] *មើលជំពូកទី ២*

គ្រឹះស្ថានហិរញ្ញវត្ថុគួរតែត្រូវបានផ្តល់ការលើកទឹកចិត្ត និងពិន័យសមស្រប ទាំងផ្នែកសេដ្ឋកិច្ច ទាំងផ្នែកបទបញ្ញត្តិនិងត្រួតពិនិត្យ ព្រមទាំងត្រូវបានគាំទ្រការអភិវឌ្ឍសមត្ថភាព ដើម្បីលើកទឹកចិត្តគ្រឹះស្ថានទាំងនោះឱ្យកែលំអប្រតិបត្តិការរបស់ខ្លួន។ ការកែលំអប្រតិបត្តិការមិនត្រឹមតែកាត់បន្ថយហានិភ័យវិបត្តិហិរញ្ញវត្ថុប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងលើកកម្ពស់តួនាទីរបស់គ្រឹះស្ថានហិរញ្ញវត្ថុក្នុងអន្តរការិយកម្ម និងការបែងចែកធនធាន ដែលនាំដល់ការគាំទ្រកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ។

៣.១៧ ហេតុដូច្នេះហើយ បទបញ្ញត្តិហិរញ្ញវត្ថុនិងការត្រួតពិនិត្យមានសារៈសំខាន់ ដើម្បីការពារប្រឆាំងនឹងវិបត្តិហិរញ្ញវត្ថុ មិនមែនត្រឹមតែតាមរយៈការការពារដែលផ្តល់ដោយបញ្ញត្តិករនោះទេ ថែមទាំងតាមរយៈការលើកទឹកចិត្ត និងការណែនាំដល់គ្រឹះស្ថានហិរញ្ញវត្ថុ ដែលផ្តល់តាមរយៈបទបញ្ញត្តិ និងការត្រួតពិនិត្យដើម្បីលើកកម្ពស់ប្រតិបត្តិការរបស់ខ្លួន។

៣.១៨ ចំពោះការអភិវឌ្ឍហិរញ្ញវត្ថុដើម្បីគាំទ្រដល់កំណើនសេដ្ឋកិច្ចនិងកាត់បន្ថយភាពក្រីក្រ មានធាតុសំខាន់៧បីគឺ ៖

- មធ្យោបាយផ្ទេរប្រាក់ ការទូទាត់សងប្រាក់ និងការទូទាត់ប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព
- ការប្រមែប្រមូលការសន្សំ
- អន្តរការិយកម្ម និងការបែងចែកធនធាន។

កត្តាគន្លឹះចំពោះធាតុសំខាន់ទាំងបី គឺរក្សានិងបង្កើនជំនឿទុកចិត្តលើប្រពន្ធ័ហិរញ្ញវត្ថុ ស្ថាប័នហិរញ្ញវត្ថុ និង បញ្ញត្តិករហិរញ្ញវត្ថុ ៖

- ជំនឿទុកចិត្តគ្រប់គ្រាន់របស់អ្នកសន្សំប្រាក់ ដូច្នេះពួកគេទុកប្រាក់នៅក្នុងស្រុក ហើយដាក់ការសន្សំរបស់ពួកគេក្នុងប្រពន្ធ័ហិរញ្ញវត្ថុផ្លូវការ
- ជំនឿទុកចិត្តរវាងអ្នកខ្ចីដើម្បីប្រើប្រាស់ប្រព័ន្ធហិរញ្ញវត្ថុផ្លូវការសម្រាប់ហិរញ្ញប្បទាន និង
- ជំនឿទុកចិត្តទៅវិញទៅមកក្នុងចំណោមស្ថាប័នហិរញ្ញវត្ថុ។

និយាយជារួម ជំនឿទុកចិត្តរបស់អ្នកសន្សំ អ្នកខ្ចីប្រាក់ និងគ្រឹះស្ថានហិរញ្ញវត្ថុ គឺជាលទ្ធផលនៃជំនឿទុកចិត្តលើប្រព័ន្ធបទបញ្ញត្តិ និងត្រួតពិនិត្យ ដែលត្រលប់មកវិញ គឺអាស្រ័យទៅលើប្រសិទ្ធភាពរបស់វា។

៣.១៩ ក្នុងការប្រមើលមើលដើម្បីសម្រេចបានស្ថិរភាពវិស័យធនាគារ និងការអភិវឌ្ឍវិស័យធនាគារ កម្ពុជានឹងបន្ថយកន្លងបទពិសោធន៍ និងស្តង់ដារក្នុងតំបន់និងអន្តរជាតិ ដូចជាគណៈកម្មការក្រុងបាសែលស្តីពីគោលការណ៍ស្នូលសម្រាប់ការត្រួតពិនិត្យដោយប្រសិទ្ធភាពជាត្រីវិស័យរបស់ខ្លួន។

## ៣. បុរេលក្ខខណ្ឌសម្រាប់ប្រតិបត្តិការធនាគារ និងការត្រួតពិនិត្យ

៣.២០ សម្រាប់បទបញ្ញត្តិ និងការត្រួតពិនិត្យធនាគារដើម្បីមានប្រសិទ្ធភាពដល់ការគាំទ្រស្ថិរភាពហិរញ្ញវត្ថុ និងការអភិវឌ្ឍហិរញ្ញវត្ថុ ចាំបាច់ត្រូវមានបុរេលក្ខខណ្ឌមួយចំនួន។ បុរេលក្ខខណ្ឌទាំងនេះមាន ៖

- គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដែលមាននិរន្តភាព និងរឹងមាំ
- ហេដ្ឋារចនាសម្ព័ន្ធសាធារណៈដែលបង្កើតឡើងយ៉ាងល្អប្រសើរ
- វិន័យទីផ្សារដែលមានប្រសិទ្ធភាព និង
- យន្តការសម្រាប់ផ្តល់ឱ្យនូវកម្រិតមួយសមស្របនៃការការពារជាប្រព័ន្ធ (បណ្តាញសុវត្ថិភាពសាធារណៈ) ។

៣.២១ គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដែលមាននិរន្តភាពនិងរឹងមាំ ត្រូវបានដោះស្រាយនៅក្នុងបរិបទនៃមូលដ្ឋានគ្រឹះហិរញ្ញវត្ថុ (ជំពូកទី ២) ។ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងបណ្តាញសុវត្ថិភាពសាធារណៈ នឹងត្រូវពិភាក្សាខាងក្រោម ។ វិន័យទីផ្សារមានដោះស្រាយនៅក្នុងបរិបទនៃជំពូកទី ១ ។

## *៣.១ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈដែលបានអភិវឌ្ឍន៍យ៉ាងល្អប្រសើរ*

៣.២២ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈដែលបង្កើតឡើងយ៉ាងល្អ រួមមាន ៖

- ប្រព័ន្ធច្បាប់អាជីវកម្ម (សាជីវកម្ម ក្ស័យធន កិច្ចសន្យា ការការពារអតិថិជន ទ្រព្យសម្បត្តិឯកជន) ដែលត្រូវបានអនុវត្តដោយសង្គតភាព និងផ្តល់នូវដំណោះស្រាយជម្លោះដោយយុត្តិធម៌ ។ ដូចបានពិភាក្សាខាងលើ អាទិភាពដែលសំខាន់បំផុតសម្រាប់កម្ពុជាគឺ (១) ការអនុមតិច្បាប់ដែលបច្ចុប្បន្នកំពុងរង់ចាំ (២) ធ្វើឱ្យប្រសើរឡើងនូវការអនុវត្តន៍ច្បាប់ និងការដោះស្រាយជម្លោះពាណិជ្ជកម្ម ។
- ស្តង់ដារគណនី និងសវនកម្មស្របតាមស្តង់ដារអន្តរជាតិ ។ ដូចបានពិភាក្សាខាងលើ អាទិភាពដែលសំខាន់បំផុតសម្រាប់កម្ពុជាគឺ (១) កែលំអសមត្ថភាពធនធានមនុស្សទាក់ទងទៅនឹងព័ត៌មានហិរញ្ញវត្ថុ និង (២) បង្កើតនិងអនុវត្តក្របខ័ណ្ឌមួយដែលមានភាពជឿនលឿននិងមានការលើកទឹកចិត្តសម្រាប់ការអភិវឌ្ឍក្រុមហ៊ុន[៥] ។
- ប្រសិទ្ធភាព និងឯករាជ្យភាពរបស់តុលាការ គណនេយ្យ សវនកម្ម និងវិជ្ជាជីវៈច្បាប់ ។ ដូចបានពិភាក្សាខាងលើ អាទិភាពសំខាន់បំផុតសម្រាប់កម្ពុជាគឺកែលំអការអនុវត្តន៍ច្បាប់ស្តីពីកិច្ចសន្យា និងការដោះស្រាយជម្លោះពាណិជ្ជកម្ម ។
- បទបញ្ញត្តិ និងការត្រួតពិនិត្យទីផ្សារហិរញ្ញវត្ថុផ្សេងទៀត ។ បញ្ហាទាំងនេះមានបញ្ជាក់បន្ថែមនៅក្នុង បរិបទជំពូកទី ៤ និងជំពូកទី ៥ ។
- ប្រព័ន្ធទូទាត់សងប្រាក់ និងផាត់ទាត់ដែលមានសុវត្ថិភាព និងប្រសិទ្ធភាព ។ នៅក្នុងបរិបទធនាគារ និងមីក្រូហិរញ្ញវត្ថុ ការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ និងផាត់ទាត់ដែលមានសុវត្ថិភាព និងមានប្រសិទ្ធភាព គឺជា **គោលដៅដ៏សំខាន់ និងជាអាទិភាពបន្ទាន់មួយ** សម្រាប់ប្រទេសកម្ពុជា ។

[៥] *មើលជំពូកទី ២ និង មើលជំពូកទី ៤*

## ៣.២ ប្រព័ន្ធទូទាត់សងប្រាក់ ៖ គោលដៅសំខាន់ៗ និងអាទិភាពបន្ទាន់

៣.២៣ បច្ចុប្បន្ន ប្រទេសកម្ពុជាពុំទាន់មានប្រព័ន្ធទូទាត់សងប្រាក់ជាតិដុលតាមអេឡិចត្រូនិចនៅឡើយទេ ដោយមានតែការទូទាត់សងប្រាក់ដែលបង្កើតឡើងតាមរយៈការប្រគល់សាច់ប្រាក់ ឬតាមរយៈមូលប្បទានប័ត្រជារៀល និងប្រាក់ដុល្លារអាមេរិកក្នុងចំនួនមួយមានកម្រិត។ ទោះបីយ៉ាងណា ក្នុងឆ្នាំ២០០៥ ជាសំខាន់ កម្ពុជាបានអនុម័តជាលើកដំបូងនូវច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ដែលផ្តល់ជាមូលដ្ឋានច្បាប់មួយសម្រាប់ឧបករណ៍អាចជួញដូរបាន ដូចជាមូលប្បទានប័ត្រ រូបិយាណត្តិ និងប័ណ្ណសងតាមបញ្ជា និងបទបញ្ញត្តិនៃប្រព័ន្ធទូទាត់សងប្រាក់។

៣.២៤ កង្វះខាតប្រព័ន្ធទូទាត់សងប្រាក់ និងប្រព័ន្ធផាត់ទាត់ជាតិដែលមានសុវត្ថិភាព និងមានប្រសិទ្ធភាពនាពេលបច្ចុប្បន្ន បង្កជាឧបសគ្គដ៏ចំបងដល់ការអភិវឌ្ឍហិរញ្ញវត្ថុ ដូចជាការទូទាត់សងប្រាក់គ្មានសុវត្ថិភាព និងពិបាកក្នុងការទូទាត់ក្នុងចំនួនប្រាក់ធំៗ ទីផ្សាររូបិយវត្ថុនិងអន្តរធនាគារមិនអាចបំពេញមុខងារប្រកបដោយប្រសិទ្ធភាព ហើយឧបករណ៍នយោបាយ ម៉ាក្រូសេដ្ឋកិច្ចមានកម្រិតកំណត់ខ្លាំង។ កត្តាទាំងនេះតម្រូវឱ្យមានការបង្កើតប្រព័ន្ធដូចនេះមួយដែលនឹងបំបាត់ឧបសគ្គ ធ្ងន់ធ្ងរដល់ការអភិវឌ្ឍហិរញ្ញវត្ថុនៅកម្ពុជា។

៣.២៥ ទៅអនាគត គោលដៅគឺការបង្កើតប្រព័ន្ធទូទាត់សងប្រាក់មួយនៅក្នុងប្រទេសកម្ពុជា ដែលមាន៖

- វិសាលភាពថ្នាក់ជាតិ
- សុវត្ថិភាព និងប្រសិទ្ធភាពក្នុងបរិបទនៃបទពិសោធន៍ និងស្តង់ដារអន្តរជាតិ ដូចជា គណៈកម្មការស្តីពីប្រព័ន្ធទូទាត់សងប្រាក់ និងផាត់ទាត់ គោលការណ៍គ្រឹះសម្រាប់ប្រព័ន្ធទូទាត់សងប្រាក់សំខាន់ជាប្រព័ន្ធ
- អេឡិចត្រូនិច។

លើសពីនេះទៅទៀត ប្រព័ន្ធទូទាត់សងប្រាក់បែបនេះនឹងគ្របដណ្តប់យ៉ាងហោចណាស់ជាប្រាក់រៀលដែរ។ ប្រព័ន្ធទូទាត់សងប្រាក់ជាប្រាក់ដុល្លារអាមេរិក ក៏នឹងត្រូវពិចារណាផងដែរ។

៣.២៦ ចំពោះចំណុចទាំងនេះ ប្រព័ន្ធទូទាត់សងប្រាក់របស់ជាតិរួមមាន៖

- ការទូទាត់ និងផាត់ទាត់មូលប្បទានប័ត្រ
- ការទូទាត់សងប្រាក់ដុលអន្តរធនាគារ
- ប្រតិបត្តិការមូលប័ត្រអន្តរធនាគារនិងរូបិយវត្ថុ និង
- គាំទ្រសម្រាប់ការទូទាត់សងប្រាក់រាយ។

## ៣.៣ បណ្ដាញសុវត្ថិភាពហិរញ្ញវត្ថុសាធារណៈ

៣.២៧ ការត្រួតពិនិត្យធនាគារ គឺជាចំណុចសំខាន់មួយនៃបណ្ដាញសុវត្ថិភាពហិរញ្ញវត្ថុសាធារណៈដែលមានប្រសិទ្ធភាព។ បណ្ដាញសុវត្ថិភាពហិរញ្ញវត្ថុ គឺជាប្រព័ន្ធទូទៅមួយសម្រាប់គាំទ្រស្ថិរភាពហិរញ្ញវត្ថុនៅក្នុងប្រព័ន្ធធនាគារ។ ហេតុនេះ វារួមបញ្ចូលនូវសមាសធាតុសំខាន់ៗមួយចំនួន ហើយដែលបទបញ្ញត្តិនិងការត្រួតពិនិត្យធនាគារ មានសារៈ សំខាន់បំផុត៖

- អ្នកឱ្យខ្ចីចុងក្រោយ
- បទបញ្ញត្តិ និងការត្រួតពិនិត្យ
- ប្រព័ន្ធសម្រាប់ដោះស្រាយធនាគារមានបញ្ហា និងអសាធនភាព និង
- ការការពារអ្នកផ្ញើប្រាក់។

៣.២៨ សមាសធាតុទី១ មុខងារជាអ្នកឱ្យខ្ចីចុងក្រោយគឺបង្កើតឡើងដើម្បីផ្ដល់សាច់ប្រាក់ងាយស្រួលបន្ទាន់ដល់ធនាគារដែលមានសាធនភាព ប៉ុន្តែប្រឈមមុខនឹងការដកប្រាក់បញ្ញើយ៉ាងគំហុកពីអ្នកផ្ញើប្រាក់។ ដោយសារសេដ្ឋកិច្ចដុល្លារូបនីយកម្មរបស់កម្ពុជា មុខងារអ្នកឱ្យខ្ចីចុងក្រោយមិនអាចមានន័យពិតប្រាកដទេ។ ជាលទ្ធផល មុខងារនេះអាចត្រូវបានបង្កើតឡើងតែក្នុងពេលណាដែលការប្រើប្រាស់ប្រាក់រៀលកើនឡើងគ្រប់គ្រាន់ ដើម្បីបង្កើតឡើងជាផ្នែក សំខាន់នៃទ្រព្យសកម្មរបស់ធនាគារ (ឧទាហរណ៍ ឥណទាន) និងទ្រព្យអកម្ម (ប្រាក់បញ្ញើជាចំបង)។ ហេតុនេះ ធនាគារជាតិនៃកម្ពុជាមិនគួរផ្ដល់ការគាំទ្រផ្នែកហិរញ្ញវត្ថុទៅគ្រឹះស្ថានហិរញ្ញវត្ថុក្នុងស្ថានភាពឫបិយវត្ថុបច្ចុប្បន្ននេះទេ។ ការគាំទ្រណាមួយបែបនេះ គឺជារូបភាពមួយនៃការឧបត្ថម្ភ ឬក៏ជាការគាំទ្ររបស់រដ្ឋាភិបាល ហើយនឹងត្រូវអនុវត្ត ដោយមានការអនុមតិពីរដ្ឋាភិបាលតែប៉ុណ្ណោះ។

៣.២៩ សមាសធាតុទី២ បទបញ្ញត្តិ និងការត្រួតពិនិត្យធនាគារ នឹងពិភាក្សាលំអិតខាងក្រោម។

៣.៣០ សមាសធាតុទី៣ ប្រព័ន្ធមួយសម្រាប់ដោះស្រាយធនាគារដែលមានបញ្ហា និងអសាធនភាព គួរតែទទួលបានការយកចិត្តទុកដាក់នៅកម្ពុជា មុននឹងមានការដួលរលំរបស់ធនាគារកើតឡើង។យ៉ាងហោចណាស់ក៏ចាំបាច់ត្រូវមានផែនការបំរុងសម្រាប់ដោះស្រាយបញ្ហា ឬការដួលរលំ នាអនាគតណាមួយរបស់ធនាគារ។ ដូចគ្នានេះដែរ ផែនការទាំងនេះគួរពង្រីកទៅដល់ការដោះស្រាយបញ្ហាក្ស័យធនរបស់ធនាគារផងដែរ។ កម្ពុជានឹងសំឡឹងមើលទៅការណែនាំ និងបទពិសោធន៍ជាអន្តរជាតិ ដូចជាក្របខ័ណ្ឌច្បាប់ស្ថាប័ន និងបទបញ្ញត្តិ សម្រាប់ដោះស្រាយបញ្ហាធនាគារដែលមានអសាធនភាព ដើម្បីបង្កើតប្រព័ន្ធសមស្របមួយសម្រាប់ដោះស្រាយធនាគារ មានបញ្ហានិងអសាធនភាពនៅក្នុងប្រទេស។

៣.៣១ សមាសធាតុទី៤ ការការពារអ្នកផ្ញើប្រាក់ ត្រូវបានដោះស្រាយនៅក្នុងសមាសធាតុទាំងបីខាងលើ ជាពិសេស បទបញ្ញត្តិ និងការត្រួតពិនិត្យធនាគារ។ សមាសធាតុនេះក៏អាចបញ្ចូលនូវវចនាសម្ព័ន្ធដូចជា (១)ចំណូលចិត្តរបស់អ្នកផ្ញើប្រាក់ក្នុងបរិបទ

អសាធនភាព និង(២) ការធានារ៉ាប់រងប្រាក់បញ្ញើ ។ កម្ពុជាអាចពិចារណាពីលទ្ធភាពដាក់ការការពារអ្នកផ្ញើប្រាក់ដែលមិនស្ថិតនៅក្រោមបទបញ្ញត្តិ និងការត្រួតពិនិត្យនៅក្នុងការធានារ៉ាប់រងប្រាក់បញ្ញើក្នុងរយៈពេលមធ្យមទៅរយៈពេលវែង។ បច្ចុប្បន្ន មិនមានការឯកភាពគ្នាថា តើកម្ពុជាគួរឬមិនគួរអនុវត្តការធានារ៉ាប់រងលើប្រាក់បញ្ញើ ប៉ុន្តែនេះគឺជាបញ្ហាដែលត្រូវពិចារណាបន្ថែមទៅអនាគត ។

## ៤. បទបញ្ញត្តិ និងការត្រួតពិនិត្យធនាគារ

៣.៣២ បទបញ្ញត្តិ និងការត្រួតពិនិត្យធនាគារ ចាំបាច់ត្រូវដោះស្រាយនូវទិដ្ឋភាពមួយចំនួន ។

### *៤.១ គោលបំណង ឯករាជ្យ សិទ្ធិអំណាច តម្លាភាព និងសហប្រតិបត្តិការ*

៣.៣៣ អ្នកត្រួតពិនិត្យធនាគារត្រូវមានគោលដៅច្បាស់លាស់ ឯករាជ្យ និងសិទ្ធិអំណាចគ្រប់គ្រាន់ ដើម្បីសម្រេចគោលដៅទាំងនោះ នៅក្នុងបរិបទតម្លាភាព និងកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរ និងភ្នាក់ងារដែលពាក់ព័ន្ធ ។ ជាទូទៅ ក្របខ័ណ្ឌច្បាប់ជាមូលដ្ឋានមានរួចហើយដើម្បីគាំទ្រដល់ចំណុចសំខាន់ទាំងនេះនៅប្រទេសកម្ពុជា។ ទន្ទឹមគ្នានេះ វានៅតែមានការចាំបាច់បន្តការយកចិត្តទុកដាក់លើការធ្វើឱ្យប្រសើរឡើងនូវឯករាជ្យនៃប្រតិបត្តិការ តម្លាភាព អភិបាលកិច្ច ធនធាន និងគណនេយ្យភាព។ ដូចគ្នានេះដែរ ក្នុងរយៈពេលមធ្យម កម្ពុជានឹងអនុវត្តការពិនិត្យឡើងវិញ ជាទូទៅ នូវក្របខ័ណ្ឌច្បាប់សម្រាប់ធនាគារ ដើម្បីដោះស្រាយគំលាតនិងភាពមិនស៊ីសង្វាក់គ្នាទាំងឡាយ ។

### *៤.២ សកម្មភាពធនាគារ*

៣.៣៤ ក្របខ័ណ្ឌសម្រាប់បទបញ្ញត្តិធនាគារគួរដោះស្រាយនូវសកម្មភាពរបស់ធនាគារដ៏ទូលំទូលាយ រួមមាន ៖

- សកម្មភាពដែលត្រូវបានអនុញ្ញាតិរបស់ធនាគារ
- លក្ខណៈវិនិច្ឆ័យសម្រាប់ផ្តល់អាជ្ញាប័ណ្ណ
- ការផ្ទេរភាពជាម្ចាស់កម្មសិទ្ធិសំខាន់ៗ
- ការទិញយកធនាគារ
- ភាពគ្រប់គ្រាន់នៃដើមទុន
- ដំណើរការគ្រប់គ្រងហានិភ័យ
- ហានិភ័យឥណទាន
- ទ្រព្យសកម្មមានបញ្ហា សំវិធានធន និងទុនបំរុង
- កម្រិតកំណត់ហានិភ័យធំៗ
- ហានិភ័យចំពោះសម្ព័ន្ធញាតិ
- ហានិភ័យប្រទេស និងការផ្ទេរប្រាក់

- ហានិភ័យទីផ្សារ
- ហានិភ័យសាច់ប្រាក់ងាយស្រួល
- ហានិភ័យប្រតិបត្តិការ
- ហានិភ័យអត្រាការប្រាក់
- ការត្រួតពិនិត្យផ្ទៃក្នុង និងសវនកម្ម
- ការរំលោភលើសេវាហិរញ្ញវត្ថុ និង
- គណនេយ្យ និងការបើកចំហព័ត៌មានហិរញ្ញវត្ថុ ។

៣.៣៥ កម្ពុជាបានដោះស្រាយបញ្ហាខាងលើជាច្រើនមកហើយតាមរយៈបទបញ្ញត្តិទាំងឡាយ ប៉ុន្តែការខ្វះចន្លោះនៅតែមានដែលនឹងត្រូវដោះស្រាយក្នុងអនាគតយ៉ាងខ្លី សំខាន់បំផុតចំពោះការសំអាតប្រាក់ នឹងការរំលោភសេវាហិរញ្ញវត្ថុ ។ ក្រៅពីនេះ ការយកចិត្តទុកដាក់ជាគន្លឹះគឺការអនុវត្តន៍ ជាពិសេសនៅក្នុងបរិបទនៃការធ្វើឱ្យប្រសើរឡើង នូវដំណើរការផ្ទៃក្នុងរបស់ធនាគារផ្ទាល់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ។ ការយកចិត្តទុកដាក់ត្រូវផ្តោតលើការកែលំអ សង្គតភាព និងគុណភាពនៃការតាមដាន និងការដាក់ឱ្យអនុវត្តច្បាប់របស់ធនាគារជាតិនៃកម្ពុជា រួមបញ្ចូលតាមរយៈការអភិវឌ្ឍប្រពន្ធ័ និងដំណើរការត្រួតពិនិត្យដ៏សមស្រប ។

## *៤.៣ អ្នកត្រួតពិនិត្យ*

៣.៣៦ អ្នកត្រួតពិនិត្យធនាគារត្រូវមានសិទ្ធិអំណាចសមស្រប និងប្រពន្ធ័ទាក់ទងនិងគោលការណ៍ត្រួតពិនិត្យ គោលការណ៍បច្ចេកទេស របាយការណ៍ត្រួតពិនិត្យ សិទ្ធិអំណាចកែតម្រូវបន្ទាន់ ការត្រួតពិនិត្យរួមបញ្ចូលគ្នា និងទំនាក់ទំនងជាមួយស្នាក់ការកណ្តាលនៅក្រៅប្រទេស ។

៣.៣៧ ធនាគារជាតិនៃកម្ពុជាបានខិតខំយ៉ាងខ្លាំង ដើម្បីធ្វើឱ្យប្រសើរឡើងនូវការត្រួតពិនិត្យរបស់ខ្លួន ក៏ប៉ុន្តែនៅតែមានការងារជាច្រើនទៀតដែលត្រូវធ្វើ ។ គោលដៅសំខាន់ៗមាន ៖

- កែលំអបច្ចេកទេសត្រួតពិនិត្យដល់ទីកន្លែង និងលើឯកសារ
- បន្តការកសាងសមត្ថភាពនៅធនាគារជាតិនៃកម្ពុជា និងនៅធនាគារ
- អភិវឌ្ឍន៍ប្រព័ន្ធដំណើការ និងប្រព័ន្ធព័ត៌មានវិទ្យារបស់ធនាគារជាតិនៃកម្ពុជា
- ធនាគារជាតិនៃកម្ពុជា និងការដាក់ឱ្យអនុវត្តច្បាប់ ។

## ៥. អាទិភាព ២០០៦-២០១៥ : វិស័យធនាគារ

៣.៣៨ ទៅអនាគត គោលដៅសំខាន់ៗគឺ ៖

- បង្កើតប្រពន្ធ័ដោះស្រាយធនាគារមានបញ្ហា និងអសាធនភាព
- បង្កើតប្រពន្ធ័ទូទាត់សងប្រាក់ និងផាត់ទាត់ជាតិដែលមានសុវត្ថិភាព ប្រសិទ្ធភាព និងសមត្ថភាព និង

- បន្តធ្វើឱ្យប្រសើរឡើងទាំងក្របខ័ណ្ឌច្បាប់ និងបទបញ្ញត្តិសម្រាប់ការត្រួតពិនិត្យធនាគារ និងការត្រួតពិនិត្យធនាគារខ្លួនឯងផ្ទាល់ សំដៅគាំទ្រស្ថិរភាពផ្នែកហិរញ្ញវត្ថុ និងការអភិវឌ្ឍធនាគារ ដើម្បីបង្កើនទូវកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ ។

## *៥.១ អាទិភាពចំពោះមុខ*

៣.៣៩ គោលដៅរយៈពេលខ្លីរួមមាន ៖

- បន្តលើកកម្ពស់ការត្រួតពិនិត្យ ការកសាងសមត្ថភាពនៅធនាគារជាតិនៃកម្ពុជានិងធនាគារ និងការអប់រំអតិថិជន និងផ្សព្វផ្សាយការយល់ដឹងផ្សេងៗ
- ស្វ័យប្រវត្តិកម្មការផាត់ទាត់ និងការទូទាត់មូលប្បទានប័ត្រ
- អភិវឌ្ឍន៍ប្រព័ន្ធទូទាត់សងប្រាក់ជាតិដុលតាមអេឡិចត្រូនិច រួមមានការគាំទ្រសម្រាប់ទីផ្សារអន្តរធនាគារ ជាមួយការចាប់ផ្តើមពីអ្នកចូលរួមជាធនាគារពាណិជ្ជ និងធនាគារឯកទេស
- បញ្ចូលអ្នកឱ្យខ្ចីចងការ និងអ្នកប្តូរប្រាក់ទៅក្នុងក្របខ័ណ្ឌបទបញ្ញត្តិផ្លូវការ ដោយចាប់ផ្តើមតាមរយៈការចុះបញ្ជី និងបំពេញនូវកាតព្វកិច្ចផ្សេងៗ
- អភិវឌ្ឍន៍ព័ត៌មានវិទ្យា និងការគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យាទូលំទូលាយមួយរបស់ធនាគារជាតិនៃកម្ពុជា ដើម្បីគាំទ្រដល់មុខងាររបស់ខ្លួន និង
- ពង្រឹងការដាក់ឱ្យអនុវត្តច្បាប់របស់ធនាគារជាតិនៃកម្ពុជា និងប្រព័ន្ធតុលាការ ។

## *៥.២ អាទិភាពចំពោះមុខ និងរយៈពេលមធ្យម*

៣.៤០ អាទិភាពរយៈពេលមធ្យម រួមមាន ៖

- ពង្រីកប្រព័ន្ធទូទាត់សងប្រាក់ដោយបញ្ចូលអ្នកចូលរួមជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណ
- ផ្តល់ប្រាតិភោគចំពោះហានិភ័យប្រព័ន្ធទូទាត់សងប្រាក់តាមរយៈមូលប័ត្ររដ្ឋរយៈកាលខ្លី
- បន្តកសាងសមត្ថភាពធនាគារជាតិនៃកម្ពុជា និងធនាគារពាណិជ្ជ
- អប់រំអតិថិជន និងសកម្មភាពផ្សព្វផ្សាយការយល់ដឹងផ្សេងៗ
- បន្តលើកកម្ពស់ការត្រួតពិនិត្យ
- ផ្ទេរប្រពន្ធ័ព័ត៌មានឥណទានអន្តរធនាគារទៅឱ្យផ្នែកឯកជន រួមទាំងការបង្កើតក្របខ័ណ្ឌច្បាប់ និង បទបញ្ញត្តិ ដើម្បីការប្រព្រឹត្តទៅនៃប្រព័ន្ធឯកជននោះ និង
- គាំទ្រការបង្កើតផលិតផលហិរញ្ញវត្ថុថ្មីនិងសកម្មភាពថ្មីៗ ក្នុងបរិបទចាត់ចែងដោយសមធម៌នៃអ្នកផ្តល់ផលិតផល និងស្ថិរភាពហិរញ្ញវត្ថុ ។ ទាំងនេះរួមបញ្ចូលទាំងបញ្ញត្តិកម្មអ្នកឱ្យខ្ចីចងការ និងអ្នកប្តូរប្រាក់ ដែលកំពុងប្រកបអាជីវកម្មធនាគារ ។

### ៥.៣ គោលដៅរយៈពេលវែង

៣.៤១ អាទិភាពរយៈពេលមធ្យម និងរយៈពេលវែង នឹងចាប់ផ្ដើមបន្ទាប់ពីបំពេញអាទិភាពចំពោះមុខ និងអាទិភាពរយៈ ពេលមធ្យមរួចហើយ រួមមាន ៖

- ការពិនិត្យឡើងវិញគ្រប់ជ្រុងជ្រោយនូវច្បាប់ស្ដីពីគ្រឹះស្ថានធនាគារ និងបទបញ្ញត្តិ ដើម្បីធ្វើបច្ចុប្បន្នកម្ម ឬធ្វើឱ្យកាន់តែប្រសើរឡើង តាមការចំបាច់
- ការពិនិត្យឡើងវិញប្រព័ន្ធការពារអ្នកផ្ញើប្រាក់ ។

## ខ. មីក្រូហិរញ្ញវត្ថុ

៣.៤២ ចក្ខុវិស័យនិងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០១-២០១០ បានកំណត់ថា ហិរញ្ញវត្ថុជនបទ ជាវិស័យមួយយ៉ាងសំខាន់ដែលតម្រូវឱ្យមានការអភិវឌ្ឍនិងគាំទ្រ ។ ប្រព័ន្ធធនាគារត្រូវបានទទួលស្គាល់ថាជាប្រព័ន្ធ មិនអាចដោះស្រាយប្រភេទនៃតម្រូវការរបស់ពលរដ្ឋក្រីក្រ ដើម្បីសម្រួលការប្រើប្រាស់ ការសន្សំទ្រព្យសម្បត្តិ និង ការអភិវឌ្ឍមីក្រូសហគ្រាសបានឡើយ ។ ទាំងនេះត្រូវបានស្ដែងឡើងយ៉ាងច្បាស់ដោយភាពក្រីក្រគោកយ៉ាកយ៉ាងខ្លាំង ដូចជាចំណូលគ្រួសារមិនគ្រប់គ្រាន់ កង្វះខាតទ្រព្យសម្បត្តិដែលមានផលិតភាព និងមិនមានលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុជាដើម ។

៣.៤៣ ចាប់ពីឆ្នាំ២០០១មក វិស័យមីក្រូហិរញ្ញវត្ថុបានអភិវឌ្ឍន៍គួរឱ្យកត់សម្គាល់ ។ ជោគជ័យដ៏ធំនេះគឺជាលទ្ធផលមួយផ្នែកធំបានមកពីគោលការណ៍ផ្អែកលើទីផ្សារជាចំបងដើម្បីអភិវឌ្ឍន៍ និងមានអន្តរាគមន៍តិចតួចរបស់រដ្ឋាភិបាល ។ បច្ចុប្បន្ន មានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ១៦ បានទទួលអាជ្ញាប័ណ្ណ ដែលមានដំណើរការល្អតាមទីផ្សារ ហើយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលចុះបញ្ជីក៏បានកើនឡើងដែរ ។ លើសពីនេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួនបានប្រែក្លាយពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទៅជាធនាគារ (ធនាគារពាណិជ្ជ ឬជាធនាគារឯកទេស) ។ ប្រតិបត្តិការរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបច្ចុប្បន្ន មានទាំងការផ្ដល់ឥណទាន និងការទទួលប្រាក់បញ្ញើតិចតួច ។

### ១. ភាពរីកចម្រើន និងសមិទ្ធផលចាប់ពីឆ្នាំ២០០១

៣.៤៤ នៅក្នុងការអភិវឌ្ឍមីក្រូហិរញ្ញវត្ថុ ចក្ខុវិស័យនិងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០១-២០១០ បានចង្អុលបង្ហាញនូវការងារចំនួន ៥ ផ្នែក ដោយរៀបចំជាដំណាក់កាល ៖

- ការអនុវត្តន៍ និងការជម្រុញគោលនយោបាយឥណទានជនបទ
- ការពង្រឹងបទបញ្ញត្តិ និងការត្រួតពិនិត្យ
- កសាងហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុសម្រាប់មីក្រូហិរញ្ញវត្ថុ

- ការបង្កើតសមត្ថភាពស្ថាប័ន និង
- ធានាទិសដៅឆ្ពោះទៅរកពលរដ្ឋក្រីក្រ ។

៣.៤៥ ជាទូទៅ ការទទួលខុសត្រូវ ត្រូវបានបែងចែករវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុគាំទ្រការអភិវឌ្ឍគោលនយោបាយ និងការសម្របសម្រួលមូលនិធិ ធនាគារជាតិនៃកម្ពុជា ទទួលខុសត្រូវបទបញ្ញត្តិ និងការត្រួតពិនិត្យ និងសមាគមមីក្រូហិរញ្ញវត្ថុ ទទួលខុសត្រូវអំពីទិដ្ឋភាពប្រតិបត្តិការ ។

៣.៤៦ សមិទ្ធផលភាគច្រើនសម្រេចបានចំពោះសកម្មភាពដំណាក់កាលទី១ ។ សកម្មភាពក្នុងដំណាក់កាលទី២ កំពុងតែដំណើរការ ទោះបីជាតាមសង្វាក់ខុសគ្នា និងលទ្ធផលប្រែប្រួលយ៉ាងខ្លាំងក៏ដោយ ។ សកម្មភាពដំណាក់កាលទី៣ ដែលបានគ្រោងរួចហើយ មិនទាន់ត្រូវបានចាប់ផ្តើម និងមិនទាន់ដល់ពេលកំណត់ដើម្បីចាប់ផ្តើមនៅឡើយទេរហូតដល់ឆ្នាំ២០០៨ ប៉ុន្តែសកម្មភាពមួយចំនួនត្រូវបានកើតឡើងរួចទៅហើយ ដែលសម្តែងឱ្យឃើញពីថាមភាពនៃវិស័យនេះ ។

## ១.១ ការអនុវត្តន៍ និងការរៀបចំគោលនយោបាយឥណទានជនបទ

៣.៤៧ រដ្ឋាភិបាលបានបង្កើតគណៈកម្មាធិការអភិវឌ្ឍន៍ឥណទានជនបទ ។ ក្រោមលក្ខខណ្ឌនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើរតួនាទីសំខាន់ក្នុងការរៀបចំនូវក្របខ័ណ្ឌគោលនយោបាយ និងយុទ្ធសាស្ត្រពាក់ព័ន្ធនឹងមីក្រូហិរញ្ញវត្ថុ ដោយសហការជាមួយធនាគារជាតិនៃកម្ពុជា វិស័យឯកជន និងភាគីពាក់ព័ន្ធដទៃទៀត នៅពេលដែលធនាគារជាតិនៃកម្ពុជាទទួលខុសត្រូវបញ្ញត្តិកម្ម និងការត្រួតពិនិត្យ ។ គោលនយោបាយឥណទានជនបទកំពុងស្ថិតនៅក្រោមការរៀបចំនៅឡើយ ប៉ុន្តែដោយពិនិត្យមើលលើការផ្លាស់ប្តូរក្នុងវិស័យនេះដែលបានកើតឡើងក្នុងប៉ុន្មានឆ្នាំនេះ ជាមួយការអនុវត្តន៍យ៉ាងល្អជាអន្តរជាតិដែលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកំពុងអនុវត្តយ៉ាងត្រឹមត្រូវ ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ តាមរយៈសមាគមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បច្ចុប្បន្នកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយគណៈកម្មាធិការអភិវឌ្ឍន៍ឥណទានជនបទ និងជាមួយភាគីពាក់ព័ន្ធ ដើម្បីបង្កើតគោលនយោបាយមួយសមស្របក្នុងក្របខ័ណ្ឌនៃការអនុវត្តន៍ល្អបំផុតជាអន្តរជាតិ ។

៣.៤៨ មីក្រូហិរញ្ញវត្ថុនៅកម្ពុជាត្រូវបានអភិវឌ្ឍន៍ឡើងហួសពីការគិតទុកតែខាងឥណទានប៉ុណ្ណោះ និងត្រូវឈានទៅផ្នែកផ្សេងៗទៀត ដូចជាការសន្សំ ការធានារ៉ាប់រង និងសេវាហិរញ្ញវត្ថុដទៃទៀតសម្រាប់អនាគត ។ គោលនយោបាយណាមួយដែលនឹងត្រូវបង្កើតឡើងត្រូវតែបង្កលក្ខណៈងាយស្រួលដល់ការអភិវឌ្ឍ និងបង្កលក្ខណៈឱ្យគ្រឹះស្ថានមីក្រូ ហិរញ្ញវត្ថុជាអ្នកអនុវត្តដោយខ្លួនឯងក្នុងគោលនយោបាយទាំងនោះ ។ ស្ថាប័នដែលគ្រប់គ្រងពួកគេគួរបង្កើតគោលនយោបាយដោយផ្អែកលើមូលដ្ឋានតម្រូវការទីផ្សារ ។ មានការកើនឡើងនៃការអនុវត្តន៍ល្អបំផុតជាអន្តរជាតិនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ហើយមុខងារនៃស្ថាប័នដែលគាំទ្រគួរតែផ្សព្វផ្សាយគោលនយោបាយនេះ និងលើកទឹកចិត្តដល់ការទទួលយក ឬសម្របសម្រួលទៅតាមស្ថានភាពរបស់ប្រទេសកម្ពុជា ។

៣.៤៩ ការពិនិត្យឡើងវិញ និងការសម្របសម្រួលគោលនយោបាយកំពុងបន្តនាពេលបច្ចុប្បន្ននេះ និងមានលក្ខណៈរយៈពេលវែងនៃការអភិវឌ្ឍតាមវិស័យ។

## ១.២ ការពង្រឹងបទបញ្ញត្តិ និងការត្រួតពិនិត្យ

៣.៥០ ខណៈពេលដែលតួនាទីរបស់ស្ថាប័នផ្សេងៗក្នុងការដាក់បញ្ញត្តិកម្មនិងការត្រួតពិនិត្យត្រូវបានទទួលស្គាល់នោះ នៅមានការងារជាច្រើនដែលត្រូវធ្វើនៅក្នុងការញែកឱ្យច្បាស់នូវតួនាទី និងការបន្តដាក់បញ្ញត្តិកម្មនិងត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព។ កម្ពុជាបានបង្ហាញនូវការរឹតត្បិតអន្តរាគមន៍ទៅក្នុងវិស័យនេះ ដែលបង្កលក្ខណៈដោយផ្ទាល់ដល់វិស័យនេះឱ្យអភិវឌ្ឍន៍បានយ៉ាងល្អ។ ហេតុដូច្នេះ វានឹងមានសារៈសំខាន់ចំពោះការកំណត់នូវផ្នែកផ្សេងទៀតដែលរដ្ឋាភិបាលមិនគួរធ្វើអន្តរាគមន៍ដើម្បីរក្សាសេរីភាពសម្រាប់ការអភិវឌ្ឍទីផ្សារដូចដែលបានគ្រោងទុក ធ្វើឱ្យមានប្រសិទ្ធភាពនូវមុខងារបញ្ញត្តិកម្មនិងត្រួតពិនិត្យ ដើម្បីការពារក្រុមងាយរងគ្រោះពីការកេងប្រវ័ញ្ច។

៣.៥១ បទបញ្ញត្តិប្រុងប្រយ័ត្នមានរួចហើយដើម្បីការពារផលប្រយោជន៍របស់អ្នកចូលរួមទាំងអស់នៅក្នុងវិស័យនេះ។ ជាការពិត បទបញ្ញត្តិផ្តល់នូវក្របខ័ណ្ឌ ដែលក្នុងនោះវិស័យមីក្រូហិរញ្ញវត្ថុអាចធ្វើដំណើរការបាន។ បទបញ្ញត្តិត្រូវបានដាក់ជាធរមានដើម្បីឱ្យមានការអនុវត្តន៍ត្រឹមត្រូវតាមច្បាប់ ហើយនៅកម្រិតសហគ្រាស បទបញ្ញត្តិផ្តល់នូវក្របខ័ណ្ឌសម្រាប់ដាក់ចេញនូវលក្ខន្តិកៈនិងបទបញ្ជាផ្សេងៗដើម្បីអនុវត្ត។ ដើម្បីកុំឱ្យបទបញ្ញត្តិបែបនេះរាំងស្ទះដល់ការអភិវឌ្ឍ ជាការសំខាន់ដែលតួនាទីរបស់ស្ថាប័នរដ្ឋាភិបាលត្រូវបានរៀបចំដើម្បីធានាឱ្យមានភាពច្បាស់លាស់នៅក្នុងការអនុវត្តន៍បទបញ្ញត្តិទាំងនេះ។ ការលើកកម្ពស់ការអនុវត្តន៍បទបញ្ញត្តិប្រុងប្រយ័ត្ននៅតែចាំបាច់ធ្វើបន្តទៀត។

៣.៥២ លើសពីនេះទៅទៀត មានតម្រូវការបន្ទាន់មួយលើកាតព្វកិច្ចរាយការណ៍ឯកភាពគ្នាដោយឈរលើមូលដ្ឋានប្រតិបត្តិការដោយប្រុងប្រយ័ត្ន។ នៅពេលដែលមានប្រព័ន្ធរាយការណ៍ឯកភាពរួម ស្តង់ដារអនុវត្តឯកភាពរួមនឹងត្រូវបានអនុវត្តដែរ ហើយទាំងនេះអាចត្រូវបានប្រើប្រាស់ជាមូលដ្ឋានលើការធ្វើចំណាត់ថ្នាក់ ការវិភាគការអនុវត្តន៍ និងការត្រួតពិនិត្យដ៏មានសារៈសំខាន់។

## ១.៣ កសាងហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុសម្រាប់មីក្រូហិរញ្ញវត្ថុ

៣.៥៣ ការកសាងហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុសម្រាប់មីក្រូហិរញ្ញវត្ថុមានសារៈសំខាន់ និងទូលំទូលាយ ដែលរួមបញ្ចូលនូវសំណុំសកម្មភាព ហើយត្រូវបន្តអនុវត្តតទៅអនាគត ខណៈដែលវិស័យនេះឆ្លើយតបទៅនឹងការប្រែប្រួលជាបន្តបន្ទាប់នៃស្ថានការណ៍ជាក់ស្តែងរបស់ទីផ្សារ។

៣.៥៤ ចក្ខុវិស័យនិងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០០១-២០១០ ផ្តល់អនុសាសន៍ឱ្យបង្កើតអ្នកផ្តល់សេវាមួយចំនួន ដោយសន្មតថា តម្រូវការសម្រាប់សេវានោះ ដូចជាភតិសន្យា មូលនិធិអភិវឌ្ឍន៍ និងមូលនិធិជាទ្រព្យសម្បត្តិ នឹងកើតឡើងស្របទៅតាមការរីកចំរើននៃវិស័យនេះ។ ក៏ប៉ុន្តែ នេះមិនមែនជាករណីសម្រាប់មីក្រូហិរញ្ញវត្ថុទេ ហើយផលិតផលដែលវិស័យមីក្រូហិរញ្ញវត្ថុបង្កើតឡើងមិនសូវស្មុគស្មាញទេ ប៉ុន្តែកំពុងតែព្យាយាមដើម្បីបំពេញតម្រូវការនៃទីផ្សារដ៏ធំ។ បើ

និយាយពីផលិតផលវិញ វិស័យមីក្រូហិរញ្ញវត្ថុកំពុងព្យាយាមពង្រីកដែនអាជីវកម្ម ដើម្បីឆ្លើយតបតម្រូវការទីផ្សារ មុននិងពង្រីកផលិតផលឱ្យបានស៊ីជំរៅ។ ផលិតផលណាមួយដែលបានបង្កើតឡើងគឺតាមតម្រូវការទីផ្សារ គឺមិនមែនជាការបង្កើតឡើងក្នុងបំណងបង្កើតទីផ្សារថ្មីនោះទេ។ទន្ទឹមគ្នានេះក៏មានតម្រូវការឱ្យមានអ្នកផ្តល់សេវាកម្មបន្ថែមផងដែរដូចជាអ្នកផ្តល់សេវាឯកទេស បណ្តុះបណ្តាល និងសវនកម្ម។

៣.៥៥ ការអភិវឌ្ឍនៃចំណងទាក់ទងរវាងវិស័យធនាគារពាណិជ្ជ និងវិស័យមីក្រូហិរញ្ញវត្ថុ គឺជាអាទិភាព។ ដូចមានចង្អុលបង្ហាញនៅក្នុងចក្ខុវិស័យនិងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០០១-២០១០ វិស័យមីក្រូហិរញ្ញវត្ថុ ទាមទារឱ្យមានការបន្ថែមសាច់ប្រាក់ងាយស្រួលជាប្រចាំ ដើម្បីពង្រីកសកម្មភាពរបស់ខ្លួន ប្រកបដោយនិរន្តភាព ចូលទៅកាន់តំបន់ថ្មី។ ខណៈពេលដែលផលិតផលថ្មីត្រូវបានបង្កើតឡើង នោះទាមទារឱ្យមានសាច់ប្រាក់ងាយស្រួលបន្ថែមលើទីផ្សារ។ មានតែប្រព័ន្ធធនាគារពាណិជ្ជប៉ុណ្ណោះ ដែលមានកម្រិតសាច់ប្រាក់ងាយស្រួលគ្រប់គ្រាន់ ដើម្បីបំពេញតម្រូវការដែលកើតឡើង។ វិស័យនេះបានបង្កើតឱ្យមានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាប័ណ្ណចំនួន១៦ ហើយដែលបានដំណើរការយ៉ាងល្អ។ ការអភិវឌ្ឍបណ្តាញរវាងវិស័យធនាគារ និងវិស័យមីក្រូហិរញ្ញវត្ថុបច្ចុប្បន្ននឹងពឹងផ្អែកលើការអភិវឌ្ឍផលិតផលនិងទីផ្សារដែលមានអត្ថប្រយោជន៍ទៅវិញទៅមក។ ការតម្រូវបច្ចុប្បន្នរបស់ធនាគារមួយចំនួនឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដាក់វត្ថុធានាគ្រប់គ្រាន់ គឺជាប្រពៃណីនិងដើម្បីកាត់បន្ថយហានិភ័យដែលអាចយល់បាន។ កិច្ចខិតខំប្រឹងប្រែងត្រូវតែធ្វើឡើងដើម្បីជំនះឧបសគ្គទាំងនេះ និងឈានទៅរកកិច្ចសហប្រតិបត្តិការបន្ថែម តាមរយៈការជំនួសដោយអរូបិយដែលអាចធ្វើទៅបានចំពោះវត្ថុធានា ក្នុងករណីដែលហានិភ័យអាចគ្រប់គ្រងបានដូចជាការធានា ការចូលរួមភាគហ៊ុន ការធ្វើឱ្យប្រសើរឡើងនូវការវាយតម្លៃហានិភ័យ និងការងារផ្សេងៗទៀត ដែលនឹងជួយដល់ការបង្កើតចំណងទាក់ទងរវាងធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

៣.៥៦ មុននឹងបង្កើតបណ្តាញស្ថាប័នមួយ និងក្របខ័ណ្ឌច្បាប់ សម្រាប់ធ្វើសមាហរណកម្មទៅដល់កសិករនិងសហគមន៍តូចៗ មានតម្រូវការមួយដើម្បីកំណត់និងពង្រីកទីផ្សារ ជាមួយការប្រែប្រួល ភាពទន់ភ្លន់ និងលក្ខណៈវិនិច្ឆ័យនៃទីផ្សារនោះ។ ទាំងនេះនឹងគួសបញ្ជាក់ពីចរិតនៃរចនាសម្ព័ន្ធជាយថាហេតុ និងសមាហរណកម្មមួយ ហើយដូចនេះនឹងកំណត់ឱ្យកាន់តែច្បាស់នូវច្បាប់ និងកាតព្វកិច្ចផ្សេងៗទៀត។

## ១.៤ ការបង្កើតសមត្ថភាពស្ថាប័ន

៣.៥៧ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាច្រើនបានផលចំណេញ និងមាននិរន្តភាពរួចទៅហើយ ហើយវឌ្ឍនភាពមួយចំនួន ត្រូវបានកើតឡើងរួចហើយនៅក្នុងផ្នែកនេះ។ បណ្តាញគាំទ្រសម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងនោះ ទោះជាយ៉ាងណាក៏ដោយ ក៏តម្រូវឱ្យមានការអភិវឌ្ឍ ហើយនិរន្តភាពរយៈពេលយូរអង្វែងរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនឹងត្រូវការការគាំទ្រទាំងនោះ។ ជាថ្មីម្តងទៀត ការគាំទ្រទាំងនេះនឹងជាសកម្មភាព ហើយត្រូវបន្តអនុវត្តតទៅអនាគត ខណៈ ដែលវិស័យនេះឆ្លើយតបទៅនឹងការប្រែប្រួលនូវការពិតនៃទីផ្សារ។

៣.៥៨ អន្តរាគមន៍យ៉ាងខ្លាំងក្លាសម្រាប់ការកសាងសមត្ថភាព តាមរយៈការគាំទ្រការបណ្តុះបណ្តាល នៅតែជាអាទិភាពចំបង។ ការគាំទ្រនេះមិនគ្រាន់តែសម្រាប់ការបណ្តុះបណ្តាលតាមទ្រឹស្តីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសម្រាប់ការអភិវឌ្ឍរចនាសម្ព័ន្ធកសាងសមត្ថភាពនៅក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផ្ទាល់ និងប្រព័ន្ធចង្អុលបង្ហាញអំពីតម្រូវការ ការអភិវឌ្ឍជំនាញ និងការបន្តតំណែងគ្រប់គ្រង។ ប្រការនេះទាមទារឱ្យមានការកំណត់អត្តសញ្ញាណនៃគ្រឹះស្ថានសមស្របមួយដែលត្រូវបានរៀបចំដើម្បីពង្រីកខ្លួនទៅក្នុងផ្នែកបណ្តុះបណ្តាលនេះ ហើយផ្តល់ការគាំទ្របែបនេះក្នុងរយៈពេលវែង។

៣.៥៩ ធ្វើបច្ចុប្បន្នកម្ម និងលើកកម្ពស់កម្រិតជំនាញថ្មីៗ គឺជាផ្នែកមួយមានអាទិភាព ដែលត្រូវតែមានការអភិវឌ្ឍជាប្រចាំជាមួយសមត្ថភាពស្ថាប័នសម្រាប់លើកកម្ពស់និងធ្វើឱ្យស៊ីជំរៅនូវការបណ្តុះបណ្តាលឱ្យស្របតាមភាពស៊ីជំរៅនៃប្រព័ន្ធហិរញ្ញវត្ថុ។ ក្នុងខណៈដែលវិសាលភាពប្រព័ន្ធហិរញ្ញវត្ថុរីកកាន់តែធំ កម្រិតជំនាញក៏កាន់តែអភិវឌ្ឍន៍ តាមរយៈការអភិវឌ្ឍសមត្ថភាពស្ថាប័នកាន់តែទូលំទូលាយក្នុងការបណ្តុះបណ្តាល។

## *១.៥ ធានាទិសដៅឆ្ពោះទៅរកពលរដ្ឋក្រីក្រ*

៣.៦០ ជាថ្មីម្តងទៀត ការគាំទ្រទាំងនេះគឺជាសំណុំសកម្មភាពដែលត្រូវធ្វើជាបន្តបន្ទាប់តទៅអនាគត ពេលដែលវិស័យនេះមានការប្រែប្រួល ហើយជំនាញនិងប្រព័ន្ធកាន់តែមានការអភិវឌ្ឍ។

៣.៦១ ខណៈដែលវិស័យមីក្រូហិរញ្ញវត្ថុបានពង្រីកនិងអភិវឌ្ឍន៍ ដូច្នេះអាទិភាពជាច្រើនបានផ្លាស់ប្តូរ។ សម្រាប់អ្នកដែលបាត់បង់សមត្ថភាពពលកម្ម និងអ្នកដែលរស់នៅក្នុងតំបន់ខ្សត់ប្រភពធនធាន នោះនឹងមានឱកាសដើម្បីផ្តល់ជំនួយ តាមរយៈការបង្កើតសិក្ខាសាលាក្នុងស្រុក បណ្តាញម៉ាឃេធីង ឬឱកាសការងារផ្សេងៗ ហើយនិរន្តរភាពរបស់ពួកគេ ត្រូវតែបានវាយតម្លៃតាមវិធីដូចគ្នាទៅនឹងដៃគូពាណិជ្ជកម្មដែលមានសក្តានុពលផ្សេងទៀត ព្រោះថាពួកគេបន្ទាប់មក គឺជាគោលដៅនៃកំលាំងទីផ្សារដូចទៅនឹងសហគ្រិនផ្សេងទៀតដែរ។ គោលនយោបាយមិនត្រូវផាត់ចេញនូវអតិថិជនដែលមានសក្តានុពល ដោយផ្អែកលើពិការភាពផ្លូវកាយ ឬការរស់នៅដាច់ស្រយាលទេ ហើយនៅតំបន់ខ្លះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអាចមានបំណងស្នើសុំរដ្ឋាភិបាលនូវមូលនិធិជាជំនួយពិសេស ដើម្បីជួយក្នុងការបង្កើតឱ្យមានយន្តការគាំទ្របែបនេះនោះទេ។

៣.៦២ ដូចគ្នាដែរ ចាំបាច់ត្រូវមានកិច្ចខិតខំបន្ថែមដោយធ្វើយ៉ាងណាបញ្ចូលស្ត្រីទៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ជាពិសេសចំពោះស្ត្រីដែលជាមេគ្រួសារ។ មានការបង្ហាញដូចៗគ្នាជាអន្តរជាតិថា សកម្មភាពទ្រទ្រង់ហិរញ្ញវត្ថុដែលសំដៅដល់ស្ត្រី ផ្តល់មកវិញនូវភាពកាន់តែប្រសើរឡើងក្នុងការចិញ្ចឹមគ្រួសារ ការសិក្សា និងសុខភាពគ្រួសារ ច្រើនជាងលទ្ធផលនៃសកម្មភាពទ្រទ្រង់ហិរញ្ញវត្ថុដែលផ្តល់ទៅឱ្យបុរស។ ដូចគ្នាផងដែរ ស្ត្រីបានបង្ហាញឱ្យឃើញអំពីការទទួលខុសត្រូវច្រើនជាងបុរសក្នុងការប្រើប្រាស់ការទ្រទ្រង់ហិរញ្ញវត្ថុ និងក្នុងការសងប្រាក់កម្ចីមកវិញ។ ការសិក្សាវាយតម្លៃភាពក្រីក្រ អាចនាំទៅដល់ទិសដៅទ្រទ្រង់ហិរញ្ញវត្ថុកាន់តែមានប្រសិទ្ធភាពនិងឱ្យការចូលរួមរបស់ស្ត្រីក្នុងវិស័យមីក្រូហិរញ្ញវត្ថុកាន់តែច្រើនឡើងដោយផ្អែកលើបំណងដែលធ្វើឱ្យកាន់តែប្រសើរឡើងនូវជីវភាពរស់នៅរបស់គ្រួសារ។

៣.៦៣ ចាំបាច់ត្រូវតែធ្វើការសិក្សាស្រាវជ្រាវអំពីកាលានុវត្តភាព ដែលមានសម្រាប់ការណែនាំឱ្យមានសេវាមីក្រូធានារ៉ាប់រង សោធននិវត្តន៍ និងសេវាហិរញ្ញវត្ថុផ្សេងៗទៀត ដែលអាចបង្កើតឡើងដើម្បីផ្តល់សេវាបណ្តាញសុវត្ថិភាពដែលអតិថិជនមានស្រាប់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទាន់មានសេវាខាងលើ ។

## ២. ការអភិវឌ្ឍមីក្រូហិរញ្ញវត្ថុ : ជំហានបន្ទាប់

៣.៦៤ បច្ចុប្បន្ននេះ ជាលទ្ធផលនៃការអភិវឌ្ឍដ៏លឿន ចាំបាច់ត្រូវចូលឱ្យស៊ីជំរៅទៅក្នុងបញ្ហាជារចនាសម្ព័ន្ធដែលនៅជុំវិញវិស័យនេះ និងលំដាប់លំដោយនៃអន្តរាគមន៍ដើម្បីគាំទ្រការអភិវឌ្ឍនៃវិស័យមីក្រូហិរញ្ញវត្ថុដែលមានដំណើរការដ៏ល្អប្រសើរ ។ អន្តរាគមន៍ក្នុងការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុត្រូវតែសំបូរបែប ប៉ុន្តែត្រូវតែពឹងផ្អែកគ្នាទៅវិញ ទៅមក ។ មានបញ្ហាចំបងៗមួយចំនួនដែលចាំបាច់ត្រូវធ្វើការដោះស្រាយ ហើយដែលមានឥទ្ធិពលដោយផ្ទាល់លើការអភិវឌ្ឍវិស័យនេះ ។

៣.៦៥ វិស័យមីក្រូហិរញ្ញវត្ថុខ្លួនឯងផ្ទាល់បានអភិវឌ្ឍន៍ដោយខ្លួនឯងនៅក្នុងប្រទេសកម្ពុជា តាំងពីឆ្នាំ២០០១ ហើយបានឆ្ពោះទៅកាន់តំបន់ជាច្រើន ។ ដោយសារថាមភាពជាភស្តុតាងរបស់វិស័យនេះ លក្ខណៈតម្រូវការនៃអន្តរាគមន៍ត្រូវបានផ្លាស់ប្តូរហើយបច្ចុប្បន្ននេះ មានភាពចាំបាច់ដើម្បីធ្វើការកំណត់អត្តសញ្ញាណអាទិភាព និងធ្វើកាលវិភាគអន្តរាគមន៍ឡើងវិញ ដើម្បីឆ្លុះបញ្ចាំងពីតម្រូវការកាន់តែច្រើនឡើងនៃវិស័យនេះ ។

៣.៦៦ ជាទូទៅ កត្តាដំណើរការផ្ទៃក្នុង ក៏ដូចជាការអន្តរាគមន៍ពីខាងក្រៅ នឹងកំណត់នូវកំណើនរបស់វិស័យនេះ ។ តម្រូវការអន្តរាគមន៍ក៏ផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ផងដែរ ។បច្ចុប្បន្ន ប្រភេទនៃអន្តរាគមន៍មានចរិតគាំទ្រកាន់តែច្រើនចំពោះសកម្មភាពដែលកំពុងដំណើរការ ។ ការពង្រីកវិសាលភាព កំណើន និងការពង្រីកសកម្មភាព នឹងកើតឡើងពីការណែនាំជំនាញ ទស្សនៈវិស័យ និងគំនិតថ្មីៗ ក៏ដូចជាការផ្តល់មូលនិធិបន្ថែម ។

៣.៦៧ ដើម្បីធ្វើឱ្យបានប្រសើរបំផុតនូវការអភិវឌ្ឍ និងដំណើរការ របស់វិស័យមីក្រូហិរញ្ញវត្ថុ និងផ្តល់ការត្រួតពិនិត្យដោយប្រុងប្រយ័ត្ន ដើម្បីការពារក្រុមងាយរងគ្រោះបំផុតនៅក្នុងសង្គមពីការកេងប្រវ័ញ្ចមិនសមហេតុផល គឺចាំបាច់ត្រូវមានការធ្វើអន្តរាគមន៍ដែលបានគិតនិងពិចារណាជាមុន ដែលនឹងបង្កើតឱ្យមានកំណើន និងបង្កើតឱ្យមានស្ថាបត្យកម្ម ដើម្បីការពារផលប្រយោជន៍ភាគីដែលពាក់ព័ន្ធទាំងអស់ ។

៣.៦៨ វាមានសារៈសំខាន់ផងដែរ ក្នុងការកំណត់អត្តសញ្ញាណអ្នកទាំងឡាយណាដែលមីក្រូហិរញ្ញវត្ថុមិនអាចផ្តល់សេវា ហិរញ្ញវត្ថុបាន ។ តាមនិយមន័យ ទុរគតជនគឺជាជនមិនមានទ្រព្យសម្បត្តិ ឬមុខរបរដែលមានសក្តានុពលរកប្រាក់ចំណូល ។ ដូច្នេះ ពួកគេគ្មានប្រាក់សម្រាប់ដាក់ផ្ញើ ឬប្រាក់ចំណូលដែលពួកគេអាចសងឥណទានដែលបានផ្តល់ឱ្យពួកគេនោះទេ ។ ប្រសិនបើឥណទានត្រូវបានផ្តល់ វានឹងនាំឱ្យស្ថានភាពរបស់ទុរគតជននោះកាន់តែអាក្រក់ជាងមុន ដោយពួកគេមិនបានទទួលឥណទានតទៅទៀតដោយសារពួកគេនឹងត្រូវដាក់ឱ្យស្ថិតនៅក្រោមសំពាធនៃការសងឥណទាន ហើយពួកគេនឹងមានបំណុលដែលពុំធ្លាប់មានពីមុនមក ។ ទុរគតជនអាចត្រូវបានជួយតែតាមរយៈអំណោយឬសេវាមិនបង់ថ្លៃតែប៉ុណ្ណោះដើម្បីទាញពួកគេចេញពីភាពទុរគតហើយជាយថាហេតុ ឈានចូលទៅក្នុងទីផ្សារសម្រាប់សេវាមីក្រូហិរញ្ញវត្ថុ ។

៣.៦៩ ក្នុងបរិបទនេះ បញ្ហាសំខាន់៧មាន ៖

- **យុទ្ធសាស្រ្តផ្តល់មូលនិធិរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ :** គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុត្រូវបន្តអភិវឌ្ឍន៍មូលនិធិពាណិជ្ជកម្មឯករាជ្យពីដៃគូអភិវឌ្ឍន៍អន្តរជាតិ ឬពីធនាគារជាតិនៃកម្ពុជា។ ការបង្កើតប្រព័ន្ធទូទាត់សងប្រាក់ជាតិដុល ទីផ្សារអន្តរធនាគារ និងរូបិយវត្ថុ និងការបន្តធ្វើឱ្យប្រសើរឡើងនូវព័ត៌មានហិរញ្ញវត្ថុ នឹងបំរើដល់ការគាំទ្រដើម្បីអភិវឌ្ឍន៍ចំណងទាក់ទងរវាងធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុតែងតែប្រឈមមុខនឹងហានិភ័យអត្រាប្តូរប្រាក់ ប្រសិនបើមូលនិធិបានមកពីក្រៅប្រទេសកម្ពុជា។ នៅពេលដែលការប្រើប្រាស់ប្រាក់រៀលកើនឡើង ការផ្តល់ឥណទានជាប្រាក់រៀលរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនឹងមានការកើនឡើង ហើយជាថ្មីម្តងទៀតនេះ គូសបញ្ជាក់អំពីតួនាទីរបស់វិស័យធនាគារក្នុងអន្តរការិយកម្ម និងការគ្រប់គ្រងហានិភ័យ។
- **ការទទួលប្រាក់បញ្ញើដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ :** មូលនិធិអាចបានមកពីការទទួលប្រាក់បញ្ញើ ហើយ នេះគូសបញ្ជាក់នូវសារៈសំខាន់នៃបញ្ញត្តិកម្ម និងការត្រួតពិនិត្យសមស្របរបស់ធនាគារជាតិនៃកម្ពុជាទៅលើសកម្មភាពធនាគាររបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ ប្រព័ន្ធបទបញ្ញត្តិគួរមានការជឿនលឿននិងអាចអភិវឌ្ឍន៍ជាលំដាប់តាមស្តង់ដារសមស្របសម្រាប់គ្រឹះស្ថានដែលមានសកម្មភាពខុសគ្នា ហើយដែលផ្តល់នូវក្របខ័ណ្ឌលើកទឹកចិត្ត ដើម្បីគាំទ្រការអភិវឌ្ឍស្ថាប័ន ឧទាហរណ៍ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលបានចុះបញ្ជីអាចឈានទៅជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាបណ្ណ័ទៅជាធនាគារឯកទេស និងទៅជាធនាគារពាណិជ្ជ។
- **ភាពស្មើគ្នាចំពោះបទបញ្ញត្តិ :** គ្រឹះស្ថានផ្សេងទៀតដែលធ្វើអាជីវកម្មមីក្រូហិរញ្ញវត្ថុ ឬអាជីវកម្មធនាគារ ត្រូវបានផ្តល់ដោយស្មើភាពគ្នាចំពោះបទបញ្ញត្តិ ដើម្បីដោះស្រាយហានិភ័យឱ្យបានសមស្រប កាត់បន្ថយការរំលោភបទបញ្ញត្តិ និងផ្តល់នូវទីលានប្រកួតស្មើភាពមួយ។ ឧទាហរណ៍ ទាំងនេះរាប់បញ្ចូលទាំងអាជីវករប្តូរប្រាក់ អ្នកឱ្យខ្ចីចងការ សហករណ៍ឥណទាន និងគ្រឹះស្ថានសង្គហសមាគម ដែលទាំងអស់គ្នា គួរតែបំពេញស្តង់ដារដូចគ្នា ប្រសិនបើប្រកបអាជីវកម្មធនាគារ និងមីក្រូហិរញ្ញវត្ថុ។

## ៣. មីក្រូធានារ៉ាប់រង

៣.៧០ មីក្រូធានារ៉ាប់រងគឺជាឧបករណ៍គ្រប់គ្រងហានិភ័យដ៏សំខាន់មួយសម្រាប់គ្រួសារក្រីក្រ និងមានយុទ្ធសាស្រ្តដោះស្រាយជាច្រើនផ្សេងគ្នា ទូទាំងពិភពលោក ដែលគ្រួសារមានចំណូលទាបប្រើដើម្បីដោះស្រាយវិបត្តិ។ ក៏ប៉ុន្តែ ប្រការដែលគ្រួសារមានចំណូលទាប ជាក់ស្តែង គឺបានដាក់ពួកគេឱ្យស្ថិតនៅក្នុងស្ថានភាពងាយរងគ្រោះខ្ពស់បំផុត។ ដើម្បីលុបបំបាត់ភាពងាយរងគ្រោះនេះ និងដើម្បីកែលំអសមត្ថភាពដោះស្រាយតាមរយៈការផ្តល់បណ្តាញសុវត្ថិភាពបន្ថែម មានតែបង្កើតឱ្យមានផលិតផលមីក្រូធានារ៉ាប់រងដើម្បីបំពេញឱ្យតម្រូវការទីផ្សារ។ មានគំរោងសាកល្បងមួយចំនួនតូចដែលបានបង្កើតឡើងដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលទទួលបានអាជ្ញាប័ណ្ណនៅកម្ពុជា ដើម្បីធ្វើការសាកល្បងពីលទ្ធភាពធានារ៉ាប់រងដែលមានកំណត់ ប៉ុន្តែ ពុំទាន់មានសេចក្តីសន្និដ្ឋានស្តីពីលទ្ធផលនិងសក្តានុពលទៅអនាគតនៅឡើយ។

## ៤. អាទិភាព ២០០៦-២០១៥ : មីក្រូហិរញ្ញវត្ថុ

៣.៧១ ឯកសារយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០៦-២០០១៥ បានកែសម្រួលឡើងវិញនូវការញែកវិស័យនេះ ដែលបានធ្វើឡើងនៅក្នុងចក្ខុវិស័យនិងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០១-២០១០ដោយប្តូរពី "ហិរញ្ញវត្ថុជនបទ" ដើម្បីឱ្យកាន់តែគ្របដណ្តប់ច្រើនជាងមុន និងចាត់ទុកវិស័យនេះជា "មីក្រូហិរញ្ញវត្ថុ" វិញ។ ប្រការ នេះលើកទឹកចិត្តឱ្យមានការបំបែកហានិភ័យ និងកំណើននៃផលិតផលសំបូរបែប ព្រមទាំងកាន់តែរួមបញ្ចូលគ្នា សម្រាប់អ្នកនៅតំបន់ទីក្រុង។ ដូច្នេះ គោលដៅគឺប្រព័ន្ធមីក្រូហិរញ្ញវត្ថុមួយដែលមានប្រសិទ្ធភាព ជួយពលរដ្ឋក្រីក្រ និង អាចដំណើរការបាន ដើម្បីផ្តល់សេវាហិរញ្ញវត្ថុដែលជួយពលរដ្ឋក្រីក្រឱ្យបង្កើនចំណូល និងកាត់បន្ថយភាពក្រីក្រ។

៣.៧២ តាំងពីឆ្នាំ២០០១ វិស័យមីក្រូហិរញ្ញវត្ថុបានបង្ហាញពីថាមភាពគួរឱ្យកត់សម្គាល់ជាមួយនិងលទ្ធផលគួរឱ្យកោតសរសើរនៅក្នុងដំណាក់កាលអភិវឌ្ឍន៍បច្ចុប្បន្ន។ នេះមិនមែនជាចំណែកដ៏តូចនោះទេចំពោះឆន្ទៈរបស់រដ្ឋាភិបាលក្នុងការអនុញ្ញាតិឱ្យធ្វើពាណិជ្ជភាវូបនីយកម្មមីក្រូហិរញ្ញវត្ថុនៅក្នុងប្រទេស ជាមួយនឹងគោលការណ៏វិស័យឯកជនដែលគាំទ្រដោយរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍តាមការចាំបាច់។ ការអភិវឌ្ឍជាបន្តបន្ទាប់នូវបណ្តាញគាំទ្ររបស់រដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ដែលអនុញ្ញាតឱ្យវិស័យឯកជនមានសេរីភាពធ្វើសកម្មភាពក្នុងក្របខ័ណ្ឌច្បាប់និងបទបញ្ញត្តិ នឹងនាំឱ្យមានកំណើនលឿនបន្ថែមទៀត។

៣.៧៣ ចំណងទាក់ទងទៅវិញទៅមក និងសមាហរណកម្មវិស័យមីក្រូហិរញ្ញវត្ថុជាមួយវិស័យធនាគារពាណិជ្ជ នៅតែជាអាទិភាពចំបងមួយ។ នាពេលអនាគត វិស័យធនាគារជាប្រភពសាច់ប្រាក់ងាយស្រួលដ៏ធំទូលំទូលាយ ដែលអាចទុកចិត្តបានតែមួយគត់ ដែលអាចបំពេញតម្រូវការរបស់វិស័យមីក្រូហិរញ្ញវត្ថុបាន។ លើសពីនេះ មានការទាក់ទាញ អាជីវកម្មសុះសាយសម្រាប់វិស័យធនាគារ។ អតិថិជនដែលមានជោគជ័យធំៗក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ជាយថាហេតុ នឹងក្លាយជាអតិថិជនរបស់ធនាគារ។

៣.៧៤ ការអភិវឌ្ឍទៅអនាគតរបស់វិស័យមីក្រូហិរញ្ញវត្ថុ គួរយកចិត្តទុកដាក់ទៅលើកម្រិតចំនួន ៣ : កម្រិតម៉ាក្រូ កម្រិតមេសូ និងកម្រិតមីក្រូ។ លើសពីនេះ ការអភិវឌ្ឍមិនគួរកំណត់ពេល ឬដាក់កំហិតពេលនោះទេ ប៉ុន្តែគួរកំណត់អាទិភាព និងកំណត់លំដាប់លំដោយផ្អែកលើផលប៉ះពាល់ដែលនឹងអាចកើតមាន និងសមត្ថភាពដែលអាចស្រូបយកបាន។

៣.៧៥ **កម្រិតម៉ាក្រូ** (រដ្ឋាភិបាល និងអាជ្ញាធរបញ្ញត្តិកម្ម)

- គាំទ្រការអភិវឌ្ឍសមត្ថភាពជាបន្តនៅធនាគារជាតិនៃកម្ពុជា សម្រាប់បញ្ញត្តិកម្ម និងការត្រួតពិនិត្យវិស័យមីក្រូហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាព ដែលនៅពេលជាមួយគ្នានោះ ត្រូវប្រាកដថា រាល់គ្រឹះស្ថានដែលទទួលប្រាក់បញ្ញើត្រូវនៅក្រោមបទបញ្ញត្តិ និងការត្រួតពិនិត្យតាមកម្រិត ដោយផ្អែកលើទំហំ និងលក្ខណៈស្មុគស្មាញនៃសកម្មភាព។
- ចាំបាច់ត្រូវមានកិច្ចព្រមព្រៀងស្តីពីស្តង់ដាររបាយការណ៏រួម ដើម្បីបង្កើតឱ្យមានការវិភាគដំណើរការហិរញ្ញវត្ថុដ៏រឹងមាំ និងអាចគាំទ្រដល់កំណើនរបស់វិស័យនេះ ព្រមទាំងផ្តល់ព័ត៌មានដល់សាធារណជន តាមរយៈព្រឹត្តិប័ត្រប្រចាំខែ។

- សិក្សាអំពីហានិភ័យជារចនាសម្ព័ន្ធដែលផ្សារភ្ជាប់ជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អំពីអភិបាលកិច្ច កម្មសិទ្ធិភាព និងទំហំតូចនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួន ដើម្បីព្យាយាមដោះស្រាយចំណុចខ្សោយដែលមាន ។
- សម្គាល់អត្តសញ្ញាណ និងកំណត់ទីផ្សារមីក្រូហិរញ្ញវត្ថុទូទាំងប្រទេសកម្ពុជា ហើយនេះជាផ្នែកមួយដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរផ្តល់ការគាំទ្រដ៏សំខាន់នេះ ។ មានតម្រូវការដែលត្រូវធ្វើឱ្យប្រសើរឡើងនូវការវិភាគស្ថិតិ និងនិយមន័យនៃទីផ្សារតាមភូមិសាស្ត្រនិងតំបន់ ជាទំហំ និងជាវិសាលភាព ។ ក៏មាន តម្រូវការផងដែរក្នុងការកំណត់ និងបរិយាយអំពីវិសាលភាពនៃជំរើសប្រភពផ្តល់ហិរញ្ញប្បទាននៅក្នុងស្រុក ( អ្នកឱ្យខ្ចីចងការ គ្រួសារ មិត្តភ័ក្ត្រ ធនាគារភូមិ សហករណ៍ ។ល ។) ។ ប្រការនេះនឹងផ្តល់ព័ត៌មានដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងផ្តល់ជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍផលិតផលសម្រាប់គោលនយោបាយ និងសម្រាប់រដ្ឋាភិបាល នូវអត្តសញ្ញាណប្រកបដោយសក្តានុពលនៃការលើកទឹកចិត្ត ដើម្បីជម្រុញឱ្យមានការអភិវឌ្ឍ ព្រមទាំងការត្រួតពិនិត្យ និងបទបញ្ញត្តិមួយសមស្រប ។
- ការបង្កើតលទ្ធភាពទ្រទ្រង់ទម្រង់ផ្សេងទៀតនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដូចជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផ្អែកលើសហគមន៍ និងមិនបានចុះបញ្ជី ។ល ។ ដើម្បីពង្រីកនូវប្រភេទតម្រូវការដែលគ្រឹះស្ថាននឹងជួបប្រទះ និងបង្កើតនូវប្រភេទផ្សេងៗទៀត និងភាពទន់ភ្លន់នៅក្នុងប្រព័ន្ធមីក្រូហិរញ្ញវត្ថុកាន់តែទូលាយឡើង ។

## ៣.៧៦ **កម្រិតមេសូ** ( កម្រិតគាំទ្របច្ចេកទេស)

- បង្កើតសេវាបណ្តុះបណ្តាលដែលអាចផ្តល់ការបណ្តុះបណ្តាលជាទ្រឹស្តី និងការអនុវត្តន៍ការងារជាក់ស្តែង សម្រាប់គ្រប់កម្រិតក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ។ សេវាបណ្តុះបណ្តាលគួរបញ្ចូលនូវក្រុមប្រឹក្សាភិបាលមួយសម្រាប់ការកសាងសមត្ថភាពមីក្រូហិរញ្ញវត្ថុ រួមបញ្ចូលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទាំងមានអាជ្ញាប័ណ្ណ និងបានចុះបញ្ជី ដើម្បីបំពេញតម្រូវការរបស់វិស័យនេះ ។ វគ្គបណ្តុះបណ្តាលជាទ្រឹស្តី និងការអភិវឌ្ឍ សមត្ថភាព ដើម្បីគាំទ្រការបង្កើតប្រព័ន្ធគ្រប់គ្រងការបណ្តុះបណ្តាលលើការងារជាក់ស្តែងដ៏មាន ប្រសិទ្ធភាពមួយនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនិងគ្រឹះស្ថានផ្សេងទៀតនឹងត្រូវបង្កើតឱ្យមានឡើង ។ទាំងនេះនឹងរួមបញ្ចូលការបណ្តុះបណ្តាលគ្រូ ការវិភាគមុខងារ ការវាយតម្លៃពីតម្រូវការ ការធ្វើផែនការបណ្តុះបណ្តាល ការធ្វើផែនការថវិកានិងការប្រគល់ការងារ វិធីសាស្ត្រនៃការវាយតម្លៃ ការបណ្តុះបណ្តាលអ្នកគ្រប់គ្រងស្នង និងប្រព័ន្ធកត់ត្រាការបណ្តុះបណ្តាល ។ សេវាបណ្តុះបណ្តាលអាចប្រព្រឹត្តទៅ ជាផ្នែកដ៏សំខាន់មួយដែលឆ្លើយតបនឹងតម្រូវការរបស់វិស័យមីក្រូហិរញ្ញវត្ថុ ហើយទ្រទ្រង់ដោយមូលនិធិ បានមកពីការកំណត់ថ្លៃសេវាដែលមាននិរន្តភាព ។
- លើកកម្ពស់ប្រព័ន្ធគ្រប់គ្រងដោយព័ត៌មានវិទ្យាសម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។ គុណភាពនៃកម្មវិធីសូហ្វវែរ និងប្រព័ន្ធមានការប្រែប្រួលយ៉ាងខ្លាំងនៅពេលបច្ចុប្បន្ន ដែលនាំឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយ ចំនួនមិនអាចចូលទៅក្នុងប្រព័ន្ធឥណទាន និងគណនេយ្យដែលអាចធ្វើសមាហរណកម្មបាន ខណៈដែលគ្រឹះស្ថានផ្សេងទៀតមានប្រព័ន្ធដែលមានតម្លៃខ្ពស់ និងមានប្រសិទ្ធភាព ។ ស្តង់ដារអប្បបរមាសម្រាប់ប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យានៅកម្ពុជា ចាំបាច់ត្រូវបានបង្កើតឡើង ជាពិសេស នៅពេលដែលស្តង់ដារ របាយការណ៍រួមដែលកែលំអរួចស្រេចត្រូវបានដាក់ឱ្យប្រើប្រាស់ ។ ប្រការនេះអាចទាមទារ

ឱ្យមានការកាន់កាប់អាជ្ញាប័ណ្ណថ្នាក់ជាតិដោយអង្គការកម្រិតម៉ាក្រូ ឬមេសូ តំណាងឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្នុងគោលបំណងធានាពីគុណភាពអប្បបរមានៃការគាំទ្រដល់អង្គការទាំងនេះ។

- បង្កើតឱ្យមានទីផ្សារលក់ដុំសម្រាប់ការផ្តល់ហិរញ្ញប្បទានឥណទាន ដែលធ្វើប្រតិបត្តិការនៅក្នុងវិស័យឯកជន និងភ្ជាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាមួយវិស័យធនាគារពាណិជ្ជ។ បច្ចុប្បន្ននេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានការលំបាកក្នុងការខ្ចីឥណទានជាប្រាក់រៀល។ ប្រព័ន្ធទូទាត់សងប្រាក់ជាតិដុលមួយ និង ទីផ្សាររូបិយវត្ថុនិងអន្តរធនាគារ មិនត្រឹមតែភ្ជាប់ទំនាក់ទំនងរវាងវិស័យធនាគារនិងមីក្រូហិរញ្ញវត្ថុតែប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងផ្តល់លទ្ធភាពក្នុងការផ្តល់ឥណទានបត់បែនតាមប្រភេទរូបិយប័ណ្ណផងដែរ (សូមមើលហិរញ្ញវត្ថុមិនមែនធនាគារ ទីផ្សាររូបិយវត្ថុ ជំពូកទី ៤)។ លើសពីនេះ ការភ្ជាប់ទំនាក់ទំនងគួរត្រូវបានពង្រីកទៅតាមវិធានការដែលអាចឱ្យធនាគារទទួលបានបទពិសោធន៍ក្នុងការផ្តល់ឥណទាន និងការធ្វើការងារជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ ទាំងនេះទាមទារនូវវត្ថុធានាជាមូលដ្ឋានតិចតួច ចំពោះការផ្តល់ឥណទាន និងបង្កើតឱ្យមានការគិតទៅលើការវិភាគគណនីនិងលំហូរសាច់ប្រាក់កាន់តែច្រើនឡើង។ សក្តានុពលសម្រាប់វិធានការធានាជំនួសដើម្បីឱ្យបទពិសោធន៍នេះទទួលបានផល នឹងត្រូវ យកមកពិចារណា។
- ការបង្កើតសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និងការទទួលស្គាល់ជាផ្លូវការនាពេលថ្មីៗនេះដែលទទួលបានការស្វាគមន៍ បានផ្តល់នូវឱកាសសម្រាប់ការតំណាងក្នុងវិស័យនេះ។ សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជាអាចធ្វើសហការប្រតិបត្តិការជាមួយគណៈកម្មាធិការអភិវឌ្ឍន៍ឥណទានជនបទ ដើម្បីបង្កើតនិងផ្សព្វផ្សាយ ជំរើសគោលនយោបាយដែលបានកែលំអ ដើម្បីកែលំអការផ្លាស់ប្តូរយោបល់ ការជួយការពារ ការស្រាវជ្រាវ និងការផ្លាស់ប្តូរព័ត៌មាន។ តួនាទីរបស់សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជានៅអនាគតត្រូវពិនិត្យមើលឡើងវិញនូវទិដ្ឋភាពច្បាប់ និងបទបញ្ញត្តិរបស់វិស័យនេះ។
- ការកសាងសមត្ថភាពចំណាត់ថ្នាក់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងស្រុក ដោយផ្អែកលើការគាំទ្រចំណាត់ថ្នាក់ ផ្នែកពាណិជ្ជកម្មនិងផ្សារភ្ជាប់ផងដែរជាមួយការផ្លាស់ប្តូរព័ត៌មានឥណទាន។ ការផ្លាស់ប្តូរព័ត៌មានគួរបញ្ចូលទាំងព័ត៌មានវិជ្ជមាន និងអវិជ្ជមាន។ ប្រសិនបើអតិថិជនឈានចូលទៅក្នុងប្រព័ន្ធធនាគារពាណិជ្ជ ពួកគេត្រូវតែមានប្រវត្តិឥណទានល្អ។ ប្រព័ន្ធព័ត៌មានឥណទានកម្ពុជាដែលត្រូវបានបង្កើតឡើងសម្រាប់ធនាគារពាណិជ្ជ អាចពង្រីកដល់វិស័យមីក្រូហិរញ្ញវត្ថុផងដែរ។
- ទ្រទ្រង់ការអភិវឌ្ឍជាបន្តនូវការចូលទុន និងវិនិយោគជាហ៊ុនពីអ្នកវិនិយោគក្នុងស្រុកនិងបរទេស ចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

## ៣.៧៧ កម្រិតមីក្រូ (រាយ)

- គាំទ្រដល់ការពង្រឹងគ្រឹះស្ថានរាយ ជាពិសេសគ្រឹះស្ថានដែលស្ថិតក្រោមកម្រិតគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណ។
- ផ្អែកលើការស្រាវជ្រាវ និងការវិភាគស្ថិតិដែលបានធ្វើឡើងនៅកម្រិតម៉ាក្រូ តម្រូវការអាចកើតមានឡើងដើម្បីជួយដល់ប្រភេទគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផ្សេងទៀត ដូចជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផ្អែកលើសហគមន៍និងមិនបានចុះបញ្ជី។ល។ និងដើម្បីធានាថា នៅពេលដែលតម្រូវការត្រូវបានបំពេញដោយគ្រឹះស្ថានពិសេសនោះ តម្រូវការនោះនឹងបន្តទៀត។ នៅពេលដែលមានប្រភេទច្រើនបែបនៃគ្រឹះស្ថាន នៅក្នុងប្រព័ន្ធកាន់តែច្រើនឡើងប្រព័ន្ធនោះនឹងកាន់តែខ្លាំងក្លាឡើង។

- ការផ្សារភ្ជាប់បន្ថែមគួរត្រូវបានបង្កើតឡើងរវាងអង្គការមិនមែនរដ្ឋាភិបាលដែលជាប់ទាក់ទងនឹងទុគតជន និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ ប្រការនេះនឹងអាចឱ្យទុរគតជនដែលនឹងក្លាយទៅជាមិនមែនទុរគតជន តាមរយៈការគាំទ្ររបស់អង្គការក្រៅរដ្ឋាភិបាល មានភាពងាយស្រួលចូលទៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ។

# វិស័យហិរញ្ញវត្ថុ មិនមែនធនាគារ

## ជំពូកទី ៤

# វិស័យហិរញ្ញវត្ថុមិនមែនធនាគារ



៤.០១ នៅប្រទេសកម្ពុជា ហិរញ្ញវត្ថុមិនមែនធនាគារនាពេលបច្ចុប្បន្ននៅមានកម្រិតត្រឹមវិស័យធានារ៉ាប់រង (មីក្រូហិរញ្ញវត្ថុ អ្នកឱ្យប្រាក់ខ្ចី អ្នកប្តូរប្រាក់ ការឱ្យខ្ចីមិនផ្លូវការ ត្រូវបានពិចារណានៅក្នុងជំពូកទី ៣ ស្តីពីមីក្រូហិរញ្ញវត្ថុ និងធនាគារ ដោយសារសកម្មភាពរបស់វាដូចធនាគារ)។ ទន្ទឹមជាមួយនឹងការអនុមតិច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្ម និងវិជ្ជាជីវៈគណនេយ្យ និងច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាននិងប្រតិបត្តិការទូទាត់សងប្រាក់ ទិដ្ឋភាពមួយចំនួននៃទីផ្សារហិរញ្ញវត្ថុអាចចាប់ផ្តើមបង្កើតឡើងបាន។ ជាងនេះទៀត ជាមួយការអនុមតិច្បាប់ស្តីពីមូលប័ត្ររដ្ឋ និងការអនុមតិនាពេលឆាប់ៗនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរ មូលប័ត្រមហាជន ច្បាប់ស្តីពីប្រតិបត្តិការមានកិច្ចធានា និងច្បាប់ស្តីពីភតិសន្យា រួមជាមួយការបង្កើតនូវការចុះបញ្ជីប្រតិបត្តិការមានកិច្ចធានា និងសកម្មភាពភតិសន្យា សកម្មភាពហិរញ្ញវត្ថុមិនមែនធនាគារផ្សេងទៀតទំនងជាត្រូវបានបង្កើតឡើងនាពេលអនាគតឆាប់ៗផងដែរ។

## ក. វិស័យធានារ៉ាប់រង

៤.០២ វិស័យធានារ៉ាប់រងឯកជននៅក្នុងប្រទេសមួយ អាចដើរតួនាទីយ៉ាងសំខាន់នៅក្នុងសរសៃឈាមសេដ្ឋកិច្ចប្រទេសនោះ។ ក្រុមហ៊ុនធានារ៉ាប់រងអាចជួយគ្រប់គ្រងហានិភ័យឱ្យអាជីវកម្ម។ អាស្រ័យតាមកម្រិតដែលសហគ្រិនម្នាក់អាចផ្ទេរទៅឱ្យក្រុមហ៊ុនធានារ៉ាប់រងនូវហានិភ័យទាំងឡាយ ដែលខ្លួនមិនអាចគ្រប់គ្រងដោយផ្ទាល់ សហគ្រិននោះ ជាបន្ត អាចត្រៀមធនធានដែលទំនេរសម្រាប់ដោះស្រាយជាមួយនិងហានិភ័យពាណិជ្ជកម្មដែលខ្លួនអាចដឹងប្រសើរជាង។ នៅក្នុងដំណាក់កាលដំបូង ធានារ៉ាប់រងគឺអាជីវកម្មលំហូរសាច់ប្រាក់មួយជាមួយនិងការបង្ករទុនមានកម្រិត។ ភាគច្រើននៃបុព្វលាភដែលទទួលបានពីអតិថិជនត្រូវបានប្រើចំណាយលើការទាមទារទូទាត់សងការខូចខាត និងចំណាយរដ្ឋបាលផ្សេងៗ។ ក៏ប៉ុន្តែ កាតព្វកិច្ចសងបំណុលមួយចំនួនច្បាស់ជាកើតមានឡើង ដែលទាមទារឱ្យមានការបង្កើតទុនបំរុង ឬសវិធានធនសម្រាប់ធ្វើការទូទាត់សងនៅឆ្នាំខាងមុខ។ កាតព្វកិច្ចបែបនេះកើតឡើងជាមួយការទាមទារសំណងសម្រាប់តាវកាលិកពីពិការភាព ហើយស្ថិតនៅក្រោមកិច្ចសន្យាធានារ៉ាប់រងអាយុជីវិតដែលជាធម្មតាមានរយៈកាលវែង។ ក្នុងការគាំទ្រកាតព្វកិច្ចទាំងនេះ ក្រុមហ៊ុនធានារ៉ាប់រងនឹងដើរតួនាទីជាគ្រឹះស្ថានវិនិយោគ ដូច្នេះហើយ ក្រុមហ៊ុនទាំងនេះអាចក្លាយជាឧបករណ៍នៃការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុ។

៤.០៣ ដំណើរការអភិវឌ្ឍន៍វិស័យធានារ៉ាប់រងនៅក្នុងសេដ្ឋកិច្ចទីផ្សារកំពុងវិវឌ្ឍតាមគន្លងមួយ ដែលអាចរំពឹងទុកជាមុន ហើយជាធម្មតា ដំណើរការនេះចាប់ផ្តើមជាមួយការចូលរួមពីសាធារណជននៅក្នុងកាតព្វកិច្ចធានារ៉ាប់រងតាមប្រភេទមួយចំនួន ដូចជាការធានារ៉ាប់រងកាតព្វកិច្ចលើតតិយជនសម្រាប់អ្នកប្រើប្រាស់យានយន្ត។ ការធានារ៉ាប់រងប្រភេទនេះគឺមានកាតព្វកិច្ចការពារជនរងគ្រោះស្លូតត្រង់ដែលអាចទទួលរងរបួស ឬខូចខាត ដែលបង្កឡើងដោយគ្រោះថ្នាក់។ ជំហានបន្ទាប់ កើតឡើងនៅពេលដែលគ្រឹះស្ថានផ្តល់ឥណទាន ដូចជាធនាគារ ចាប់ផ្តើមតម្រូវឱ្យមានវត្ថុបញ្ចាំសម្រាប់ខ្ចីប្រាក់ត្រូវឱ្យមានការធានារ៉ាប់រង។ ជំហានដែលទាក់ទិនមួយទៀត គឺតម្រូវឱ្យមានការធានារ៉ាប់រងអាយុជីវិត និងសុខភាពរបស់អ្នកខ្ចីប្រាក់។

៤.០៤ ជាទូទៅ ការលក់ធានារ៉ាប់រងអាយុជីវិតបានចាប់ផ្តើមនៅពេលដែលនិយោជកផ្តល់ដល់និយោជិតរបស់ខ្លួននូវកញ្ចប់ផលប្រយោជន៍មួយដែលអាចរាប់បញ្ចូលផលប្រយោជន៍សម្រាប់មរណភាពដល់សមាជិកគ្រួសារដែលនៅរស់ ក្នុងករណីដែលនិយោជិតទទួលមរណភាពមុនចូលនិវត្តន៍។ កំលាំងជម្រុញដ៏សំខាន់សម្រាប់កំណើនមុខរបរធានារ៉ាប់រងអាយុជីវិត ជារឿយៗ កើតឡើងនៅពេលដែលនិយោជក ឬរដ្ឋាភិបាល បង្កើតកម្មវិធីក្នុងការផ្តល់ប្រាក់ចំណូលសោធននិវត្តន៍ដល់បុគ្គលិក។ ការធានារ៉ាប់រងអាយុជីវិតក្នុងកាលៈទេសៈដូចនេះ ជារឿយៗ ដើរតួនាទីជាការធានាទ្រទ្រង់ក្នុងករណីដែលបុគ្គលិកម្នាក់មិននៅរស់រហូតដល់ចូលនិវត្តន៍ ទោះបីក្នុងករណីខ្លះ ការធានារ៉ាប់រងអាយុជីវិតនេះ អាចត្រូវប្រើជាមធ្យោបាយផ្តល់មូលនិធិសម្រាប់ផលប្រយោជន៍នៃសោធននិវត្តន៍ក៏ដោយ។

៤.០៥ ខណៈដែលសេវាធានារ៉ាប់រងដំបូង ហាក់ដូចជាមានទំនាក់ទំនងជាមួយការធានាជាកាតព្វកិច្ច វិស័យធានារ៉ាប់រងមិនមានការរីកចំរើនខ្លាំងទេ រហូតដល់ពេលមួយដែលមានការទិញធានារ៉ាប់រងដោយស្ម័គ្រចិត្តចាប់ផ្តើម។ ការបង្គរទ្រព្យសម្បត្តិក្រោមប័ណ្ណសន្យារ៉ាប់រងអាយុជីវិត អាចទទួលនូវសមាមាត្រច្រើនបានតែនៅពេលដែលអតិថិជនចាប់ផ្តើមឱ្យតម្លៃខ្ពស់ទៅលើអត្ថប្រយោជន៍វានៅក្នុងផែនការហិរញ្ញវត្ថុផ្ទាល់ខ្លួន ការសន្សំសម្រាប់ការចូលនិវត្តន៍ ឬសម្រាប់សេចក្តីត្រូវការរបស់គ្រួសារ ដូចជាការសិក្សារបស់កូនជាដើម[១០] ។ កំណើននៅក្នុងវិស័យធានារ៉ាប់រងគឺអាស្រ័យដោយមានការសម្រេចចិត្តលើចំណូលនៅសល់ពីការប្រើប្រាស់ និងជំរើសផ្ទាល់ខ្លួន។

៤.០៦ កត្តាមួយចំនួនជួយឱ្យមានជំនឿទុកចិត្តពីអតិថិជនមកលើសេវាធានារ៉ាប់រង។ កត្តាទី១ដែលសំខាន់បំផុតនោះ គឺចាំបាច់ឱ្យមានការយល់ដឹងរបស់សាធារណជនមកលើអាជីវកម្មធានារ៉ាប់រង និងសេវាដែលអាចផ្តល់ជូនបាន។ វាជាការសំខាន់ផងដែរដែលអាជីវកម្មធានារ៉ាប់រងត្រូវប្រព្រឹត្តទៅក្នុងលក្ខណៈតម្លាភាព តាមដែលអាចធ្វើទៅបាន។ រាល់ការទាមទារសំណងរបស់អ្នកទិញប័ណ្ណសន្យារ៉ាប់រងត្រូវតែបានដោះស្រាយឱ្យបានឆាប់រហ័សដោយក្រុមហ៊ុនពាក់ព័ន្ធ។ ជានិច្ចកាល ការទូទាត់សំណងត្រូវធ្វើឱ្យស្របតាមលក្ខខណ្ឌដែលមានក្នុងប័ណ្ណសន្យារ៉ាប់រង ប៉ុន្តែក៏ត្រូវពិនិត្យមើលពីភាពត្រឹមត្រូវ និងសមហេតុផលក្នុងរាល់កាលៈទេសៈផងដែរ។ ជារឿយៗ ត្រូវបានគេនិយាយថា នាយកដ្ឋានទូទាត់សំណងនៃក្រុមហ៊ុនធានារ៉ាប់រង គឺជានាយកដ្ឋានទំនាក់ទំនងសាធារណៈរបស់ក្រុមហ៊ុននោះ។

៤.០៧ រដ្ឋាភិបាលអាចចូលរួមចំណែកដល់ការអភិវឌ្ឍវិស័យធានារ៉ាប់រងតាមរយៈ ៖

- ការបង្កើតឱ្យមានប្រព័ន្ធបទបញ្ញត្តិធានារ៉ាប់រងមួយ ដែលធានាថាមានតែក្រុមហ៊ុនធានារ៉ាប់រងដែលមានហិរញ្ញវត្ថុរឹងមាំ និងមានការគ្រប់គ្រងដោយប្រុងប្រយ័ត្នទេ ដែលត្រូវបានប្រគល់សិទ្ធិឱ្យផ្តល់នូវសេវាធានារ៉ាប់រង។
- អនុវត្តប្រព័ន្ធត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព និងជោគជ័យ ដើម្បីធានាការឃ្លាំមើលជានិច្ចកាលនូវភាពខ្លាំងផ្នែកហិរញ្ញវត្ថុ និងការប្រព្រឹត្តិផ្នែកទីផ្សាររបស់ក្រុមហ៊ុន។

[១០] *មានទ្រព្យសកម្មបង្គរតិចក្នុងការទ្រទ្រង់វិស័យធានារ៉ាប់រងអាយុជីវិតសំរាប់ក្រុមនិយោជិត ឬតាមរយៈការលក់ប័ណ្ណសន្យារ៉ាប់រងជីវិតរយៈពេលខ្លី។*

- ផ្តល់អំណាចឱ្យអ្នកត្រួតពិនិត្យនូវរាល់ឧបករណ៍ និងសិទ្ធិអំណាចដែលចាំបាច់ ដើម្បីដោះស្រាយស្ថានភាពដែលមិនគោរពតាមបទបញ្ញត្តិ និងតម្រូវឱ្យអនុវត្តវិធានទាំងនោះក្នុងទីផ្សារធានារ៉ាប់រង។
- ធានាថាបទបញ្ញត្តិដែលកំពុងអនុវត្តចំពោះប្រតិបត្តិការរបស់ក្រុមហ៊ុនធានារ៉ាប់រង ដូចជាបទបញ្ញត្តិគ្រប់គ្រងលើសិទ្ធិនៃការវិនិយោគរបស់ក្រុមហ៊ុនទាំងនោះមិនត្រូវបានរឹតត្បិតដោយមិនសមហេតុផល ស្តង់ដារដូចគ្នានេះនឹងត្រូវអនុវត្តចំពោះគ្រប់ក្រុមហ៊ុនទាំងអស់នៅក្នុងទីផ្សារធានារ៉ាប់រង។
- ផ្តល់ការការពារចំពោះហានិភ័យជាប្រព័ន្ធ។ នៅពេលដែលក្រុមហ៊ុនធានារ៉ាប់រងមួយក្ស័យធន រដ្ឋាភិបាលត្រូវចាត់វិធានការដ៏សមស្រប ដើម្បីការពារផលប្រយោជន៍របស់អ្នកកាន់ប័ណ្ណសន្យារ៉ាប់រង។
- លើកកម្ពស់ការយល់ដឹងចំពោះសាធារណជនអំពីការធានារ៉ាប់រង។
- ផ្តល់ការបណ្តុះបណ្តាលដើម្បីបង្កើនវិជ្ជាជីវៈដល់អ្នកជំនាញខាងធានារ៉ាប់រង។
- ការពារអតិថិជន ដោយលើកទឹកចិត្តតាមការតម្រូវឱ្យបើកចំហព័ត៌មានដែលធានាថា ព័ត៌មានដែលផ្តល់ដោយក្រុមហ៊ុនធានារ៉ាប់រង គឺមានភាពត្រឹមត្រូវ។

៤.០៨ ដូចដែលបានរៀបរាប់ខាងលើ ប័ណ្ណសន្យារ៉ាប់រងអាយុជីវិតគឺជាកិច្ចសន្យារយៈកាលវែង។ ការអភិវឌ្ឍទីផ្សារធានារ៉ាប់រងអាយុជីវិតដ៏រឹងមាំ តម្រូវឱ្យមាន៖

- ការប្រព្រឹត្តទៅនៃទីផ្សារហិរញ្ញវត្ថុដែលផ្តល់ឱកាសវិនិយោគដ៏រឹងមាំ។ កង្វះទីផ្សារក្នុងស្រុកសម្រាប់ឱកាសវិនិយោគអាចត្រូវបានកាត់បន្ថយតាមរយៈការវិនិយោគអន្តរជាតិ ហើយជាក់ស្តែង ទោះបីជាទីផ្សារក្នុងស្រុកមានប្រសិទ្ធភាពក៏ដោយ ការវិនិយោគអន្តរជាតិនេះចាំបាច់ត្រូវតែមានដើម្បីឱ្យមានពិពិធកម្ម។
- ប្រព័ន្ធគណនេយ្យដែលមានតម្លាភាពពេញលេញ
- ភាសាគោលនយោបាយច្បាស់លាស់ដែលត្រូវបានទទួលយក ដោយឯកភាពជាមួយការយល់ដឹងគ្រប់គ្រាន់របស់សាធារណជន។
- ការយកពន្ធសមរម្យលើការសន្សំតាមរយៈការធានារ៉ាប់រងអាយុជីវិត
- លក្ខខណ្ឌនៃប័ណ្ណសន្យារ៉ាប់រងនិងតម្លៃ ត្រូវបានគាំទ្រដោយការផ្តល់យោបល់លើផ្នែកគណនាតម្លៃហានិភ័យដែលមានការគិតគូរដ៏ត្រឹមត្រូវ។

## ១. សមិទ្ធផល និងការរីកចំរើនពីឆ្នាំ២០០១

៤.០៩ ចាប់តាំងពីឆ្នាំនៃការអនុមតិឯកសារចក្ខុវិស័យនិងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០០១-២០១០ មក មានការរីកចំរើនជាច្រើនក្នុងការអភិវឌ្ឍក្របខ័ណ្ឌបទបញ្ញត្តិ និងច្បាប់សម្រាប់វិស័យធានារ៉ាប់រង។ ក៏ប៉ុន្តែ ការរីកចំរើននៅក្នុងវិស័យធានារ៉ាប់រងនៅមានកម្រិតតិចតួច ហើយតម្រូវឱ្យមានសកម្មភាពបន្ថែមប្រសិនបើចង់ឈានដល់កម្រិតសក្តានុពល។

៤.១០ នៅឆ្នាំ២០០១ មានក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជា "កាមិនកូ" របស់រដ្ឋតែមួយគត់ ដែលបានធ្វើប្រតិបត្តិការផ្តាច់មុខនៅប្រទេសកម្ពុជា។ បច្ចុប្បន្ន មានក្រុមហ៊ុនធានារ៉ាប់រងឯកជនចំនួនពីរ ដែលផ្តល់សេវាធានារ៉ាប់រងលើគ្រោះថ្នាក់ និងការ

បាត់បង់ទ្រព្យសម្បត្តិនៅកម្ពុជា ក្រៅពីក្រុមហ៊ុនកាមិនកូ។ ក្រុមហ៊ុនឯកជនមួយទៀតបានធ្វើប្រតិបត្តិការរហូតដល់ឆ្នាំ២០០៤ ប៉ុន្តែត្រូវបានជំរះបញ្ជីនៅពេលដែលក្រុមហ៊ុនជួបប្រទះការលំបាកផ្នែកហិរញ្ញវត្ថុ។ ក្រុមហ៊ុនកាមិនកូកំពុងស្ថិតក្នុងដំណើរការធ្វើឯកជនភាវូបនីយកម្ម។

៤.១១ បន្ថែមពីលើនេះ ក្រុមហ៊ុនធានារ៉ាប់រងបន្តក្នុងស្រុកមួយឈ្មោះ កម្ពុជា រី ត្រូវបានបង្កើតឡើង។ ត្បិតក្រុមហ៊ុននេះពីដំបូងត្រូវរៀបចំជាក្រុមហ៊ុនរដ្ឋមួយ ប៉ុន្តែបច្ចុប្បន្ន អ្នកវិនិយោគឯកជនមួយចំនួនបានកាន់កាប់ភាគហ៊ុនមួយភាគធំនៅក្រុមហ៊ុនធានារ៉ាប់រងបន្តនេះ។ ក្រុមហ៊ុនកម្ពុជា រី ទទួលផលប្រយោជន៍ពីលក្ខខណ្ឌតម្រូវដែលមានចែងក្នុង បទបញ្ញត្តិដែលតម្រូវឱ្យក្រុមហ៊ុនធានារ៉ាប់រងដែលមានអាជ្ញាប័ណ្ណទាំងឡាយត្រូវធ្វើការធានារ៉ាប់រងបន្ត ២០ ភាគរយ នៃបុព្វលាភរបស់ខ្លួន ឱ្យទៅក្រុមហ៊ុនកម្ពុជា រី។

៤.១២ គិតមកត្រឹមខែឧសភា ឆ្នាំ២០០៦នេះ រដ្ឋាភិបាលកម្ពុជាបានប្រកាសអំពីភាពជាដៃគូរវាងឯកជននិងសាធារណៈជាមួយក្រុមហ៊ុនធានារ៉ាប់រងបរទេសចំនួនបួន ដើម្បីបង្កើតក្រុមហ៊ុនចំរុះមួយ ដែលនឹងត្រួតពិនិត្យមើលឡើងវិញនូវលទ្ធភាពទៅអនាគត នូវការធានារ៉ាប់រងអាយុជីវិត។ គំរោងនេះទាក់ទិននឹងការសិក្សាក្នុងរយៈពេល១ឆ្នាំ ពីលទ្ធភាពដែលអាចអនុវត្តបានមុនពេលដែលការលក់សេវាធានារ៉ាប់រងត្រូវបានពិចារណា។

៤.១៣ បុព្វលាភសរុបសម្រាប់ទីផ្សារធានារ៉ាប់រងនៅកម្ពុជាមានប្រមាណ ១១ លានដុល្លារអាមេរិក។ ចំនួននេះតំណាងឱ្យបុព្វលាភដុលផ្ទាល់ មុននឹងធ្វើការធានារ៉ាប់រងបន្ត។ ដោយសារទំហំទីផ្សារក្នុងស្រុកតូច និងមូលដ្ឋានដើមទុនមានកម្រិត សេវាធានារ៉ាប់រងជាច្រើននៅកម្ពុជាត្រូវបានធ្វើការធានារ៉ាប់រងបន្ត ដើម្បីធានាថា ហានិភ័យនិមួយៗដែលក្រុមហ៊ុនបានរក្សាទុក មិនច្រើនជ្រុល បើធៀបនិងដើមទុនផ្ទាល់របស់ក្រុមហ៊ុននិមួយៗ[១១] ។

៤.១៤ ចក្ខុវិស័យនិងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០០១-២០១០ ផ្តោតលើទិដ្ឋភាពដូចខាងក្រោម៖

- ការត្រួតពិនិត្យ និងបទបញ្ញត្តិ
- ការធានារ៉ាប់រងជាកាតព្វកិច្ច
- ការរៀបចំវិស័យធានារ៉ាប់រង
- ការកសាងសមត្ថភាព និង
- ប្រព័ន្ធសោធននិវត្តន៍។

## *១.១ ការត្រួតពិនិត្យ និងបទបញ្ញត្តិ*

៤.១៥ ច្បាប់ស្តីពីការធានារ៉ាប់រងត្រូវបានអនុម័តនៅឆ្នាំ២០០០ ហើយបទបញ្ញត្តិចាំបាច់សម្រាប់ការអនុវត្តន៍ច្បាប់នេះត្រូវបានអនុម័តនៅក្នុងឆ្នាំ២០០១។ ជាងនេះទៀត ការបញ្ជាក់បន្ថែមសម្រាប់ក្របខ័ណ្ឌបទបញ្ញត្តិ កំពុងត្រូវបានផ្តល់ តាមរយៈការចេញ

[១១] *ការអនុវត្តន៍ដ៏ល្អរបស់អន្តរជាតិនាពេលបច្ចុប្បន្នគឺដើម្បីធានាថាហានិភ័យចំពោះឯកត្តជនកម្រិតមិនឱ្យលើសពី១០% នៃដើមទុនក្រុមហ៊ុន។ កម្រិតកំណត់នេះកំណត់ការផ្តល់ឥណទានរបស់ធនាគារដល់ឯកត្តជន។*

ជាបន្តបន្ទាប់នូវបទបញ្ញត្តិមួយចំនួននៅចន្លោះឆ្នាំ២០០១-២០០៤ ដែលដោះស្រាយបាននូវបញ្ហាមួយចំនួន ដូចជា បទបញ្ញត្តិស្តីពីការចេញអាជ្ញាប័ណ្ណ តម្រូវការដើមទុន (សាធនភាព) និងតម្រូវការគណនេយ្យ ដោយរាប់បញ្ចូលការគណនាសវិធានធនសម្រាប់ចំនួនប្រាក់បំរុងសម្រាប់ការទាមទារសំណង ។

## ១.២ ការធានារ៉ាប់រងជាកាតព្វកិច្ច

៤.១៦ បទបញ្ញត្តិមួយត្រូវបានអនុម័ត ដោយតម្រូវឱ្យមានការទិញធានារ៉ាប់រងជាកាតព្វកិច្ច ក្នុងស្ថានភាពបីដូចខាងក្រោម ៖

- ការធានារ៉ាប់រងចំពោះតតិយជន សម្រាប់យានយន្តដែលគ្រប់គ្រងដោយសហគ្រាសពាណិជ្ជកម្ម អង្គការក្រៅរដ្ឋាភិបាល និងនីតិបុគ្គលផ្សេងទៀត លើកលែងយានយន្តផ្ទាល់ខ្លួន ។
- ការធានារ៉ាប់រងចំពោះម្ចាស់យានយន្តដឹកជញ្ជូនសាធារណៈ ចំពោះអ្នកធ្វើដំណើរ ក៏ដូចជាចំពោះតតិយជន ដែលទទួលរងការបាត់បង់ខូចខាត ឬរងរបួសក្នុងគ្រោះថ្នាក់ ដែលបណ្តាលមកពីការប្រព្រឹត្តរបស់ម្ចាស់យានយន្តដឹកជញ្ជូនសាធារណៈ និង
- ការធានារ៉ាប់រងរបស់អ្នកម៉ៅការលើគំរោងសាងសង់ចំពោះកម្មករក្នុងការដ្ឋាន ក៏ដូចជាបុគ្គលដែលអាចមានវត្តមាននៅក្នុង ឬនៅក្បែរការដ្ឋានសំណង់នោះ ។

ច្បាប់ក៏តម្រូវផងដែរឱ្យការធានារ៉ាប់រងលើហានិភ័យនៅកម្ពុជា ត្រូវតែទិញពីក្រុមហ៊ុនដែលទទួលអាជ្ញាប័ណ្ណក្នុងស្រុក ។ ពុំអនុញ្ញាតឱ្យទិញការធានារ៉ាប់រងនៅក្រៅស្រុកឡើយ ។

៤.១៧ ទោះយ៉ាងណា ការអនុវត្តន៍និងការប្រតិបត្តិនៃការធានារ៉ាប់រងជាកាតព្វកិច្ចទាំងនេះពុំទាន់បានដំណើរការល្អប្រសើរទេ ។

## ១.៣ សមាគមធានារ៉ាប់រង

៤.១៨ សមាគមធានារ៉ាប់រងទូទៅនៃកម្ពុជា (GIAC) ត្រូវបានបង្កើតឡើង និងកំពុងដើរតួនាទីនៅក្នុងការអភិវឌ្ឍរបស់វិស័យនេះ ។

## ១.៤ ការកសាងសមត្ថភាព

៤.១៩ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវទទួលខុសត្រូវជាបញ្ញត្តិករធានារ៉ាប់រង ហើយការិយាល័យធានារ៉ាប់រងមួយ ត្រូវបានបង្កើតឡើងនៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ១.៥ ប្រព័ន្ធសោធននិវត្តន៍

៤.២០ នៅឆ្នាំ២០០៣ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា បានរៀបចំច្បាប់ស្តីពីសន្តិសុខសង្គម ហើយត្រូវបានអនុម័តដោយរដ្ឋសភា ។ នៅក្រោមច្បាប់នេះ ពលករផ្លូវការទាំងអស់ត្រូវចូលរួមនៅក្នុងកម្មវិធីសន្តិសុខសង្គមមួយ ដែលផ្តល់ផលប្រយោជន៍ដល់អ្នកមានជីវិត នៅក្នុងករណីដែលពលករជាសមាជិកនៃកម្មវិធីនេះ ទទួលមរណភាពមុន

អាយុចូលនិវត្តន៍ ព្រមទាំងសំណង និងផលប្រយោជន៍សម្រាប់ចូលនិវត្តន៍ចុងក្រោយរបស់ពលករនោះ ។ បទបញ្ញត្តិចាំបាច់ក្នុងការអនុវត្តន៍ច្បាប់នេះមិនទាន់ត្រូវបានអនុម័តចេញផ្សាយនៅឡើយ ។ ចំណុចគន្លឹះលំអិតមួយចំនួនមិនទាន់ត្រូវបានកំណត់នៅឡើយ ដែលក្នុងចំណោមចំណុចទាំងនេះ អត្រាវិភាគទានដែលត្រូវបង់ជំនួសឱ្យពលករ និងរបៀបថាតើនិយោជកនិងពលករត្រូវបែងចែកបន្ទុកនៃវិភាគទានទាំងនេះ និងរូបមន្តបែងចែកផលប្រយោជន៍យ៉ាងណាខ្លះនោះ ក៏មិនទាន់បានកំណត់នៅឡើយដែរ ។

៤.២១ បច្ចុប្បន្ន នៅមិនទាន់មានក្របខ័ណ្ឌច្បាប់សម្រាប់ផែនការសោធននិវត្តន៍សម្រាប់សាជីវកម្ម ឬឯកជនដោយស្ម័គ្រចិត្តនៅឡើយទេ ។

## ២. គាំទ្រការអភិវឌ្ឍនៃវិស័យធានារ៉ាប់រងនៅកម្ពុជា

៤.២២ ជាគោលការណ៍ ទីផ្សារធានារ៉ាប់រងនៅកម្ពុជាមានសក្តានុពលក្នុងការទទួលបានកំណើនខ្លាំង ។ ក៏ប៉ុន្តែ ប្រសិនបើវិស័យនេះត្រូវអភិវឌ្ឍន៍ថែមទៀត និងទទួលបានសមាមាត្រ ដែលនឹងអាចធ្វើឱ្យសេវានេះចូលរួមចំណែកក្នុងមធ្យោបាយសំភារៈចំពោះការអភិវឌ្ឍសេដ្ឋកិច្ច នោះជំហានសំខាន់បន្ទាប់ទៀតគួរត្រូវតែបានប្រកាន់យក ។

៤.២៣ នៅក្នុងស្ថានភាពប្រទេសកម្ពុជា ជាក់ស្តែង ទីផ្សារនេះមានទំហំតូចនៅឡើយ បើគិតទៅលើចំណូលបុព្វលាភ ( ប្រាក់បុព្វលាភប្រចាំឆ្នាំប្រហែល ១១ លានដុល្លារអាមេរិក) ហើយទាមទារឱ្យមានការអភិវឌ្ឍច្រើនថែមទៀត ។ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០០៦-២០១៥នឹងកសាងពីលើមូលដ្ឋានគ្រឹះដែលបានកសាងហើយ ក្នុងកំឡុងពេលប្រតិបត្តិការ៥ឆ្នាំដំបូង នៅក្នុងចក្ខុវិស័យនិងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០១-២០១០ ។ នៅក្នុងរយៈពេលដំបូងនេះ បទពិសោធន៍ដែលទទួលបានរាប់បញ្ចូលទាំងបទពិសោធន៍ដែលទាក់ទិននឹងការដួលរលំរបស់ក្រុមហ៊ុនធានារ៉ាប់រងដ៏ធំមួយនឹងជួយដល់ផែនការសម្រាប់រយៈពេល១០ឆ្នាំបន្ទាប់នេះ ។

### *២.១ គោលដៅ និងការណែនាំ*

៤.២៤ គោលដៅដែលពាក់ព័ន្ធទៅនឹងវិស័យធានារ៉ាប់រង គឺជាការធានារ៉ាប់រងមួយដែលការពារដល់មុខរបរ និងឯកត្តជនពីគ្រោះមហន្តរាយទាំងឡាយ និងប្រព័ន្ធសោធននិវត្តន៍ដែលគាំទ្រដល់ផែនការចូលនិវត្តន៍ ហើយផ្នែកទាំងពីរនេះអាចផ្តល់ទុនវិនិយោគរយៈពេលវែង ។ ក្នុងការស្វែងរកកិច្ចគាំទ្រដល់គោលដៅនេះ ប្រទេសកម្ពុជានឹងត្រូវបានចង្អុលផ្លូវដោយបទពិសោធន៍ពីអន្តរជាតិនិងតំបន់ ដែលរួមបញ្ចូលទាំងគោលការណ៍ស្នូលនៃសមាគមអន្តរជាតិសម្រាប់អ្នកត្រួតពិនិត្យធានារ៉ាប់រង (IAIS) ។ សម្រាប់ទីផ្សារដ៏ក្មេងខ្ចីដូចកម្ពុជា លក្ខណៈវិនិច្ឆ័យលម្អិតមួយចំនួនមិនអាចអនុវត្តបានចំពោះការទិញទូវផលិតផលវិនិយោគនិស្សន្ទនោះទេ ។ លក្ខណៈវិនិច្ឆ័យមួយចំនួនទៀតដែលប្រហែលជាមិនសមស្របសម្រាប់ប្រទេសកម្ពុជានៅពេលបច្ចុប្បន្ន រួមមានរូបមន្តលើការកំណត់ដើមទុនដោយផ្អែកលើកម្រិតហានិភ័យ ការធ្វើតេស្តដ៏មានថាមពលសម្រាប់ស្ទង់សាធនភាព និងបច្ចេកទេសជឿនលឿនជាច្រើនទៀត សម្រាប់ធ្វើឱ្យមានភាពស៊ីគ្នារវាងទ្រព្យសកម្ម និងទ្រព្យអកម្ម ។

## ២.២ លក្ខខណ្ឌសម្រាប់ទីផ្សារ និងការត្រួតពិនិត្យធានារ៉ាប់រងមួយប្រកបដោយប្រសិទ្ធភាព

៤.២៥ លក្ខខណ្ឌជាមូលដ្ឋានសម្រាប់ទីផ្សារ និងការត្រួតពិនិត្យធានារ៉ាប់រងមួយប្រកបដោយប្រសិទ្ធភាពមានដូចតទៅ ៖

- គោលនយោបាយ ស្ថាប័ន និងក្របខ័ណ្ឌច្បាប់សម្រាប់ការត្រួតពិនិត្យវិស័យហិរញ្ញវត្ថុ
- ហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុមួយដែលត្រូវបានអភិវឌ្ឍន៍យ៉ាងល្អប្រកបដោយប្រសិទ្ធភាព និង
- ទីផ្សារហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព ។

លក្ខខណ្ឌទាំងអស់នេះ នឹងមានចែងនៅក្នុងផ្នែកដែលពាក់ព័ន្ធ នៅក្នុងឯកសារនេះ ។

## ២.៣ ក្របខ័ណ្ឌបទបញ្ញត្តិសម្រាប់ធានារ៉ាប់រង

៤.២៦ ក្នុងខណៈដែលក្របខ័ណ្ឌទូទៅនៃប្រព័ន្ធបទបញ្ញត្តិមានរួចហើយ ធាតុសំខាន់នៃប្រព័ន្ធត្រួតពិនិត្យទំនើបមួយ កំពុងមានភាពខ្វះចន្លោះ ។ ការងារបន្ថែមដែលចាំបាច់ត្រូវធ្វើរួមមាន ៖

- តួនាទី និងអំណាចរបស់អ្នកត្រួតពិនិត្យ
- វិធានការសម្រាប់ដោះស្រាយជាមួយក្រុមហ៊ុនដែលមានបញ្ហា និង
- អភិបាលកិច្ចក្រុមហ៊ុន ។

៤.២៧ ប្រព័ន្ធធានារ៉ាប់រងត្រូវបានកំណត់ដោយច្បាប់ និងបទបញ្ញត្តិ ។ ឧបករណ៍ទាំងនេះត្រូវតែបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ ធ្វើយ៉ាងណាឱ្យអ្នកចូលរួមទាំងអស់បានយល់ដឹងយ៉ាងស៊ីជម្រៅអំពីខ្លឹមសារនៃច្បាប់និងបទបញ្ញត្តិទាំងនោះ ។ ក្របខ័ណ្ឌទាំងនេះក៏គួរជាកម្មវត្ថុនៃការពិនិត្យមើលឡើងវិញឱ្យគ្រប់ជ្រុងជ្រោយ និងកំណត់លក្ខខណ្ឌប្រៀបធៀបជាមួយអន្តរជាតិនិងថ្នាក់តំបន់ដែលល្អបំផុត រាប់បញ្ចូលទាំងខ្លឹមសារដែលមានចែងនៅក្នុងគោលការណ៍គ្រឹះនៃសមាគមអន្តរជាតិសម្រាប់អ្នកត្រួតពិនិត្យធានារ៉ាប់រង ។

៤.២៨ ប្រព័ន្ធសម្រាប់ធ្វើការវាស់ស្ទង់សាធនភាពរបស់ក្រុមហ៊ុនធានារ៉ាប់រង ទាមទារឱ្យមានការយកចិត្តទុកដាក់ជាពិសេស ។ ការវាស់ស្ទង់លើភាពគ្រប់គ្រាន់នៃដើមទុនចាំបាច់ត្រូវឈរលើមូលដ្ឋាននៃភាពរឹងមាំនិងវិធានទូលំទូលាយសម្រាប់វាយតម្លៃទ្រព្យសកម្មនិងទ្រព្យអកម្ម រួមជាមួយការណែនាំមួយចំនួនដូចជាភាពសមស្របនៃសំពៀតទ្រព្យសកម្ម យោងទៅលើសភាពដើមលក្ខខណ្ឌចែង និងទិន្នផលនៃទ្រព្យអកម្ម ។ ការធ្វើតេស្តជាក់ស្តែងលើភាពគ្រប់ គ្រាន់នៃដើមទុន ត្រូវប្រៀបធៀបចំនួនដើមទុនមិនបានប្រើប្រាស់ និងអតិរេកនៃតម្រូវការរូបមន្តមួយចំនួន ។

៤.២៩ បទពិសោធន៍បានបញ្ជាក់ពីភាពចាំបាច់បន្ទាន់សម្រាប់ប្រព័ន្ធប្រសិទ្ធភាពមួយ សម្រាប់ដោះស្រាយអសាធនភាពរបស់ក្រុមហ៊ុនធានារ៉ាប់រង ដោយរាប់បញ្ចូលទាំងសិវិធានធនដែលទាក់ទងនឹងការក្ស័យធន និងការជំរះបញ្ជី ។ ប្រព័ន្ធនេះគួរទទួលស្គាល់ និងការពារស្ថានភាពពិសេសរបស់អ្នកកាន់ប័ណ្ណសន្យារ៉ាប់រងដែលជាម្ចាស់បំណុលម្នាក់របស់ក្រុមហ៊ុនធានារ៉ាប់រង ។

៤.៣០ ជាទូទៅ ក្របខ័ណ្ឌបទបញ្ញត្តិបច្ចុប្បន្ន មិនទាន់បានផ្តល់ឱ្យអាជ្ញាធរត្រួតពិនិត្យនូវរាល់អំណាចសំខាន់ និងឧបករណ៍ដោះស្រាយទាំងអស់ដែលចាំបាច់ សម្រាប់អនុវត្តជាទៀងទាត់នៅក្នុងដំណើរការត្រួតពិនិត្យក្រុមហ៊ុនធានារ៉ាប់រង។ ប្រព័ន្ធនេះគួរញែកឱ្យច្បាស់នូវកាលៈទេសៈទាំងឡាយណាដែលនឹងទាក់ទាញអន្តរាគមន៍ពីអ្នកត្រួតពិនិត្យ ចង្អុលបង្ហាញអំពីបែបបទនៃអន្តរាគមន៍ និងបញ្ជាក់ពីមធ្យោបាយដែលផ្អែកលើនេះអន្តរាគមន៍ត្រូវបានធ្វើឡើង។

## ២.៤ ប្រព័ន្ធសម្រាប់ការត្រួតពិនិត្យក្រុមហ៊ុនធានារ៉ាប់រង

៤.៣១ ការត្រួតពិនិត្យក្រុមហ៊ុនធានារ៉ាប់រងកំពុងត្រូវបានអនុវត្តដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ដំណើរការនេះ រួមមានការប្រមូលស្ថិតិពីក្រុមហ៊ុនធានារ៉ាប់រង ការវិភាគលើឯកសារដែលបានផ្ញើមក និងតាមដានមើលអ្វីដែលបានរកឃើញ។ មន្ត្រីទាំងនោះក៏បានចាប់ផ្តើមអនុវត្តការត្រួតពិនិត្យដល់ទីកន្លែង ប៉ុន្តែមិនទាន់បង្កើតនីតិវិធីឱ្យគ្រប់ជ្រុងជ្រោយមួយសម្រាប់ការធ្វើអធិការកិច្ចបែបនេះនៅឡើយទេ។ សមាជិកនៃក្រុមមន្ត្រីអធិការកិច្ចនឹងទាញផលប្រយោជន៍ពីកម្មវិធីបណ្តុះបណ្តាលដ៏ទូលំទូលាយមួយ និងដោយមានកិច្ចគាំទ្រពីប្រព័ន្ធគ្រប់គ្រងព័ត៌មាន និងព័ត៌មានវិទ្យាផងដែរ។

៤.៣២ ក្រោមប្រព័ន្ធបច្ចុប្បន្ននេះ ក្រុមហ៊ុនផ្ញើជូននូវរបាយការណ៍ហិរញ្ញវត្ថុទាំងមូល អមដោយការបញ្ជាក់ពីសវនករមួយដងក្នុងមួយឆ្នាំ។ ព័ត៌មានស្ថិតិបន្ថែមទៀតត្រូវបានប្រមូលក្នុងចន្លោះឆ្នាំ។ ក្នុងការគាំទ្រដល់របាយការណ៍ហិរញ្ញវត្ថុ ដែលត្រូវបានធ្វើសវនកម្មរួមហើយនោះ ក្រុមហ៊ុនក៏ត្រូវបំពេញគំរូបញ្ញត្តិពិសេសមួយដែលបង្កើតឡើងដោយក្រុមការងារត្រួតពិនិត្យធានារ៉ាប់រងអាស៊ាន។

៤.៣៣ បច្ចុប្បន្ន មន្ត្រីនៅក្នុងការិយាល័យធានារ៉ាប់រងនេះរំពឹងថានឹងបង្កើត ធ្វើសេចក្តីព្រាង និងជម្រុញការផ្លាស់ប្តូរនៅក្នុងគោលនយោបាយបទបញ្ញត្តិទាក់ទងនឹងក្រុមហ៊ុនធានារ៉ាប់រង ក្នុងខណៈដែលពេលពួកគេត្រូវបន្តការត្រួតពិនិត្យយ៉ាងសកម្មទៅលើក្រុមហ៊ុនដែលទទួលបានអាជ្ញាប័ណ្ណ។ គួរកត់សម្គាល់ថា នៅក្នុងយុត្តាធិការភាគច្រើន អ្នកត្រួតពិនិត្យត្រូវបានរំពឹងថានឹងផ្តោតការយកចិត្តទុកដាក់លើការត្រួតពិនិត្យលើអាជីវកម្មប៉ុណ្ណោះ ដោយបន្សល់ទុកនូវការងារអភិវឌ្ឍន៍ច្បាប់និងបទបញ្ញត្តិឱ្យទៅអង្គភាពនយោបាយមួយ។ តួនាទីតែមួយគត់របស់អ្នកត្រួតពិនិត្យនៅក្នុងការបង្កើតគោលនយោបាយបទបញ្ញត្តិគឺត្រូវកំណត់នូវគំលាត និងភាពទន់ខ្សោយនៅក្នុងក្របខ័ណ្ឌបទបញ្ញត្តិដែលតម្រូវឱ្យមានការយកចិត្តទុកដាក់ និងបញ្ជូនទៅអង្គភាពនយោបាយដើម្បីតាមដាន។ នេះគឺជាបញ្ហាមួយគួរត្រូវធ្វើការពិចារណាឱ្យកាន់តែទូលំទូលាយថែមទៀតក្នុងរយៈពេលមធ្យម (ជំពូកទី ៥ ការពិចារណាឆ្លងវិស័យទូទៅ)។

## ២.៥ តួនាទីរបស់រាជរដ្ឋាភិបាល

៤.៣៤ ការដែលវិស័យធានារ៉ាប់រងមិនទាន់មានការអភិវឌ្ឍ គឺមិនមែនដោយសាររដ្ឋាភិបាលមិនចង់ឱ្យសេវានេះរីកចំរើននោះទេ។ ការអភិវឌ្ឍស៊ីជំរៅបំផុតនៃឧស្សាហ៍កម្មហិរញ្ញវត្ថុបែបនេះ អាចកើតឡើងបានដោយសារតែសកម្មភាពរបស់ឯកត្តជនសហគ្រាស និងសាជីវកម្ម ដែលជ្រើសរើសធ្វើអាជីវកម្មជាមួយក្រុមហ៊ុនធានារ៉ាប់រងក្នុងស្រុកប៉ុណ្ណោះ។ សហគ្រិនបានយល់ដឹង

ពីផលប្រយោជន៍ដែលធានារ៉ាប់រងផ្តល់ឱ្យពួកគេលើការគ្រប់គ្រងហានិភ័យជាដើម ។ ជាឧទាហរណ៍ដំណើរការនេះមិនអាចទៅមុខបាននោះទេ បើសាធារណជនមិនបានយល់ដឹងអំពីសេវាដែលក្រុមហ៊ុនធានារ៉ាប់រងអាចផ្តល់ឱ្យបាន ដោយមិនមានការជឿទុកចិត្តទៅលើអាជីវកម្មនេះ និងការគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រុមហ៊ុនទាំងនោះ ។ រដ្ឋាភិបាលអាចជួយជម្រុញដំណើរការនេះតាមមធ្យោបាយមួយចំនួនដូចខាងក្រោម ៖

- បង្កើតក្របខ័ណ្ឌគោលនយោបាយដ៏គ្រប់ជ្រុងជ្រោយនិងត្រឹមត្រូវមួយសម្រាប់វិស័យហិរញ្ញវត្ថុទាំងមូល ។ ក្របខ័ណ្ឌនេះគួរសម្របសម្រួលសកម្មភាពទាំងឡាយរបស់អ្នកចូលរួមទាំងអស់នៅក្នុងវិស័យនេះ ។ កម្ពុជាបានបង្កើតក្រុមការងារវិស័យហិរញ្ញវត្ថុមួយដើម្បីសម្រេចគោលដៅទាំងនោះ ។ ក្រុមហ៊ុនធានារ៉ាប់រង និងអ្នកត្រួតពិនិត្យ ជាអ្នកចូលរួមយ៉ាងសកម្មនៅក្នុងក្រុមការងារនេះ ។
- ដាក់ឱ្យមានប្រព័ន្ធត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពមួយដែលធានាថា វិធានដូចគ្នាត្រូវបានអនុវត្តចំពោះអ្នកចូលរួមទាំងអស់ ។ ទីផ្សារគួរបើកចំហ និងមានការប្រកួតប្រជែង ។
- ធានាថាប្រព័ន្ធបទបញ្ញត្តិសម្រាប់ក្រុមហ៊ុនធានារ៉ាប់រងគ្មានអ្វីមកគាបសង្កត់ទេ ដូចជាការតម្រូវទាំងឡាយក្នុងការវិនិយោគដែលកម្រិតហួសហេតុពេកដល់សកម្មភាពវិនិយោគរបស់អ្នកគ្រប់គ្រងក្រុមហ៊ុនធានារ៉ាប់រង ។
- ធានាថា វិធានសារពើពន្ធមិនដាក់បន្ទុកពន្ធដោយមិនសមហេតុផលមួយទៅលើប្រតិបត្តិការក្រុមហ៊ុនធានារ៉ាប់រង ។ ចំពោះការយកពន្ធវិញ ការសន្សំតាមរយៈធានារ៉ាប់រងគួរត្រូវបានយកពន្ធដូចគ្នាទៅនឹងការសន្សំតាមរយៈគ្រឹះស្ថានធនាគារ ។

## *២.៦ សហប្រតិបត្តិការក្នុងតំបន់*

៤.៣៥ ធម្មជាតិ និងភាពស្មុគស្មាញនៃអាជីវកម្មធានារ៉ាប់រងបែបនេះ គឺមានការលំបាក និងត្រូវចំណាយច្រើនសម្រាប់ប្រទេសមួយក្នុងការបំពាក់ឱ្យភ្នាក់ងារត្រួតពិនិត្យរបស់ខ្លួននូវប្រភពធនធានចំណេះដឹង និងប្រភពផ្សេងទៀត ក៏ដូចជាឧបករណ៍វិភាគទំនើបទាំងឡាយ ដែលចាំបាច់សម្រាប់ដោះស្រាយនូវបញ្ហាគ្រប់ប្រភេទដែលអាចកើតមានឡើង ។ យោងទៅតាមទំហំទីផ្សារធានារ៉ាប់រងនៅកម្ពុជានាពេលបច្ចុប្បន្ន ប្រទេសកម្ពុជាគួរប្រឹក្សាជាមួយប្រទេសជិតខាងរបស់ខ្លួន និងដៃគូអាស៊ាន ដើម្បីមើលថា តើការចែកចាយប្រភពធនធានត្រួតពិនិត្យអាចប្រព្រឹត្តទៅបានឬទេ ។

## ៣. មីក្រូធានារ៉ាប់រង

៤.៣៦ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលធ្វើប្រតិបត្តិការនៅកម្ពុជា ក៏ដូចប្រទេសដទៃទៀត បានកំណត់ថា អតិថិជនរបស់ពួកគេគឺមានតម្រូវនូវការធានារ៉ាប់រងខ្នាតតូច ។ មរណភាព ឬជំងឺរបស់អ្នកខ្ចីប្រាក់ ការបាត់បង់នូវទ្រព្យសម្បត្តិដែលមានតម្លៃលើផ្នែកណាមួយ ដូចជា សត្វពាហនៈ បញ្ហាអាកាសធាតុដែលធ្វើឱ្យខូចខាតដល់ដំណាំ ព្រឹត្តិការណ៍ទាំងអស់នេះ អាចនាំឱ្យអ្នកចូលរួមមានបញ្ហាដល់ស្ថានភាពហិរញ្ញវត្ថុនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ។ គ្រឹះស្ថានផ្តល់ឥណទានមានទស្សនៈថា ការធានាលើលទ្ធភាពនៃការទូទាត់សងកម្ចីត្រលប់មកវិញជាវិធានការសមរម្យ ។ ក្នុងហេតុផលនេះ គំរោងសាកល្បងធានារ៉ាប់រងលើសុខភាពត្រឹមកម្រិតមីក្រូត្រូវបានអនុវត្តក្នុងប្រទេសកម្ពុជា និងទទួលបានជោគជ័យផងដែរ ។

៤.៣៧ គំនិតការផ្តួចផ្តើមថ្មីៗនេះ គឺការបង្កើតសមាគមដែលផ្តល់ផលប្រយោជន៍ទៅវិញទៅមក ឬផលប្រយោជន៍ប្រកបដោយភាតរភាព ដែលផ្តល់កិច្ចការពារដោយធានារ៉ាប់រងដល់សមាជិកនៃក្រុមរូបវន្តបុគ្គល ។ ចំនួនប្រាក់នៃការធានាមានចំនួនតិចតួច ហើយជារឿយៗ សមាជិកក្រុមធ្វើការបែងចែកទៅតាមលទ្ធផលដែលទទួលបាន ។ ឧទាហរណ៍ គឺជារឿងធម្មតាសម្រាប់កិច្ចសន្យាដែលផ្តល់ផលប្រយោជន៍ទៅវិញទៅមកនៅក្នុងសង្គម ដោយសមាជិកនៅក្នុងសង្គមមួយអាចជាកម្មវត្ថុនៃ "ការវាយតម្លៃ" ជាពិសេស ក្នុងករណីនៃបទពិសោធន៍ក្នុងការធ្វើប្រតិបត្តិមានលក្ខណៈអន់ថយសម្រាប់សង្គម ។ ជាធម្មតា ការវាយតម្លៃទាំងនេះមានទម្រង់ជាការកាត់បន្ថយតម្លៃដែលត្រូវបង់ ។

៤.៣៨ នៅគ្រប់ប្រទេសទាំងអស់ ការធានារ៉ាប់រងប្រភេទនេះ ស្ថិតនៅក្រោមស្តង់ដារខុសៗគ្នានៃបទបញ្ញត្តិ និងការត្រួតពិនិត្យ ។ ស្តង់ដារត្រួតពិនិត្យដែលមិនម៉ត់ចត់ នឹងធ្វើឱ្យមានតម្រូវការដើមទុនមានកម្រិតទាប តម្រូវឱ្យមានរបាយការណ៍មិនសូវលម្អិត និងការធ្វើអធិការកិច្ចដោយអ្នកត្រួតពិនិត្យក៏តិច ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកំពុងរិះរកវិធានការសម្រាប់ដាក់ឱ្យអនុវត្ត ដើម្បីដោះស្រាយបញ្ហាទាំងនេះ ។

## ៤. អាទិភាពសម្រាប់ឆ្នាំ២០០៦-២០១៥ : ធានារ៉ាប់រង

៤.៣៩ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០០៦-២០១៥ បានបង្ហាញអំពីជំហានដែលត្រូវប្រកាន់យក ដើម្បីជម្រុញវិស័យនេះទៅមុខ ដែលក្នុងនោះមានសកម្មភាពដែលចាំបាច់ត្រូវធ្វើជាបន្ទាន់ សកម្មភាពអន្តរកាល ឬអាទិភាពរយៈពេលមធ្យម និងអាទិភាពទាបឬរយៈពេលវែង ។

៤.៤០ ជាក់ស្តែង ការងារមួយភាគធំដែលពាក់ព័ន្ធទៅនឹងសោធននិវត្តន៍ឯកជនសោធននិវត្តន៍សម្រាប់មន្ត្រីរាជការ នឹងត្រូវចាត់ទុកជាគោលដៅរយៈពេលវែង សម្រាប់គោលបំណងនៃផ្នែកនេះ ។ រីឯបេឡាជាតិធានារ៉ាប់រងសង្គម សម្រាប់មន្ត្រីរាជការបច្ចុប្បន្ននេះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល កំពុងសិក្សាបង្កើតឱ្យបានឆាប់រហ័សតាមរយៈព្រះរាជក្រឹត្យ ។ ប៉ុន្តែការអភិវឌ្ឍវិស័យនេះអាចចាត់ទុកថាជាផ្នែកមួយឯករាជ្យពីគំរោងនៃវិស័យធានារ៉ាប់រង ។ ប្រសិនបើមានធនធានគ្រប់គ្រាន់ក្នុងការសិក្សា និងបណ្តុះបណ្តាល ដល់វិស័យនេះ គំនិតផ្តួចផ្តើមពីសោធននិវត្តន៍នឹងអាចត្រូវបានចាប់ផ្តើមឡើងក្នុងពេលមួយឆាប់ជាងការកំណត់ ។ ប៉ុន្តែ ដោយផ្អែកទៅលើភាពខ្សត់ខ្សោយនៃធនធានមនុស្សជាទូទៅ ព្រមទាំងកង្វះខាតអ្នកជំនាញនៅក្នុងវិស័យសេវា សាធារណៈ ដែលអាចមានសមត្ថភាព និងពេលវេលាដើម្បីធ្វើការងារនេះ ដូច្នេះបញ្ហាសោធននិវត្តន៍គួរត្រូវបានទុក មួយឡែកសិនរហូតដល់វេលាដែលបញ្ហាបន្ទាន់ៗចំពោះមុខត្រូវបានដោះស្រាយជាមុនសិន ។

### *៤.១ អាទិភាពចំពោះមុខ*

៤.៤១ អាទិភាពចំពោះមុខមានដូចជា ៖

- ការពិនិត្យឡើងវិញនូវប្រព័ន្ធទាំងមូល : ការពិនិត្យឡើងវិញគ្រប់ជ្រុងជ្រោយទៅលើប្រព័ន្ធបទបញ្ញត្តិនឹងត្រូវធ្វើឡើងស្របតាមការអនុវត្តន៍ដ៏ប្រសើរបំផុតរបស់អន្តរជាតិ ។

- ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុ ៖ ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុសម្រាប់ក្រុមហ៊ុនធានារ៉ាប់រង ត្រូវបានអភិវឌ្ឍន៍ វិធានច្បាស់លាស់ស្តីពីការបង្កើតទុនបំរុងខាតសម្រាប់សងការទាមទារសំណងនឹងត្រូវបានបង្កើត និងតម្រូវការឱ្យមានសវនកម្មសម្រាប់ក្រុមហ៊ុនធានារ៉ាប់រងត្រូវតែបានកំណត់យ៉ាងច្បាស់លាស់ ។
- បញ្ហាពាក់ព័ន្ធនឹងសកម្មភាពរបស់មន្ត្រីត្រួតពិនិត្យ ៖ ការកសាងសមត្ថភាពរបស់បុគ្គលិកនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រួមបញ្ចូលទាំងការបណ្តុះបណ្តាលទូទៅដ៏ទូលំទូលាយមួយ ការពិចារណាលើ កិច្ចសហការក្នុងតំបន់និងបែងចែកធនធានចំណេះដឹង បង្កើនជំនឿទុកចិត្តលើវិជ្ជាជីវៈ ដោយរួមបញ្ចូលការប្រកាន់យកវិធីសាស្ត្រចងក្រង និងប្រើប្រាស់នូវរបាយការណ៍ ការបង្កើតនូវប្រព័ន្ធគ្រប់គ្រងព័ត៌មាន (MIS) និងទ្រទ្រង់ដោយព័ត៌មានវិទ្យា និងចូលជាសមាជិកនៃ IAIS ។
- ការធ្វើឯកជនភាវូបនីយកម្មក្រុមហ៊ុនកាមិនកូ ៖ ការធ្វើឯកជនភាវូបនីយកម្មក្រុមហ៊ុននេះនឹងបំពេញបង្គ្រប់ដំណើរការនៃការអភិវឌ្ឍវិស័យធានារ៉ាប់រងឯកជននៅកម្ពុជា ។
- កិច្ចសហប្រតិបត្តិការអន្តរក្រសួង ៖ បុគ្គលិកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬក្រុមណាមួយក៏ដោយ ដែលទទួលខុសត្រូវលើការរៀបចំនូវគោលនយោបាយលើផ្នែកធានារ៉ាប់រង នឹងត្រូវចូលរួមនៅក្នុងគណៈកម្មការអន្តរក្រសួង ដែលមានតំណាងមកពីក្រសួងសាធារណៈការនិងដឹកជញ្ជូន ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ក្រសួងទេសចរណ៍ និងក្រសួងមហាផ្ទៃ ដើម្បីពិនិត្យមើលមធ្យោបាយ នៅក្នុងការជម្រុញការអនុវត្តន៍ឱ្យកាន់តែប្រសើរ តាមវិធានចាំបាច់សម្រាប់ការធានារ៉ាប់រងលើយានយន្ត និងការដ្ឋានសំណង់ ។
- ចាប់ផ្តើមគាំទ្រចំពោះការអភិវឌ្ឍការធានារ៉ាប់រងអាយុជីវិតតាមរយៈការសិក្សាលើលទ្ធភាព និងការអភិវឌ្ឍលើបទបញ្ញត្តិ និងច្បាប់ ។ ការសិក្សានឹងត្រូវបានធ្វើការវាយតម្លៃនូវសក្តានុពលភាពទីផ្សារសម្រាប់អាជីវកម្មធានារ៉ាប់រងអាយុជីវិតនៅកម្ពុជា រួមទាំងមីក្រូហិរញ្ញវត្ថុ ។
- មីក្រូធានារ៉ាប់រង ៖ ណែនាំនូវប្រព័ន្ធពិសេសមួយសម្រាប់ដាក់បទបញ្ញត្តិ និងធ្វើការត្រួតពិនិត្យសកម្មភាពទាំងឡាយនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលមានបំណងផ្តល់សេវាធានារ៉ាប់រងការពារដល់សមាជិករបស់ខ្លួន ។ វិធានដែលដាក់ចេញ ត្រូវតែមានលក្ខណៈធូរស្រាលជាងវិធានទាំងឡាយដែលអនុវត្តចំពោះក្រុមហ៊ុនធានារ៉ាប់រងធម្មតា ព្រមទាំងបញ្ចូលនូវប៉ារ៉ាម៉ែត្រដែលកំណត់អំពីប្រភេទនៃគ្រឹះស្ថាន ដែលអាចផ្តល់សេវាមីក្រូធានារ៉ាប់រងនិងកំណត់ព្រំដែនសមស្របទៅតាមវិសាលភាពនៃដំណើរការរបស់គ្រឹះស្ថានទាំងនោះ ។
- វិស័យធានារ៉ាប់រងអាយុជីវិត ៖ អភិវឌ្ឍន៍យុទ្ធសាស្ត្រសមស្របសម្រាប់ការអភិវឌ្ឍវិស័យធានារ៉ាប់រងអាយុជីវិត រួមទាំងសមាសធាតុចាំបាច់នៃក្របខ័ណ្ឌបទបញ្ញត្តិ ។ ចាប់ផ្តើមទ្រទ្រង់ការអភិវឌ្ឍការធានារ៉ាប់រងជីវិតតាមរយៈការសិក្សាអំពីភាពអាចប្រព្រឹត្តទៅបាន និងការអភិវឌ្ឍច្បាប់ និងបទបញ្ញត្តិ ។ ការសិក្សាមួយនឹងត្រូវបានប្រព្រឹត្តទៅ ដើម្បីវាយតម្លៃនូវទីផ្សារដែលមានសក្តានុពលសម្រាប់មុខរបរធានារ៉ាប់រងជីវិតនៅកម្ពុជា រួមបញ្ចូលទាំងមីក្រូហិរញ្ញវត្ថុផងដែរ ។ កម្ពុជានឹងត្រូវកែសម្រួលក្របខ័ណ្ឌបទបញ្ញត្តិដើម្បីមានលទ្ធភាពផ្តល់អាជ្ញាប័ណ្ណ និងអាចអនុញ្ញាតឱ្យក្រុមហ៊ុនធានារ៉ាប់រងធ្វើប្រតិបត្តិការលក់ប័ណ្ណសន្យារ៉ាប់រងអាយុជីវិត ។

## ៤.២ អាទិភាពអន្តរកាល និងរយៈពេលមធ្យម

៤.៤២ អាទិភាពអន្តរកាល និងរយៈពេលមធ្យម មានដូចជា៖

- ធានារ៉ាប់រងអាយុជីវិត : អនុញ្ញាតឱ្យយកកិច្ចសន្យាធានារ៉ាប់រងអាយុជីវិតធ្វើជាមធ្យោបាយប្រមូលមូលនិធិសម្រាប់ផែនការសោធននិវត្តន៍ និងផែនការសន្សំសម្រាប់ចូលនិវត្តន៍។
- តម្រូវការអ្នកគណនាតម្លៃហានិភ័យ : បច្ចុប្បន្ននេះពុំមានអ្នកគណនាតម្លៃហានិភ័យដែលមានមូលដ្ឋាននៅកម្ពុជាទេ ហើយម៉្យាងទៀត លទ្ធភាពនៃការបង្កើតអង្គភាពវិជ្ជាជីវៈមួយនេះនៅកម្ពុជាក៏ស្ថិតនៅឆ្ងាយនៅឡើយដែរ។ លុះត្រាណាតែមានសកម្មភាពច្រើននៅក្នុងវិស័យធានារ៉ាប់រងអាយុជីវិត និងសោធននិវត្តន៍ ទើបអាចមានការងារគ្រប់គ្រាន់ ដើម្បីទាក់ទាញអ្នកគណនាតម្លៃហានិភ័យចូលមកកម្ពុជាបាន។ អ្នកគណនាតម្លៃហានិភ័យប្រើប្រាស់នូវជំនាញបច្ចេកទេសចាំបាច់របស់ខ្លួនដើម្បីវាយតម្លៃកាតព្វកិច្ចរយៈពេលវែង ទាំងនៅក្នុងការធានារ៉ាប់រង ក៏ដូចជាសោធននិវត្តន៍ដែរ។ នៅក្នុងទីផ្សារដែលកំពុងអភិវឌ្ឍន៍ភាគច្រើន ជំនាញគណនាតម្លៃហានិភ័យចាំបាច់បែបនេះ ត្រូវបានទទួលតាមរយៈសេវាកម្មរបស់ការិយាល័យអន្តរជាតិដែលមានទីតាំងនៅក្នុងមជ្ឈមណ្ឌលសំខាន់ៗ។ ការណែនាំឱ្យមានប្រតិបត្តិការធានារ៉ាប់រងអាយុជីវិតនឹងនាំឱ្យមានការបង្កើតជាចាំបាច់នូវវិធានផ្សេងៗតាមក្រោយ។
- វិទ្យាស្ថានបណ្តុះបណ្តាល : បច្ចុប្បន្ននេះ ពុំទាន់មានស្ថាប័នបណ្តុះបណ្តាលខាងវិស័យធានារ៉ាប់រងនៅឡើយទេ។ ការកសាងសមត្ថភាពរបស់បុគ្គលិកក្រុមហ៊ុនធានារ៉ាប់រងឯកជន ក៏ដូចជាសម្រាប់មន្ត្រីត្រួតពិនិត្យ គឺជាការចាំបាច់ណាស់។ ក្នុងខណៈដែលវិស័យធានារ៉ាប់រងបានបង្ហាញនូវកំណើនមាំទាំហើយនោះ ក្នុងរយៈកាលមធ្យម គឺជាការសមស្របដើម្បីពិចារណាបង្កើតនូវវិទ្យាស្ថានបណ្តុះបណ្តាលនៅកម្ពុជា។ វិទ្យាស្ថាននេះអាចចូលរួមចំណែកបណ្តុះបណ្តាលដល់តំណាងលក់ ក៏ដូចជាមន្ត្រីត្រួតពិនិត្យ និងអ្នកគ្រប់គ្រង។
- កិច្ចការពារអតិថិជន និងការយល់ដឹងរបស់អតិថិជន : ធានារ៉ាប់រងគឺជាមុខរបរដែលពាក់ព័ន្ធនឹងកិច្ចសន្យា។ ដូច្នេះដើម្បីឱ្យមុខរបរប្រភេទនេះទទួលបាននូវប្រសិទ្ធភាពខ្ពស់ ភាគីទាំងពីរនៃកិច្ចសន្យា ត្រូវទទួលបាននូវព័ត៌មានគ្រប់គ្រាន់ពេញលេញមុននឹងធ្វើកិច្ចសន្យា។ ដំណោះស្រាយចំពោះការទាមទារសំណងណាមួយដែលកើតឡើងក្រោមកិច្ចសន្យា ត្រូវតែបានធ្វើឡើងស្របតាមលក្ខខណ្ឌដែលមានចែងនៅក្នុងកិច្ចសន្យា។ យោបល់ខុសគ្នាចំពោះដំណោះស្រាយនោះត្រូវតែជំរះតាមរយៈតុលាការ ឬក៏តាមរយៈប្រព័ន្ធដោះស្រាយជម្លោះផ្លូវការណាមួយ។ ដើម្បីគាំទ្រកិច្ចអភិវឌ្ឍន៍ កម្ពុជានឹងពិចារណាបង្កើតនូវអង្គភាពទទួលខុសត្រូវលើកិច្ចការរបស់អ្នកប្រើប្រាស់មួយដោយឡែកពីអង្គភាពត្រួតពិនិត្យ។ បន្ទាប់មកទៀត រដ្ឋាភិបាល និងវិស័យធានារ៉ាប់រងរួមគ្នាប្រកាន់យកវិធានការដើម្បីលើកកម្ពស់ចំណេះដឹងសាធារណជនឱ្យស្គាល់អ្វីជាធានារ៉ាប់រង និងតើសេវាអ្វីខ្លះដែលពួកគេអាចទទួលបានពីប័ណ្ណសន្យារ៉ាប់រង។ ការបណ្តុះបណ្តាលដល់អ្នកច្បាប់ និងតុលាការ ក៏គួរពិចារណាផងដែរ។
- តម្រូវឱ្យមានតារាងតម្លៃនិងឱ្យមានការឯកភាពគ្នាក្នុងការប្រើប្រាស់ពាក្យពេចន៍លើប័ណ្ណសន្យារ៉ាប់រង : សមាគមធានារ៉ាប់រងទូទៅនៃកម្ពុជានឹងបង្កើត និងស្នើនូវតារាងតម្លៃជាអប្បបរមាមួយ ដែលត្រូវកំណត់យកសម្រាប់សេវាធានារ៉ាប់រង

សាមញ្ញបំផុត ។ តារាងតម្លៃដែលបានស្នើឡើងត្រូវតែមានការគាំទ្រពីសំណាក់អ្នកមានវិជ្ជាជីវៈខាងវាយតម្លៃឯករាជ្យ ដើម្បីធានាថា តម្លៃនោះនឹងអាចគ្រប់គ្រាន់សម្រាប់ធានាដល់ការទូទាត់សំណងដែលអាចកើតឡើងនៅក្រោមប័ណ្ណសន្យារ៉ាប់រង ។ មន្ត្រីត្រួតពិនិត្យធានារ៉ាប់រងត្រូវទទួលស្គាល់តារាងតម្លៃនោះ និងដាក់បញ្ញត្តិថា អត្រាតម្លៃដែលគិតដោយក្រុមហ៊ុនមិនត្រូវតិចជាងអ្វីដែលបានកំណត់នៅក្នុងតារាងតម្លៃនេះឡើយ ។ ការរៀបចំនេះត្រូវបានធ្វើឡើងដើម្បីដាក់ឱ្យអនុវត្តនូវតារាងតម្លៃនោះ ។ ការប្រើប្រាស់រួមនូវពាក្យពេចន៍លើប័ណ្ណសន្យារ៉ាប់រងអាចត្រូវបានបញ្ជាក់ជាពិសេស ហើយនឹងត្រូវរំពឹងថាក្រុមហ៊ុនធានារ៉ាប់រងទាំងអស់អាចកំណត់ទំហំ និងលក្ខណៈនៃការទាមទារសំណងនូវការខូចខាតក្នុងលក្ខខណ្ឌដូចគ្នា ។ ការប្រើប្រាស់ពាក្យពេចន៍លើប័ណ្ណសន្យារ៉ាប់រងក៏ត្រូវតែដាក់ឱ្យអនុវត្តតាមផងដែរ ។

- ការសិក្សាលើលទ្ធភាពដែលអាចធ្វើបានចំពោះការអភិវឌ្ឍប្រព័ន្ធសោធននិវត្តន៍ឯកជន និងស្ម័គ្រចិត្តមួយសម្រាប់កម្ពុជា : គំរោងសោធននិវត្តន៍ឯកជនដែលត្រូវរៀបចំឡើងផ្អែកលើការស្ម័គ្រចិត្ត គឺជាការវិនិយោគជាស្ថាប័នដែលមានលក្ខណៈដូចក្រុមហ៊ុនធានារ៉ាប់រងដែរ ។ ចំពោះកម្មវិធីសន្តិសុខសង្គមនិងកម្មវិធីដែលចាំបាច់ផ្សេងៗទៀត ចំពោះការសន្សំសម្រាប់ការចូលនិវត្តន៍ គឺស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ស្ថាប័នទទួលបន្ទុកសុខមាលភាពសង្គម រីឯគំរោងសោធននិវត្តន៍ស្ម័គ្រចិត្ត និងការត្រួតពិនិត្យលើគំរោងនេះត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ការជម្រុញឱ្យមានការសន្សំស្ម័គ្រចិត្តសម្រាប់ការចូលនិវត្តន៍នឹងត្រូវបានទទួលជំនួយគាំទ្រជាច្រើន ប្រសិនបើមានការលើកទឹកចិត្តសារពើពន្ធដែលទាក់ទាញដល់រូបវន្តបុគ្គល ឬនិយោជក ក្នុងការរក្សាទុកមួយផ្នែកនូវប្រាក់ចំណូលបច្ចុប្បន្នជាប្រាក់សន្សំសម្រាប់ការចូលនិវត្តន៍ ។ ការបង្កើតនូវផែនការសោធននិវត្តន៍ ដែលជាអ្នកវិនិយោគជាស្ថាប័ន គឺជាកាតាលីករដែលអាចជួយសម្រួលដល់ការវិវឌ្ឍនៃទីផ្សារមូលប័ត្រក្នុងស្រុកផងដែរ ។

## *៤.៣ គោលដៅរយៈពេលវែង*

៤.៤៣ គោលដៅរយៈពេលវែង មានដូចជា ៖

- អនុវត្តច្បាប់ស្តីពីសន្តិសុខសង្គម ដោយរួមទាំងការដាក់ចេញនូវឧបករណ៍គាំទ្រដ៏សមស្រប ។
- អភិវឌ្ឍន៍ប្រព័ន្ធបទបញ្ញត្តិដើម្បីដោះស្រាយបញ្ហាសោធននិវត្តន៍ឯកជន ។ ចាំបាច់ត្រូវបូកបញ្ចូលនូវវិធានផ្តល់សិទ្ធិដល់និយោជកក្នុងការចូលរួមវិភាគទាន ការតម្រូវឱ្យមានមូលនិធិសម្រាប់ធានាដល់ផលប្រយោជន៍ លិខិតបញ្ជាក់ពីការគណនាតម្លៃហានិភ័យសម្រាប់គំរោងផលប្រយោជន៍ដែលបានកំណត់វិធាននៃការវិនិយោគដែលសង្កត់ធ្ងន់លើទិន្នផលខ្ពស់ដោយត្រូវការសុវត្ថិភាពខ្ពស់ផងដែរ និងសាច់ប្រាក់ងាយស្រួល ជាចាំបាច់ ។
- ពិនិត្យមើលលើគុណសម្បត្តិនៃការបញ្ចូលគំរោងសន្សំជាកាតព្វកិច្ច សម្រាប់ពលករនៅក្នុងវិស័យផ្លូវការ ដែលប្រហែលជាផ្នែកមួយនៃប្រព័ន្ធសន្តិសុខសង្គម ។ កម្មវិធីបែបនេះប្រហែលជាមិនចាំបាច់សម្រាប់កម្ពុជា ដោយសារថាប្រជាជនភាគច្រើនមានអាយុតិចហើយជាក់ស្តែងទស្សនៈដ៏ទូលំទូលាយក្នុងការគាំទ្រគ្រួសារនៅមានឥទ្ធិពលខ្លាំងក្លានៅឡើយ ។ប៉ុន្តែត្រូវទទួលស្គាល់ថាស្ថានភាពដូចនេះនឹងអាចផ្លាស់ប្តូរជាមួយ និងការធ្វើទំនើបភាវូបនីយកម្មកាន់តែទូលំទូលាយឡើង ។

## ខ. ទីផ្សារហិរញ្ញវត្ថុ

៤.៤៤ មិនដូចវិស័យផ្សេងៗដែលបានលើកឡើងខាងលើទេ ប្រទេសកម្ពុជាមិនទាន់បានអភិវឌ្ឍន៍ទីផ្សារហិរញ្ញវត្ថុនៅឡើយ ។

៤.៤៥ ទីផ្សាររូបិយវត្ថុ ជាទីផ្សារសម្រាប់ជួញដូរឧបករណ៍ហិរញ្ញវត្ថុដែលអាចជួញដូរបាន ដូចជា ប័ណ្ណ លិខិតបំណុល សញ្ញាប័ណ្ណរដ្ឋ និងប័ណ្ណភាគហ៊ុន និងសញ្ញាប័ណ្ណសាជីវកម្ម ។ ទីផ្សារហិរញ្ញវត្ថុរួមមានទីផ្សាររូបិយវត្ថុនិងអន្តរធនាគារ និងទីផ្សារទុន ។ ទីផ្សារអាចពាក់ព័ន្ធនឹងអន្តរការិយកម្ម ដូចជាទីផ្សារមូលប័ត្រ ប្រតិបត្តិកររក្សាទុកមូលប័ត្រ និងមូលនិធិវិនិយោគជាក្រុម និងមូលនិធិសោធននិវត្តន៍ ។ ទីផ្សារអន្តរធនាគារជាទីផ្សារសម្រាប់កម្ចីរយៈពេលខ្លី ជាទូទៅ ក្នុងរយៈពេលរវាង ២៤ម៉ោង និង ១២ខែ ជារឿយៗ ក្នុងទម្រង់ជាមូលប័ត្រ ដូចជាប័ណ្ណសងតាមបញ្ជា រវាងធនាគារនានា និងគ្រឹះស្ថានហិរញ្ញវត្ថុដទៃទៀត នៅក្នុងទីផ្សារហិរញ្ញវត្ថុដែលមានការអភិវឌ្ឍច្រើន ។ ទីផ្សាររូបិយវត្ថុ ជាទីផ្សារសម្រាប់ឥណទានរយៈពេលខ្លីដែលមានរយៈពេលតិចជាងមួយឆ្នាំ ជាទូទៅក្នុងទម្រង់ជាមូលប័ត្រ ដូចជា ប័ណ្ណសងតាមបញ្ជា និងសញ្ញាប័ណ្ណរដ្ឋរយៈពេលខ្លី ។ ទីផ្សារអន្តរធនាគារផ្តល់នូវយន្តការដ៏សំខាន់ក្នុងការកំណត់អត្រាការប្រាក់ ការគ្រប់គ្រងសាច់ប្រាក់ងាយស្រួល និងការគ្រប់គ្រងហានិភ័យដោយធនាគារ និងអន្តរការិយផ្សេងទៀត ។ ទីផ្សាររូបិយវត្ថុពង្រីកនូវយន្តការក្នុងការកំណត់ថ្លៃ ការគ្រប់គ្រងសាច់ប្រាក់ងាយស្រួល និងការគ្រប់គ្រងហានិភ័យទៅ ដល់រដ្ឋាភិបាលនិងក្រុមហ៊ុន ។ បច្ចុប្បន្ន ពុំទាន់មានទីផ្សាររូបិយវត្ថុនិងអន្តរធនាគារនៅកម្ពុជាឡើយ ទោះបីជាមានការអនុមតិច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាននិងប្រតិបត្តិការទូទាត់សងប្រាក់ និងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មនៅ ឆ្នាំ២០០៥ ពោលគឺមានមូលដ្ឋានច្បាប់ជាសំខាន់សម្រាប់ទីផ្សាររូបិយវត្ថុនិងអន្តរធនាគាររួចក៏ដោយ ។

៤.៤៦ ផ្ទុយទៅវិញ ទីផ្សារទុនពាក់ព័ន្ធនឹងឧបករណ៍ដែលមានរយៈពេលមួយឆ្នាំ ឬលើសពីនេះ (ទុន) ។ ទីផ្សារទុន រាប់បញ្ចូលទាំងទីផ្សារមូលប័ត្របំណុល ដូចជា សញ្ញាប័ណ្ណ និងទីផ្សារមូលប័ត្រកម្មសិទ្ធិ ដូចជា ភាគហ៊ុនរបស់ក្រុមហ៊ុន ក៏ដូចជានៅក្នុងទីផ្សារដែលមានការអភិវឌ្ឍឧបករណ៍និស្សន្ទ (ឧបករណ៍ដែលតម្លៃរបស់វាត្រូវបានគណនាពីតម្លៃឧបករណ៍ហិរញ្ញវត្ថុដំបូងមួយផ្សេងទៀត ដូចជាប័ណ្ណភាគហ៊ុន ឬសញ្ញាប័ណ្ណ) ។ ទីផ្សារទុនអាចផ្តល់នូវយន្តការមួយផ្សេងទៀត ក្រៅពីការផ្តល់ឥណទានរបស់ធនាគារ និងការវិនិយោគផ្ទាល់សម្រាប់ហិរញ្ញប្បទានរយៈពេលវែង ។ លើសពីនេះទៀត ទីផ្សារនេះអាចផ្តល់នូវជំរើសមួយផ្សេងទៀត ក្រៅពីការដាក់ប្រាក់បញ្ញើនៅធនាគារ ឬវិនិយោគលើប្រភេទនៃទ្រព្យសកម្មផ្សេងទៀត ដូចជាទ្រព្យសម្បត្តិ ។ ក្រៅពីនេះ ទីផ្សារទុនដែលដំណើរការល្អ អាចផ្តល់នូវព័ត៌មានដ៏មានសារៈសំខាន់អំពីសេដ្ឋកិច្ច និងការប្រព្រឹត្តទៅរបស់ក្រុមហ៊ុន ។ បច្ចុប្បន្ន មានចំនួនមូលប័ត្រតិចតួចណាស់ដែលបានបោះផ្សាយនៅកម្ពុជា ភាគច្រើនបោះផ្សាយដោយស្ថាប័នរដ្ឋបាលកណ្តាល និងសហគ្រាសពាក់ព័ន្ធ ។ បច្ចុប្បន្ន នៅពុំទាន់មានក្រុមហ៊ុនចុះបញ្ជីទីផ្សារមូលប័ត្រ ឬប្រតិបត្តិកររក្សាទុកមូលប័ត្ររួមទេ ទោះបីជាមូលដ្ឋានគតិយុត្តជាសំខាន់សម្រាប់ការអភិវឌ្ឍទីផ្សារនេះមានរួចហើយ តាមរយៈការអនុមតិច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម និងច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្ម និងវិជ្ជាជីវៈគណនេយ្យ ។

៤.៤៧ បន្ថែមទៅលើទីផ្សាររូបិយវត្ថុនិងអន្តរធនាគារ និងទីផ្សារទុន ទីផ្សារហិរញ្ញវត្ថុផ្សេងៗរួមមាន ទីផ្សារទំនិញ ដែលកិច្ចសន្យាសម្រាប់ការទិញនិងលក់ទំនិញមួយចំនួន ដូចជា មាស ឬស្រូវ អាចត្រូវបានជួញដូរ ។ ទីផ្សារនេះត្រូវបានគ្រោងប្រមូល

ផ្តុំនៅក្នុងមជ្ឈមណ្ឌលអន្តរជាតិផ្សេងៗ ហើយផ្តល់មុខងារដ៏សំខាន់ក្នុងការកំណត់ថ្លៃ ការគ្រប់គ្រងសាច់ប្រាក់ងាយស្រួល និងការគ្រប់គ្រងហានិភ័យដល់ការជួញដូរពាណិជ្ជកម្មដោយទំនិញនានា។ បច្ចុប្បន្ន ទោះបីជាមានទីផ្សារដែលមិនសូវមានភាពជាផ្លូវការបានកើតមានតាំងពីយូរហើយក្តីសម្រាប់ទំនិញកសិកម្មជាក់លាក់មួយចំនួន ក៏កម្ពុជាមិនទាន់មានទីផ្សារប្រមូលផ្តុំសម្រាប់ទំនិញនៅឡើយ ។

៤.៤៨ ជាចុងក្រោយ បន្ថែមលើនេះ ទីផ្សារហិរញ្ញវត្ថុដែលមានការអភិវឌ្ឍខ្ពស់ ក៏ត្រូវមានឧបករណ៍និស្សន្ទផងដែរ : ឧបករណ៍ហិរញ្ញវត្ថុដែលតម្លៃរបស់វាបានមកពីទ្រព្យសកម្មដំបូងផ្សេងទៀត ដូចជាប័ណ្ណភាគហ៊ុនរបស់ក្រុមហ៊ុនចុះបញ្ជីមូលប័ត្រទំនិញ ។ល។ ឧបករណ៍និស្សន្ទ នៅពេលដែលអភិវឌ្ឍន៍ដល់ចំណុចសមស្របនៅក្នុងប្រព័ន្ធហិរញ្ញវត្ថុ ហើយអាចផ្តល់នូវយន្តការដ៏សំខាន់សម្រាប់ការវិនិយោគនិងការគ្រប់គ្រងហានិភ័យ ។ បច្ចុប្បន្នទីផ្សារឧបករណ៍និស្សន្ទមិនទាន់មានទេនៅកម្ពុជាប៉ុន្តែអាចនឹងត្រូវបានលើកមកពិចារណា បើសិនជាទីផ្សាររូបិយវត្ថុនិងអន្តរធនាគារ និងទីផ្សារទុនដ៏មានប្រសិទ្ធភាព ត្រូវបានអភិវឌ្ឍហើយ ។

៤.៤៩ អ្នកចូលរួមនៅក្នុងទីផ្សារហិរញ្ញវត្ថុមានមូលនិធិវិនិយោគ ដូចជា មូលនិធិសង្គហៈ និងមូលនិធិសោធននិវត្តន៍ គ្រឹះស្ថានហិរញ្ញវត្ថុ ដូចជាធនាគារនិងក្រុមហ៊ុនធានារ៉ាប់រង និងអ្នកវិនិយោគជាឯកត្តជននិងសាជីវកម្ម ព្រមទាំងអន្តរការិយនានា ដូចជាភ្នាក់ងារទិញលក់មូលប័ត្រ ឬប្រតិបត្តិកររក្សាទុកមូលប័ត្រ និងប្រព័ន្ធផាត់ទាត់មូលប័ត្រជាដើម ។ បច្ចុប្បន្នពុំមានមូលនិធិវិនិយោគ ប្រតិបត្តិកររក្សាទុកមូលប័ត្រ ឬប្រព័ន្ធផាត់ទាត់មូលប័ត្រនៅកម្ពុជាទេ ហើយធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងក្រុមហ៊ុនធានារ៉ាប់រង ក៏មិនមានពាក់ព័ន្ធជាមួយនឹងធុរកិច្ចមូលប័ត្រកម្ពុជាដែរ ។

៤.៥០ ជារួម ទីផ្សារហិរញ្ញវត្ថុអាចផ្តល់នូវអត្ថប្រយោជន៍មួយចំនួនដល់ប្រព័ន្ធហិរញ្ញវត្ថុ រួមមាន ៖

- ហិរញ្ញវត្ថុ
- ព័ត៌មាន
- សាច់ប្រាក់ងាយស្រួល និង
- អភិបាលកិច្ចសាជីវកម្ម ។

ទន្ទឹមនេះ ទោះជាយ៉ាងណា ក៏ទីផ្សារហិរញ្ញវត្ថុមិនមែនជាកត្តាគ្រប់គ្រាន់សម្រាប់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុឡើយ : បទពិសោធន៍នៅលើពិភពលោកបង្ហាញថា ទីផ្សារហិរញ្ញវត្ថុមិនងាយទទួលបានជោគជ័យក្នុងការបញ្ចៀសបញ្ហានៅក្នុងវិស័យធនាគារឡើយ ។ លើសពីនេះទៀត បទពិសោធន៍នៅលើពិភពលោកក៏បានបង្ហាញដែរថាទីផ្សារហិរញ្ញវត្ថុដ៏មានប្រសិទ្ធភាពមិនងាយស្រួលនឹងអភិវឌ្ឍទេ ទោះបីជានៅក្នុងប្រទេសដែលមានការអភិវឌ្ឍក៏ដោយ ។

## ១. ការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុនៅកម្ពុជា

៤.៥១ រាជរដ្ឋាភិបាលកម្ពុជាកំពុងតែគាំទ្រការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុនៅកម្ពុជា ដោយមានហេតុផល ៣ ដូចខាងក្រោម ៖

- ក្នុងរយៈពេលខ្លី ដើម្បីដោះស្រាយហានិភ័យដែលកើតឡើងនៅក្នុងប្រព័ន្ធហិរញ្ញវត្ថុ
- ក្នុងរយៈពេលអន្តរកាល ដើម្បីបំបាត់នូវឧបសគ្គដែលរាំងស្ទះដល់ការអភិវឌ្ឍន៍ហិរញ្ញវត្ថុនៅក្នុងវិស័យផ្សេងៗទៀត
- ក្នុងរយៈពេលមធ្យមទៅវែង ដើម្បីអភិវឌ្ឍន៍យន្តការមួយផ្សេងៗទៀតសម្រាប់ការធ្វើហិរញ្ញប្បទាន និងវិនិយោគ ។

### ១.១ *អាទិភាពទី១ : ការដោះស្រាយហានិភ័យ*

៤.៥២ អាទិភាពទី១ នៅក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ គឺត្រូវដោះស្រាយហានិភ័យជាសក្តានុពលចំពោះស្ថិរភាពហិរញ្ញវត្ថុ ។ ក្នុងបរិបទនេះ មានការបារម្ភចំបង ២ នាពេលបច្ចុប្បន្ន : ការរីកដុះដាលនៃគំរោងអូសទាញបោកបញ្ឆោតបន្ត និងការក្លែងបន្លំផ្នែកហិរញ្ញវត្ថុ និងការអភិវឌ្ឍជាសក្តានុពលនូវការចុះបញ្ជីមូលប័ត្រដែលកំពុងមានភាពប្រកួតប្រជែងសម្រាប់មូលប័ត្ររបស់ក្រុមហ៊ុនមហាជន ។

៤.៥៣ ទាក់ទងទៅនឹងគំរោងអូសទាញបោកបញ្ឆោតបន្ត និងការក្លែងបន្លំ ប្រការនេះអាចមានបច្ច័យជាអវិជ្ជមានធំៗចំពោះស្ថិរភាពហិរញ្ញវត្ថុ និងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ តាមរយៈការបាត់បង់ដ៏សំខាន់ជាសក្តានុពលនូវជំនឿទុកចិត្តរបស់សាធារណជនចំពោះប្រព័ន្ធហិរញ្ញវត្ថុ និងក្របខ័ណ្ឌគ្រប់គ្រងនិងក្របខ័ណ្ឌត្រួតពិនិត្យរបស់ខ្លួន ។ គំរោងអូសទាញបោកបញ្ឆោតបន្ត និងការក្លែងបន្លំហិរញ្ញវត្ថុ កំពុងរីកដុះដាលនៅប្រទេសកម្ពុជា ដូច្នេះត្រូវមានប្រព័ន្ធមួយដើម្បីការពារសាធារណជនទប់ទល់នឹងសកម្មភាពប្រភេទទាំងនេះ ។ ជាបន្ថែម គួរធ្វើយ៉ាងណា ឱ្យសាធារណជនយល់ដឹងកាន់តែច្រើនឡើងអំពីការក្លែងបន្លំ និងហានិភ័យ តាមរយៈសកម្មភាពផ្សព្វផ្សាយការយល់ដឹងជាសាធារណៈ ។

៤.៥៤ ចំពោះការចុះបញ្ជីមូលប័ត្រ ការអនុមតិច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មនៅឆ្នាំ២០០៥ គឺជាជំហានមួយដ៏សំខាន់សម្រាប់ឈានទៅអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ប៉ុន្តែទន្ទឹមនេះ ច្បាប់នេះក៏នាំមកជាមួយនូវហានិភ័យថ្មីៗមួយចំនួនដែរ ។ កត្តាសំខាន់ជាងគេនៃហានិភ័យទាំងនេះស្ថិតនៅក្នុងក្របខ័ណ្ឌសម្រាប់ក្រុមហ៊ុនមហាជនដែលបានបង្កើតឡើងនៅក្រោមច្បាប់នេះ ។ បច្ចុប្បន្នពុំមានក្រុមហ៊ុនមហាជនត្រូវបានចុះបញ្ជីទេ ។ បើសិនជាក្រុមហ៊ុនមហាជនត្រូវបានអនុញ្ញាតនៅក្រោមកាលៈទេសៈបច្ចុប្បន្នឱ្យចុះបញ្ជី រួចហើយក្រុមហ៊ុនមហាជនត្រូវបានបង្កើតឡើង បែបនេះអាចបង្កើតហានិភ័យដល់អ្នកវិនិយោគ និងដល់ជំនឿទុកចិត្តរបស់សាធារណជន ជាពិសេសតាមរយៈលទ្ធភាពអភិវឌ្ឍន៍ការចុះបញ្ជីមូលប័ត្រដ៏ប្រកួតប្រជែងនៅក្នុងបរិបទនៃជម្លោះអំពីកម្មសិទ្ធិ ។ ការអភិវឌ្ឍបែបនេះនឹងអាចមានគ្រោះថ្នាក់ណាស់ចំពោះជំនឿទុកចិត្តទៅលើក្រុមហ៊ុន និងមូលដ្ឋានគតិយុត្តរបស់ក្រុមហ៊ុនទាំងនោះ ។

## ១.២ អាទិភាពទី២ ៖ ការបំបាត់ឧបសគ្គដល់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ

៤.៥៥ អាទិភាពទី២ ចំពោះរាជរដ្ឋាភិបាលកម្ពុជា គឺដើម្បីអភិវឌ្ឍន៍នូវទស្សនាទាននៃទីផ្សារហិរញ្ញវត្ថុ ដែលការមិនទាន់មានទស្សនាទាននេះ បង្កើតជាឧបសគ្គដល់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុជាទូទៅ។ ទស្សនាទានទាំងនេះមួយចំនួន ត្រូវបានលើកឡើងជាពិសេសដូចខាងក្រោម ៖

- ការកែលំអការងារគ្រប់គ្រងសារពើពន្ធរបស់រាជរដ្ឋាភិបាល
- ការកែលំអឧបករណ៍គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច
- ការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ជាតិដុល និង
- ការអភិវឌ្ឍទីផ្សាររូបិយវត្ថុនិងអន្តរធនាគារ។

៤.៥៦ សម្រាប់ទស្សនាទានទាំងនេះ ការអភិវឌ្ឍទីផ្សារមួយសម្រាប់មូលប័ត្ររដ្ឋ ជាពិសេសមូលប័ត្ររដ្ឋរយៈពេលខ្លី អាចមានតួនាទីយ៉ាងសំខាន់។

## ១.៣ អាទិភាពទី៣ ៖ យន្តការវិនិយោគ និងហិរញ្ញប្បទាន

៤.៥៧ នៅក្នុងរយៈពេលមធ្យមទៅវែង ទីផ្សារហិរញ្ញវត្ថុអាចផ្តល់នូវយន្តការមួយដើម្បីគាំទ្រដល់ការធ្វើហិរញ្ញប្បទាន និងវិនិយោគ។ ទន្ទឹមនេះ ចាំបាច់ត្រូវអភិវឌ្ឍន៍ក្របខ័ណ្ឌវឌ្ឍនភាពសម្រាប់ការអភិវឌ្ឍក្រុមហ៊ុន ដែលអាចលើកទឹកចិត្តដល់ការអភិវឌ្ឍក្រុមហ៊ុន និងធនធានមនុស្ស។

៤.៥៨ ក្នុងបរិបទនេះ ទិសដៅគឺត្រូវបង្កើតក្របខ័ណ្ឌវឌ្ឍនភាព មានការអភិវឌ្ឍ និងដែលមានការលើកទឹកចិត្ត សម្រាប់ការអភិវឌ្ឍក្រុមហ៊ុន។ ដូចដែលបានពិភាក្សានៅក្នុងបរិបទនៃជំពូកមូលដ្ឋានគ្រឹះនៃវិស័យហិរញ្ញវត្ថុ (ជំពូកទី ១) ក្របខ័ណ្ឌបែបនេះត្រូវផ្តល់នូវប្រព័ន្ធមួយដោយឡែកតាមលំដាប់ក្នុងការដោះស្រាយជាមួយ ៖

- ក្រុមហ៊ុនតូចៗ
- ក្រុមហ៊ុនឯកជនផ្សេងៗទៀត
- ក្រុមហ៊ុនមហាជន និង
- (បើសិនជាមានតម្រូវការ) ក្រុមហ៊ុនចុះបញ្ជី។

បើសិនជាក្រុមហ៊ុនមហាជន ជាចុងក្រោយ បានប្រែក្លាយទៅក្រុមហ៊ុនចុះបញ្ជីដែលមានមូលប័ត្រលក់ឱ្យទៅសាធារណជនតាមរយៈទីផ្សារមូលប័ត្រ នៅពេលនោះ វាជាប្រការសំខាន់ដែលត្រូវចាប់ផ្តើមពីឥឡូវ ដើម្បីគាំទ្រដល់ការអភិវឌ្ឍវិស័យដែលពាក់ព័ន្ធ។

## ២. ទិសដៅ និងបទពិសោធន៍អន្តរជាតិ

៤.៥៩ ជាទិសដៅគឺការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុ ដែលដោះស្រាយហានិភ័យបានយ៉ាងសមស្រប បំបាត់នូវឧបសគ្គទាំងឡាយចំពោះការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ទ្រទ្រង់ការគ្រប់គ្រងហានិភ័យ និងកេណ្ឌប្រមូលនិងបែងចែកធនធានហិរញ្ញវត្ថុ។

៤.៦០ បទពិសោធន៍ជាអន្តរជាតិបានបង្ហាញថា វាជាការលំបាកណាស់ក្នុងការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុមានប្រសិទ្ធភាព។ ប្រការនេះត្រូវបានបង្ហាញតាមរយៈការងារជាង៤០ឆ្នាំកន្លងមកនេះនៅក្នុងសហគមន៍អឺរ៉ុប ជាពិសេសប្រទេសដែលមានប្រព័ន្ធច្បាប់ស៊ីវិល និងជាង២០ឆ្នាំកន្លងមកតាមរយៈបទពិសោធន៍នៅប្រទេសរុស្ស៊ី អឺរ៉ុបកណ្តាលនិងខាងកើត អាស៊ី និងចិន។

៤.៦១ ទន្ទឹមនេះ មេរៀនវិជ្ជមានសំខាន់ៗមួយចំនួនបានកើតឡើងចេញពីបណ្តាប្រទេសដែលចង់អភិវឌ្ឍន៍ទីផ្សារហិរញ្ញវត្ថុ។ ក្របខ័ណ្ឌច្បាប់ដ៏មានប្រសិទ្ធភាពគឺជាប្រការសំខាន់ដើម្បីឱ្យទីផ្សារអភិវឌ្ឍន៍។ ក្របខ័ណ្ឌគតិយុត្តគួរតែរៀបចំឡើងដើម្បីគាំទ្រ ៖

- ការការពារអ្នកវិនិយោគ
- ការធានាឱ្យទីផ្សារមានលក្ខណៈស្មើភាព ប្រសិទ្ធភាព និងតម្លាភាព និង
- ការកាត់បន្ថយហានិភ័យជាប្រព័ន្ធ។

ព័ត៌មានហិរញ្ញវត្ថុដែលមានគុណភាពខ្ពស់គឺជាប្រការដ៏មានសារៈសំខាន់ណាស់ដើម្បីឱ្យទីផ្សារនានាមានដំណើរការ។ ការដាក់ឱ្យអនុវត្តប្រកបដោយប្រសិទ្ធភាពតាមលក្ខខណ្ឌហិរញ្ញវត្ថុនិងលក្ខខណ្ឌបង្ហាញព័ត៌មានផ្សេងៗ ការការពារចំពោះការក្លែងបន្លំ និងការប្រព្រឹត្តកំហុសទីផ្សារ ហើយការការពារសិទ្ធិរបស់ភាគហ៊ុនិក គឺជាមូលដ្ឋានគ្រឹះក្នុងការកសាងទំនុកចិត្តលើទីផ្សារហិរញ្ញវត្ថុឱ្យបានគ្រប់គ្រាន់ដើម្បីឱ្យទីផ្សារនោះកាន់តែមានប្រយោជន៍ចំពោះភាគហ៊ុនិក។

៤.៦២ ក្នុងការស្វែងរកការគាំទ្រដល់ការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុនៅកម្ពុជា រដ្ឋាភិបាលត្រូវអនុវត្តតាមបទពិសោធន៍ និងស្តង់ដារអន្តរជាតិ និងតំបន់ រួមទាំងទិសដៅនិងគោលការណ៍របស់អង្គការអន្តរជាតិនៃគណៈកម្មការមូលប័ត្រ (IOSCO) និងបទពិសោធន៍ និងស្តង់ដារអាស៊ានដែលកំពុងតែវិវត្ត សម្រាប់អភិវឌ្ឍន៍ទីផ្សារសញ្ញាប័ណ្ណ និងទីផ្សារភាគហ៊ុន។

## ៣. ក្របខ័ណ្ឌគតិយុត្តសម្រាប់ទីផ្សារហិរញ្ញវត្ថុ

៤.៦៣ វិស័យមួយចំនួននៃក្របខ័ណ្ឌច្បាប់ត្រូវតែមានដើម្បីឱ្យទីផ្សារហិរញ្ញវត្ថុអភិវឌ្ឍន៍ ៖

- ច្បាប់ក្រុមហ៊ុន : ប្រទេសកម្ពុជាបានអនុម័តច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម នៅឆ្នាំ២០០៥។
- ក្រមរដ្ឋប្បវេណី និងច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម : ច្បាប់ទាំងនេះមិនទាន់ត្រូវបានអនុម័តទេ ក៏ប៉ុន្តែ រំពឹងថានឹងត្រូវបានអនុម័តនៅពេលអនាគតដ៏ខ្លីខាងមុខ។ លើសពីនេះទៀត ច្បាប់ស្តីពីភ្នាក់ងារ នឹងត្រូវបានអនុម័តក្នុងពេលឆាប់ៗនេះ។

- ផ្នែកពន្ធដារ : ផ្នែកពន្ធដារត្រូវបានកែលំអ ប៉ុន្តែទាមទារឱ្យមានការធ្វើកាន់តែសាមញ្ញ និងធ្វើការបញ្ជាក់បន្ថែមទៀត នៅក្នុងបរិបទកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីកុំឱ្យខ្វាស់ជាមួយនឹងការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុ ។
- ច្បាប់ស្តីពីក្ស័យធន : ច្បាប់ស្តីពីក្ស័យធនត្រូវបានរំពឹងថានឹងត្រូវបានអនុម័តនាពេលឆាប់ៗខាងមុខ ។
- ច្បាប់ស្តីពីការប្រកួតប្រជែង : ច្បាប់នេះបច្ចុប្បន្នកំពុងត្រូវបានរៀបចំ ។
- ច្បាប់ធនាគារ : បញ្ហាពាក់ព័ន្ធមានពិភាក្សានៅក្នុងជំពូកស្តីពីធនាគារ និងមីក្រូហិរញ្ញវត្ថុ ( ជំពូកទី ៣) ។
- ប្រព័ន្ធដោះស្រាយជម្លោះ : ដូចបានពិភាក្សាខាងលើ ប្រព័ន្ធនេះនៅតែជាការបារម្ភនៅកម្ពុជា ទោះបីជា មជ្ឈត្តការពាណិជ្ជកម្ម និងយន្តការដោះស្រាយជម្លោះថ្នាក់ខេត្ត អាចជាមធ្យោបាយមួយដើម្បីដោះស្រាយបញ្ហាមួយចំនួន មុនពេលដែលតុលាការពាណិជ្ជកម្មត្រូវបានបង្កើតឡើងក៏ដោយ ។

## ៤. អាទិភាពសម្រាប់ឆ្នាំ២០០៦-២០១៥ : ទីផ្សារហិរញ្ញវត្ថុ

៤.៦៤ ដូចបានពិភាក្សាខាងលើ អាទិភាពទី១ គឺត្រូវដោះស្រាយហានិភ័យ ដូចជាគំរោងអូសទាញបោកបញ្ឆោតបន្ត និងការក្លែងបន្លំ ក៏ដូចជាត្រូវបង្កើតប្រតិបត្តិកររក្សាទុកមូលប័ត្ររួម សម្រាប់មូលប័ត្ររបស់ក្រុមហ៊ុនមហាជនទាំងអស់ ។ អាទិភាពទី២ គឺត្រូវបំបាត់ឧបសគ្គចំពោះការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ដោយផ្តោតទៅលើការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់និងផាត់ទាត់ជាតិដុល និងការអភិវឌ្ឍទីផ្សាររូបិយវត្ថុនិងអន្តរធនាគារ រួមទាំង មូលប័ត្ររដ្ឋរយៈពេលខ្លី ។ អាទិភាពទី៣ គឺត្រូវគាំទ្រដល់ការអភិវឌ្ឍយន្តការវិនិយោគ និងហិរញ្ញប្បទានដ៏មានប្រសិទ្ធភាព ដោយផ្តោតទៅលើការបង្កើតឡើងនូវប្រព័ន្ធមួយដែលមានភាពរីកចំរើនមានវឌ្ឍនភាព និងដែលផ្អែកលើការលើកទឹកចិត្តសម្រាប់ក្រុមហ៊ុន ។

### *៤.១ ទីផ្សាររូបិយវត្ថុនិងអន្តរធនាគារ*

៤.៦៥ ឥឡូវនេះ ក្របខ័ណ្ឌគតិយុត្តជាមូលដ្ឋានគ្រឹះសម្រាប់ទីផ្សាររូបិយវត្ថុនិងអន្តរធនាគារ មានរួចហើយជាមួយនឹងការអនុមតិច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ។ ទន្ទឹមនេះ ទីផ្សាររូបិយវត្ថុនិងអន្តរធនាគារ ប្រហែលជាមិនអាចអភិវឌ្ឍន៍បានដោយគ្មានប្រព័ន្ធទូទាត់សងប្រាក់ ដែលមានសុវត្ថិភាពនិងប្រសិទ្ធភាព និងការកើនឡើងនូវជំនឿទុកចិត្តក្នុងចំណោមគ្រឹះស្ថានហិរញ្ញវត្ថុដែលនឹងត្រូវអភិវឌ្ឍន៍ នៅពេលដែលការគ្រប់គ្រងនិងការត្រួតពិនិត្យត្រូវបានកែលំអ ។ ក្រៅពីភាពចាំបាច់ចំពោះមុខទាំងនេះ ការអភិវឌ្ឍទីផ្សាររូបិយវត្ថុនិងអន្តរធនាគារ អាចត្រូវបានគាំទ្រតាមរយៈការបោះផ្សាយមូលប័ត្ររយៈពេលខ្លីដែលអាចព្យាករណ៍មុនបាន ដើម្បីបង្កើតជាមូលដ្ឋាននៃខ្សែកោងរបាយអត្រាការប្រាក់និងទ្រទ្រង់ដល់លំហូរសាច់ប្រាក់ងាយស្រួល និងការគ្រប់គ្រងហានិភ័យ ឧទាហរណ៍ : ប្រាតិភោគនៅក្នុងប្រព័ន្ធទូទាត់សងប្រាក់ ។

៤.៦៦ ច្បាប់ស្តីពីមូលប័ត្ររដ្ឋត្រូវបានរដ្ឋសភាអនុម័តនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៦ ។ ច្បាប់នេះផ្តល់នូវមូលដ្ឋានសម្រាប់ការអភិវឌ្ឍទីផ្សារមូលប័ត្ររដ្ឋរយៈពេលខ្លី ប៉ុន្តែនឹងទាមទារឱ្យមានវិធានការសំខាន់ៗដែលត្រូវអនុវត្ត មុនពេលមូលប័ត្រនេះអាចត្រូវបានបោះផ្សាយប្រកបដោយជោគជ័យ ។

៤.៦៧ ទីផ្សាររូបិយវត្ថុនិងអន្តរធនាគារ : ដំណាក់កាលចំពោះមុខ

- ប្រព័ន្ធទូទាត់សងប្រាក់ជាតិដុល : បញ្ហានេះត្រូវបានពិភាក្សានៅក្នុងបរិបទធនាគារ និងមីក្រូហិរញ្ញវត្ថុ (ជំពូកទី ៣) និងនៅជំពូកមូលដ្ឋានគ្រឹះនៃវិស័យហិរញ្ញវត្ថុ (ជំពូកទី ២)
- កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបន្តក្រោមការដឹកនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ប្រព័ន្ធមូលប័ត្ររដ្ឋអេឡិចត្រូនិច ភ្ជាប់ទៅនឹងប្រព័ន្ធចុះបញ្ជីប្រតិបត្តិការមានកិច្ចធានា លក្ខខណ្ឌដើមទុនសម្រាប់គ្រឹះស្ថានហិរញ្ញវត្ថុ និងប្រព័ន្ធទូទាត់សងប្រាក់ជាតិដុល ដែលស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា។ ការអភិវឌ្ឍនឹងចាប់ផ្តើមជាមួយការបោះផ្សាយប័ណ្ណរយៈពេលខ្លី មានរយៈពេលតិចជាង១ឆ្នាំ ដោយគួរចាប់ផ្តើមជាមួយសញ្ញាប័ណ្ណដែលមានរយៈពេល ៣០ថ្ងៃ។

៤.៦៨ ទីផ្សាររូបិយវត្ថុនិងអន្តរធនាគារ : ដំណាក់កាលអន្តរកាល

- មូលដ្ឋានសម្រាប់ដំណាក់កាលបន្ទាប់នៃការអភិវឌ្ឍ គឺការបញ្ចប់នូវដំណាក់កាលចំពោះមុខខាងលើ
- បន្តពង្រឹងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ពង្រីកឥណប្រតិទាននៃមូលប័ត្ររដ្ឋដោយផ្អែកលើការណែនាំ និងការត្រៀមលក្ខណៈសមស្រប
- ពិចារណាលើការអនុញ្ញាតឱ្យគ្រឹះស្ថានហិរញ្ញវត្ថុដែលកំពុងស្ថិតក្រោមការគ្រប់គ្រង ជាដំបូង ធនាគារ បន្ទាប់មក ពង្រីកទៅដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណស្រាប់ បោះផ្សាយលក់ផលប័ត្រពាណិជ្ជកម្មរយៈពេលខ្លី (១ឆ្នាំ ឬតិចជាង) តាមរយៈប្រព័ន្ធមូលប័ត្ររដ្ឋដែលបង្កើតបានជាមូលដ្ឋានសម្រាប់ទីផ្សាររូបិយវត្ថុនិងអន្តរធនាគារពិតប្រាកដមួយ។

## *៤.២ ទីផ្សារទុន*

៤.៦៩ ច្បាប់ស្តីពីគណនីសហគ្រាស សវនកម្ម និងវិជ្ជាជីវៈគណនេយ្យ និងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ផ្តល់នូវក្របខ័ណ្ឌជាមូលដ្ឋានសម្រាប់ក្រុមហ៊ុន ព័ត៌មានហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងមូលប័ត្ររបស់ក្រុមហ៊ុន។ តែទោះជាយ៉ាងណា មូលដ្ឋានច្បាប់ទាំងអស់នេះនៅមានខ្លឹមសារមិនទាន់គ្រប់គ្រាន់ ដើម្បីទ្រទ្រង់ដល់ការអភិវឌ្ឍទីផ្សារទុនឡើយ។

### ទីផ្សារទុន : ដំណាក់កាលចំពោះមុខ

៤.៧០ ដើម្បីដោះស្រាយហានិភ័យ (អាទិភាពទី១) ដំណាក់កាលមួយចំនួនចាំបាច់ត្រូវអនុវត្តជាបន្ទាន់៖

- មិនត្រូវអនុញ្ញាតឱ្យមានការចុះបញ្ជីជាទូទៅរបស់ក្រុមហ៊ុនមហាជនរហូតទាល់តែមានក្របខ័ណ្ឌគ្រប់គ្រងសមស្រប រួមទាំង៖
  - ការអនុមតិច្បាប់ស្តីពីក្ស័យធន
  - ការព្រមព្រៀងនូវសមាសធាតុក្របខ័ណ្ឌបំប្លែងទម្រង់ក្រុមហ៊ុន រួមទាំងលក្ខខណ្ឌតាមលំដាប់សម្រាប់ក្រុមហ៊ុនតូច ក្រុមហ៊ុនឯកជនផ្សេងៗ ក្រុមហ៊ុនមហាជន និងក្រុមហ៊ុនចុះបញ្ជី

- ការយល់ដឹងជាសាធារណៈ ការអប់រំអ្នកវិនិយោគ និងការអភិវឌ្ឍធនធានមនុស្ស ដើម្បីទ្រទ្រង់ដល់ការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុ ខណៈដែលអាចជួយកាត់បន្ថយវិសាលភាព និងភាពងាយរងគ្រោះនៃការប្រព្រឹត្តកំហុសទីផ្សារ
- ទីផ្សាររូបិយវត្ថុនិងអន្តរធនាគារ : ការបញ្ចប់អាទិភាពចំពោះមុខ
- បន្តធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពគណនេយ្យនិងសវនកម្ម
- បង្កើតភាពជាដៃគូជាមួយទីផ្សារមូលប័ត្របរទេស ដើម្បីជំនួយដល់ការអភិវឌ្ឍទីផ្សារទុនក្នុងស្រុក ។

៤.៧១ នៅពេលដែលសមាសធាតុទាំងនេះមានរួចហើយ ព្រមជាមួយនិងការផ្អាកដំណើរចុះបញ្ជីក្រុមហ៊ុនមហាជន ដំណាក់កាលបន្ទាប់គឺការអនុមតិច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលប័ត្រមហាជន ដែលយ៉ាងហោចណាស់ផ្តល់នូវ ៖

- ក្របខ័ណ្ឌប្រតិបត្តិ និងអាជ្ញាធរប្រតិបត្តិសមស្របមួយ សម្រាប់ត្រួតពិនិត្យការក្លែងបន្លំហិរញ្ញវត្ថុ និងគំរោងអូសទាញបោកបញ្ឆោតបន្ត ។ល ។ ស្របតាមស្តង់ដារអន្តរជាតិ ។
- ប្រតិបត្តិកររក្សាទុកមូលប័ត្រអេឡិចត្រូនិចរួមសម្រាប់មូលប័ត្ររបស់ក្រុមហ៊ុនមហាជនទាំងអស់ ដែលភ្ជាប់ទៅនឹងប្រព័ន្ធចុះបញ្ជីប្រតិបត្តិការមានកិច្ចធានា ។

៤.៧២ លើសពីនេះទៀតចាំបាច់ត្រូវធ្វើការលើកកម្ពស់ជាបន្តបន្ទាប់នូវសមត្ថភាពគណនេយ្យនិងសវនកម្មដូចបានពិភាក្សានៅជំពូកមូលដ្ឋានគ្រឹះនៃវិស័យហិរញ្ញវត្ថុ (ជំពូកទី ២) ។

## ទីផ្សារទុន : ដំណាក់កាលអន្តរកាល

៤.៧៣ ឈរលើមូលដ្ឋាននៃការបញ្ចប់ដំណាក់កាលចំពោះមុខ ៖

- អនុវត្តក្របខ័ណ្ឌវឌ្ឍនភាពសម្រាប់ក្រុមហ៊ុន
- បង្កើតប្រតិបត្តិកររក្សាទុកមូលប័ត្ររួមសម្រាប់មូលប័ត្រក្រុមហ៊ុនមហាជនទាំងអស់ និងចាប់ផ្តើមការចុះបញ្ជីជាទូទៅនូវក្រុមហ៊ុនមហាជន។ ប្រការនេះនឹងបង្កើតបានជាមូលដ្ឋានគ្រឹះសម្រាប់ទីផ្សារមូលប័ត្រមហាជន និងបញ្ចូលនូវការចុះបញ្ជីឈ្មោះពិតប្រាកដ ទិន្នន័យថ្លៃ ព្រមទាំងមូលប័ត្របំណុល និងមូលប័ត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនមហាជន ហើយជាពិសេសអាចដាក់ឱ្យដំណើរការជាប្រភេទទីផ្សារមូលប័ត្រក្រុមហ៊ុនមហាជនរំលងបញ្ជរ ។

## ទីផ្សារទុន : អាទិភាពរយៈពេលមធ្យម

៤.៧៤ ឈរលើមូលដ្ឋាននៃការបញ្ចប់ដំណាក់កាលចំពោះមុខ និងអន្តរកាល ៖

- អនុវត្តប្រព័ន្ធគ្រប់គ្រង និងប្រព័ន្ធបង្ខំឱ្យអនុវត្ត តាមរយៈស្ថាប័នសមស្រប
- បន្តគាំទ្រដល់ការអភិវឌ្ឍព័ត៌មានហិរញ្ញវត្ថុ និងក្រុមហ៊ុននានា
- ពិចារណាលើការបង្កើតទីផ្សារមូលប័ត្រផ្លូវការ ដោយផ្អែកលើការបង្កើតប្រតិបត្តិកររក្សាទុកមូលប័ត្រ ក្រុមហ៊ុនមហាជន

ដោយធ្វើការសិក្សាអំពីលទ្ធភាពដែលអាចធ្វើបានជាមុនសិន

- ការអភិវឌ្ឍក្របខ័ណ្ឌនៃការផ្តល់អាជ្ញាប័ណ្ណ និងក្របខ័ណ្ឌគ្រប់គ្រងសមស្រប សម្រាប់អន្តរការីមូលប័ត្រ រួមបញ្ចូលទាំងធនាគារ ក្រុមហ៊ុនធានារ៉ាប់រង និងក្រុមហ៊ុនមូលប័ត្រ
- សំណើលក់មូលប័ត្រជាសាធារណៈអាចត្រូវបានអនុញ្ញាតតែតាមរយៈទីផ្សារមូលប័ត្រផ្លូវការនិងតែតាមរយៈការបោះផ្សាយដោយក្រុមហ៊ុនមហាជន រួមទាំង សម្រាប់មូលនិធិវិនិយោគ។ គ្មានក្រុមហ៊ុនណា មួយត្រូវបានអនុញ្ញាតឱ្យធ្វើសំណើលក់មូលប័ត្រមហាជនជាសាធារណៈឡើយ លើកលែងតែក្រុមហ៊ុន នោះជាក្រុមហ៊ុនមហាជន ហើយត្រូវបានធ្វើឡើងតាមរយៈការចុះបញ្ជីលក់នៅក្នុងទីផ្សារមូលប័ត្រ។ ការធ្វើសំណើលក់ជាលក្ខណៈឯកជននឹងត្រូវបានអនុញ្ញាត សម្រាប់តែក្រុមហ៊ុនមហាជន និងក្រុមហ៊ុន ចុះបញ្ជី។
- គំរោងសំណងព្យសនកម្មទៅអ្នកវិនិយោគ : នៅពេលដែលគ្រឹះស្ថានហិរញ្ញវត្ថុអាចនឹងប្រកបអាជីវកម្ម មូលប័ត្រ ចាំបាច់ត្រូវពិចារណាការអភិវឌ្ឍនូវក្របខ័ណ្ឌសមស្រប និងផ្អែកលើមូលដ្ឋានទីផ្សារសម្រាប់ ផ្តល់សំណងព្យសនកម្មទៅអ្នកវិនិយោគនៅក្នុងករណីដែលក្រុមហ៊ុនមូលប័ត្រដួលរលំ។

## ទីផ្សារទុន : ទិសដៅសម្រាប់រយៈពេលវែង

៤.៧៥ ឈរលើមូលដ្ឋានដំណាក់កាលមុននេះ កម្ពុជាអាចពិចារណាទៅលើទិដ្ឋភាពមួយចំនួនផ្សេងទៀតរបស់ទីផ្សារទុននៅក្នុងរយៈពេលវែង៖

- មូលនិធិវិនិយោគ : នៅពេលចាប់ផ្តើម មូលនិធិវិនិយោគមិនត្រូវបានអនុញ្ញាតឱ្យបង្កើតឡើងទេ រហូតទាល់តែមានកាលានុវត្តភាពវិនិយោគ រួមទាំងទីផ្សាររូបិយវត្ថុនិងអន្តរធនាគារ និងមូលប័ត្រក្រុមហ៊ុនមហាជន។ នៅពេលដែលបញ្ហាទាំងអស់នេះមានការអភិវឌ្ឍហើយ ក្របខ័ណ្ឌសម្រាប់អនុញ្ញាតឱ្យបង្កើត មូលនិធិវិនិយោគនឹងត្រូវបានពិចារណា ជាពិសេសដោយសារវាពាក់ព័ន្ធទៅនឹងសោធននិវត្តន៍។
- សោធននិវត្តន៍ : ស្របតាមការលើកឡើងនៅក្នុងវិស័យធានារ៉ាប់រង កម្ពុជានឹងពិចារណាលើការអភិវឌ្ឍប្រព័ន្ធសោធននិវត្តន៍ដែលមានសរសរទ្រចំនួនបី រួមទាំង គំរោងមូលនិធិសន្សំដែលស្រដៀងគ្នាទៅនឹងគំរោងរបស់ប្រទេសផ្សេងៗ ពិសេសនៅអាស៊ី។
- មូលប័ត្រនីយកម្ម : ក្នុងការស្វែងរកហិរញ្ញប្បទានរយៈកាលវែងសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ និងប្រភេទ ផ្សេងៗនៃការអភិវឌ្ឍផ្សេងៗ កម្ពុជាអាចពិចារណាលើការអភិវឌ្ឍក្របខ័ណ្ឌមួយសមស្របដើម្បីទ្រទ្រង់ដល់ការធ្វើមូលប័ត្រនីយកម្ម។ ក្របខ័ណ្ឌនេះអាចមានបញ្ចូលទាំងគ្រឹះស្ថានធ្វើមូលប័ត្រនីយកម្ម ដូចជា សាជីវកម្មផ្តល់កម្ចីដែលមានអចលនវត្ថុជាទ្រព្យបញ្ចាំ ឬហៅថា សាជីវកម្មនិក្ខេប។
- ឧបករណ៍និស្សន្ទ : នៅពេលក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច រូបិយវត្ថុ និងសារពើពន្ធ មានភាពប្រសើរឡើង ហើយការប្រើប្រាក់រៀលក៏មានការកើនឡើង កម្ពុជាអាចពិចារណាឱ្យមានការអភិវឌ្ឍប្រភេទឧបករណ៍និស្សន្ទមួយចំនួន ដើម្បីជួយដល់ការគ្រប់គ្រងហានិភ័យ។

# ការពិចារណាក្នុងវិស័យទូទៅ

## ជំពូកទី ៥

៥.០១ ក្រៅពីការបារម្ភជាចំបងដែលទាក់ទងទៅនឹងមូលដ្ឋានគ្រឹះនៃវិស័យហិរញ្ញវត្ថុ ធនាគារ និងមីក្រូហិរញ្ញវត្ថុ និងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ នៅពេលប្រព័ន្ធហិរញ្ញវត្ថុមានការអភិវឌ្ឍ បញ្ហាបន្ថែមទៀតនឹងកើតមានឡើង។ ដូចបញ្ហាទូទៅដែរ បញ្ហាទាំងនេះត្រូវតែដោះស្រាយដោយផ្អែកលើគោលការណ៍ទូទៅដែលបានលើកឡើងនៅក្នុង ជំពូកទី១ និងផ្តោតទៅលើបញ្ហាពីរ : (១) ស្ថិរភាពហិរញ្ញវត្ថុនិងហានិភ័យ និង(២) ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ។ ក្រោមក្របខ័ណ្ឌនេះ វិធីសាស្ត្រចំពោះការពិចារណាឆ្លងវិស័យទូទៅត្រូវដោះស្រាយនូវហានិភ័យជាសក្តានុពល ដែលអាចមានចំពោះស្ថិរភាពហិរញ្ញវត្ថុដែលជាការបារម្ភទី១ ដែលក្នុងពេលជាមួយគ្នានេះ គាំទ្រដល់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងរបកគំហើញថ្មីៗ។

៥.០២ នៅចំណុចនេះ ក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុកម្ពុជា មានការពិចារណាបីដែលចាំបាច់ត្រូវលើកឡើង៖

- ការប្រកួតប្រជែង
- គំនិតច្នៃប្រឌិតថ្មីខាងហិរញ្ញវត្ថុ និង
- រចនាសម្ព័ន្ធបទបញ្ញត្តិហិរញ្ញវត្ថុ។

ការពិចារណាផ្សេងៗទៀតនឹងពិតជាកើតឡើងគ្រប់ពេល ហើយនៅពេលវិស័យហិរញ្ញវត្ថុកម្ពុជាអភិវឌ្ឍន៍ និងត្រូវដោះស្រាយនៅក្នុងបរិបទគោលការណ៍ណែនាំនៃស្ថិរភាពហិរញ្ញវត្ថុនិងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅក្នុងបរិបទស្តង់ដារអន្តរជាតិ និងតំបន់។

## ក. សេរីភាវូបនីយកម្ម : ការចូលរួមក្នុងស្រុកនិងក្រៅប្រទេស និងការប្រកួតប្រជែង

៥.០៣ សេរីភាវូបនីយកម្ម និងការប្រកួតប្រជែង នាំមកនូវអត្ថប្រយោជន៍សេដ្ឋកិច្ចដ៏សំខាន់នៅក្នុងបរិបទទ្រទ្រង់ ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ កំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ។ ការស្រាវជ្រាវ និងបទពិសោធន៍ បានបង្ហាញថាវិស័យហិរញ្ញវត្ថុដែលមានលក្ខណៈសេរី និងមានភាពប្រកួតប្រជែង បានទ្រទ្រង់ដល់ការកើនឡើងនៃកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ។ ទន្ទឹមនេះ សេរីភាវូបនីយកម្មវិស័យហិរញ្ញវត្ថុនាំមកជាមួយនូវហានិភ័យ ដែលចាំបាច់ត្រូវដោះស្រាយឱ្យបានសមស្រប។ សំខាន់ជាងនេះទៀត សេរីភាវូបនីយកម្មហិរញ្ញវត្ថុអាចបង្កើននូវឱកាសវិបត្តិហិរញ្ញវត្ថុ បើសិនជាសេរីភាវូបនីយកម្មនេះកើតឡើងដោយគ្មានលំដាប់លំដោយសមស្រប និងការអភិវឌ្ឍក្របខ័ណ្ឌច្បាប់និងបទបញ្ញត្តិ ដើម្បីកាត់បន្ថយហានិភ័យ។ ដូចនេះ ការបារម្ភដែលបានលើកឡើងនៅជំពូកមុនៗទាក់ទងទៅនឹងមូលដ្ឋានគ្រឹះនៃវិស័យហិរញ្ញវត្ថុ ធនាគារនិងមីក្រូហិរញ្ញវត្ថុ និងហិរញ្ញវត្ថុមិនមែនធនាគារ មានសារៈសំខាន់ពិសេស នៅពេលដែលវិស័យហិរញ្ញវត្ថុត្រូវបានធ្វើសេរីភាវូបនីយកម្ម អភិវឌ្ឍន៍ និងកាន់តែមានភាពស្មុគស្មាញ។

៥.០៤ មិនដូចសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍ជាច្រើនទេ ជាពិសេសនៅអាស៊ី វិស័យហិរញ្ញវត្ថុកម្ពុជាបានធ្វើសេរីភាវូបនីយកម្មក្នុងកម្រិតមួយយ៉ាងទូលាយទៅហើយ ។ ទន្ទឹមនេះដែរ វាស្ថិតនៅដំណាក់កាលចាប់ផ្តើមនៃការអភិវឌ្ឍ ។ ជាលទ្ធផល ការបារម្ភជាគន្លឹះទាក់ទងទៅនឹងសេរីភាវូបនីយកម្ម និងការប្រកួតប្រជែង ទាក់ទងជាខ្លាំងទៅនឹងបញ្ហាដែលបានពិភាក្សា នៅជំពូកមុនៗ ពោលគឺការកែលំអមូលដ្ឋានគ្រឹះនៃវិស័យហិរញ្ញវត្ថុ ធនាគារនិងមីក្រូហិរញ្ញវត្ថុ និងហិរញ្ញវត្ថុមិនមែនធនាគារ ។

## ១. ការប្តេជ្ញាចិត្តធ្វើសេរីភាវូបនីយកម្មអន្តរជាតិ និងតំបន់

៥.០៥ ក្នុងការសំឡឹងទៅរកការធ្វើសេរីភាវូបនីយកម្ម ការអនុវត្តន៍ជាអន្តរជាតិបង្ហាញថា ការកសាងវិស័យហិរញ្ញវត្ថុមួយដែលមានលក្ខណៈប្រកួតប្រជែង ប្រទេសនានាអាចប្រើកិច្ចសម្របសម្រួលអន្តរជាតិនិងតំបន់ ដើម្បីប្រមូលផ្តុំភាពជឿនលឿន និងជម្រុញការប្រកួតប្រជែង ។ ប្រទេសកម្ពុជាបានធ្វើដូចគ្នានឹងរបៀបនេះតាមរយៈការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក និងជាសមាជិកអាស៊ាន ។ ជាសមាជិកភាពអង្គការពាណិជ្ជកម្មពិភពលោក និងអាស៊ាន ទាមទារឱ្យមានការបើកចំហវិស័យហិរញ្ញវត្ថុដើម្បីប្រកួតប្រជែងជាមួយបរទេស ហើយដំណើរការចូលជាសមាជិករបស់កម្ពុជានេះបានសំលឹងឃើញការប្រើដំណើរការនៃការធ្វើសេរីភាវូបនីយកម្ម ដើម្បីពង្រឹងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុក្នុងស្រុក ។

៥.០៦ នៅក្នុងបរិបទនៃការប្តេជ្ញាចិត្តផ្នែកវិស័យហិរញ្ញវត្ថុទាំងជាមួយអង្គការពាណិជ្ជកម្មពិភពលោក និងអាស៊ាន កម្ពុជាបានប្រកាន់យកនូវវិធីសាស្ត្រមួយដែលមានលក្ខណៈចំហចំពោះការចូលរួមរបស់បរទេស ហើយវិធីសាស្ត្រនេះកំពុងតែចេញផ្លែផ្កាដោយសារវាគាំទ្រដល់ការប្រកួតប្រជែងក្នុងស្រុកនិងក្រៅប្រទេស ដើម្បីកែលំអស្ថានភាពវិស័យហិរញ្ញវត្ថុ ។

## ២. គោលនយោបាយ និងច្បាប់ស្តីពីការប្រកួតប្រជែង

៥.០៧ ក្រៅពីបន្តអនុវត្តវិស័យហិរញ្ញវត្ថុនៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក និងអាស៊ាន និងការប្តេជ្ញាចិត្តដែលពាក់ព័ន្ធរបស់ខ្លួន កម្ពុជាក៏ចាំបាច់ត្រូវពិចារណាទៅលើបរិបទនៃការប្រកួតប្រជែងក្នុងស្រុក ហើយដែលបច្ចុប្បន្ននេះ កំពុងធ្វើតាមរយៈការរៀបចំច្បាប់ស្តីពីការប្រកួតប្រជែង និងគោលនយោបាយពាក់ព័ន្ធ ព្រមទាំងក្របខ័ណ្ឌស្ថាប័ន ។ ក្របខ័ណ្ឌនេះនឹងជួយដោះស្រាយការបារម្ភជាពិសេសដែលកើតឡើងទាក់ទងនឹងវិស័យហិរញ្ញវត្ថុ ជាពិសេសដែលទាក់ទងនឹងវិស័យធនាគារ និងធនាគារនានា ។ កិច្ចប្រឹងប្រែងទាំងនេះនឹងបន្ត ហើយនឹងត្រូវបានរៀបចំឡើង ដើម្បីទ្រទ្រង់ដល់ការប្រកួតប្រជែងជាបន្តនៅក្នុងវិស័យហិរញ្ញវត្ថុ ដែលក្នុងពេលជាមួយគ្នានេះដែរ ជួយដោះស្រាយហានិភ័យដែលកើតឡើងនៅក្នុងស្ថានភាពអនុវត្តជាក់ស្តែង និងឆ្ពោះទៅរកទីផ្សារ ។

## ៣. ចក្ខុវិស័យសម្រាប់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ : សេរីភាវូបនីយកម្ម និងការប្រកួតប្រជែង

៥.០៨ អាទិភាពចំពោះមុខ រួមមាន ៖

- ការអនុវត្តន៍ជាបន្តនូវវិស័យហិរញ្ញវត្ថុរបស់អង្គការពាណិជ្ជកម្មពិភពលោក និងអាស៊ាន និងការប្តេជ្ញាចិត្ត ដែលពាក់ព័ន្ធ
- ការរៀបចំគោលនយោបាយ និងច្បាប់ស្តីពីការប្រកួតប្រជែង ។ ការរៀបចំនេះត្រូវគិតទៅដល់តម្រូវការពិសេសនៃវិស័យ

ហិរញ្ញវត្ថុ ដោយចាំបាច់ត្រូវពិគ្រោះយោបល់ជាមួយស្ថាប័នបញ្ញត្តិកម្មសមស្រប ដើម្បីដោះស្រាយបញ្ហាប្រកួតប្រជែងនៅក្នុងវិស័យហិរញ្ញវត្ថុ។ នេះគឺជាវិស័យមួយដែលស្មុគស្មាញ ហើយទាមទារឱ្យមានការខិតខំប្រឹងប្រែងជាខ្លាំងក្នុងការអភិវឌ្ឍច្បាប់មួយដ៏សមស្រប និងប្រព័ន្ធដែលពាក់ព័ន្ធ។

៥.០៩ អាទិភាពអន្តរកាល និងរយៈពេលមធ្យម មាន៖

- ការអនុវត្តនីគោលនយោបាយ និងច្បាប់ស្តីពីការប្រកួតប្រជែង តាមរយៈក្របខ័ណ្ឌប្រតិបត្តិនិងស្ថាប័ន ជាតិឯករាជ្យសមស្រប រួមទាំងកិច្ចសហប្រតិបត្តិការនិងការពិគ្រោះយោបល់ជាមួយស្ថាប័នបញ្ញត្តិកម្ម ហិរញ្ញវត្ថុដែលពាក់ព័ន្ធនឹងសេវាកម្មហិរញ្ញវត្ថុ និងគ្រឹះស្ថានហិរញ្ញវត្ថុ។ អាជ្ញាធរនឹងចាំបាច់ត្រូវមានសមត្ថភាពគ្រប់គ្រាន់ដើម្បីស៊ើបអង្កេត វិភាគ និងធ្វើចំណាត់ការប្រព្រឹត្តកម្មរដ្ឋបាលនានាដែលទាក់ទងនឹងបញ្ហាប្រកួតប្រជែង។ ប្រការនេះទាមទារឱ្យមានការអភិវឌ្ឍនូវប្រព័ន្ធទ្រទ្រង់រដ្ឋបាល និងបទបញ្ញត្តិសមស្រប ព្រមទាំងការផ្សព្វផ្សាយ ការអភិវឌ្ឍកម្មវិធីសិក្សា និងការបណ្តុះបណ្តាល។
- ការចូលរួមជាបន្តនៅក្នុង និងការទ្រទ្រង់សកម្មភាពអភិវឌ្ឍន៍ទីផ្សារហិរញ្ញវត្ថុតំបន់អាស៊ាន។

៥.១០ គោលដៅរយៈពេលវែង មាន៖

- ជម្រុញឱ្យសមាជិកអាស៊ាន និងអង្គការពាណិជ្ជកម្មពិភពលោកផ្សេងៗទៀតធ្វើសេរីភាវូបនីយកម្ម តាមរយៈការធ្វើឱ្យមានភាពស៊ីគ្នានូវការប្តេជ្ញាចិត្តលើវិស័យហិរញ្ញវត្ថុរបស់កម្ពុជាដែលតាមរយៈនេះនឹងនាំមកនូវអត្ថប្រយោជន៍មិនចំពោះតែវិស័យហិរញ្ញវត្ថុកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែក៏ចំពោះការអភិវឌ្ឍវិស័យហិរញ្ញវត្ថុអាស៊ីផងដែរ។

## ខ. គំនិតច្នៃប្រឌិតថ្មីខាងហិរញ្ញវត្ថុ

៥.១១ គំនិតច្នៃប្រឌិតថ្មីខាងហិរញ្ញវត្ថុជាផ្នែកមួយនៃការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ហើយដូចនេះ ត្រូវបានគាំទ្រនិងជម្រុញនៅក្នុងបរិបទរក្សាស្ថិរភាពវិស័យហិរញ្ញវត្ថុ តាមរយៈដំណោះស្រាយដ៏សមស្របនូវហានិភ័យដែលអាចកើតឡើង។ ក្នុងការពិនិត្យទៅប្រព័ន្ធហិរញ្ញវត្ថុនៅលើពិភពលោក យើងឃើញមានវិធីសាស្ត្រចំបងៗពីរចំពោះគំនិតច្នៃ ប្រឌិតថ្មីខាងហិរញ្ញវត្ថុៈ បែបអនុញ្ញាត និងបែបរឹតត្បិត។ វិធីសាស្ត្របែបអនុញ្ញាត ជាសំខាន់ អាចនាំឱ្យមានគំនិតច្នៃប្រឌិតថ្មីខាងហិរញ្ញវត្ថុ លើកលែងតែត្រូវបានហាមឃាត់ផ្សេងទៀត ក៏ប៉ុន្តែជានិច្ចកាលត្រូវតែស្ថិតនៅក្នុងបរិបទដោះស្រាយហានិភ័យដែលបានកើតឡើង។ វិធីសាស្ត្រនេះមាននៅក្នុងប្រព័ន្ធហិរញ្ញវត្ថុដែលមានការអភិវឌ្ឍខ្លាំង ជាងគេនៅលើពិភពលោក។ វិធីសាស្ត្របែបរឹតត្បិត ជាសំខាន់ រារាំងនូវគំនិតច្នៃប្រឌិតថ្មីខាងហិរញ្ញវត្ថុ លើកលែងតែមានការអនុញ្ញាតដោយឡែក។ វិធីសាស្ត្រនេះមាននៅក្នុងប្រព័ន្ធហិរញ្ញវត្ថុដែលមានការអភិវឌ្ឍទាបនៅលើពិភពលោក។

៥.១២ ដើម្បីទ្រទ្រង់ដល់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ កម្ពុជានឹងប្រកាន់យកនូវវិធីសាស្ត្របែបអនុញ្ញាតចំពោះគំនិតច្នៃប្រឌិតថ្មីខាងហិរញ្ញវត្ថុ ជាមួយនិងគោលនយោបាយទូទៅដែលនាំឱ្យមានគំនិតច្នៃប្រឌិតថ្មីខាងហិរញ្ញវត្ថុ ឱ្យតែមិនមានការហាមឃាត់ដោយឡែក ប៉ុន្តែក្នុងពេលជាមួយគ្នានេះដែរ ត្រូវមានការប្រុងប្រយ័ត្នចំពោះហានិភ័យ ជាសក្តានុពលដែលអាចកើតមានឡើង។

ជាឧទាហរណ៍ នៅក្នុងបរិបទធានារ៉ាប់រងវិធីសាស្ត្រនៃការ "ប្រើប្រាស់ទៅតាមឯកសារតំកល់" នឹងត្រូវបានប្រកាន់យក ដែលនៅក្រោមវិធីសាស្ត្រនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមិនត្រូវបានរំពឹងថានឹងពាក់ព័ន្ធនៅក្នុងការស៊ើបអង្កេតអំពីទម្រង់បែបបទ និងអត្រាថ្លៃទេ ប៉ុន្តែអាចទាមទារឱ្យរាល់ការតំកល់ឯកសារ ប័ណ្ណសន្យារ៉ាប់រងថ្មីត្រូវតែមានជារបាយការណ៍ និងមានយោបល់ពីអ្នកជំនាញធានារ៉ាប់រង។

៥.១៣ គំនិតច្នៃប្រឌិតថ្មីខាងហិរញ្ញវត្ថុ មានទម្រង់មួយចំនួន ដូចខាងក្រោម ៖

- គ្រឹះស្ថានហិរញ្ញវត្ថុថ្មី
- ផលិតផល និងសេវាកម្មហិរញ្ញវត្ថុថ្មីៗ និង
- សកម្មភាពគ្រឹះស្ថានហិរញ្ញវត្ថុ និងក្រុមហ៊ុនចំរុះអាជីវកម្មហិរញ្ញវត្ថុ។

## ១. គ្រឹះស្ថានហិរញ្ញវត្ថុថ្មី

៥.១៤ ក្នុងស្មារតីគាំទ្រដល់ការប្រកួតប្រជែងក្នុងស្រុក និងក្រៅប្រទេសនៅក្នុងវិស័យហិរញ្ញវត្ថុ គ្រឹះស្ថានហិរញ្ញវត្ថុថ្មីត្រូវបានអនុញ្ញាតឱ្យបង្កើតលុះណាតែគ្រឹះស្ថាននេះបំពេញបាននូវកាតព្វកិច្ចសមស្របផ្អែកលើស្តង់ដារអន្តរជាតិនិងតំបន់ សម្រាប់ការទទួលអាជ្ញាប័ណ្ណ ការអនុញ្ញាត និងធ្វើប្រតិបត្តិការទាក់ទងទៅនឹងសេវាហិរញ្ញវត្ថុជាក់លាក់ ដែលគ្រឹះស្ថាននេះនឹងផ្តល់ឱ្យ។ ឧទាហរណ៍ ធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងក្រុមហ៊ុនធានារ៉ាប់រងថ្មី ទោះជាបរទេសឬក្នុងស្រុកក្តី គួរត្រូវបានអនុញ្ញាតឱ្យបង្កើតលុះណាតែធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងក្រុមហ៊ុន ទាំងអស់នេះ បំពេញបាននូវកាតព្វកិច្ចសមស្របសម្រាប់ការទទួលអាជ្ញាប័ណ្ណ ការអនុញ្ញាត និងការធ្វើប្រតិបត្តិការ ទាក់ទងទៅនឹងធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងក្រុមហ៊ុនធានារ៉ាប់រង។ លើសពីនេះទៀត ទម្រង់ថ្មីរបស់គ្រឹះស្ថានហិរញ្ញវត្ថុ ឧទាហរណ៍ ក្រុមហ៊ុនមូលប័ត្រ គួរត្រូវបានអនុញ្ញាតឱ្យបង្កើតលុះណាតែរចនាសម្ព័ន្ធស្ថាប័ន និងក្របខ័ណ្ឌច្បាប់និងបទបញ្ញត្តិសមស្របមានរួចជាស្រេចហើយ។

## ២. ផលិតផល និងសេវាកម្មហិរញ្ញវត្ថុ

៥.១៥ គំនិតច្នៃប្រឌិតថ្មីចំពោះផលិតផលនិងសេវាកម្មហិរញ្ញវត្ថុមានសារៈសំខាន់ណាស់សម្រាប់ការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុ។ ទន្ទឹមនេះដែរ ផលិតផលនិងសេវាកម្មហិរញ្ញវត្ថុថ្មីៗ អាចនាំមកនូវហានិភ័យចំពោះស្ថិរភាពហិរញ្ញវត្ថុ ដែលត្រូវតែដោះស្រាយដោយប្រុងប្រយ័ត្ន នៅពេលដែលផលិតផលនិងសេវាកម្មនេះមានការអភិវឌ្ឍ។

៥.១៦ ជាបញ្ហាទូទៅ គ្រឹះស្ថានហិរញ្ញវត្ថុត្រូវបានអនុញ្ញាតឱ្យបង្កើតផលិតផលនិងសេវាកម្មហិរញ្ញវត្ថុថ្មីៗដែលស្ថិត នៅក្នុងដែនធុរកិច្ចរបស់ខ្លួន ពោលគឺ បច្ចុប្បន្នមាន ធនាគារ មីក្រូហិរញ្ញវត្ថុ និងធានារ៉ាប់រង លុះណាតែគ្រឹះស្ថានហិរញ្ញវត្ថុទាំងនេះបានបំពេញគ្រប់លក្ខខណ្ឌកំណត់ដោយអាជ្ញាធរត្រួតពិនិត្យ។ ចំពោះគ្រឹះស្ថានហិរញ្ញវត្ថុដែលចង់ផ្តល់ផលិតផល និងសេវាកម្មហិរញ្ញវត្ថុនៅក្នុងវិស័យផ្សេងទៀត ឧទាហរណ៍ ធនាគារដែលលក់ធានារ៉ាប់រង មានពិភាក្សានៅផ្នែកខាងក្រោមស្តីពីសកម្មភាពគ្រឹះស្ថានហិរញ្ញវត្ថុ និងក្រុមហ៊ុនចំរុះអាជីវកម្មហិរញ្ញវត្ថុ។

៥.១៧ នៅពេលដែលផលិតផលថ្មីកើតឡើង បញ្ញត្តិករនិងអ្នកត្រួតពិនិត្យត្រូវស្វែងយល់អំពីផលិតផលទាំងនេះ និងហានិភ័យទាំងឡាយដែលអាចនាំមកឱ្យគ្រឹះស្ថានហិរញ្ញវត្ថុពាក់ព័ន្ធ អតិថិជនសក្តានុពល និងប្រព័ន្ធហិរញ្ញវត្ថុទាំងមូល។ គ្រឹះស្ថានហិរញ្ញវត្ថុត្រូវមានរួចជាស្រេចនូវប្រព័ន្ធសមស្របដើម្បីទ្រទ្រង់ដល់ផលិតផលថ្មី ហើយយន្តការសមស្របសម្រាប់ការពារអតិថិជននិងប្រព័ន្ធ ត្រូវតែមានជាស្រេច តាមការចាំបាច់។ ទន្ទឹមនេះ ក្នុងករណីខ្លះ ការអភិវឌ្ឍនូវក្របខ័ណ្ឌគតិយុត្ត និង/ឬក្របខ័ណ្ឌបទបញ្ញត្តិអាចជាប្រការចាំបាច់សម្រាប់ផលិតផល ឬសេវាកម្មហិរញ្ញវត្ថុ ហើយបញ្ញត្តិករហិរញ្ញវត្ថុត្រូវគាំទ្រដល់ការអភិវឌ្ឍផ្នែកច្បាប់និងបទបញ្ញត្តិ ដើម្បីទ្រទ្រង់ដល់គំនិតច្នៃប្រឌិតថ្មីខាងហិរញ្ញវត្ថុ នៅក្នុងបរិបទដោះស្រាយហានិភ័យនានាដោយសមស្រប។

៥.១៨ ជាឧទាហរណ៍នៃការអនុវត្តន៍នូវគោលការណ៍ទូទៅទាំងនេះ កម្ពុជាបានគាំទ្រដល់ការអភិវឌ្ឍភតិសន្យាដោយធនាគារនិងដោយគ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារ តាមការសមស្រប។ បទពិសោធន៍នេះផ្តល់នូវការណែនាំ នៅពេលដែលវិធីសាស្ត្រដែលត្រូវប្រកាន់យកជាមួយនឹងផលិតផលនិងសេវាកម្មហិរញ្ញវត្ថុថ្មីៗផ្សេងទៀតនាពេលអនាគត។

## ៣. សកម្មភាពគ្រឹះស្ថានហិរញ្ញវត្ថុ និងក្រុមហ៊ុនចំរុះអាជីវកម្មហិរញ្ញវត្ថុ

៥.១៩ នៅពេលដែលវិស័យហិរញ្ញវត្ថុរបស់ប្រទេសមួយអភិវឌ្ឍន៍ ហើយធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀតរបស់ប្រទេសនោះអភិវឌ្ឍន៍ក្នុងភាពជឿនលឿន បញ្ហាដែលមិនអាចចៀសផុតនឹងកើតឡើងពាក់ព័ន្ធនឹងសកម្មភាពហិរញ្ញវត្ថុឆ្លងវិស័យ និងក្រុមហ៊ុនចំរុះអាជីវកម្មហិរញ្ញវត្ថុ។ ជាបញ្ហាទូទៅ ប្រទេសនានានៅលើពិភពលោកបានប្រកាន់យករចនាសម្ព័ន្ធជាចំបងៗ ៤ សម្រាប់ដោះស្រាយសកម្មភាពគ្រឹះស្ថានហិរញ្ញវត្ថុឆ្លងវិស័យ និងក្រុមហ៊ុនចំរុះអាជីវកម្មហិរញ្ញវត្ថុ៖

- ធនាគារសាកល
- ការបែងចែកជាវិស័យដ៏តឹងរឹង
- ក្រុមហ៊ុនហូលឌីងហិរញ្ញវត្ថុ ឬ
- រចនាសម្ព័ន្ធមេនិងបុត្តសម្ព័ន្ធ។

៥.២០ នៅក្រោមរចនាសម្ព័ន្ធធនាគារជាសាកល គ្រឹះស្ថានហិរញ្ញវត្ថុត្រូវបានអនុញ្ញាតឱ្យធ្វើសកម្មភាពហិរញ្ញវត្ថុគ្រប់ប្រភេទដោយពុំចាំបាច់ឱ្យបុត្តសម្ព័ន្ធមានដើមទុន និង/ឬបទបញ្ញត្តិដោយឡែកឡើយ។ នៅក្រោមទម្រង់នៃការបែងចែកជាវិស័យដ៏តឹងរឹង គ្រឹះស្ថានហិរញ្ញវត្ថុត្រូវបានអនុញ្ញាតឱ្យធ្វើតែសកម្មភាពហិរញ្ញវត្ថុនៅក្នុងវិស័យ ដែលត្រូវបានអនុញ្ញាតតែចំពោះគ្រឹះស្ថាននោះប៉ុណ្ណោះ : ធនាគារនិងវិជ្ជាជីវៈធនាគារ ធានារ៉ាប់រង។ល។ សកម្មភាពឆ្លងវិស័យមិនត្រូវបានអនុញ្ញាតទេ។ នៅក្រោមទម្រង់ក្រុមហ៊ុនហូលឌីងហិរញ្ញវត្ថុ ក្រុមហ៊ុនមេមួយដែលជាក្រុមហ៊ុនហូលឌីងហិរញ្ញវត្ថុអាចត្រូវបានបង្កើតឡើង ហើយដូចនេះអាចកាន់កាប់គ្រឹះស្ថានហិរញ្ញវត្ថុដែលជាបុត្តសម្ព័ន្ធដែលធ្វើសកម្មភាពនៅក្នុងរង្វង់វិស័យហិរញ្ញវត្ថុរបស់ខ្លួន។ ក្រុមហ៊ុនហូលឌីងហិរញ្ញវត្ថុជាក្រុមហ៊ុនមួយដោយឡែកពីបុត្តសម្ព័ន្ធរបស់ខ្លួន និងមិនធ្វើសកម្មភាពហិរញ្ញវត្ថុដោយផ្ទាល់ទេ។ នៅក្រោមទម្រង់មេ និងបុត្តសម្ព័ន្ធ គ្រឹះស្ថានហិរញ្ញវត្ថុមេ ឧទាហរណ៍ ធនាគារ ឬក្រុមហ៊ុនធានារ៉ាប់រង អាចបង្កើតបុត្តសម្ព័ន្ធដោយឡែកដើម្បីធ្វើសកម្មភាពហិរញ្ញវត្ថុនៅក្នុងវិស័យផ្សេងៗទៀត។

៥.២១ ឥឡូវនេះ ពុំមានការឯកភាពជាទូទៅដែលបង្ហាញថាទម្រង់ណាល្អជាងគេនោះទេ។ ដូចគ្នាដែរ មានទំនាក់ទំនងដោយផ្ទាល់រវាងទម្រង់ដែលបានជ្រើសរើសសម្រាប់គ្រឹះស្ថានហិរញ្ញវត្ថុនិងក្រុមហ៊ុនចំរុះអាជីវកម្មហិរញ្ញវត្ថុ និងរចនាសម្ព័ន្ធបទបញ្ញត្តិហិរញ្ញវត្ថុរបស់ប្រទេសមួយ។

៥.២២ បន្ថែមទៅលើសកម្មភាពហិរញ្ញវត្ថុឆ្លងវិស័យនិងរចនាសម្ព័ន្ធស្ថាប័ន បញ្ហាទី២ដែលកើតឡើងនោះគឺថា តើគ្រឹះស្ថានហិរញ្ញវត្ថុគួរត្រូវបានអនុញ្ញាតឱ្យប្រកបមុខរបរមិនមែនហិរញ្ញវត្ថុដែរឬទេ។ ជាឧទាហរណ៍៖

- តើធនាគារត្រូវបានអនុញ្ញាតឱ្យប្រកបមុខរបរមិនមែនហិរញ្ញវត្ថុ ក្រៅពីមុខរបរធនាគារឬទេ? តើធនាគារសាកលត្រូវបានអនុញ្ញាតឱ្យប្រកបមុខរបរមិនមែនហិរញ្ញវត្ថុ និងមុខរបរហិរញ្ញវត្ថុដែរឬទេ?
- តើក្រុមហ៊ុនហូលឌីងហិរញ្ញវត្ថុត្រូវបានអនុញ្ញាតឱ្យមានបុគ្គលសម្ព័ន្ធមិនមែនហិរញ្ញវត្ថុ និងបុគ្គលសម្ព័ន្ធគ្រឹះស្ថានហិរញ្ញវត្ថុដែរឬទេ ?
- តើក្រុមហ៊ុនហូលឌីងត្រូវបានអនុញ្ញាតឱ្យកាន់កាប់ក្រុមហ៊ុនហូលឌីងហិរញ្ញវត្ថុ និងប្រកបមុខរបរមិនមែនហិរញ្ញវត្ថុដែរឬទេ ?

៥.២៣ បច្ចុប្បន្ន ពុំមានការឯកភាពជារួមថា តើក្រុមហ៊ុនមិនមែនហិរញ្ញវត្ថុអាចកាន់កាប់គ្រឹះស្ថានហិរញ្ញវត្ថុ ឬក្រុមហ៊ុនហូលឌីងហិរញ្ញវត្ថុដែរឬទេ។ ផ្អែកលើកម្រិតនៃការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងធនធានមនុស្ស ប្រទេសកម្ពុជាកំពុងពិចារណាប្រកាន់យកវិធីសាស្ត្រមួយដែលរឹតត្បិតទៅលើកម្មសិទ្ធិភាពក្រុមហ៊ុនមិនមែនហិរញ្ញវត្ថុរបស់គ្រឹះស្ថានហិរញ្ញវត្ថុ ឬក្រុមហ៊ុនហូលឌីងហិរញ្ញវត្ថុ បើសិនជាមានបង្កើតឡើងនៅពេលអនាគត។

៥.២៤ ដូច្នេះ ការពិចារណាជាគន្លឹះដែលកើតឡើងនៅក្នុងបរិបទនេះគឺរចនាសម្ព័ន្ធបទបញ្ញត្តិ និងសមត្ថភាពត្រួតពិនិត្យរបស់ប្រទេសមួយ ក៏ដូចជាកម្រិតជឿនលឿននៅក្នុងវិស័យហិរញ្ញវត្ថុរបស់ខ្លួន។

## ៤. អាទិភាពសម្រាប់ឆ្នាំ២០០៦-២០១៥: គំនិតច្នៃប្រឌិតថ្មីខាងហិរញ្ញវត្ថុ

### *អាទិភាពចំពោះមុខ*

៥.២៥ អាទិភាពចំពោះមុខ មាន៖

- អនុញ្ញាតឱ្យបង្កើតគ្រឹះស្ថានហិរញ្ញវត្ថុថ្មីដែលបំពេញបានតាមកាតព្វកិច្ចពាក់ព័ន្ធនឹងអាជ្ញាប័ណ្ណ ការអនុញ្ញាត និងប្រតិបត្តិការ
- ទ្រទ្រង់ដល់វិធីសាស្ត្រដែលអនុញ្ញាតសម្រាប់ផលិតផលនិងសេវាកម្មហិរញ្ញវត្ថុនៅក្នុងបរិបទដោះស្រាយហានិភ័យនានា
- បញ្ចប់នូវក្របខ័ណ្ឌច្បាប់ និងបទបញ្ញត្តិគតិសន្យា
- បញ្ជាក់នូវវិធីសាស្ត្រសម្រាប់សកម្មភាពគ្រឹះស្ថានហិរញ្ញវត្ថុ ជាពិសេស នៅក្នុងបរិបទធនាគារ និងក្រុមហ៊ុនធានារ៉ាប់រង និងរៀបចំការយល់ដឹងនេះតាមរយៈអនុស្សារណៈស្តីពីការយោគយល់ (MOU) ដែលទាក់ទងទៅនឹងស្ថាប័នបញ្ញត្តិកម្មពាក់ព័ន្ធ។

៥.២៦ អាទិភាពអន្តរកាល មាន៖

- រៀបចំវិធីសាស្ត្រដែលអនុញ្ញាតសម្រាប់ការអភិវឌ្ឍផលិតផលហិរញ្ញវត្ថុ ដោយផ្អែកលើបទពិសោធន៍ទទួលបានពីបរិបទគតិសន្យា។

៥.២៧ គោលដៅរយៈពេលវែង មាន៖

- រៀបចំក្របខ័ណ្ឌច្បាប់និងបទបញ្ញត្តិតាមការចាំបាច់ ដើម្បីទ្រទ្រង់ដល់គំនិតច្នៃប្រឌិតថ្មីចំពោះផលិតផល និងសេវាកម្មហិរញ្ញវត្ថុ
- រៀបចំវិធីសាស្ត្រច្បាស់លាស់មួយសម្រាប់សកម្មភាពគ្រឹះស្ថានហិរញ្ញវត្ថុ និងក្រុមហ៊ុនចំរុះអាជីវកម្មហិរញ្ញវត្ថុ ដែលទ្រទ្រង់ដោយក្របខ័ណ្ឌច្បាប់និងបទបញ្ញត្តិសមស្រប ឬអនុស្សារណៈស្តីពីការយោគយល់ (MOU) តាមការចាំបាច់។

## គ. រចនាសម្ព័ន្ធបទបញ្ញត្តិហិរញ្ញវត្ថុ

៥.២៨ នៅពេលដែលរបកគំហើញថ្មីនៃផលិតផលនិងសេវាកម្មហិរញ្ញវត្ថុ និងសកម្មភាពគ្រឹះស្ថានហិរញ្ញវត្ថុអភិវឌ្ឍន៍ និងកើនឡើងក្នុងភាពជឿនលឿន ប្រទេសនានានៅលើពិភពលោកត្រូវលើកឡើងនូវការពិចារណាទី២ ដែលទាក់ទងទៅនឹងរចនាសម្ព័ន្ធរួមនៃបទបញ្ញត្តិនិងការត្រួតពិនិត្យហិរញ្ញវត្ថុ។

៥.២៩ ជាបញ្ហាទូទៅ ប្រទេសនានានៅលើពិភពលោកបានប្រកាន់យករចនាសម្ព័ន្ធទូទៅនៃបទបញ្ញត្តិ និងការត្រួតពិនិត្យហិរញ្ញវត្ថុ ចំនួន ៤៖

- បញ្ញត្តិករតែមួយ
- បទបញ្ញត្តិតាមវិស័យ
- បទបញ្ញត្តិតាមមុខងារ ឬ
- បទបញ្ញត្តិតាមស្ថាប័ន។

៥.៣០ ជាថ្មីម្តងទៀត នៅពេលនេះ គ្មានការព្រមព្រៀងគ្នាជាទូទៅណាដែលមានទម្រង់ល្អឥតខ្ចោះទេ បញ្ហាជាគន្លឹះគឺត្រូវរៀបចំរចនាសម្ព័ន្ធបទបញ្ញត្តិហិរញ្ញវត្ថុរបស់ប្រទេសមួយដែលស្របទៅនឹងកាលៈទេសៈផ្ទាល់របស់ខ្លួន និងជាពិសេសរចនាសម្ព័ន្ធហិរញ្ញវត្ថុ ដើម្បីឆ្លើយតបទៅនឹងសកម្មភាពគ្រឹះស្ថានហិរញ្ញវត្ថុ និងក្រុមហ៊ុនចំរុះអាជីវកម្មហិរញ្ញវត្ថុ។

៥.៣១ ប្រទេសកម្ពុជាបានអនុម័តប្រព័ន្ធបទបញ្ញត្តិតាមវិស័យ ដោយមានប្រព័ន្ធត្រួតពិនិត្យដោយឡែកៗពីគ្នា ចំពោះសម្រាប់ធនាគារពាណិជ្ជនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុនធានារ៉ាប់រង និងការជួញដូរមូលប័ត្រ។ ការអនុមតិបទបញ្ញត្តិនេះនៅតែបន្តជាបញ្ហា បើទោះបីជាហានិភ័យដែលទាក់ទងទៅនឹងធនាគារដោយកាតព្វកិច្ចបទបញ្ញត្តិពិសេសរបស់ពួកគេត្រូវបានយកមកគិតពិចារណាយ៉ាងណាក៏ដោយ។

៥.៣២ បន្ថែមទៅលើបទបញ្ញត្តិ ប្រទេសនានាក៏ត្រូវពិចារណាផងដែរទៅលើគោលនយោបាយដែលកំណត់ សម្រាប់វិស័យហិរញ្ញវត្ថុ។ ក្នុងបរិបទនេះ ប្រទេសកម្ពុជានឹងពិចារណានូវកិច្ចសម្របសម្រួលសមស្របសម្រាប់ការទទួលខុសត្រូវចំពោះការអភិវឌ្ឍគោលនយោបាយវិស័យហិរញ្ញវត្ថុ។

៥.៣៣ អាទិភាពចំពោះមុខមាន ៖

- បញ្ជាក់ឱ្យច្បាស់នូវសកម្មភាពនានារបស់គ្រឹះស្ថានហិរញ្ញវត្ថុ និងវិធីសាស្ត្រដែលត្រូវបានអនុញ្ញាត ដែលមានការយកចិត្តទុកដាក់ ជាពិសេសចំពោះហានិភ័យជាប្រព័ន្ធដែលកើតឡើងដោយសកម្មភាពធនាគារ និងសកម្មភាពធនាគារ ។
- ពិចារណានូវកិច្ចសម្របសម្រួលសមស្របសម្រាប់ការទទួលខុសត្រូវ ចំពោះការអភិវឌ្ឍគោលនយោបាយវិស័យហិរញ្ញវត្ថុ ។
- គាំទ្រតាមរយៈការកែប្រែក្របខ័ណ្ឌច្បាប់និងបទបញ្ញត្តិ ឬអនុស្សារណៈស្តីពីការយោគយល់ (MOU) តាមការចាំបាច់ ។

៥.៣៤ អាទិភាពអន្តរកាល និងរយៈពេលមធ្យម រួមមាន ៖

- ធ្វើការវាយតម្លៃគ្រប់ជ្រុងជ្រោយនូវរចនាសម្ព័ន្ធបទបញ្ញត្តិហិរញ្ញវត្ថុក្នុងបរិបទនៃសកម្មភាពគ្រឹះស្ថានហិរញ្ញវត្ថុ និងក្រុមហ៊ុនចំរុះអាជីវកម្មហិរញ្ញវត្ថុ និងសមត្ថភាពត្រួតពិនិត្យនិងបទបញ្ញត្តិក្នុងស្រុក ។
- អនុវត្តការកែប្រែជាចាំបាច់ចំពោះរចនាសម្ព័ន្ធបទបញ្ញត្តិដែលជាលទ្ធផលនៃការវាយតម្លៃគ្រប់ជ្រុងជ្រោយ ។

៥.៣៥ គោលដៅរយៈពេលវែង រួមមានការអនុវត្តន៍នូវការពិនិត្យវិស័យហិរញ្ញវត្ថុឡើងវិញឱ្យបានគ្រប់ជ្រុងជ្រោយ ។

# ម៉ាក្រូស្ថិរភាព នៃការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ឆ្នាំ២០០៦-២០១៥

## ជំពូកទី ៦

# ■ ម៉ាទ្រីសអាទិភាពនៃការអភិវឌ្ឍ វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០៦-២០១៥

ឧបសម្ព័ន្ធ ៦

ចក្ខុវិស័យនិងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០១-២០១០ នេះ ទោះបីជាកំពុងដំណើរការនៅក្នុងរយៈពេលកំណត់ ១០ ឆ្នាំក៏ដោយ ក៏មិនបានកំណត់ពេលវេលាគោលដៅជាច់ខាតដើម្បីសំរេចបាននូវសកម្មភាព និងលទ្ធផលនានាក្នុងរយៈពេល១០ឆ្នាំឡើយ។ ការអភិវឌ្ឍនឹងអាចកើតឡើងតាមរយៈកត្តាផ្សេងៗពាក់ព័ន្ធទៅនឹងការរីកចំរើនក្នុងការទ្រទ្រង់ទូទាំងវិស័យនៃការធ្វើអន្តរាគមន៍ និងការអនុវត្តន៍គោលនយោបាយ។ ជំហាននៃការប្រែប្រួលនៅក្នុងវិស័យនិមួយៗនឹងអាស្រ័យទៅលើរយៈពេលនៃការធ្វើអន្តរាគមន៍ សមត្ថភាពស្រូបយក និងគុណភាពនៃការគាំទ្រ។ ការអាស្រ័យគ្នាទៅវិញទៅមក ភាពស្មើគ្នា និងការរីកចំរើនទៅវិញទៅមកលើបញ្ហានានានឹងកាន់តែមានសារៈសំខាន់ជាងពេលវេលាទៅទៀត។ ហេតុនេះហើយបានជាចាំបាច់ត្រូវផ្តល់លំដាប់អាទិភាពទៅលើលំដាប់លំដោយ ជាជាងកំណត់ពេលវេលាជាក់លាក់។

ខណៈពេលដែលធ្វើបច្ចុប្បន្នកម្ម និងការពិនិត្យឡើងវិញនូវចក្ខុវិស័យនិងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០១-២០១០ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០៦-២០១៥ បញ្ជាក់ផងដែរនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែង (ជំពូកទី១) និងអាទិភាពមួយចំនួនតាមរយៈផែនការអភិវឌ្ឍន៍តាមវិស័យជាលំដាប់លំដោយ។ យុទ្ធសាស្ត្ររយៈពេលវែងបានផ្អែកលើមេរៀនសំខាន់ៗដែលជាបទពិសោធន៍នៃការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងកំណែទម្រង់នៅបណ្តាប្រទេសផ្សេងៗ ហើយយុទ្ធសាស្ត្រនេះដឹកនាំផែនការអភិវឌ្ឍន៍តាមវិស័យ។ ផែនការអភិវឌ្ឍន៍តាមវិស័យនិមួយៗរួមមានចក្ខុវិស័យអភិវឌ្ឍន៍ កម្មវិធីកំណែទម្រង់ចំពោះមុខ អន្តរកាលនិងរយៈពេលមធ្យម និងរយៈពេលវែង និងវិធានការគោលនយោបាយទៅតាមលំដាប់លំដោយចង្អុលបង្ហាញនៅក្នុងវិស័យនីមួយៗ ជាមួយនឹងការទទួលខុសត្រូវរបស់ស្ថាប័ននាំមុខ។ គោលដៅអភិវឌ្ឍន៍លើកឡើងនូវយុទ្ធសាស្ត្រតាមវិស័យដើម្បីសម្រេចបាននូវចក្ខុវិស័យនៅក្នុងវិស័យនិមួយៗ តាមលំដាប់អាទិភាព និងជំហានបន្តបន្ទាប់។ កម្មវិធីកំណែទម្រង់ត្រូវបានជ្រើសរើសដើម្បីជួយ (១) កំណត់វិធានការគោលនយោបាយជាក់លាក់ដើម្បីសំរេចបានគោលដៅដែលបានកំណត់ និង (២) កំណត់លំដាប់លំដោយនិងជំហានវិធានការគោលនយោបាយទាំងនេះ និង (៣) បញ្ជាក់ការទទួលខុសត្រូវចំបងៗ។ ទោះជាយ៉ាងណា កម្មវិធីកំណែទម្រង់ រួមបញ្ចូលនូវភាពទន់ភ្លន់ក្នុងការបត់បែនតាមសភាពការណ៍ ព្រោះវាអាចជួយឱ្យអ្នករៀបចំគោលនយោបាយក្នុងការបន្ថែមឬពិនិត្យកម្មវិធីឡើងវិញ ដើម្បីឆ្លុះបញ្ចាំងនូវការរីកចំរើនដែលសំរេចបាននៅក្នុងវិស័យនិមួយៗ និងដំណាក់កាលនិមួយៗជាមួយនឹងស្ថានភាពប្រែប្រួលនៃទីផ្សារហិរញ្ញវត្ថុ។ ប្រការនេះមិនអាចចៀសបានទេ ព្រោះកម្មវិធីកំណែទម្រង់និមួយៗត្រូវបានចាក់ស្រេះគ្នា ទាំងខ្សែទទឹងនិង/ឬខ្សែបណ្តោយ ជាមួយនឹងកម្មវិធីកំណែទម្រង់នៅក្នុងវិស័យផ្សេងៗទៀត។ ក្នុងករណីសកម្មភាពខ្លះមិនត្រូវបានអនុវត្ត សកម្មភាពដែលត្រូវបន្តពីនេះនឹងមិនអាចធ្វើបានទេ។ វិធានការគោលនយោបាយនៅក្រោមកម្មវិធីកំណែទម្រង់អន្តរកាល គឺជាឧទាហរណ៍ និងជាការចង្អុលបង្ហាញ។ ដូចនេះ នៅពេលអនុវត្តផែនការអភិវឌ្ឍន៍តាមវិស័យ អ្នករៀបចំគោលនយោបាយអាចចាំបាច់ត្រូវពិនិត្យសកម្មភាពគោលនយោបាយឡើងវិញឱ្យកាន់តែប្រសើរឡើងថែមទៀត។

ផែនការអភិវឌ្ឍន៍តាមវិស័យដោះស្រាយបញ្ហាច្បាប់ បទបញ្ញត្តិ និងស្តង់ដារចាំបាច់នានា ក៏ដូចជា ការរៀបចំធនធានមនុស្សចាំបាច់ និងសមត្ថភាពស្ថាប័នសម្រាប់អនុវត្ត។ ការបង្កើតច្បាប់និងស្តង់ដារនានា មិនមែនមានន័យថា បានបំពេញនូវគោលដៅអភិវឌ្ឍន៏វិស័យហិរញ្ញវត្ថុនោះទេប៉ុន្តែយុទ្ធសាស្ត្រអភិវឌ្ឍន៏វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥បានផ្តោតលើការកសាងសមត្ថភាពធនធានមនុស្សនិងស្ថាប័ន ដែលត្រូវការជាចាំបាច់សម្រាប់អនុវត្តវិធានការដែលអាចដោះស្រាយបាននូវភាពទន់ខ្សោយផ្នែកវិស័យហិរញ្ញវត្ថុ។

ចំពោះចក្ខុវិស័យ និងផែនការអភិវឌ្ឍន៏វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០១-២០១០ យុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ ឆ្នាំ ២០០៦-២០១៥ គឺជាផែនការរំកិលបន្តដែលចាំបាច់ត្រូវធ្វើបច្ចុប្បន្នកម្មជាបន្តបន្ទាប់ដើម្បីឆ្លុះបញ្ចាំងនូវលទ្ធផលដែលសំរេចបាន និងការប្រែប្រួលនៃបរិដ្ឋានសេដ្ឋកិច្ចសង្គម។ បើសិនជាគោលដៅអភិវឌ្ឍន៍ត្រូវបានបំពេញលឿនជាងការកំណត់គោលដៅនោះ ចាំបាច់ត្រូវតែកែតម្រូវ។

| មូលដ្ឋានគ្រឹះនៃការ<br>អភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ | អាទិភាពចំពោះមុខ<br>( ក្នុងរយៈពេល ៣ឆ្នាំ )<br>គោលដៅ : ២០០៦-២០០៩ | អាទិភាពអន្តរកាល និងរយៈពេលមធ្យម<br>( ៣ ទៅ ៥ឆ្នាំ )<br>គោលដៅ : ២០០៩-២០១២ | គោលដៅរយៈពេលវែង<br>( ៥ ទៅ ១០ឆ្នាំ )<br>គោលដៅ : ២០១២-២០១៥ |
|---|---|---|---|
| ចក្ខុវិស័យ : មូលដ្ឋានគ្រឹះ គតិយុត្ត ស្ថាប័ន និងគោលនយោបាយសមស្រប ដើម្បីជម្រុញវិស័យហិរញ្ញវត្ថុ ដែលផ្អែកលើទីផ្សារ និងគាំទ្រអភិបាលកិច្ចល្អ និងនីតិរដ្ឋ។ | | | |
| បុរេលក្ខខណ្ឌសម្រាប់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងកំណើនសេដ្ឋកិច្ច :<br>- អភិបាលកិច្ចដ៏មានប្រសិទ្ធភាព<br>- កម្មសិទ្ធិទ្រព្យសម្បត្តិ និងការការពារ<br>- ការដាក់ឱ្យអនុវត្តនូវកិច្ចសន្យា និងដំណោះស្រាយជម្លោះពាណិជ្ជកម្ម<br>- ការអភិវឌ្ឍធនធានមនុស្ស | បញ្ចប់ការចុះបញ្ជីដីធ្លី និងអចលនវត្ថុដោយត្រូវយកចិត្តទុកដាក់លើផ្នែកណាដែលប្រតិបត្តិការទំនងមានការកើនឡើង( តំបន់ទីប្រជុំជនធំៗ) ។(ស្ថាប័ននាំមុខ: ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់)<br><br>បង្កើតក្របខ័ណ្ឌបទបញ្ញត្តិសមស្របដើម្បីទ្រទ្រង់ដល់សេវាវាយតម្លៃអចលនវត្ថុ និងសេវាប្រតិបត្តិការអចលនវត្ថុ។ (ស្ថាប័ននាំមុខ :ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)<br><br>ពង្រឹងការកសាងសមត្ថភាពដល់អ្នកវាយតម្លៃ និងបញ្ញត្តិករអចលនវត្ថុ។<br>(ស្ថាប័ននាំមុខ: ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ/ ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់)<br><br>ការអនុវត្តន៍និងការដាក់ឱ្យអនុវត្តនូវក្របខ័ណ្ឌច្បាប់ពាណិជ្ជកម្មរបស់កម្ពុជា រួមទាំងការអនុមតិច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម ការអនុវត្តន៍តាមរយៈ | បញ្ចប់ដំណើរការចុះបញ្ជីដីធ្លី និងអចលនវត្ថុ : នៅចាត់ទុកជាអាទិភាពសំខាន់បន្តទៀត។(ស្ថាប័ននាំមុខ : ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់)<br><br>បង្កើតប្រព័ន្ធសមស្របពាក់ព័ន្ធនឹងសេវាវាយតម្លៃអចលនវត្ថុ និងសេវាប្រតិបត្តិការអចលនវត្ថុ រួមទាំងពង្រឹងនូវការអនុវត្តន៍ច្បាប់ និងបទបញ្ញត្តិផងដែរ។ (ស្ថាប័ននាំមុខ : ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)<br><br>បង្កើតវិទ្យាស្ថានបណ្តុះបណ្តាលសម្រាប់អ្នកវាយតម្លៃ និងអ្នកចូលរួមក្នុងទីផ្សារអចលនវត្ថុ។(ស្ថាប័ននាំមុខ: ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) | បញ្ចប់ដំណើរការចុះបញ្ជីដីធ្លី និងអចលនវត្ថុ។ (ស្ថាប័ននាំមុខ : ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់)<br><br>ពិនិត្យឡើងវិញ និងកែសម្រួលនូវក្របខ័ណ្ឌច្បាប់និងបទបញ្ញត្តិសម្រាប់ទីផ្សារអចលនវត្ថុ ដើម្បីឱ្យសមស្របទៅតាមស្តង់ដារអន្តរជាតិ ក៏ដូចជាបន្តនូវការកសាងសមត្ថភាពផងដែរ។ (ស្ថាប័ននាំមុខ:ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ)<br><br>បន្តដំណើរការកែទម្រង់ផ្នែកតុលាការ និងច្បាប់ឱ្យបានគ្រប់ជ្រុងជ្រោយ។ (ស្ថាប័ននាំមុខ : ក្រសួងពាណិជ្ជកម្ម/ ក្រសួងយុត្តិធម៌) |

| | | | |
|---|---|---|---|
| | បទបញ្ញត្តិនិងប្រព័ន្ធរដ្ឋបាលសមស្រប ការផ្សព្វផ្សាយ ការអភិវឌ្ឍកម្មវិធីសិក្សា និងសកម្មភាពបណ្តុះបណ្តាល។ (ស្ថាប័ននាំមុខ : ក្រសួងពាណិជ្ជកម្ម/ក្រសួងយុត្តិធម៌)<br><br>ការអភិវឌ្ឍប្រព័ន្ធមជ្ឈត្តការពាណិជ្ជកម្ម តាមរយៈបទបញ្ញត្តិ និងប្រព័ន្ធរដ្ឋបាលសមស្រប (រួមទាំងមជ្ឈមណ្ឌលមជ្ឈត្តការពាណិជ្ជកម្ម) ការផ្សព្វផ្សាយ ការអភិវឌ្ឍកម្មវិធីសិក្សា និងសកម្មភាពបណ្តុះបណ្តាល។ (ស្ថាប័ននាំមុខ: ក្រសួងពាណិជ្ជកម្ម )<br><br>រិះរកការទ្រទ្រង់សម្រាប់ការអភិវឌ្ឍបច្ចេកទេសដោះស្រាយជម្លោះនៅថ្នាក់ខេត្ត និងថ្នាក់ដទៃទៀត។ (ស្ថាប័ននាំមុខ: ក្រសួងពាណិជ្ជកម្ម/ក្រសួងយុត្តិធម៌)<br><br>ការអភិវឌ្ឍធនធានមនុស្ស។ ការងារនេះជាតម្រូវការចំពោះមុខ និងជាបន្ត នឹងត្រូវដំណើរការរហូតទូទាំងឆ្នាំ២០០៦-២០១៥។ អាទិភាពរួមមាន ការអភិវឌ្ឍបុគ្គលិករដ្ឋាភិបាលជាបន្ត ការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលសាធារណៈ គាំទ្រនូវគំនិតផ្តួចផ្តើមលើការបណ្តុះបណ្តាលវិស័យឯកជន (រួមទាំងការបណ្តុះបណ្តាលរបស់ក្រុមប្រឹក្សាជាតិគណនេយ្យ និងវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា សមាគមធនាគារិកកម្ពុជា សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និងសមាគមធានារ៉ាប់រងទូទៅនៃកម្ពុជា) | ការអនុវត្តន៍និងការដាក់ឱ្យអនុវត្តនូវក្របខ័ណ្ឌច្បាប់ពាណិជ្ជកម្មរបស់កម្ពុជា ដោយបន្តគាំទ្រការអភិវឌ្ឍមជ្ឈត្តការពាណិជ្ជកម្ម និងការអនុវត្តន៍ច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម ព្រមទាំងប្រព័ន្ធតុលាការពាណិជ្ជកម្ម រួមបញ្ចូលបទបញ្ញត្តិនិងប្រព័ន្ធរដ្ឋបាលសមស្រប ការផ្សព្វផ្សាយ ការអភិវឌ្ឍកម្មវិធីសិក្សា និងសកម្មភាពបណ្តុះបណ្តាល។ (ស្ថាប័ននាំមុខ : ក្រសួងពាណិជ្ជកម្ម/ ក្រសួងយុត្តិធម៌)<br><br>ដំណើរការកំណែទម្រង់ប្រព័ន្ធច្បាប់និងតុលាការឱ្យបានគ្រប់ជ្រុងជ្រោយ។ (ស្ថាប័ននាំមុខ : ក្រសួងពាណិជ្ជកម្ម/ក្រសួងយុត្តិធម៌) | |

| | | | |
|---|---|---|---|
| | និងបន្តគាំទ្រការអភិវឌ្ឍកម្មវិធីសិក្សាតាមសាកលវិទ្យាល័យនិងវិទ្យាស្ថានអប់រំនិងបណ្តុះបណ្តាលដទៃទៀត។ (ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា/ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ/ក្រសួងពាណិជ្ជកម្ម) | | |
| ការទ្រទ្រង់វិស័យហិរញ្ញវត្ថុជាលក្ខណៈស្ថាប័ន :<br>- ប្រតិបត្តិការមានកិច្ចធានា និងភតិសន្យា<br>- ច្បាប់ក្រុមហ៊ុន<br>- ប្រព័ន្ធពន្ធដារ និងសារពើពន្ធប្រកបដោយចីរភាព<br>- គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង រូបិយវត្ថុ និងក្របខ័ណ្ឌស្ថាប័នពាក់ព័ន្ធ<br>- នីតិរដ្ឋ | បន្តទ្រទ្រង់នីតិរដ្ឋក្នុងវិស័យហិរញ្ញវត្ថុ តាមរយៈ :<br>- ការពិគ្រោះយោបល់ជាសាធារណៈ អំពីសេចក្តីព្រាងច្បាប់ និងបទបញ្ញត្តិ ដែលទាក់ទងនឹងវិស័យហិរញ្ញវត្ថុ និង<br>- ផ្សព្វផ្សាយជាសាធារណៈនូវច្បាប់ និងបទបញ្ញត្តិដែលមានទាំងអស់ដែលទាក់ទងនឹងវិស័យហិរញ្ញវត្ថុតាមអ៊ីនធឺណែត។ (ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា/ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ/ក្រសួងពាណិជ្ជកម្ម)<br><br>អនុម័តច្បាប់/ក្រមពាណិជ្ជកម្មដែលកំពុងរង់ចាំការអនុមតិនិងការអភិវឌ្ឍនូវបទបញ្ញត្តិពាក់ព័ន្ធនិងប្រព័ន្ធរដ្ឋបាល ការផ្សព្វផ្សាយ ការរៀបចំកម្មវិធីសិក្សា និងសកម្មភាពបណ្តុះបណ្តាល រួមទាំងច្បាប់ស្តីពីប្រតិបត្តិការមានកិច្ចធានា ច្បាប់ស្តីពីភតិសន្យា ច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម ច្បាប់ស្តីពីភ្នាក់ងារ និងច្បាប់ស្តីពីសិទ្ធិរកស៊ីផ្តាច់មុខ។ (ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា/ក្រសួងពាណិជ្ជកម្ម) | ការអនុវត្តន៍ និងការដាក់ឱ្យប្រតិបត្តិតាមនូវច្បាប់/ក្រមពាណិជ្ជកម្ម ពាក់ព័ន្ធនឹងបទបញ្ញត្តិនិងប្រព័ន្ធរដ្ឋបាល ការផ្សព្វផ្សាយ ការអភិវឌ្ឍ កម្មវិធីសិក្សា និងសកម្មភាពបណ្តុះបណ្តាល សម្រាប់ច្បាប់ស្តីពីប្រតិបត្តិការមានកិច្ចធានា ច្បាប់ស្តីពីភតិសន្យា ច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម ច្បាប់ស្តីពីភ្នាក់ងារ និងច្បាប់ស្តីពីសិទ្ធិរកស៊ីផ្តាច់មុខ ព្រមទាំងការបង្កើតនូវច្បាប់ពាណិជ្ជកម្ម និងមជ្ឈមណ្ឌលឯកសារ។ (ស្ថាប័ននាំមុខ : ក្រសួងពាណិជ្ជកម្ម/ ក្រសួងយុត្តិធម៌)<br><br>ការអភិវឌ្ឍប្រព័ន្ធនីតិរដ្ឋក្នុងបរិបទពាណិជ្ជកម្ម តាមរយៈការអភិវឌ្ឍប្រព័ន្ធតុលាការពាណិជ្ជកម្ម និងដំណើរការកំណែទម្រង់ច្បាប់និងតុលាការ។ (ស្ថាប័ននាំមុខ : ក្រសួងពាណិជ្ជកម្ម/ក្រសួងយុត្តិធម៌)<br><br>អនុវត្តន៍ក្របខ័ណ្ឌវឌ្ឍនភាពក្រុមហ៊ុន។ (ស្ថាប័ននាំមុខ:ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ/ក្រសួងពាណិជ្ជកម្ម)<br>បន្តកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ (ស្ថាប័ននាំមុខ : ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) | អនុវត្តនីតិវិធាននៃប្រព័ន្ធច្បាប់នៅក្នុងបរិបទពាណិជ្ជកម្ម តាមរយៈប្រព័ន្ធតុលាការពាណិជ្ជកម្ម និងបន្តដំណើរការកំណែទម្រង់ ផ្នែកច្បាប់និងតុលាការ ឱ្យបានគ្រប់ជ្រុង ជ្រោយ។(ស្ថាប័ននាំមុខ: ក្រសួង ពាណិជ្ជកម្ម/ក្រសួងយុត្តិធម៌)<br><br>អភិវឌ្ឍន៍តាមតម្រូវការ បោះពុម្ពនូវក្រដាសប្រាក់រៀលដែលមានតម្លៃចារឹកធំ។ (ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា) |

| | | | |
|---|---|---|---|
| | រៀបចំ និងអនុវត្តន៍ក្របខ័ណ្ឌក្រុមហ៊ុនវឌ្ឍនភាពរួមបញ្ចូលទាំងការតម្រូវឱ្យមានចំណាត់ថ្នាក់តាមលំដាប់ក្រុមហ៊ុនតូច ក្រុមហ៊ុនឯកជនដទៃទៀត ក្រុមហ៊ុនមហាជន និងក្រុមហ៊ុនចុះបញ្ជី (ចូរមើលផ្នែកទីផ្សារហិរញ្ញវត្ថុ)។ (ស្ថាប័ននាំមុខ :ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ/ក្រសួងពាណិជ្ជកម្ម)<br><br>បង្កើនឧបករណ៍គោលនយោបាយរូបិយវត្ថុ និង បង្កើតក្របខ័ណ្ឌគោលនយោបាយរូបិយវត្ថុផ្អែកលើទីផ្សារ (រួមបញ្ចូលទាំងប្រព័ន្ធទូទាត់សងប្រាក់ : មើលផ្នែកវិស័យធនាគារនិងមីក្រូហិរញ្ញវត្ថុ) និង ទីផ្សាររូបិយវត្ថុ និងអន្តរធនាគារ ដោយមានទាំងមូលប័ត្ររដ្ឋរយៈកាលខ្លី (មើលផ្នែកទីផ្សារហិរញ្ញវត្ថុ)។ (ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា)<br><br>បង្កើតក្របខ័ណ្ឌច្បាប់និងបទបញ្ញត្តិគន្លឹះសម្រាប់ប្រតិបត្តិការអចលនវត្ថុនិងកសាងសមត្ថភាពអាជ្ញាធរគ្រប់គ្រងទីផ្សារអចលនវត្ថុ (រួមបញ្ចូលទាំងការចូលរួមរបស់វិស័យឯកជន)។ (ស្ថាប័ននាំមុខ : ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) | ការអភិវឌ្ឍរូបិយវត្ថុ: ការកើនឡើងនូវជំនឿទុកចិត្តលើរូបិយវត្ថុជាតិនិងការប្រើប្រាស់រូបិយវត្ថុនេះ ដោយផ្តោតទៅលើកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ជាតិដុលនិងការអភិវឌ្ឍទីផ្សាររូបិយវត្ថុនិង អន្តរធនាគារ រួមបញ្ចូលទាំងមូលប័ត្ររដ្ឋរយៈកាលខ្លី។ (ស្ថាប័ន នាំមុខ : ធនាគារជាតិនៃកម្ពុជា/ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ)<br><br>អនុវត្តន៍ក្របខ័ណ្ឌលើកទឹកចិត្តសារពើពន្ធ រួមទាំងការទូទាត់ប្រាក់ បៀវត្សរដ្ឋនិងចំណាយផ្សេងៗជាប្រាក់រៀលតាមរយៈគណនីធនាគារនិងប្រព័ន្ធទូទាត់សងប្រាក់ ហើយក៏តម្រូវឱ្យការបង់ពន្ធដារ និងចំណាយរដ្ឋាភិបាលដូចគ្នាផ្សេងៗទៀត ត្រូវធ្វើឡើងជាប្រាក់រៀលតាមរយៈប្រព័ន្ធទូទាត់សងប្រាក់ផងដែរ។<br>(ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា/ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) | |

| | | | |
|---|---|---|---|
| ហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ :<br>- ក្ស័យធន<br>- ព័ត៌មានហិរញ្ញវត្ថុ<br>- អភិបាលកិច្ចសាជីវកម្ម<br>- អំពើពុករលួយ និងសុចរិតភាពទីផ្សារ | ការអនុវត្តន៍ច្បាប់ស្តីពីក្ស័យធន និងការអភិវឌ្ឍបទបញ្ញត្តិដែលពាក់ព័ន្ធ និងប្រព័ន្ធរដ្ឋបាល ក៏ដូចជាការផ្សព្វផ្សាយ ការអភិវឌ្ឍកម្មវិធីសិក្សា និងសកម្មភាពបណ្តុះបណ្តាល ។ (ស្ថាប័ននាំមុខ: ក្រសួងពាណិជ្ជកម្ម)<br><br>បន្តអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធព័ត៌មានហិរញ្ញវត្ថុរួមទាំងគណនេយ្យ សវនកម្ម ប្រព័ន្ធរដ្ឋបាលពាក់ព័ន្ធ និងស្ថាប័ន (ក្រុមប្រឹក្សាជាតិគណនេយ្យនិងវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា) និងការអភិវឌ្ឍធនធានមនុស្ស ។ (ស្ថាប័នដឹកនាំ : ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)<br><br>រៀបចំដាក់ចេញនូវប្រព័ន្ធព័ត៌មានឥណទានអន្តរធនាគារ ។ (ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា) ។ ការបញ្ចប់ និងការអនុវត្តន៍ក្របខ័ណ្ឌប្រឆាំងនឹងការសំអាតប្រាក់និងការអភិវឌ្ឍបទបញ្ញត្តិសមស្របសម្រាប់ឧក្រិដ្ឋកម្មហិរញ្ញវត្ថុ (មើលផ្នែកទីផ្សារហិរញ្ញវត្ថុ) ។ (ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា/ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ/ក្រសួងយុត្តិធម៌/ក្រសួងមហាផ្ទៃ) | ការអនុវត្តន៍ និងការដាក់ឱ្យប្រតិបត្តិតាមនូវច្បាប់/ក្រមពាណិជ្ជកម្ម ដែលកំពុងរង់ចាំការអនុមតិ ។ (ស្ថាប័ននាំមុខ : ក្រសួងពាណិជ្ជកម្ម)<br><br>ផ្ទេរការទទួលខុសត្រូវលើប្រព័ន្ធព័ត៌មានឥណទានអន្តរធនាគារ ទៅឱ្យវិស័យឯកជន ។ (ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា) | |

| ធនាគារនិងមីក្រូហិរញ្ញវត្ថុ | អាទិភាពចំពោះមុខ<br>( ក្នុងរយៈពេល ៣ឆ្នាំ )<br>គោលដៅ : ២០០៦-២០០៩ | អាទិភាពអន្តរកាល និងរយៈពេលមធ្យម<br>( ៣ ទៅ ៥ឆ្នាំ )<br>គោលដៅ : ២០០៩-២០១២ | គោលដៅរយៈពេលវែង<br>( ៥ ទៅ ១០ឆ្នាំ )<br>គោលដៅ : ២០១២-២០១៥ |
|---|---|---|---|
| **ធនាគារ**<br>**ចក្ខុវិស័យ** : ប្រព័ន្ធធនាគារមួយដែលមានលក្ខណៈប្រកួតប្រជែង សមាហរណកម្ម និងប្រសិទ្ធភាព គឺជាប្រព័ន្ធធនាគារដែលមានការគ្រប់គ្រង និងមានការត្រួតពិនិត្យបានសមស្រប ហើយដែលគៀងគរប្រាក់សន្សំដោយមានប្រសិទ្ធភាព ដើម្បីផ្តល់ហិរញ្ញប្បទានក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ។ | | | |
| | បន្តលើកកម្ពស់ការត្រួតពិនិត្យ ការកសាងសមត្ថភាពនៅធនាគារជាតិនៃកម្ពុជា និងធនាគារពាណិជ្ជ និងការអប់រំអតិថិជន និងសកម្មភាពផ្សព្វផ្សាយការយល់ដឹងផ្សេងៗ។ (ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា)<br><br>ធ្វើឱ្យស្វ័យប្រវត្តិកម្មនូវការទូទាត់ និងផាត់ទាត់មូលប្បទានប័ត្រ។ (ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា) | ពង្រីកប្រព័ន្ធទូទាត់សងប្រាក់ និងប្រព័ន្ធព័ត៌មានឥណទាន ឱ្យបានទៅដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណ។<br>(ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា)<br><br>ផ្តល់ប្រាតិភោគនៃហានិភ័យប្រព័ន្ធទូទាត់សងប្រាក់តាមរយៈមូលប័ត្ររដ្ឋរយៈកាលខ្លី។<br>(ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា) | ដើម្បីចាប់ផ្តើមបញ្ចប់ទិសដៅចំពោះមុខ និងអន្តរ-កាល គឺ :<br>ការពិនិត្យឡើងវិញសមស្របនូវប្រព័ន្ធច្បាប់ និងបទបញ្ញត្តិក្នុងផ្ទៃក ដើម្បីលើកកម្ពស់និងធ្វើបច្ចុប្បន្នកម្ម តាមការចាំបាច់។<br>(ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា) |

| | | | |
|---|---|---|---|
| | ការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ជាតិដុល តាមអេឡិចត្រូនិច (រួមទាំងការទ្រទ្រង់ទីផ្សារអន្តរ-ធនាគារ) ជាបឋម ជាមួយធនាគារ និងធនាគារឯកទេស ជាអ្នកចូលរួម ។<br>(ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា)<br><br>ធ្វើឱ្យអ្នករកស៊ីចងការប្រាក់និងអាជីវករប្តូរប្រាក់ចូលទៅក្នុងក្របខ័ណ្ឌបទបញ្ញត្តិផ្លូវការ ជាដំបូងតាមរយៈកាតព្វកិច្ចចុះបញ្ជី និងចងក្រងឯកសារ ។<br>(ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា)<br><br>ការអភិវឌ្ឍគ្រប់ជ្រុងជ្រោយ នូវប្រព័ន្ធគ្រប់គ្រងព័ត៌មានរបស់ធនាគារជាតិនៃកម្ពុជា ដើម្បីទ្រទ្រង់មុខងារផ្សេងៗ ។<br>(ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា)<br><br>ពង្រឹងធនាគារជាតិនៃកម្ពុជា និងការអនុវត្តន៍ និងការដាក់ឱ្យអនុវត្តច្បាប់ ។<br>(ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា/ក្រសួងយុត្តិធម៌) | បន្តការកសាងសមត្ថភាពនៅធនាគារជាតិនៃកម្ពុជា និងគ្រឹះស្ថានធនាគារ ។<br>(ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា)<br><br>ធ្វើសកម្មភាពបណ្តុះបណ្តាលអតិថិជន និងផ្សព្វផ្សាយការយល់ដឹង ។<br>(ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា)<br><br>បន្តការកែលំអការត្រួតពិនិត្យ ។<br>(ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា)<br><br>ទ្រទ្រង់ការអភិវឌ្ឍផលិតផល/សកម្មភាពហិរញ្ញ-វត្ថុថ្មីៗ នៅក្នុងបរិបទនៃការស្មើភាពរវាងអ្នកផ្តល់សេវា និងនៃស្ថិរភាពហិរញ្ញវត្ថុ ។<br>(ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា/ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) ។ កិច្ចការនេះនឹងរាប់បញ្ចូលទាំងការគ្រប់គ្រងអ្នករកស៊ីចងការប្រាក់ និងអាជីវករប្តូរប្រាក់ ក្នុងបរិបទដែលពួកគេប្រកបមុខរបរធនាគារ ។<br>(ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា) | អនុវត្តការផ្លាស់ប្តូរដែលជាលទ្ធផលនៃការពិនិត្យឡើងវិញឱ្យគ្រប់ជ្រុងជ្រោយនូវច្បាប់ និងបទបញ្ញត្តិធនាគារ ។<br>(ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា)<br><br>ពិនិត្យឡើងវិញនូវប្រព័ន្ធការពារអ្នកផ្ញើប្រាក់<br>(ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា) |

| | | | |
|---|---|---|---|
| **មីក្រូហិរញ្ញវត្ថុ**<br>**ចក្ខុវិស័យ:** បង្កើតប្រព័ន្ធមីក្រូហិរញ្ញវត្ថុស្ថិតស្ថេរ យកចិត្តទុកដាក់ចំពោះពលរដ្ឋក្រីក្រ និងមានប្រសិទ្ធភាព ដែលនឹងផ្តល់សេវាហិរញ្ញវត្ថុដែលអាចរ៉ាប់រងបានឱ្យពលរដ្ឋក្រីក្រ អាចមានលទ្ធភាពបង្កើនចំណូល និងកាត់បន្ថយភាពក្រីក្រ ។ | | | |
| | ក្របខ័ណ្ឌសម្រាប់មីក្រូហិរញ្ញវត្ថុ :<br>- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងសមាគមមីក្រូហិរញ្ញ-វត្ថុកម្ពុជា : ដំណើរការ<br>- ធនាគារជាតិនៃកម្ពុជា : បទបញ្ញត្តិ និងការត្រួតពិនិត្យ<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ : ការអភិវឌ្ឍគោលនយោបាយ<br>កែលំអស្តង់ដាររាយការណ៍ជាទូទៅរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុសម្រាប់ការវិភាគការអនុវត្តន៍ហិរញ្ញវត្ថុ និងការផ្តល់ព័ត៌មានដ៏រឹងមាំ ។<br>(ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា)<br><br>ការអភិវឌ្ឍនូវវិធីសាស្ត្រចុះទៅត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា ដែលបានកែលំអសម្រាប់វាយតម្លៃ និងធ្វើចំណាត់ថ្នាក់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។ (ស្ថាប័ននាំមុខ: ធនាគារជាតិនៃកម្ពុជា) | ការអភិវឌ្ឍនូវសំភារៈឧបទ្ទេសបណ្តុះបណ្តាលមីក្រូហិរញ្ញវត្ថុ ដើម្បីឱ្យសមស្របជាមួយការបណ្តុះបណ្តាលការងារផ្នែកទ្រឹស្តី និងគាំទ្រការកសាងសមត្ថភាពក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។<br>(ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា)<br><br>ការអភិវឌ្ឍប្រព័ន្ធព័ត៌មានឥណទាន (CIS) សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងលទ្ធភាពរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណទៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទានរបស់ គ្រឹះស្ថានធនាគារ ។<br>(ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា)<br><br>ផ្តើមអនុវត្តន៍នូវសមត្ថភាពធ្វើចំណាត់ថ្នាក់នៅកម្ពុជា ដើម្បីអនុវត្តការចាត់ថ្នាក់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឱ្យបានទៀងទាត់ ។<br>(ស្ថាប័ននាំមុខ: ធនាគារជាតិនៃកម្ពុជា) | ការបង្កើតបណ្តាញទ្រទ្រង់ សំរាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុរាយដែលមានកម្រិតទាបជាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាប័ណ្ណ សម្រាប់ផ្តល់ជំនួយបច្ចេកទេសម្តងម្កាល ។<br>(ស្ថាប័ននាំមុខ : ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)<br><br>បង្កើតក្រុមហ៊ុនធ្វើចំណាត់ថ្នាក់មីក្រូហិរញ្ញវត្ថុនៅក្នុងស្រុក ដែលក្នុងរយៈពេលវែង អាចជួយដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្នុងការកែលំអគោលនយោបាយ និងប្រតិបត្តិការ ។<br>(ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា) |

| | | | |
|---|---|---|---|
| | ពិនិត្យឡើងវិញនូវក្របខ័ណ្ឌបច្ចុប្បន្នសម្រាប់គ្រឹះស្ថានហិរញ្ញវត្ថុដែលមិនចុះបញ្ជី/ក្រៅផ្លូវការ ។<br>(ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា)<br><br>កែលំអប្រព័ន្ធគ្រប់គ្រងព័ត៌មាននៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (ការសិក្សាខ្លីៗបន្តដោយកម្មវិធីអភិវឌ្ឍន៍) ។<br>(ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា)<br><br>ការសិក្សាខ្លីៗដើម្បីរៀបចំការងារមូលដ្ឋាន សម្រាប់ការអភិវឌ្ឍកម្មវិធីបន្ថែមទៀត ។<br>(ស្ថាប័ននាំមុខ : ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)<br><br>ការបង្កើតលទ្ធភាពទ្រទ្រង់ទម្រង់ផ្សេងទៀតនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (ដូចជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផ្អែកលើសហគមន៍ និងមិនបានចុះបញ្ជី ។ល ។) ដើម្បីពង្រីកនូវប្រភេទតម្រូវការដែលកំពុងជួបប្រទះ និងបង្កើតនូវប្រភេទ និងភាពទន់ភ្លន់នៅក្នុងប្រព័ន្ធឱ្យកាន់តែទូលាយឡើង ។<br>(ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា /ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) | សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា សហការជាមួយគណៈកម្មាធិការអភិវឌ្ឍន៍ឥណទានជនបទ ដើម្បីរៀបចំសម្រាប់ផ្សព្វផ្សាយជំរើសគោលនយោបាយដែលបានកែលំអ ដើម្បីជួយដល់ការពិភាក្សា ការគាំទ្រ ការស្រាវជ្រាវ និងការផ្លាស់ប្តូរព័ត៌មាន។<br>(ស្ថាប័ននាំមុខ : ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ/គណៈកម្មាធិការអភិវឌ្ឍន៍ឥណទានជនបទ/សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា)<br><br>ការអភិវឌ្ឍទីផ្សារលក់ដុំរបស់វិស័យឯកជនសម្រាប់ធ្វើហិរញ្ញប្បទានដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដោយផ្សារភ្ជាប់ទៅនឹងវិស័យធនាគារពាណិជ្ជ ។<br>(ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា/ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ)<br><br>បង្កើតចំណងទាក់ទងរវាងអ្នកចូលរួមទីផ្សារមីក្រូហិរញ្ញវត្ថុ និងអង្គការនានាដែលធ្វើសកម្មភាពជាមួយទុរគតជន ដើម្បីរៀបចំកម្មវិធី និងបង្កើតកម្មវិធីនិងវិធីសាស្ត្រសម្រាប់ទុរគតជន ដើម្បីចូលទៅទីផ្សារមីក្រូហិរញ្ញវត្ថុនិងលែងក្លាយជាទុរគតជន ។<br>(ស្ថាប័ននាំមុខ : ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) | |

| ហិរញ្ញវត្ថុមិនមែនធនាគារ | អាទិភាពចំពោះមុខ<br>( ក្នុងរយៈពេល ៣ឆ្នាំ )<br>គោលដៅ : ២០០៦-២០០៩ | អាទិភាពអន្តរកាល និងរយៈពេលមធ្យម<br>( ៣ ទៅ ៥ឆ្នាំ )<br>គោលដៅ : ២០០៩-២០១២ | គោលដៅរយៈពេលវែង<br>( ៥ ទៅ ១០ឆ្នាំ )<br>គោលដៅ : ២០១២-២០១៥ |
|---|---|---|---|
| **ការធានារ៉ាប់រង**<br>**ចក្ខុវិស័យ** : វិស័យធានារ៉ាប់រងដែលការពារអាជីវកម្ម និងការពារឯកត្តជន ចំពោះហេតុការណ៍មហន្តរាយ និង ប្រព័ន្ធសោធននិវត្តន៍ដែលទ្រទ្រង់ផែនការចូលនិវត្តន៍ ហើយប្រភពទាំងពីរនេះផ្តល់ទុនសម្រាប់ការវិនិយោគរយៈពេលវែង ។ | | | |
| | ពិនិត្យឡើងវិញគ្រប់ជ្រុងជ្រោយនូវប្រព័ន្ធបទបញ្ញត្តិទាំងមូលស្របតាមស្តង់ដារអន្តរជាតិ និងការអនុវត្តន៍ល្អបំផុត រួមទាំង :<br>- តម្រូវឱ្យមានប្រាក់កម្រិតសាធនភាព<br>- ការត្រួតពិនិត្យការវិនិយោគ<br>- តម្រូវក្នុងការធ្វើធានារ៉ាប់រងបន្ត: កម្រិត រក្សាទុកគណនេយ្យសម្រាប់ការទទួលបានពីក្រុមហ៊ុនធានារ៉ាប់រងបន្ត ។<br>- ស្តង់ដារគណនេយ្យដែលបានអនុម័តសម្រាប់ក្រុមហ៊ុនធានារ៉ាប់រងនៅកម្ពុជា ។<br>- អំណាចរបស់អ្នកត្រួតពិនិត្យ និងមធ្យោបាយដោះស្រាយ ។ | ការធានារ៉ាប់រងអាយុជីវិត :<br>- អនុញ្ញាតឱ្យយកកិច្ចសន្យាធានារ៉ាប់រងអាយុជីវិតធ្វើជាមធ្យោបាយប្រមូលមូលនិធិសម្រាប់ផែនការសោធននិវត្តន៍និងផែនការសន្សំសម្រាប់ចូលនិវត្តន៍ ។<br>(ស្ថាប័ននាំមុខ : ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)<br>- ពិនិត្យកែឡើងវិញនូវក្របខ័ណ្ឌបទបញ្ញត្តិដើម្បីសម្រួលដល់ការផ្តល់អាជ្ញាប័ណ្ណ និងប្រតិបត្តិការរបស់ក្រុមហ៊ុនដែលលក់ប័ណ្ណសន្យារ៉ាប់រងអាយុជីវិត ។<br>(ស្ថាប័ននាំមុខ : ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) | អនុវត្តន៍ច្បាប់ស្តីពីសន្តិសុខសង្គម និងបទបញ្ញត្តិពាក់ព័ន្ធ ។ (ស្ថាប័ននាំមុខ: ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា/ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)<br>អភិវឌ្ឍប្រព័ន្ធបទបញ្ញត្តិដើម្បីដោះស្រាយ កិច្ចការសោធននិវត្តន៍ឯកជន រួមទាំង :<br>- ការផ្តេវិធាននានាសម្រាប់ការចូលរួមចំណែករបស់និយោជក ។<br>- តម្រូវឱ្យមានមូលនិធិសម្រាប់តាវកាលិក ត្រូវបានធានា ។<br>-លិខិតបញ្ជាក់ពីការគណនាតម្លៃហានិភ័យសម្រាប់គំរោងតាវកាលិកដែលបានកំណត់ ។ |

| | | | |
|---|---|---|---|
| | - ដើងសារ និងភ្នាក់ងារ។ បញ្ជាក់និងសំរួលវិធាននានាសម្រាប់ផ្តល់អាជ្ញាប័ណ្ណឱ្យអន្តរការី។<br>- ការបញ្ជាក់ច្បាស់លាស់មួយ សម្រាប់ការចាកចេញពីទីផ្សារ ទោះជាចាកចេញដោយស្ម័គ្រចិត្ត ឬដោយបង្ខំ។<br>- បទបញ្ញត្តិនានាទាក់ទងនឹងការក្ស័យធន និងការជំរះបញ្ជីរបស់ក្រុមហ៊ុនធានារ៉ាប់រងក្រោមច្បាប់ស្តីពីក្ស័យធន។<br>- ដំណើរការរៀបចំ គោលនយោបាយច្បាស់លាស់និងតម្លាភាព។<br>- ពិនិត្យកែឡើងវិញនូវក្របខ័ណ្ឌបទបញ្ញត្តិ ដើម្បីកែសម្រួលដល់ការផ្តល់អាជ្ញាប័ណ្ណ និងប្រតិបត្តិការរបស់ក្រុមហ៊ុនដែលលក់ប័ណ្ណសន្យារ៉ាប់រងអាយុជីវិត។ (ស្ថាប័ននាំមុខ : ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)<br>- តម្លាភាពក្នុងការរាយការណ៍ ជាពិសេស ស្ថិតិ។ (ស្ថាប័ននាំមុខ : ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)<br>ការផ្លាស់ប្តូររចនាសម្ព័ន្ធ :<br>- បង្កើតអង្គភាពគោលនយោបាយ ដែលមានការទទួលខុសត្រូវទាំងស្រុងលើការរៀបចំគោលនយោបាយបទបញ្ញត្តិ/ត្រួតពិនិត្យ ទាក់ទងនឹងវិស័យធានារ៉ាប់រងជាមួយនឹងអ្នកត្រួតពិនិត្យវិស័យហិរញ្ញវត្ថុផ្សេងៗទៀត។<br>(ស្ថាប័ននាំមុខ : ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) | ការតម្រូវឱ្យមានការគណនាតម្លៃហានិភ័យ: ការបង្កើតប្រតិបត្តិការធានារ៉ាប់រងអាយុជីវិតនឹងតម្រូវឱ្យមានការបង្កើតនូវវិធានសម្រាប់ការគណនាតម្លៃធានាហានិភ័យ ដែលអនុញ្ញាតឱ្យក្រុមហ៊ុននិមួយៗតែងតាំងអ្នកគណនាតម្លៃហានិភ័យដែលមានគុណវុឌ្ឍិ តាមរយៈអង្គការមួយដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ។ (ស្ថាប័ននាំមុខ : ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)<br>វិទ្យាស្ថានបណ្តុះបណ្តាល :<br>ពិចារណាលើការបង្កើតវិទ្យាស្ថានបណ្តុះបណ្តាលនៅកម្ពុជា ដើម្បីរួមចំណែកដល់ការបណ្តុះបណ្តាលដល់តំណាងលក់នានា ក៏ដូចជា អ្នកត្រួតពិនិត្យ និងអ្នកចាត់ការក្នុងការិយាល័យ។<br>(ស្ថាប័ននាំមុខ : ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)<br>ការការពារអ្នកប្រើប្រាស់ និងការផ្សព្វផ្សាយជាសាធារណៈ<br>- កិច្ចការរបស់អ្នកប្រើប្រាស់ : បង្កើតឧបករណ៍ដើម្បីឱ្យអ្នកប្រើប្រាស់អាចចាត់ចែងការទាមទារសំណង ឬស៊ើបសួរ ទាក់ទងនឹងកិច្ចសន្យាធានារ៉ាប់រងរបស់ពួកគេ។<br>- រដ្ឋាភិបាល និងវិស័យនេះ ធ្វើការរួមគ្នាអនុម័តនូវវិធានការនានាដើម្បីបង្កើនការផ្សព្វផ្សាយជាសាធារណៈ ថាបានទទួលពីប័ណ្ណសន្យាធានារ៉ាប់រង។ | - វិធានវិនិយោគដែលបញ្ជាក់ពីទិន្នផលខ្ពស់ ដោយមានសុវត្ថិភាពដែរ និងសាច់ប្រាក់ងាយស្រួលជាចាំបាច់។<br>(ស្ថាប័ននាំមុខ: ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា/ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)<br>ពិនិត្យនូវអត្ថប្រយោជន៍នានានៃការបញ្ចូលផែនការសន្សំជាកាតព្វកិច្ចសម្រាប់ពលករធ្វើការនៅក្នុងវិស័យផ្លូវការ ដែលជាផ្នែកមួយនៃប្រព័ន្ធសន្តិសុខសង្គម។<br>(ស្ថាប័ននាំមុខ : ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា/ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) |

| | | | |
|---|---|---|---|
| | ស្តង់ដាររាយការណ៍ហិរញ្ញវត្ថុ :<br>- ពិនិត្យឡើងវិញនូវស្តង់ដាររាយការណ៍ហិរញ្ញវត្ថុសម្រាប់ក្រុមហ៊ុនធានារ៉ាប់រង និងបទដ្ឋាននានាដែលមានលក្ខណៈទូលំទូលាយគ្រប់ជ្រុងជ្រោយ ដែលបានរៀបចំ និងអនុម័ត : "ស្តង់ដារចាំបាច់របស់ក្រុមហ៊ុនធានារ៉ាប់រងនៅកម្ពុជា "។<br>- បង្កើតវិធានច្បាស់លាស់ទាក់ទងទៅនឹងការបង្កើតទុនបំរុងខាតសម្រាប់ការទាមទារសំណង។<br>- កំណត់តម្រូវការឱ្យមានសវនកម្មចំពោះក្រុមហ៊ុនធានារ៉ាប់រង។<br><br>បញ្ហាទាក់ទងនឹងសកម្មភាពនានារបស់អ្នកត្រួតពិនិត្យ:<br>- ការកសាងសមត្ថភាព : កម្មវិធីបណ្តុះបណ្តាលដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយសម្រាប់បុគ្គលិកដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យក្រុមហ៊ុនធានារ៉ាប់រង។<br>- ការពិចារណាចំពោះការប្រើប្រាស់ធនធានពីខាងក្រៅលើមុខងារត្រួតពិនិត្យជាក់លាក់ ជាពិសេសនៅក្នុងបរិបទតំបន់។<br>- បង្កើនការទុកចិត្តទៅលើវិជ្ជាជីវៈ : អ្នកធ្វើអធិការកិច្ចមិនត្រូវធ្វើការដូចគ្នានឹងការងាររបស់សវនករទេ។ | - សេវាទូទាត់សំណងៈ អ្នកត្រួតពិនិត្យតាមដានការអនុវត្តនីដំណោះស្រាយប្តឹងសងនានា ដែលជាផ្នែកមួយនៃការធ្វើអធិការកិច្ច។<br>- បណ្តុះបណ្តាលសហគមន៍ស្របច្បាប់។<br>(ស្ថាប័ននាំមុខ : ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)<br><br>ការតម្រូវឱ្យមានតារាងតម្លៃ និងការប្រើប្រាស់ពាក្យពេចន៍លើប័ណ្ណធានារ៉ាប់រងរួម :<br>- សមាគមពាណិជ្ជកម្មត្រូវរៀបចំ និងស្នើឡើងនូវតារាងតម្លៃអប្បបរិមាដែលត្រូវយកទៅប្រើសម្រាប់ធានារ៉ាប់រង។<br>- តារាងតម្លៃដែលស្នើឡើងត្រូវផ្អែកលើវិជ្ជាជីវៈវាយតម្លៃឯករាជ្យមួយដើម្បីធានាថា តម្លៃនេះល្មមគ្រប់គ្រាន់សម្រាប់ទូទាត់សំណង ដែលអាចកើតឡើង ដូចមានចែងក្នុងប័ណ្ណសន្យារ៉ាប់រង។<br>- អ្នកត្រួតពិនិត្យការធានារ៉ាប់រងត្រូវទទួលយកតារាងតម្លៃនេះ និងបញ្ជាក់ថា អត្រាដែលក្រុមហ៊ុនកំណត់យកមិនត្រូវតិចជាងតារាងតម្លៃដែលបានកំណត់នេះទេ។<br>- ការរៀបចំនេះត្រូវបានធ្វើឡើងសម្រាប់ជម្រុញការអនុវត្តនីតារាងតម្លៃនេះ។ | |

| | | | |
|---|---|---|---|
| | - បញ្ឈប់ការឯកភាពលើទម្រង់ប័ណ្ណធានា ហើយប្រកាន់យកវិធីសាស្ត្រមួយដែលផ្អែកលើ"ប្រើប្រាស់ទៅតាមឯកសារតំកល់"<br>- រៀបចំឯកសារនីតិវិធីធ្វើដោយដៃដើម្បីណែនាំការងារដល់បុគ្គលិកត្រួតពិនិត្យ ។<br>- ណែនាំឱ្យប្រើកុំព្យូទ័រ ដើម្បីជួយដល់ការងារត្រួតពិនិត្យ ។<br>- សមាជិកភាពក្នុងសមាគមអន្តរជាតិនៃអ្នកត្រួតពិនិត្យធានារ៉ាប់រង (IAIS) ។<br>(ស្ថាប័ននាំមុខ : ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)<br><br>បញ្ចប់ការធ្វើឯកជនភាវូបនីយកម្មក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជា "កាមិនកូ" ។ (ស្ថាប័ននាំមុខ : ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)<br><br>កិច្ចសហការអន្តរក្រសួង ។ គណៈកម្មាធិការអន្តរក្រសួង ជាមួយនឹងតំណាងក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងទេសចរណ៍ និងក្រសួងមហាផ្ទៃ ដើម្បីជម្រុញការអនុវត្តន៍តាមវិធាននានា ឱ្យបានកាន់តែច្រើនឡើង ដោយអំពាវនាវឱ្យប្រើ ប្រាស់ការធានារ៉ាប់រងកាតព្វកិច្ចសម្រាប់យានយន្ត និងការដ្ឋានសំណង់ ។<br>(ស្ថាប័ននាំមុខ : ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) | ការសិក្សាអំពីលទ្ធភាពនៅក្នុងការអភិវឌ្ឍប្រព័ន្ធសោធននិវត្តន៍ស្ម័គ្រចិត្តឯកជនមួយនៅកម្ពុជា និងការជម្រុញការសន្សំដោយស្ម័គ្រចិត្តសម្រាប់ការចូលនិវត្តន៍ តាមរយៈការលើកទឹកចិត្តសារពើពន្ធ ។<br>(ស្ថាប័ននាំមុខ : ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) | |

| | | | |
|---|---|---|---|
| | ធានារ៉ាប់រងអាយុជីវិត ៖ ការសិក្សាពីលទ្ធភាពអាចធ្វើបានដើម្បីចូលក្នុងទីផ្សារ សក្តានុពលសម្រាប់អាជីវកម្មធានារ៉ាប់រងអាយុជីវិតនៅកម្ពុជា និងទ្រទ្រង់ការអភិវឌ្ឍច្បាប់ និងបទបញ្ញត្តិសំដៅទ្រទ្រង់ការអភិវឌ្ឍវិស័យធានារ៉ាប់រងអាយុជីវិតនៅកម្ពុជា។<br>ពិនិត្យឡើងវិញនូវក្របខ័ណ្ឌបទបញ្ញាដើម្បី សម្រួលដល់ការផ្តល់អាជ្ញាប័ណ្ណ និងប្រតិបត្តិការរបស់ក្រុមហ៊ុនដែលលក់ប័ណ្ណសន្យាធានារ៉ាប់រងអាយុជីវិត។<br>(ស្ថាប័ននាំមុខ ៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)<br><br>មីក្រូធានារ៉ាប់រង។ បង្កើតប្រព័ន្ធពិសេសមួយសម្រាប់គ្រប់គ្រង និងត្រួតពិនិត្យសកម្មភាព និងគ្រឹះស្ថានមីក្រូធានារ៉ាប់រងនានា។<br>(ស្ថាប័ននាំមុខ ៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) | | |

| | | | |
|---|---|---|---|
| **ទីផ្សារហិរញ្ញវត្ថុ**<br>**ចក្ខុវិស័យ:** ទីផ្សារហិរញ្ញវត្ថុដែលសមស្របសម្រាប់ដោះស្រាយហានិភ័យ បំបាត់ឧបសគ្គរាំងស្ទះដល់ការអភិវឌ្ឍហិរញ្ញវត្ថុ និងទ្រទ្រង់ការគ្រប់គ្រងហានិភ័យ និងការបែងចែក និងបង្គរធនធានហិរញ្ញវត្ថុ។ | | | |
| | ទីផ្សាររូបិយវត្ថុនិងអន្តរធនាគារ :<br>- ប្រព័ន្ធទូទាត់សងប្រាក់ជាតិដុល (មើលវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ និងមូលដ្ឋានគ្រឹះនៃវិស័យហិរញ្ញវត្ថុ)។<br>(ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា)<br>- បន្តកំណែទម្រង់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ<br>(ស្ថាប័ននាំមុខ : ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)<br>- ប្រព័ន្ធមូលបត្ររដ្ឋអេឡិចត្រូនិច (ភ្ជាប់ទៅនឹងប្រព័ន្ធចុះបញ្ជីប្រតិបត្តិការមានកិច្ចធានា កាតព្វកិច្ចដើមទុន ប្រព័ន្ធទូទាត់សងប្រាក់) ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា។ ចាប់ផ្តើមបោះផ្សាយសញ្ញាប័ណ្ណរយៈពេលខ្លី (មានរយៈពេលតិចជាង ១ ឆ្នាំ ដោយចាប់ផ្តើមជាមួយសញ្ញាប័ណ្ណដែលមានរយៈពេល៣០ថ្ងៃ)។<br>(ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា/ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)។ | ទីផ្សាររូបិយវត្ថុនិងអន្តរធនាគារ :<br>- បន្តលើកកម្ពស់ការគ្រប់គ្រងសារពើពន្ធរបស់រដ្ឋាភិបាល / ធនាគារជាតិនៃកម្ពុជា តាមរយៈកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងសកម្មភាពដែលពាក់ព័ន្ធ។<br>(ស្ថាប័ននាំមុខ : ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)<br>- ពង្រីកដែនឥណប្រតិទានមូលប័ត្ររដ្ឋ ដោយផ្តែកលើការណែនាំនិងការត្រៀមលក្ខណៈសមស្រប។<br>(ស្ថាប័ននាំមុខ : ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ / ធនាគារជាតិនៃកម្ពុជា )<br>- ពិចារណាលើការអនុញ្ញាតឱ្យគ្រឹះស្ថានហិរញ្ញវត្ថុមួយចំនួនធ្វើសំណើលក់(ជាដំបូងធនាគារបន្ទាប់មកពង្រីកទៅដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណ) ផលប័ត្រពាណិជ្ជកម្មរយៈពេលខ្លី (១ឆ្នាំ ឬតិចជាង) តាមរយៈប្រព័ន្ធរដ្ឋាភិបាល។<br>(ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា) | ទីផ្សាររូបិយវត្ថុនិងអន្តរធនាគារ :<br>- បន្តលើកកម្ពស់ការគ្រប់គ្រងសារពើពន្ធរបស់រដ្ឋាភិបាល / ធនាគារជាតិនៃកម្ពុជា តាមរយៈកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងសកម្មភាពដែលពាក់ព័ន្ធ។<br>(ស្ថាប័ននាំមុខ : ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)<br>- ពង្រីកដែនឥណប្រតិទានមូលប័ត្ររដ្ឋ ដោយផ្តែកលើការណែនាំ និងការត្រៀមលក្ខណៈសមស្រប។<br>(ស្ថាប័ននាំមុខ : ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ / ធនាគារជាតិនៃកម្ពុជា) |

| | | | |
|---|---|---|---|
| | ទីផ្សារទុន :<br>- អនុម័តច្បាប់ស្តីពីក្ស័យធន (ស្ថាប័ននាំមុខៈ ក្រសួងពាណិជ្ជកម្ម)<br>- អភិវឌ្ឍន៍ក្របខ័ណ្ឌវឌ្ឍនភាពក្រុមហ៊ុន ជាមួយនឹងលក្ខខណ្ឌតាមដំណាក់កាល សម្រាប់ក្រុមហ៊ុនតូចៗ ក្រុមហ៊ុនឯកជន ក្រុមហ៊ុនមហាជន និងក្រុមហ៊ុនដែលបានចុះបញ្ជី មុននឹងអនុញ្ញាតឱ្យចុះបញ្ជីជាក្រុមហ៊ុនមហាជន។<br>(ស្ថាប័ននាំមុខ : ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ/ក្រសួងពាណិជ្ជកម្ម)<br>- ការអប់រំអ្នកវិនិយោគ និងការអភិវឌ្ឍធនធានមនុស្ស (ស្ថាប័ននាំមុខ : ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)<br>- បង្កើតដៃគូជាមួយទីផ្សារមូលប័ត្របរទេស និងបញ្ញត្តិករមូលប័ត្របរទេស។ (ស្ថាប័ននាំមុខ : ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ)<br>- ទីផ្សាររូបិយវត្ថុនិងអន្តរធនាគារៈ បញ្ចប់ដំណាក់កាលចំពោះមុខ។ (ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា/ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)<br>ការអនុមតិច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលប័ត្រមហាជន ដែលផ្តល់យ៉ាងហោចជាអប្បបរិមានូវចំណុចខាងក្រោម :<br>- អនុវត្តក្របខ័ណ្ឌ/អាជ្ញាធរសម្រាប់បំបាត់ការក្លែងបន្លំ ។ល ។ | ទីផ្សារទុន :<br>- អនុវត្តក្របខ័ណ្ឌអភិវឌ្ឍន៍វឌ្ឍនភាព សម្រាប់ក្រុមហ៊ុននានា ដោយធ្វើចំណាត់ថ្នាក់ក្រុមហ៊ុនតូច ក្រុមហ៊ុនឯកជនដទៃទៀត ក្រុមហ៊ុនមហាជន និងក្រុមហ៊ុនដែលបានចុះបញ្ជី។<br>(ស្ថាប័ននាំមុខ : ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ / ក្រសួងពាណិជ្ជកម្ម)<br>- ប្រតិបត្តិកររក្សាទុកមូលប័ត្រសម្រាប់មូលប័ត្រក្រុមហ៊ុនមហាជនទាំងអស់ រួមទាំងបញ្ជីចុះឈ្មោះពិតប្រាកដ ទិន្នន័យតម្លៃ និងមូលប័ត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនមហាជន<br>(ស្ថាប័ននាំមុខ : ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ/ក្រសួង ពាណិជ្ជកម្ម)<br>- អនុវត្តន៍នូវយន្តការបង្ខំឱ្យអនុវត្តន៍ផ្នែកហិរញ្ញវត្ថុ និងវិធានហិរញ្ញវត្ថុ (ស្ថាប័ននាំមុខៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)<br>- បន្តអភិវឌ្ឍន៍ព័ត៌មានហិរញ្ញវត្ថុ / បទបញ្ញត្តិក្រុមហ៊ុន<br>(ស្ថាប័ននាំមុខ : ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ / ក្រសួងពាណិជ្ជកម្ម)<br>- រៀបចំបង្កើតទីផ្សារមូលប័ត្រ រួមបញ្ចូលទាំងការសិក្សាលទ្ធភាពដែលអាចធ្វើបាន ការអភិវឌ្ឍបច្ចេកវិទ្យា ការធ្វើសំណើលក់មូលប័ត្រជាសាធារណៈតាមរយៈទីផ្សារមូលប័ត្រតែប៉ុណ្ណោះ | ទីផ្សារទុន :<br>ពិចារណាបង្កើតនូវ :<br>- មូលនិធិវិនិយោគ<br>- គំរោងមូលនិធិសោធននិវត្ត/សន្សំ<br>- គ្រឹះស្ថាន/ក្របខ័ណ្ឌមូលប័ត្រនីយកម្ម<br>- ឧបករណ៍និស្សន្ទ<br>(ស្ថាប័ននាំមុខ : ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) |

| | | | |
|---|---|---|---|
| | - ប្រតិបត្តិករក្សាទុកមូលប័ត្រអេឡិចត្រូនិចរួមសម្រាប់មូលប័ត្ររបស់ក្រុមហ៊ុនមហាជនទាំងអស់ (ដែលភ្ជាប់ទៅនឹងប្រព័ន្ធចុះបញ្ជី ប្រតិបត្តិការមានកិច្ចធានា)។<br>(ស្ថាប័ននាំមុខ : ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)<br>បន្តការកែលំអនូវសមត្ថភាពគណនេយ្យ និងសវនកម្ម។ (ស្ថាប័ននាំមុខ : ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ / ធនាគារជាតិនៃកម្ពុជា) | (រួមទាំងមូលនិធិវិនិយោគ) អន្តរការីមូលប័ត្រសមស្រប (រួមមានធនាគារ ក្រុមហ៊ុនធានារ៉ាប់រង និងក្រុមហ៊ុនមូលប័ត្រ) និងពិចារណាអំពីគំរោងសំណងព្យសនកម្មទៅអ្នកវិនិយោគ។<br>(ស្ថាប័ននាំមុខ : ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ / ធនាគារជាតិនៃកម្ពុជា) | |

| បញ្ហាទូទៅ និងឆ្លងវិស័យ | អាទិភាពចំពោះមុខ ( ក្នុងរយៈពេល ៣ឆ្នាំ ) គោលដៅ : ២០០៦-២០០៩ | អាទិភាពអន្តរកាល និងរយៈពេលមធ្យម ( ៣ ទៅ ៥ឆ្នាំ ) គោលដៅ : ២០០៩-២០១២ | គោលដៅរយៈពេលវែង ( ៥ ទៅ ១០ឆ្នាំ ) គោលដៅ : ២០១២-២០១៥ |
|---|---|---|---|
| ចក្ខុវិស័យ: ការបើកទូលាយចំពោះផលិតផលហិរញ្ញវត្ថុ និងការបង្កើតថ្មីរបស់ស្ថាប័ន នូវវចនាសម្ព័ន្ធហិរញ្ញវត្ថុ ដែលកាន់តែមានតុល្យភាព បង្កើនភាពស៊ីជម្រៅនៃវិស័យហិរញ្ញវត្ថុ និងជម្រុញការប្រកួតប្រជែងនៅក្នុងបរិបទស្ថិរភាពហិរញ្ញវត្ថុ។ | | | |
| សេរីភាវូបនីយកម្ម និងការប្រកួតប្រជែង | ការអនុវត្តន៍នូវវិស័យហិរញ្ញវត្ថុរបស់អង្គការពាណិជ្ជកម្មពិភពលោក និងអាស៊ាន និងការប្តេជ្ញាចិត្តដែលពាក់ព័ន្ធ។ (ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា/ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ/ក្រសួងពាណិជ្ជកម្ម)<br><br>ការរៀបចំច្បាប់ស្តីពីការប្រកួតប្រជែង និងគោលនយោបាយដោយយកចិត្តទុកដាក់លើតម្រូវការចាំបាច់នៃវិស័យហិរញ្ញវត្ថុ។ (ស្ថាប័ននាំមុខ : ក្រសួងពាណិជ្ជកម្ម/ក្រសួងយុត្តិធម៌) | ការអនុវត្តន៍គោលនយោបាយ និងច្បាប់ស្តីពីការប្រកួតប្រជែង តាមរយៈក្របខ័ណ្ឌស្ថាប័ននិងការអនុវត្តន៍សមស្រប។<br>(ស្ថាប័ននាំមុខ: ក្រសួងពាណិជ្ជកម្ម)<br><br>ការចូលរួមក្នុងសកម្មភាពអភិវឌ្ឍន៍ទីផ្សារហិរញ្ញវត្ថុតំបន់អាស៊ាន។ (ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា/ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)<br><br>ការអនុមតិ និងអនុវត្តគោលនយោបាយនិងច្បាប់ស្តីពីការប្រកួតប្រជែង រួមមានអាជ្ញាធរឯករាជ្យសមស្រប ដើម្បីអង្កេត វិភាគ និងចាត់វិធានការរដ្ឋបាល ការផ្សព្វផ្សាយ ការអភិវឌ្ឍកម្មវិធីសិក្សា និងសកម្មភាពបណ្តុះបណ្តាល។<br>(ស្ថាប័ននាំមុខ : ក្រសួងពាណិជ្ជកម្ម) | ជម្រុញឱ្យសមាជិកអាស៊ាន និងអង្គការពាណិជ្ជកម្មពិភពលោក ធ្វើសេរីភាវូបនីយកម្ម ដោយធ្វើឱ្យមានភាពស៊ីគ្នានូវការប្តេជ្ញាចិត្តលើវិស័យហិរញ្ញវត្ថុរបស់កម្ពុជា។<br>(ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា/ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ/ក្រសួងពាណិជ្ជកម្ម)<br><br>បន្តអភិវឌ្ឍន៍ច្បាប់ស្តីពីការប្រកួតប្រជែង និងប្រព័ន្ធគោលនយោបាយ។<br>(ស្ថាប័ននាំមុខ : ក្រសួងពាណិជ្ជកម្ម) |

| | | | |
|---|---|---|---|
| **គំនិតច្នៃប្រឌិតថ្មីខាងហិរញ្ញវត្ថុ** | អនុញ្ញាតឱ្យបង្កើតគ្រឹះស្ថានហិរញ្ញវត្ថុថ្មីដែលបានបំពេញតាមកាតព្វកិច្ចពាក់ព័ន្ធនឹងការទទួលអាជ្ញាប័ណ្ណ ការអនុញ្ញាត និងធ្វើប្រតិបត្តិការ។<br>(ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា / ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)<br><br>គាំទ្រវិធីសាស្ត្រដែលអនុញ្ញាតបានសម្រាប់ផលិតផល និងសេវាកម្មហិរញ្ញវត្ថុនៅក្នុងបរិបទដោះស្រាយហានិភ័យនានា។<br>(ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា/ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ/ក្រសួងយុត្តិធម៌)<br><br>បញ្ចប់ក្របខ័ណ្ឌច្បាប់ និងបទបញ្ញត្តិសម្រាប់ភតិសន្យា។<br>(ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា/ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ/ក្រសួងពាណិជ្ជកម្ម)<br><br>បញ្ជាក់វិធីសាស្ត្រ សម្រាប់សកម្មភាពគ្រឹះស្ថានហិរញ្ញវត្ថុ ជាពិសេសនៅក្នុងបរិបទធនាគារ ក្រុមហ៊ុនធានារ៉ាប់រង និងរៀបចំឱ្យមានលក្ខណៈជាផ្លូវការតាមរយៈអនុស្សារណៈស្តីពីការយោគយល់គ្នា (MOU)។<br>(ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា/ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) | រៀបចំវិធីសាស្ត្រដែលអនុញ្ញាតបានសម្រាប់ការអភិវឌ្ឍផលិតផលហិរញ្ញវត្ថុដែលផ្អែកលើបទពិសោធន៍ដែលបានទទួលនៅក្នុងបរិបទភតិសន្យា។<br>(ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា/ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ/ក្រសួងយុត្តិធម៌)<br><br>រៀបចំវិធីសាស្ត្រច្បាស់លាស់មួយសម្រាប់សកម្មភាពគ្រឹះស្ថានហិរញ្ញវត្ថុ និងក្រុមហ៊ុនចំរុះអាជីវកម្មហិរញ្ញវត្ថុ ដែលទ្រទ្រង់ដោយក្របខ័ណ្ឌច្បាប់ និងបទបញ្ញត្តិសមស្រប ឬអនុស្សារណៈស្តីពីការយោគយល់ (MOU) តាមការចាំបាច់។<br>(ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា / ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) | អភិវឌ្ឍន៍ក្របខ័ណ្ឌច្បាប់ និងបទបញ្ញត្តិ តាមការចាំបាច់ ដើម្បីទ្រទ្រង់ដល់គំនិតច្នៃប្រឌិតថ្មីខាងហិរញ្ញវត្ថុនៃផលិតផល និងសេវាហិរញ្ញវត្ថុ។<br>(ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា / ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ / ក្រសួងពាណិជ្ជកម្ម / ក្រសួងយុត្តិធម៌) |

| | | | |
|---|---|---|---|
| **រចនាសម្ព័ន្ធបទបញ្ញត្តិ** | បញ្ជាក់នូវសកម្មភាពនានា និងវិធីសាស្ត្ររបស់គ្រឹះស្ថានហិរញ្ញវត្ថុដែលបានអនុញ្ញាត ដែលមានការពាក់ព័ន្ធជាពិសេសទៅនឹងហានិភ័យជាប្រព័ន្ធដែលបង្កើតឡើងដោយសកម្មភាពធនាគារ និងវិជ្ជាជីវៈធនាគារ។<br>(ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា/ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)<br>ទ្រទ្រង់តាមរយៈការផ្លាស់ប្តូរក្របខ័ណ្ឌច្បាប់និងបទបញ្ញត្តិ ឬអនុស្សារណៈស្តីពីការយោគយល់ (MOU) តាមការចាំបាច់។<br>(ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា / ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) | វាយតម្លៃគ្រប់ជ្រុងជ្រោយនូវរចនាសម្ព័ន្ធបទបញ្ញត្តិហិរញ្ញវត្ថុនៅក្នុងបរិបទសកម្មភាពគ្រឹះស្ថានហិរញ្ញវត្ថុ និងក្រុមហ៊ុនចំរុះអាជីវកម្មហិរញ្ញវត្ថុ និងសមត្ថភាពត្រួតពិនិត្យ និងបទបញ្ញត្តិក្នុងស្រុក។<br>(ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា / ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)<br>អនុវត្តការផ្លាស់ប្តូរជាចាំបាច់នូវរចនាសម្ព័ន្ធបទបញ្ញត្តិ ដែលជាលទ្ធផលនៃការវាយតម្លៃគ្រប់ជ្រុងជ្រោយ។<br>(ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា/ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) | ពិនិត្យមើលឡើងវិញឱ្យបានគ្រប់ជ្រុងជ្រោយលើប្រព័ន្ធហិរញ្ញវត្ថុក្នុងបរិបទបទពិសោធន៍ និងស្តង់ដារអន្តរជាតិនិងតំបន់។<br>(ស្ថាប័ននាំមុខ : ធនាគារជាតិនៃកម្ពុជា / ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) |

# ឧបសម្ព័ន្ធ ១

## គណៈកម្មាធិការសម្រាប់គោលនយោបាយហិរញ្ញវត្ថុនិងសេដ្ឋកិច្ច និងគណៈកម្មាធិការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា និងក្រុមការងារបច្ចេកទេសសម្រាប់ការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ

### គណៈកម្មាធិការសម្រាប់គោលនយោបាយហិរញ្ញវត្ថុ និងសេដ្ឋកិច្ច

(សមាសភាពចូលរួមប្រជុំថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០០៦ ដែលមានលក្ខណៈជាការប្រជុំអន្តរក្រសួងសម្រាប់ត្រៀមការប្រជុំគណៈរដ្ឋមន្ត្រី)

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម គាត ឈន់ | ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២. | ឯកឧត្តម ជា ចាន់តូ | ទេសាភិបាលធនាគារជាតិនៃកម្ពុជា | អនុប្រធាន |
| ៣. | ឯកឧត្តម ហ៊ីង ថូរ៉ាក់ស៊ី | តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៤. | ឯកឧត្តម ច័ន្ទ តុងអ៊ីវ | តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៥. | ឯកឧត្តម ញឹក ច្រឹង | តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៦. | ឯកឧត្តម អ៊ូ ឱហាត | តំណាងក្រសួងផែនការ | សមាជិក |
| ៧. | ឯកឧត្តម ច័ន្ទ មនោ | តំណាងក្រសួងយុត្តិធម៌ | សមាជិក |
| ៨. | ឯកឧត្តម នឹម ថូត | តំណាងក្រសួងសង្គមកិច្ច និងអតីតយុទ្ធជន | សមាជិក |
| ៩. | លោក កាំង សុជាតិ | តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១០. | លោក សួន សុផល | តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១១. | (អវត្តមាន) | តំណាងក្រសួងទេសចរណ៍ | សមាជិក |

### គណៈកម្មាធិការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម ជា ចាន់តូ | ទេសាភិបាលធនាគារជាតិ នៃកម្ពុជា | ប្រធាន |
| ២. | ឯកឧត្តម ជា ប៉េងឈាង | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣. | ឯកឧត្តម ស៊ុំ សន្និសិទ្ធ | អគ្គលេខាធិការធនាគារជាតិ នៃកម្ពុជា | លេខាធិការ |
| ៤. | ឯកឧត្តម នឹម ថូត | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៥. | ឯកឧត្តម ហង់ ជួនណារ៉ុន | អគ្គលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៦. | ឯកឧត្តម សុខ ចិន្តា | អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |

| | | | |
|---|---|---|---|
| ៧. | លោកជំទាវ តាល់ ណៃអ៊ីម | អគ្គនាយក ធនាគារជាតិនៃកម្ពុជា | សមាជិក |
| ៨. | ឯកឧត្តម សួស សម្បត្តិ | អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៩. | លោក ពេជ្រ ឫទ្ធី | អគ្គនាយករងបច្ចេកទេសក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១០. | លោក ឃួន វ៉ានីន | អគ្គនាយករងកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា | សមាជិក |
| ១១. | លោក តុង ពាវ | ប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ ក្រសួងយុត្តិធម៌ | សមាជិក |

## ក្រុមការងារបច្ចេកទេសរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ

| | | | |
|---|---|---|---|
| ១ | ឯកឧត្តម ហង់ ជួនណារ៉ុន | អគ្គលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២. | លោកជំទាវ តាល់ ណៃអ៊ីម | អគ្គនាយក ធនាគារជាតិនៃកម្ពុជា | អនុប្រធាន |
| ៣. | លោក ផាន់ ហូវ | អគ្គនាយករង ធនាគារជាតិនៃកម្ពុជា | សមាជិក |
| ៤. | លោក ម៉ី វ៉ាន់ | ប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥. | លោក ម៉ុញ បានកុសល | អនុប្រធានទី១ នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៦. | លោក ចាន់ សុធី | ប្រធាននាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៧. | លោក អន សុផាណារ៉ា | ប្រធាននាយកដ្ឋាននីតិកម្ម និងច្បាប់វិនិយោគ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៨. | លោក សៀង សុឃុនឌី | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៩. | លោកស្រី ងួន សុខា | ប្រធាននាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច ធនាគារជាតិនៃកម្ពុជា | សមាជិក |
| ១០. | លោក ប៊ូ ច័ន្ទភីរូ | អនុប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១១. | លោក កាំង សុជាតិ | អនុប្រធាននាយកដ្ឋានគណនេយ្យ ក្រសួងពាណិជ្ជកម្ម | សមាជិក |

| | | | |
|---|---|---|---|
| ១២. | លោក អ៊ុន ប៊ុនថា | អនុប្រធាននាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស | |
| | | ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១៣. | លោក ប៉ៅ ខ្សៀ | អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ | |
| | | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ១៤. | លោក យឹម សំអុល | អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ | |
| | | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៥. | លោក សុខ សារុន | អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ | |
| | | ក្រសួងយុត្តិធម៌ | សមាជិក |
| ១៦. | លោក នង ពិសិដ្ឋ | ប្រធានការិយាល័យទីផ្សារហិរញ្ញវត្ថុ | |
| | | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៧. | លោក ឆាយ រតនៈ | ប្រធានការិយាល័យធានារ៉ាប់រង | |
| | | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៨. | លោក ម៉ែន សុភាព | ប្រធានការិយាល័យសំភារៈ និងភស្តុភារ | |
| | | ក្រសួងយុត្តិធម៌ | សមាជិក |
| ១៩. | លោក សេស សុធីរ | ប្រធានការិយាល័យគ្រប់គ្រងអាជីវកម្ម និង | |
| | | ប្រកួតប្រជែង ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ២០. | លោក អ៊ុល ណាក់ | ប្រធានការិយាល័យគ្រប់គ្រងជំនួយពហុភាគី | |
| | | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ២១. | លោកស្រី ឈ គីមអ៊ី | ប្រធានការិយាល័យ ក្រសួងសង្គមកិច្ច | |
| | | អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ២២. | លោក យស សំអុល | ប្រធានការិយាល័យសំភារៈ | |
| | | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ២៣. | លោកស្រី ឃួន ធីរីវណ្ណ | អនុប្រធានការិយាល័យ | |
| | | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ២៤. | លោក ស៊ី ពិសេដ្ឋ | អនុប្រធានការិយាល័យគណនេយ្យ ក្រសួងយុត្តិធម៌ | សមាជិក |

# ឧបសម្ព័ន្ធ ២

## យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០០៦-២០១៥
## ក្រុមការងារ

### មូលដ្ឋានគ្រឹះនៃវិស័យហិរញ្ញវត្ថុ

- លោក ផាន់ ហូវ ធនាគារជាតិនៃកម្ពុជា
- លោកស្រី ងួន សុខា នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចនិងស្ថិតិ ធនាគារជាតិនៃកម្ពុជា
- លោក ឯម កំណាន់ នាយកដ្ឋានត្រួតពិនិត្យ ធនាគារជាតិនៃកម្ពុជា
- លោក អ៊ុន ប៊ុនថា នាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស ក្រសួងពាណិជ្ជកម្ម
- លោក ឌិម តារារិទ្ធ នាយកដ្ឋានកិច្ចការនីតិកម្ម ក្រសួងពាណិជ្ជកម្ម
- លោក មុី វ៉ាន់ នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- លោក មុិញ បានកុសល នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- លោក នង ពិសិដ្ឋ នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- លោក Douglas Arner ធនាគារអភិវឌ្ឍន៍អាស៊ី និងសាកលវិទ្យាល័យហុងកុង

### ធនាគារ

- លោក គិម វ៉ាដា នាយកដ្ឋានត្រួតពិនិត្យ ធនាគារជាតិនៃកម្ពុជា
- លោកស្រី ជា សិរី នាយកដ្ឋានត្រួតពិនិត្យ ធនាគារជាតិនៃកម្ពុជា
- លោក រ័ត្ន សាវុធ នាយកដ្ឋានប្រតិបត្តិការ ធនាគារជាតិនៃកម្ពុជា
- លោកស្រី គាំ គណ្ឋា នាយកដ្ឋានប្រតិបត្តិការ ធនាគារជាតិនៃកម្ពុជា
- លោកស្រី ស្រី ស៊ីយុត នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ ធនាគារជាតិនៃកម្ពុជា
- លោក សាផុន សុផាណ្ណារ៉ុន នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចនិងស្ថិតិ ធនាគារជាតិនៃកម្ពុជា
- លោក ហុង ភូម៉ា នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចនិងស្ថិតិ ធនាគារជាតិនៃកម្ពុជា
- លោក ឌិម តារាឫទ្ធិ នាយកដ្ឋាននីតិកម្ម ក្រសួងពាណិជ្ជកម្ម
- លោក Douglas Arner ធនាគារអភិវឌ្ឍន៍អាស៊ី និងសាកលវិទ្យាល័យហុងកុង

### មីក្រូហិរញ្ញវត្ថុ

- លោក គិម វ៉ាដា នាយកដ្ឋានត្រួតពិនិត្យ ធនាគារជាតិនៃកម្ពុជា
- លោក រ័ត្ន សាវុធ នាយកដ្ឋានប្រតិបត្តិការ ធនាគារជាតិនៃកម្ពុជា
- លោក ឡឹក ធី នាយកដ្ឋានត្រួតពិនិត្យ ធនាគារជាតិនៃកម្ពុជា

- លោក ប៊ុន ចន្ទី នាយកដ្ឋានត្រួតពិនិត្យ ធនាគារជាតិនៃកម្ពុជា
- លោក សុខ សុភក្រ្តា នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចនិងស្ថិតិ ធនាគារជាតិនៃកម្ពុជា
- លោក ជូ វណ្ណៈ នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- លោក អ៊ូ ជួបកុសល នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- លោក ខៃត រីដ ធនាគារអភិវឌ្ឍន៍អាស៊ី

ការធានារ៉ាប់រង

- លោក ម៉ី វ៉ាន់ នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- លោក ប៊ូ ច័ន្ទភិរូ នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- លោក ឆាយ រតនៈ នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- លោក អ៊ុច សុផាន់ណូ នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- លោក ថាត ជីវី នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- លោក Donald McIsaac ធនាគារអភិវឌ្ឍន៍អាស៊ី

ទីផ្សារហិរញ្ញវត្ថុ

- លោក ម៉ិញ បានកុសល នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- លោក កៅ ថាច នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- លោក អ៊ិន មាត្រា នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- លោក ឆឹង ចន្ថា នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- លោក ឱម តារាឫទ្ធិ នាយកដ្ឋាននីតិកម្ម ក្រសួងពាណិជ្ជកម្ម
- លោកស្រី ងួន សុខា នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចនិងស្ថិតិ ធនាគារជាតិនៃកម្ពុជា
- លោក លោក Douglas Arner ធនាគារអភិវឌ្ឍន៍អាស៊ី និងសាកលវិទ្យាល័យហុងកុង

ការពិចារណាឆ្លងវិស័យទូទៅ

- ឯកឧត្តម ហង់ ជួនណារ៉ុន អគ្គលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- លោកជំទាវ តាល់ ណៃអ៊ីម អគ្គនាយកធនាគារជាតិនៃកម្ពុជា
- ឯកឧត្តម ម៉ៅ ថូរ៉ា អនុរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម
- លោក Douglas Arner ធនាគារអភិវឌ្ឍន៍អាស៊ី និងសាកលវិទ្យាល័យហុងកុង

# ឧបសម្ព័ន្ធ ៣

## ក្រុមការងាររបស់ធនាគារអភិវឌ្ឍន៍អាស៊ីសម្រាប់យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ

### ធនាគារអភិវឌ្ឍន៍អាស៊ី

- João Farinha-Fernandes, Mission ប្រធានបេសកកម្ម និងជាមន្ត្រីគំរោង TA4677–ជំនួយបច្ចេកទេសខ្នាតតូច (SSTA) សម្រាប់បច្ចុប្បន្នកម្មចក្ខុវិស័យនិងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ធនាគារអភិវឌ្ឍន៍អាស៊ី
- Purnima Rajapakse សេដ្ឋវិទូជាន់ខ្ពស់ទទួលបន្ទុកគ្រប់គ្រងកម្មវិធី ស្ថានតំណាងធនាគារអភិវឌ្ឍន៍ អាស៊ីប្រចាំកម្ពុជា
- លោក ហែម វណ្ណឌី មន្ត្រីទទួលបន្ទុកសេដ្ឋកិច្ចនិងវិស័យហិរញ្ញវត្ថុ ស្ថានតំណាងធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំកម្ពុជា

### ក្រុមការងារ TA4677 - SSTA ធនាគារអភិវឌ្ឍន៍អាស៊ី

- លោក Douglas Arner ប្រធានក្រុមការងារ/អ្នកឯកទេសខាងវិស័យហិរញ្ញវត្ថុ និងជានាយកវិទ្យាស្ថានច្បាប់ហិរញ្ញវត្ថុអន្តរជាតិ (AIIFL) សាកលវិទ្យាល័យហុងកុង
- លោក ខៃត វីដ អ្នកឯកទេសខាងមីក្រូហិរញ្ញវត្ថុ
- លោក Donald McIsaacs អ្នកឯកទេសខាងធានារ៉ាប់រង
- លោក កង ច័ន្ទតារាវ័ត្ន អ្នកឯកទេសខាងវិស័យហិរញ្ញវត្ថុកម្ពុជា និងជានាយកវិទ្យាស្ថានកម្ពុជាដើម្បីសិក្សាការអភិវឌ្ឍ

### ក្រុមការងារសម្របសម្រួលសម្រាប់យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ

- អ្នកស្រី សំបូរ រម្យមុនី ធនាគារជាតិ នៃកម្ពុជា
- កញ្ញា ជា វឌ្ឍី ធនាគារជាតិ នៃកម្ពុជា
- លោក សោម កុសុម ធនាគារជាតិ នៃកម្ពុជា

បោះពុម្ពក្រោមការឧបត្ថម្ភពីគម្រោងជំនួយបច្ចេកទេសខ្នាតតូចរបស់
ធនាគារអភិវឌ្ឍន៍អាស៊ី លេខ ៤៦៧៧: បច្ចុប្បន្នកម្មចក្ខុវិស័យនិងផែនការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ

Designed by: **Intent** *Creative Design*